ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល

ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ

ករណីសិក្សា



មន្ទីរពេទ្យខេត្តកំពង់ចាម

ជំយោរតីចំណាត់ថ្នាក់លេខ១ CPA3 ឆ្នាំ២០១៩

គុណតាត ប្រសិទ្ធតាត សុវត្ថិតាត និងសមធម៌
សាលាភូមិន្ទរដ្ឋបាល
២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងមុខងារសាធារណៈ
សាលាតុលាការ

ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ

ករណីសិក្សា

មន្ទីរពេទ្យខេត្តកំពង់ចាម

ជំយោតីចំណាត់ថ្នាក់លេខ១ CPA3 ឆ្នាំ២០១៩

គុណតាង ប្រសិទ្ធតាង សុវត្ថិតាង និងសមធម៌
សាលាតុលាការ

២០២០

បុព្វកថា

អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា តាំងពីដំណាក់កាលទី១ រហូតដល់ដំណាក់កាលទី៤នេះ ដែលត្រូវបានកំណត់ក្រោមចក្ខុវិស័យដឹកនាំផ្ទាល់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីកែទម្រង់ជារចនាសម្ព័ន្ធគន្លឹះ ចំនួនបួន ដែលរួមមានកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ដែលកម្មវិធីកែទម្រង់ទាំងបួននេះជាក្បាលម៉ាស៊ីនដឹកនាំកែលម្អអភិបាលកិច្ចសាធារណៈ សំដៅបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានកាន់តែមានប្រសិទ្ធភាព។

ការដាក់ចេញនូវគោលនយោបាយកែទម្រង់ឱ្យចំអាទិភាព គឺជាបេសកកម្មរបស់រាជរដ្ឋាភិបាលតែអ្វីដែលវិតតែត្រូវផ្តល់ការយកចិត្តទុកដាក់នោះ គឺប្រសិទ្ធភាពជាក់ស្តែងនៃគោលនយោបាយទាំងនោះដែលត្រូវអនុវត្តដោយតួអង្គនីមួយៗ តាមមុខងារនិងភារកិច្ចរៀងៗខ្លួន រាប់ចាប់តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។ ដូចនេះ ការចុះអង្កេតដោយផ្ទាល់ ការសិក្សា និងការវាយតម្លៃអំពីការផ្តល់សេវាសាធារណៈនៅក្នុងកម្រិតមូលដ្ឋាន គឺជាកញ្ចក់ឆ្លុះមួយដែលអាចឱ្យរដ្ឋបាលថ្នាក់ជាតិយល់អំពីសភាពការណ៍ពិតធៀបនឹងការដាក់ចេញគោលនយោបាយនៅថ្នាក់ជាតិ។ កន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញនូវយន្តការគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដើម្បីជាការសិក្សា ការវាយតម្លៃ និងស្វែងរកនូវធាតុចូលសំខាន់ៗក្នុងការកែលម្អអភិបាលកិច្ច ដែលនៅក្នុងនោះមានការផ្តល់ចំណាត់ថ្នាក់ជាការលើកទឹកចិត្តដល់អង្គភាពដែលមានអភិបាលកិច្ចនិងការផ្តល់សេវាសាធារណៈល្អប្រសើរជាងគេ។

ក្នុងស្មារតីខាងលើនេះ ខ្ញុំពិតជាមានក្តីរំភើបនិងសូមកោតសរសើរដោយស្មោះចំពោះគំនិតរៀបចំឱ្យមានជាឯកសារ ការគ្រប់គ្រងនិងការផ្តល់សេវានៃមន្ទីរពេទ្យខេត្តកំពង់ចាម **«គុណភាព ប្រសិទ្ធភាព សុវត្ថិភាព និងសមធម៌»** នេះ។

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងសម្រេចចេញជាសមិទ្ធផលនេះឡើង ក្រោមការដឹកនាំរបស់ឯកឧត្តមកិត្តិបណ្ឌិត **ពេជ្ជ ប៊ុនឆិន** ទេសរដ្ឋមន្ត្រីនិងជាប្រធានគណៈកម្មការជាតិវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដោយមានការចូលរួមសហការយ៉ាងសស្រាក់សស្រាំរបស់ពីឯកឧត្តមបណ្ឌិត-សភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងឯកឧត្តម **ង្វៃ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រោមឱវាទនៃសាមីក្រសួងនីមួយៗ។

ខ្ញុំរំពឹងថាឯកសារនេះ នឹងក្លាយជាមគ្គទេសក៍អភិបាលកិច្ចសាធារណៈដ៏មានគុណ-ប្រយោជន៍មួយ សម្រាប់អង្គភាពផ្តល់សេវាសាធារណៈផ្សេងទៀត ជាពិសេសអង្គភាពផ្តល់សេវាសុខាភិបាល អាចយកជាការដកស្រង់បទពិសោធន៍ និងជាធាតុចូលនៃការគ្រប់គ្រងអង្គភាព និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ទន្ទឹមនេះ ឯកសារនេះក៏អាចផ្តល់វិភាគទានខាងពុទ្ធិ ដល់ការយល់ដឹង ការរៀនសូត្រ និងការសិក្សាស្រាវជ្រាវរបស់និស្សិតសាស្ត្រាចារ្យ អ្នកស្រាវជ្រាវ បញ្ញវន្ត និងសាធារណជនជាទូទៅផងដែរ។

ថ្ងៃ ចន្ទ ១៤ រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំកិច្ចដឹកនាំនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

អារម្ភកថា

ការកសាងជំនឿនិងទំនុកចិត្តពីប្រជាពលរដ្ឋ គឺជាការលំបាកដែលរាជរដ្ឋាភិបាល ត្រូវបន្តយកចិត្តទុកដាក់តាមរយៈការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពជូនប្រជាពលរដ្ឋ។ ផ្តើមចេញពីចំណុចនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបំផុសឡើងវិញនូវយន្តការនៃការលើកទឹកចិត្តមន្ត្រីរាជការ និងអង្គភាពដែលមានស្មារដៃឆ្នើមក្នុងការបង្កើនផលិតភាពការងារក្នុងរដ្ឋបាលសាធារណៈ និងការលើកកម្ពស់គុណភាពសេវាសាធារណៈ ដែលកន្លងមកធ្លាប់ត្រូវបានអនុវត្តនៅអតីតសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា។ ផ្អែកលើសំណើរបស់ក្រសួងមុខងារសាធារណៈ ក្នុងនាមគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំឱ្យមានយន្តការនេះឡើងវិញ ដើម្បីលើកទឹកចិត្តដល់បណ្តាអង្គភាពផ្តល់សេវាសាធារណៈ រាជរដ្ឋាភិបាលបានសម្រេចឱ្យមានការប្រកួតប្រជែងអង្គភាពផ្តល់សេវាសាធារណៈគំរូ តាមរយៈការដាក់ឱ្យអនុវត្តអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។

តាមរយៈអនុក្រឹត្យនេះ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ និងគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំនិងបង្កើតឡើង ដើម្បីពិនិត្យនិងវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងកម្រិតវិទ្យាល័យសម្រាប់វិស័យអប់រំ និងក្នុងកម្រិតមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដែលផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់កម្រិត១ កម្រិត២ និងកម្រិត៣ សម្រាប់វិស័យសុខាភិបាល ដោយផ្អែកលើសូចនាករលក្ខណៈវិនិច្ឆ័យគោល លក្ខណៈវិនិច្ឆ័យរង និងលក្ខណៈវិនិច្ឆ័យលម្អិត។ ការវាយតម្លៃនេះត្រូវបានអនុវត្តផ្អែកលើគោលការណ៍តម្លាភាព សុចរិតភាព និងភាពជឿទុកចិត្តបាន។ ការវាយតម្លៃក៏បានឆ្លុះបញ្ចាំងអំពីការគ្រប់គ្រងនិងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពនិងនវានុវត្តន៍ ក្នុងក្របខណ្ឌនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ថ្នាក់ដឹកនាំ មន្ត្រីអង្គភាពអាជ្ញាធរមូលដ្ឋាន សហគមន៍ និងអង្គការដៃគូអភិវឌ្ឍនានា ក្នុងគោលដៅកែលម្អ និងពង្រឹង

គុណភាពសេវាសាធារណៈឱ្យកាន់តែល្អប្រសើរសម្រាប់បម្រើប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន។

ក្នុងឱកាសនៃពិធីប្រកាសទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានណែនាំឱ្យមានការរៀបចំជាករណីសិក្សា ចងក្រងបទពិសោធន៍នៃការអនុវត្តការងាររបស់បណ្តាជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូសម្រាប់ផ្សព្វផ្សាយជូនដល់បណ្តាអង្គភាពផ្តល់សេវាសាធារណៈផ្សេងទៀតក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ដើម្បីដកស្រង់បទពិសោធន៍ និងពង្រីកនវានុវត្តន៍ក្នុងការកែលម្អគុណភាពសេវាសាធារណៈរបស់ខ្លួន។ ក្នុងន័យនេះ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ បានរៀបចំនិងកំណត់យកអង្គភាពជ័យលាភីលេខ១ ផ្តល់សេវាសាធារណៈគំរូក្នុងកម្រិតវិទ្យាល័យសម្រាប់វិស័យអប់រំ និងអង្គភាពជ័យលាភីលេខ១ ផ្តល់សេវាសាធារណៈគំរូក្នុងកម្រិតមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងមន្ទីរពេទ្យបង្អែកក្រុងស្រុក ខណ្ឌ ដែលផ្តល់សេវាសំណុំសកម្មភាពបង្ត្រប់កម្រិត១ កម្រិត២ និងកម្រិត៣ សម្រាប់វិស័យសុខាភិបាល ទុកជាមេរៀនបទពិសោធន៍សម្រាប់អង្គភាពផ្តល់សេវាសាធារណៈផ្សេងទៀតក្នុងក្របខណ្ឌទូទាំងប្រទេស។

ថ្ងៃ ពុធ ៩ រោច ខែ ឆិតសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឆ្នូ ឆ្នាំ២០២០

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសនិងជាប្រធាន

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ

កិត្តិបណ្ឌិត ពេជ្រ ម៉ុនធិន

អារម្ភកថា

នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងរដ្ឋបាលសាធារណៈ ឱ្យកាន់តែ**ខ្លាំង ស្អាតស្អំ និងផ្តោតលើប្រជាជនជាស្នូល**។ ក្នុងន័យនេះ ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ការពង្រឹងរដ្ឋបាលសាធារណៈឱ្យកាន់តែមានតម្លាភាព ភាពឆ្លើយតប និងប្រសិទ្ធភាព និងជំនឿទុកចិត្តបាន។

ឈរលើស្មារតីនេះ ក្រសួងមុខងារសាធារណៈ ដែលមានតួនាទីគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យមុខងារសាធារណៈ និងកែលម្អអភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ បានទទួលការគាំទ្រនិងចូលរួមសហការពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ក្នុងការរៀបចំនូវគោលការណ៍ នីតិវិធី និងដំណើរការនៃការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ក៏ដូចជាការចូលរួមគាំទ្រក្នុងការរៀបចំឱ្យមានការចងក្រងករណីសិក្សាសម្រាប់អង្គភាពជំយលាភីលេខ១ នៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ ករណីសិក្សានេះ នឹងអាចយកទៅប្រើប្រាស់សម្រាប់ធ្វើជាមេរៀនពិសោធន៍ដល់បណ្តាអង្គភាពផ្សេងៗទៀត ដើម្បីពង្រឹងអភិបាលកិច្ចនិងការកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈរបស់ខ្លួនឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព។

ការកែលម្អ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋគឺជាផ្នែកដ៏សំខាន់មួយ ដែលនឹងរួមចំណែកក្នុងការសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ឱ្យទទួលបានជោគជ័យ។ ផ្អែកលើការគាំទ្រ និងការចូលរួមអនុវត្តដ៏សកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ និងតួអង្គពាក់ព័ន្ធទាំងអស់ ខ្ញុំសង្ឃឹមថា អភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈនឹងមានដំណើរការកាន់តែមានប្រសិទ្ធភាពនិងគាំទ្រដល់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព បរិយាប័ន្ន និងសមធម៌។

ក្នុងនាមក្រសួងមុខងារសាធារណៈ ខ្ញុំសូមបន្តគាំទ្រ និងផ្តល់កិច្ចសហការជាមួយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាលនិងក្រសួង ស្ថាប័នផ្សេងទៀត ធ្វើការផ្សព្វផ្សាយឯកសារករណីសិក្សានេះឱ្យបានទូលំទូលាយ ដើម្បីពង្រីកវិសាលភាពនៃការអនុវត្តការប្រកួតប្រជែងក្នុងការផ្តល់សេវាសាធារណៈគំរូ នៅតាមអង្គភាពផ្តល់សេវាសាធារណៈផ្សេងៗទៀត។

ថ្ងៃ អង្គារ ០៥ កាត ខែ មិថុនា ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឆ្នូ ឆ្នាំ២០២០

រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

ព្រុំ-សុខា

អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកសុខភាពរបស់ប្រជាជន គឺជាស្នូលនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេស។ ភាពរឹងមាំនៃប្រព័ន្ធសុខាភិបាល រួមជាមួយនឹងវឌ្ឍនភាពនៃវិស័យពាក់ព័ន្ធផ្សេងទៀត ជាពិសេសឆន្ទៈនយោបាយដ៏រឹងមាំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងវឌ្ឍនភាពឆ្ពោះទៅកាន់ការគ្របដណ្តប់សុខភាពជាសកល រួមជាមួយនឹងវឌ្ឍនភាពនៃកំណែទម្រង់នានាបានផ្តល់ឱកាសឱ្យក្រសួងសុខាភិបាលធ្វើការលើកកម្ពស់វិស័យសុខាភិបាល ក្នុងការផ្តល់សេវាមានគុណភាពនៅគ្រប់មូលដ្ឋានសុខាភិបាល កាន់តែមានភាពឆ្លើយតប និងគណនេយ្យភាពចំពោះប្រជាជន។

លទ្ធផលនៃការអនុវត្តអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ “**ស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល**” បានបង្ហាញឱ្យឃើញថាមន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ ចំនួន១០ កម្រិត២ ចំនួន១០ និងកម្រិត៣ ចំនួន១០ ត្រូវបានវាយតម្លៃនិងទទួលស្គាល់ជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល នៅឆ្នាំ២០១៩ ដែលក្នុងនោះមានមន្ទីរពេទ្យបង្អែកបាកាន មន្ទីរពេទ្យខេត្តកោះកុង និង មន្ទីរពេទ្យខេត្តកំពង់ចាម បានទទួលជ័យលាភីជាអង្គភាពផ្តល់សេវាសាធារណៈគំរូថ្នាក់លេខ១។

ការចងក្រងករណីសិក្សាពីមន្ទីរពេទ្យទាំង៣ខាងលើ ដែលបានទទួលជ័យលាភីលេខ១ ស្តីពី“**ការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យ**” មានគោលបំណងផ្តល់ជាមេរៀនបទពិសោធន៍ ដើម្បីចែករំលែកពីគុណតម្លៃនៃភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ក្នុងវិស័យសុខាភិបាល។ ករណីសិក្សានេះ នឹងបង្ហាញពីដំណើរការនៃការវិវត្តក្នុងអង្គភាព បញ្ហាប្រឈម ដំណោះស្រាយ បទពិសោធន៍ជោគជ័យ និងវិធីសាស្ត្រនានាក្នុងការកែលម្អគុណភាពនិងផលិតភាពការងារក្នុងអង្គភាព ជាពិសេស ការចូលរួមចំណែកជំរុញការអនុវត្តនវានុវត្តន៍និងឧត្តមានុវត្តន៍ ក្នុងការពង្រឹងនិងលើកកម្ពស់សុខុមាលភាពជូនដល់ប្រជាជនកម្ពុជា។

ក្នុងនាមក្រសួងសុខាភិបាល ខ្ញុំសូមកោតសរសើរដ៏ស្មោះដល់មន្ត្រីនិងបុគ្គលិកសុខា-

ភិបាលទាំងអស់ ព្រមទាំងមន្ត្រីរពេទ្យទទួលជ័យលាភីដែលបាននាំមកនូវវឌ្ឍនភាព និងភាពជោគជ័យដ៏ត្រចះត្រចង់ក្នុងការបម្រើសេវាជូនប្រជាជន។ ជាមួយគ្នានេះ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គភាពគ្រប់លំដាប់ថ្នាក់ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ព្រមទាំងប្រជាជនកម្ពុជាទាំងអស់ ដែលបានឧបត្ថម្ភ គាំទ្រ សហការ និងចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តសកម្មភាពសុខាភិបាលនាពេលកន្លងទៅ។

ខ្ញុំសង្ឃឹមថា ករណីសិក្សានេះ នឹងបានជាមេរៀនបទពិសោធន៍ល្អៗ សម្រាប់មន្ត្រីគ្រប់គ្រងអង្គភាពសុខាភិបាលទាំងអស់ ដើម្បីធ្វើការកែលម្អ និងអភិវឌ្ឍអង្គភាពរបស់ខ្លួនឱ្យកាន់តែរីកចំរើនថែមទៀត រួមចំណែកលើកកម្ពស់សុខភាព និងសុខុមាលភាពជូនប្រជាជនកម្ពុជាកាន់តែល្អប្រសើរឡើង។

ថ្ងៃសុក្រ ២កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០
រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ម៉ម ប៊ុនហេង

សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមសំដែងនូវការគោរពដ៏ខ្ពង់ខ្ពស់ និងកតវេទិតាដ៏ស្មោះស្ម័គ្រជូន **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានគាំទ្រ និងយកចិត្តទុកដាក់ខ្ពស់លើវិស័យអប់រំ និងវិស័យសុខាភិបាល។ ជាពិសេសបានដាក់ចេញនូវអនុក្រឹត្យលេខ៥៤ អនក្រ.បកចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគុំរក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានជំរុញ គាំទ្របង្កើតឱ្យមានការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគុំរក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល និងការរៀបចំចងក្រងបទពិសោធន៍នៃការអនុវត្តការងាររបស់បណ្តាជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈ គុំរនេះឡើង។

ជាមួយគ្នានេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនឆិន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងឯកឧត្តម **ង្ហុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ចំពោះការផ្តល់នូវកិច្ចគាំទ្រ និងការជំរុញលើកទឹកចិត្តដល់ក្រុមការងាររៀបចំករណីសិក្សា ដែលជាហេតុធ្វើឱ្យដំណើរការសិក្សាស្រាវជ្រាវទទួលបានលទ្ធផលនាពេលនេះ។

ទន្ទឹមគ្នានេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ចំពោះការផ្តល់នូវកិច្ចគាំទ្រ សម្របសម្រួលនិងអនុញ្ញាតឱ្យក្រុមការងាររៀបចំករណីសិក្សាបានបំពេញភារកិច្ចរបស់ខ្លួន រហូតទទួលបានលទ្ធផលនាពេលនេះ។

នៅក្នុងការងារនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម **យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការនៃក្រសួងមុខងារសាធារណៈ និងជានាយកសាលាភូមិន្ទរដ្ឋបាល ដែលបានផ្តួចផ្តើមគំនិត និងដឹកនាំគម្រោងរៀបចំករណីសិក្សានេះ រហូតទទួលបានលទ្ធផលជាទីមោទនៈនាពេលនេះ។

ក្នុងឱកាសនេះ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម **អ៊ុន ចាន់ដា** អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ឯកឧត្តម **ហាន កុសល** អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ចាម លោកជំទាវ **ង៉ោ ដានី** អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ចាម លោក **គីមសួ គីរុណ** ប្រធានមន្ទីរនិងថ្នាក់ដឹកនាំនៃមន្ទីរសុខាភិបាលខេត្តកំពង់ចាម ចំពោះការលះបង់នូវពេលវេលា ការគាំទ្រ ការសម្របសម្រួល និងការអនុញ្ញាតឱ្យក្រុមការងារ រៀបចំករណីសិក្សាបានបំពេញភារកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងភាពរលូន រហូតទទួលបានលទ្ធផលនាពេលនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោក **ចាន់ ផល្លី** អភិបាលក្រុងកំពង់ចាម និងប្រធានការិយាល័យជំនាញទាំងអស់ដែលបានលះបង់នូវពេលវេលា ចូលរួម សម្របសម្រួល និងអនុញ្ញាតឱ្យក្រុមការងាររៀបចំករណីសិក្សាបានបំពេញភារកិច្ចរបស់ខ្លួន រហូតទទួលបានលទ្ធផលដូចបានគ្រោងទុក។

យើងខ្ញុំមិនភ្លេចឡើយ និងសូមអរគុណចំពោះ សាស្ត្រាចារ្យ **យិន សុីណាត** ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម លោក លោកស្រីអនុប្រធានមន្ទីរពេទ្យ ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃមន្ទីរពេទ្យខេត្តកំពង់ចាម ដែលបានលះបង់នូវពេលវេលាដ៏ច្រើន ចូលរួមយ៉ាងសកម្ម សម្របសម្រួល និងផ្តល់ទិន្នន័យ ឱ្យក្រុមការងាររៀបចំករណីសិក្សាបានបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងលទ្ធផល។

ជាមួយគ្នានេះដែរ យើងខ្ញុំសូមអរគុណចំពោះលោកបណ្ឌិត**សំ ចន្ធី** និងក្រុមជំនាញការបច្ចេកទេសនៃកម្មវិធីកំណែទម្រង់វិមជ្ឈការនិងរដ្ឋបាល នៃទីភ្នាក់ងារសហប្រត្តិការអន្តរជាតិអាល្លឺម៉ង់ (DAR/GIZ) ដែលតែងតែផ្តល់នូវការគាំទ្រ និងការតម្រង់ទិសនៅក្នុងដំណើរការនៃការរៀបចំករណីសិក្សានេះ។

សូមថ្លែងអំណរគុណចំពោះក្រុមការងារដឹកនាំ និងគ្រប់គ្រងគម្រោងរៀបចំករណី-សិក្សា ដែលបានណែនាំតម្រង់ទិស និងផ្តល់ជាធាតុចូលក្នុងការរៀបចំចងក្រងករណីសិក្សានេះ។ ជាមួយគ្នានេះដែរ សូមអរគុណចំពោះក្រុមការងាររៀបចំករណីសិក្សារបស់មន្ទីរពេទ្យខេត្តកំពង់ចាម និងក្រុមការងារសម្របសម្រួល ដែលបានលះបង់កម្លាំងកាយចិត្ត និងបញ្ញាក្នុងការសម្របសម្រួល រៀបចំ តាក់តែង និងចងក្រងករណីសិក្សានេះឱ្យទទួលបានលទ្ធផលដូចការគ្រោងទុក។

បញ្ជីអក្សរកាត់

អក្សរកាត់	ពាក្យពេញ
ស៥	សម្រិតសម្រាំង សណ្តាប់ធ្នាប់ សោភ័ណភាព ស្តង់ដា ស្ថិរភាព
-ដ-	ដដែល
5 S	Sort, Set, Shine, Standardize, Sustain
CPA	Complementary Package of Activities
AHF	Aids Healthcare Foundation
DMDP	Diagnosis Microbiology Development Program
ECG	Electrocardiogram
H-EQIP	Health Equity and Quality Improvement Project
HMIS	Health Management Information System
ICU	Intensive Care Unit
ICRC	International Committee of the Red Cross Cambodia
IPC	Infection Prevention and Control
WHO	World Health Organization
JICA	Japan International Cooperation Agency
KOICA	Korea International Cooperation Agency
KWWA	Kampuchea Women‟s Welfare Action
LDSC	Last Day Saint Charities
NAMRU-2	Naval Medical Research Unit 2
PCA	Payment Certification Agency

PMRS	Patient Management Registration System
QI	Quality Improvement
UHC	Universal Health Coverage
URC	University Research Co. LLC
UNFPA	United Nation Population Fund
UNICEF	United Nations Children's Fund

មាតិកានុក្រមសង្ខេប

បុព្វកថា ឱបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ I
អារម្ភកថា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន គណៈកម្មការចាយតម្លៃរង្គសាពផ្តល់សេវាសាធារណៈថ្លាក់ជាតិ III
អារម្ភកថា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ: V
អារម្ភកថា រដ្ឋមន្ត្រីក្រសួងសុខាភិបាល VII
សេចក្តីថ្លែងអំណរគុណ..... IX
បញ្ជីអក្សរកាត់ XI
បញ្ជីតារាង XV
បញ្ជីរូបភាព XVI
បញ្ជីក្រាហ្វិក..... XVII
បញ្ជីឱបសម្ព័ន្ធ..... XVIII
ជំពូកទី១. សេចក្តីផ្តើម ១
១.១. លំនាំបញ្ហានៃការស្រាវជ្រាវ..... ១
១.២. គោលបំណងនៃការស្រាវជ្រាវ..... ៥
១.៣. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ..... ៥
១.៤. វិធីសាស្ត្រស្រាវជ្រាវ ៦
ជំពូកទី២. ស្ថានភាពទូទៅទីស័យសុខាភិបាល និងសមិទ្ធកម្មនៃមន្ទីរពេទ្យ ខេត្តកំពង់ចាម ៩
២.១. បរិបទរួមនៃការកែទម្រង់..... ៩
២.២. ទិដ្ឋភាពរួមនៃប្រព័ន្ធសុខាភិបាល..... ១០
២.៣. ស្ថានភាពទូទៅរបស់មន្ទីរពេទ្យខេត្តកំពង់ចាម..... ១៥

២.៤. សមិទ្ធផលនៃការផ្តល់សេវាសុខាភិបាលរបស់មន្ទីរពេទ្យខេត្តកំពង់ចាម.... ២៩

ជំពូកទី៣. បទពិសោធន៍ជោគជ័យរបស់មន្ទីរពេទ្យខេត្តកំពង់ចាម ៣៧

៣.១. ស្តង់ដាសេវាសាធារណៈ: ៣៧

៣.២. និយាមនៃការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យខេត្តកំពង់ចាម..... ៥១

៣.៣. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់មន្ទីរពេទ្យខេត្តកំពង់ចាម ៧៣

៣.៤. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព ៨៤

៣.៥. ការរៀបចំ និងកែលម្អបរិស្ថានរបស់មន្ទីរពេទ្យ..... ៩៥

៣.៦. ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ
ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ: ១២០

៣.៧. ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍ ១២៥

៣.៨. ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីធ្វើឱ្យអង្គភាពមាន
ជំណើរការកាន់តែប្រសើរ ១៣២

៣.៩. កត្តាគន្លឹះនៃភាពជោគជ័យរបស់មន្ទីរពេទ្យខេត្តកំពង់ចាម ១៣៦

ជំពូកទី៤. សេចក្តីសន្និដ្ឋាន.....១៣៩

គន្ថនិទ្ទេស ១៤១

ឧបសម្ព័ន្ធ..... ១៤៥

បញ្ជីតារាង

តារាង ២.១ ស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់បង្កើតមូលដ្ឋានសុខាភិបាល ១២
តារាង ២.២ ស្តីពីចំនួនមន្ត្រីរាជការនៅតាមផ្នែក ២៥
តារាង ២.៣ ស្តីពីសកម្មភាពពិនិត្យ ព្យាបាលជំងឺ សម្រាកពេទ្យតាមឆ្នាំ (២០១៥ ដល់ ២០១៩) ២៩
តារាង ៣.១ ស្តីពីសំណល់នៅមន្ទីរពេទ្យខេត្តកំពង់ចាម ប្រចាំខែមករា ឆ្នាំ២០២០ ... ៦២
តារាង ៣.២ ស្តីពីចំណូល-ចំណាយរបស់មន្ទីរពេទ្យខេត្តកំពង់ចាមប្រចាំត្រីមាស ទី២ ឆ្នាំ២០១៩..... ៧៨
តារាង ៣.៣ ស្តីពីចំនួនអ្នកចូលរួមវគ្គបណ្តុះបណ្តាលពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩... ៩២
តារាង ៣.៤ ស្តីពីបំណែងចែកការថែទាំសួនច្បារក្នុងមន្ទីរពេទ្យខេត្តកំពង់ចាម..... ១០៦

បញ្ជីរូបតារាង

រូបភាព ២.១ ស្តីពីថ្នាក់ទាំង៣ នៃប្រព័ន្ធសុខាភិបាលសាធារណៈ ១១
រូបភាព ២.២ ស្តីពីប្រព័ន្ធផ្តល់សេវាសុខាភិបាល..... ១៤

បញ្ជីក្រាហ្វិក

ក្រាហ្វិក ២.១ ស្តីពីចំនួនមន្ត្រីបម្រើការនៅមន្ទីរពេទ្យខេត្តកំពង់ចាម ដើមឆ្នាំ២០២០.... ២៤
ក្រាហ្វិក ២.២ ស្តីពីកម្រិតជំនាញមន្ត្រីបម្រើការនៅមន្ទីរពេទ្យខេត្តកំពង់ចាម..... ២៤
ក្រាហ្វិក ២.៣ ស្តីពីជំងឺពិគ្រោះសរុប ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩..... ៣០
ក្រាហ្វិក ២.៤ ស្តីពីជំងឺសម្រាកសរុបពីឆ្នាំ២០១៥-២០១៩ (គិតជានាក់)..... ៣០
ក្រាហ្វិក ២.៥ ស្តីពីអត្រាប្រើប្រាស់គ្រែពីឆ្នាំ២០១៥-២០១៩ (គិតជា%)..... ៣១
ក្រាហ្វិក ២.៦ ស្តីពីរយៈពេលសម្រាកពេទ្យជាមធ្យមពីឆ្នាំ២០១៥-២០១៩ (គិតជាថ្ងៃ)... ៣២
ក្រាហ្វិក ២.៧ ស្តីពីចំនួនអ្នកសម្រាលកូនពីឆ្នាំ២០១៥-២០១៩ (គិតជានាក់)..... ៣៣
ក្រាហ្វិក ២.៨ ស្តីពីចំនួនវះកាត់សរុបពីឆ្នាំ២០១៥-២០១៩ (គិតជាករណី)..... ៣៣
ក្រាហ្វិក ២.៩ ស្តីពីអត្រាស្លាប់ពីឆ្នាំ២០១៥-២០១៩ (គិតជា%)..... ៣៥

បញ្ជីខ្លឹមសង្ខេប

១. ឯកសារទូទៅ ១៤៧

២. ស្តង់ដាសេវាសាធារណៈ..... ១៥៧

៣. និយាមនៃការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យ..... ១៩១

៤. ការគ្រប់គ្រងហិរញ្ញវត្ថុ..... ២៣១

៥. ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅក្នុងមន្ទីរពេទ្យ..... ២៣៥

៦. ការរៀបចំនិងកែលម្អបរិស្ថានមន្ទីរពេទ្យ..... ២៥៥

ជំពូកទី១. សេចក្តីផ្តើម

១.១. សំនាំបញ្ហានៃការស្រាវជ្រាវ

ការប្រកួតប្រជែងការផ្តល់សេវាសាធារណៈនៅតាមអង្គភាពក្នុងស្ថាប័នសាធារណៈគឺជាគន្លឹះចាំ បាច់មួយក្នុងការធានាបាននូវប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដល់គ្រប់ស្រទាប់ប្រជាពលរដ្ឋទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈយ៉ាងមោះមុត ឥតរាថយក្នុងការជំរុញការអនុវត្តការងារកែទម្រង់គ្រប់ផ្នែក គ្រប់វិស័យឱ្យកាន់តែមានលក្ខណៈទូលំទូលាយ និងស៊ីជម្រៅក្នុងគោលដៅធ្វើឱ្យប្រទេសកម្ពុជាមានសុខុដុមនីយកម្ម និងការអភិវឌ្ឍប្រកបដោយចីរភាព សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិ និងប្រជាជន។ ផ្អែកលើស្មារតីនេះ ការលើកកម្ពស់អភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈគឺជាកម្លាំងចលករដ៏ចាំបាច់ ដែលរាជរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ត្រូវយកចិត្តទុកដាក់ជាអាទិភាពបំផុត។ អភិបាលកិច្ចត្រូវបានរាជរដ្ឋាភិបាលកំណត់ថាជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងបានផ្តល់សារសំខាន់ក្នុងការជំរុញការអនុវត្តគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់តាមវិស័យផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។

ការកសាងជំនឿនិងទំនុកចិត្តពីប្រជាពលរដ្ឋគឺជាការលំបាកដែលរាជរដ្ឋាភិបាលត្រូវបន្តយកចិត្តទុកដាក់ជាយុទ្ធសាស្ត្រតាមរយៈការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពជូនប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង។ ផ្តើមចេញពីស្មារតីនេះ ការពង្រឹងស្ថាប័នផ្តល់សេវាសាធារណៈ និងភាពជាអ្នកដឹកនាំពិតប្រាកដជាកត្តាលីករដ៏មានសារសំខាន់ និងអាទិភាពបំផុតក្នុងការកែលម្អការផ្តល់សេវាសាធារណៈនៅក្នុងស្ថាប័នសាធារណៈ។

ពាក់ព័ន្ធនឹងការកែលម្អការផ្តល់សេវាសាធារណៈ រាជរដ្ឋាភិបាលបានដាក់ចេញនូវ

គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំមួយចំនួនជាអាទិ៍ គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ អនុក្រឹត្យស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជាមួយគ្នានោះដែរ ក្រសួងសុខាភិបាល ក៏ដូចជាក្រសួង ស្ថាប័នដទៃទៀត បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តនានាដើម្បីលើកកម្ពស់គុណភាពសេវាសាធារណៈឱ្យកាន់តែប្រសើរឡើង។ ឯកសារដែលក្រសួងសុខាភិបាលបានដាក់ចេញមានដូចជា ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០ ផែនការសកម្មភាពសម្រាប់បង្ការនិងគ្រប់គ្រងជំងឺមិនឆ្លង២០១៦-២០២០ ផែនការសកម្មភាពពហុវិស័យជាតិស្តីពីការការពារនិងការប្រយុទ្ធនឹងជំងឺមិនឆ្លង២០១៨-២០២៨។

ក្នុងការលើកទឹកចិត្តចំពោះអង្គភាពដែលបានខិតខំកែលម្អគុណភាពសេវារបស់ខ្លួន រាជរដ្ឋាភិបាល បានដាក់ឱ្យអនុវត្តនូវអនុក្រឹត្យលេខ៥៤ អនក្រ.បកចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ គោលបំណងនៃអនុក្រឹត្យនេះគឺដើម្បីជំរុញនិងលើកកម្ពស់ប្រសិទ្ធភាពនិងគុណភាព នៃដំណើរការរបស់អង្គភាពផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលឱ្យកាន់តែប្រសើរឡើង តាមរយៈការកំណត់ឱ្យមានការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ។

អនុលោមតាមអនុក្រឹត្យខាងលើ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើង។ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិមានរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈជាប្រធាន គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈរាជធានី ខេត្ត មានអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាងនៃគណៈអភិបាលរាជធានី ខេត្តជាប្រធាន និងគណៈកម្មការ

វាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈក្រុង ស្រុក ខណ្ឌ មានអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ឬតំណាងនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាប្រធាន។

ដោយផ្អែកលើនីតិវិធី គោលការណ៍ លក្ខណៈវិនិច្ឆ័យ និងភារកិច្ចដែលបានកំណត់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈនៅគ្រប់លំដាប់ថ្នាក់ បានខិតខំបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្មក្នុងការវាយតម្លៃនិងជ្រើសរើសអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិ-បាល។ ជាលទ្ធផល គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិបានសម្រេចជ្រើសរើសអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំចំនួន១០ និងវិស័យសុខាភិបាលចំនួន៣០ ដើម្បីផ្តល់ពានរង្វាន់ វិញ្ញាបនបត្រ និងថវិកាជារង្វាន់លើកទឹកចិត្ត។ ក្នុងចំណោមអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាលចំនួន៣០ ខាងលើមាន÷ ១) មន្ទីរពេទ្យបង្អែកដែលផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់កម្រិត៣ (CPA3) ចំនួន១០ ២) មន្ទីរពេទ្យបង្អែកដែលផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់កម្រិត២ (CPA2) ចំនួន១០ និង៣) មន្ទីរពេទ្យបង្អែកដែលផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់កម្រិត១ (CPA1) ចំនួន១០។ ក្នុងបណ្តាមន្ទីរពេទ្យបង្អែកដែលផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់កម្រិត៣ (CPA3) ចំនួន១០ គឺមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាមទទួលបានចំណាត់ថ្នាក់លេខ១។

ជាការតបស្នងដល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ (វិទ្យាល័យ) និងវិស័យ សុខាភិបាល (មន្ទីរពេទ្យបង្អែក) ទាំង៤០ខាងលើ ដែលបានខិតខំបំពេញការងារក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋបានល្អ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានប្រារព្ធពិធីប្រកាសទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ក្រោមអធិបតីភាព ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

នៅក្នុងពិធីប្រកាសទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យ

អប់រំ និងវិស័យ សុខាភិបាលនោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានផ្តល់អនុសាសន៍ចំនួនប្រាំបីចំណុច ដែលអនុសាសន៍ទីមួយនិងដំបូងបំផុតនោះ គឺស្នើឱ្យមានការរៀបចំចងក្រងបទពិសោធន៍នៃការអនុវត្តការងាររបស់បណ្តាជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ដើម្បីធ្វើជាករណីសិក្សានិងបន្តផ្សព្វផ្សាយជូនអង្គភាពវិទ្យាល័យ និងមន្ទីរពេទ្យបង្អែកផ្សេងទៀតនៅទូទាំងប្រទេស សម្រាប់ជាការដកស្រង់បទពិសោធន៍ និងពង្រីកនវានុវត្តន៍សម្រាប់ការកែលម្អគុណភាពសេវាសាធារណៈរបស់ខ្លួនជូនប្រជាពលរដ្ឋ។ បន្ថែមពីលើនេះ ការចែករំលែកបទពិសោធន៍នៃភាពជោគជ័យរវាងអង្គភាពដែលទទួលបានស្នាដៃឆ្នើម និងអង្គភាពផ្សេងៗទៀតជាកត្តាចាំបាច់ក្នុងការបន្តកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈ ពង្រឹងភាពជាអ្នកដឹកនាំ និងការច្នៃប្រឌិតដែលអាចនឹងជំរុញឱ្យអង្គភាពបោះជំហានទៅមុខប្រកបដោយភាពជឿទុកចិត្ត។

ដោយយោងអនុសាសន៍ខាងលើ និងសច្ចភាពនៃសារសំខាន់នៃការសិក្សារៀនសូត្រពីគ្នាទៅវិញមក ក្រសួងមុខងារសាធារណៈដែលមានសាលាភូមិន្ទរដ្ឋបាលជាសេនាធិការបានរៀបចំក្រុមការងារសម្រាប់រៀបចំចងក្រងនូវបទពិសោធន៍ និងមេរៀនល្អៗពីអង្គភាពផ្តល់សេវាសាធារណៈគំរូ ឬដែលទទួលបានជ័យលាភីលេខ១ នាពេលកន្លងមកទាំងក្នុងវិស័យអប់រំ ទាំងក្នុងវិស័យសុខាភិបាល។

ក្នុងវិស័យសុខាភិបាលមានអង្គភាពផ្តល់សេវាសាធារណៈគំរូទទួលបានជ័យលាភីលេខ១ ចំនួន៣រួមមាន÷ ១)មន្ទីរពេទ្យខេត្តកំពង់ចាម ដែលទទួលបានជ័យលាភីលេខ១ក្នុងបណ្តាមន្ទីរពេទ្យបង្អែកដែលផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់កម្រិត៣ (CPA3) ២)មន្ទីរពេទ្យខេត្តកោះកុង ដែលទទួលបានជ័យលាភីលេខ១ ក្នុងបណ្តាមន្ទីរពេទ្យបង្អែកដែលផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់កម្រិត២ (CPA2) និង ៣)មន្ទីរពេទ្យបង្អែកបាកាននៅខេត្តពោធិ៍សាត់ ដែលទទួលបានជ័យលាភីលេខ១ក្នុងបណ្តាមន្ទីរពេទ្យបង្អែកដែលផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់កម្រិត១ (CPA1)។ ហេតុដូច្នេះ មន្ទីរពេទ្យខេត្តកំពង់ចាមបានក្លាយជាអង្គភាពគោលដៅសម្រាប់សិក្សាស្រាវជ្រាវក្នុងការរៀបចំចងក្រងករណីសិក្សានេះ

ឡើង។

១.២. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង ប្រមូលចងក្រងនូវមេរៀន និងបទពិសោធន៍ល្អៗនៅក្នុងដំណើរការគ្រប់គ្រងនិងផ្តល់សេវារបស់មន្ទីរពេទ្យខេត្តកំពង់ចាម ដែលជាអង្គភាពផ្តល់សេវាសាធារណៈគំរូទទួលបានជ័យលាភីលេខ១ ក្នុងបណ្តាមន្ទីរពេទ្យបង្អែកដែលផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់កម្រិត ៣ (CPA3) នៃវិស័យសុខាភិបាល សម្រាប់ជាការចែករំលែកចំណេះដឹងបន្ថែមទៅដល់មន្ទីរពេទ្យដទៃ អង្គភាពផ្តល់សេវាសាធារណៈ និងគ្រឹះស្ថានសិក្សាសាធារណៈផ្សេងៗទៀត។

១.៣. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះពិនិត្យមើលទៅលើការគ្រប់គ្រង និងការផ្តល់សេវារបស់មន្ទីរពេទ្យខេត្តកំពង់ចាម ក្នុងអំឡុងឆ្នាំ២០១៥ រហូតដល់២០១៩។

ការសិក្សាស្រាវជ្រាវនេះផ្តោតសំខាន់ទៅលើការអនុវត្តតាមនូវសូចនាករគោលទាំង៨ ដែលបានចែងក្នុងអនុក្រឹត្យលេខ៥៤ អនក្រ.បកចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ សូចនាករគោលទាំង៨នោះរួមមាន÷ ១) ស្តង់ដាសេវាសាធារណៈ ២) ស្តង់ដាឬនិយាមនៃការផ្តល់សេវាសាធារណៈរបស់អង្គភាព ៣) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព ៤) ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព ៥) ការរៀបចំនិងកែលម្អបរិស្ថានអង្គភាព ៦) ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ ៧) ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋនិងសហគមន៍ និង៨) ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ។

១.៤. វិធីសាស្ត្រស្រាវជ្រាវ

១.៤.១. វិធីសាស្ត្រសិក្សាចងក្រងករណីសិក្សា

Sturman (1997) បានលើកឡើងថា ករណីសិក្សាជាទូទៅសិក្សាអំពីបុគ្គល ក្រុម និងបាតុភូត។ Creswell (2009) ក៏បានលើកឡើងដែរថា ក្នុងករណីសិក្សា អ្នកសិក្សាស្រាវជ្រាវសិក្សាស៊ីជម្រៅនៅក្នុងកម្មវិធីមួយ ព្រឹត្តិការណ៍មួយ សកម្មភាពមួយ ដំណើរការមួយ ឬបុគ្គលម្នាក់ឬច្រើននាក់។ រចនាសម្ព័ន្ធនៃករណីសិក្សាគួរតែជាបញ្ហា បរិបទ ព្រឹត្តការណ៍ និងមេរៀនបទពិសោធន៍ (Creswell, 2014)[១]។ តាមទស្សនៈរបស់ Creswell (2009) ករណីសិក្សាគឺជាប្រភេទនៃការសិក្សាស្រាវជ្រាវមួយនៅក្នុងការសិក្សាស្រាវជ្រាវបែបគុណភាព (Qualitative research)[២]។

នៅក្នុងការសិក្សាស្រាវជ្រាវនេះ យើងប្រើប្រាស់វិធីសាស្ត្របែបគុណភាព ដើម្បីប្រមូលចងក្រងបទពិសោធន៍ និងមេរៀនអនុវត្តន៍ជាក់ស្តែងរបស់អង្គភាពផ្តល់សេវាសាធារណៈគំរូសម្រាប់ចែករំលែកនិងបម្រើផលប្រយោជន៍ដល់ការរៀនសូត្ររបស់អ្នកពាក់ព័ន្ធដទៃទៀត។

១.៤.២. វិធីសាស្ត្រប្រមូលទិន្នន័យ

នៅក្នុងការរៀបចំចងក្រងករណីសិក្សានេះ ប្រើប្រាស់ទិន្នន័យ២ប្រភេទគឺ ទិន្នន័យទី១ (Primary data) និងទិន្នន័យទី២ (Secondary data)។

នៅក្នុងការប្រមូលទិន្នន័យទី១ (Primary data) ក្រុមការងារបានធ្វើឡើងតាមរយៈ កិច្ចប្រជុំពិភាក្សា ការជួបសម្ភាសន៍ និងការអង្កេតផ្ទាល់។

កិច្ចប្រជុំពិភាក្សា÷ ក្រុមការងារបានធ្វើការប្រជុំពិភាក្សាជាមួយ ១)អភិបាលរងខេត្តកំពង់ចាមដែលទទួលបន្ទុកវិស័យសុខាភិបាល ព្រមទាំងប្រធាននិងថ្នាក់ដឹកនាំមន្ទីរសុខាភិបាលខេត្តកំពង់ចាម ដែលកិច្ចប្រជុំនេះធ្វើឡើងនៅមន្ទីរសុខាភិបាលខេត្តកំពង់ចាម ២)អភិបាលក្រុងកំពង់ចាម ថ្នាក់ដឹកនាំការិយាល័យជំនាញនៅរដ្ឋបាលក្រុង បណ្តាចៅសង្កាត់

[១] ដកស្រង់ដោយ Mohajan, 2018, Qualitative Research Methodology in Social Science and Related Subjects, ទំព័រ១១។

[២] -ដ- ទំព័រ៧

បណ្តាប្រធានមណ្ឌលសុខភាពនៅក្រុងកំពង់ចាម និងសហគមន៍នៅក្រុងកំពង់ចាម ដែលកិច្ចប្រជុំនេះធ្វើឡើងនៅសាលាក្រុងកំពង់ចាម ៣)ប្រធានមន្ទីរពេទ្យ អនុប្រធានមន្ទីរពេទ្យ ប្រធានផ្នែកគណនេយ្យ និងប្រធានផ្នែករដ្ឋបាលនៃមន្ទីរពេទ្យខេត្តកំពង់ចាម ដែលកិច្ចប្រជុំនេះធ្វើឡើងនៅបន្ទប់ប្រជុំមន្ទីរពេទ្យខេត្តកំពង់ចាម។ កិច្ចប្រជុំពិភាក្សាធ្វើឡើងទៅតាមពេលវេលាដែលបានកំណត់នៅក្នុងកម្មវិធីចុះប្រមូលទិន្នន័យរបស់ក្រុមការងារ។

ការជួបសម្ភាសន៍÷ ក្រុមការងារបានធ្វើការសម្ភាសន៍ជាមួយ ១)ប្រធានមន្ទីរពេទ្យ អនុប្រធានមន្ទីរពេទ្យ ប្រធានផ្នែកគណនេយ្យ និង២)អតីតអ្នកជំងឺ អ្នកជំងឺ អ្នកកំដរអ្នកជំងឺ សរុបចំនួន២២ នាក់។ ការសម្ភាសន៍ជាមួយអតីតអ្នកជំងឺបានធ្វើឡើងតាមរយៈទូរស័ព្ទដោយផ្ទាល់។

ការអង្កេតផ្ទាល់នៅមន្ទីរពេទ្យខេត្ត÷ ក្រុមការងារបានចុះសិក្សា ពិនិត្យមើល និងធ្វើតុយកូរូបភាពជាក់ស្តែងនៃទីតាំង បរិវេណ ហេដ្ឋារចនាសម្ព័ន្ធ អនាម័យ បរិស្ថាន ការគ្រប់គ្រង និងការផ្តល់សេវារបស់មន្ទីរពេទ្យខេត្តកំពង់ចាម។

នៅក្នុងការប្រមូលទិន្នន័យទី២ (Secondary data) ធ្វើឡើងតាមរយៈការប្រមូលឯកសារដែលមានស្រាប់ ដូចជា អនុក្រឹត្យ ប្រកាស របាយការណ៍វាយតម្លៃរបស់គណៈកម្មការបច្ចេកទេសអន្តរក្រសួង បទបង្ហាញរបស់ប្រធានមន្ទីរពេទ្យក្នុងពេលប្រឡងប្រណាំង និងក្នុងពេលចែករំលែកពិសោធន៍ និងរបាយការណ៍ផ្សេងៗរបស់មន្ទីរពេទ្យខេត្តកំពង់ចាម។

ដំណើរការនៃការសិក្សាស្រាវជ្រាវនេះចែកចេញជា២ដំណាក់កាល ១)សិក្សាស្រាវជ្រាវនៅនឹងកន្លែង (Desk research) ២)សិក្សាស្រាវជ្រាវនៅទីកន្លែងគោលដៅ (Field research)។

១.៤.៣. វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យដែលទទួលបាន ត្រូវបានយកមករៀបចំទៅតាមដំណាក់កាល រួមមាន÷ ១)រៀបចំទិន្នន័យដែលទទួលបានទៅតាមសូចនាករដែលបានគ្រោងទុក ២)ធ្វើសុក្រឹត្យភាពទិន្នន័យតាមរយៈការប្រៀបធៀបទិន្នន័យដែលទទួលបានពីប្រភពផ្សេងៗ និងការប្រជុំ

ពិភាក្សានៅក្នុងក្រុមការងារដែលចុះសិក្សាស្រាវជ្រាវ ៣)វិភាគទិន្នន័យទៅតាមសូចនាករ និង ៤)បញ្ជូនលទ្ធផលនៃការវិភាគទៅអង្គភាពគោលដៅ (មន្ទីរពេទ្យខេត្តកំពង់ចាម)និងភាគីពាក់ព័ន្ធដើម្បីពិនិត្យ និងផ្តល់យោបល់។ ការវិភាគទិន្នន័យធ្វើឡើងតាមវិធីសាស្ត្រ “*ការពិពណ៌នាបែបគុណភាព*”។ ចំណែកឯទិន្នន័យដែលមានលក្ខណៈជាបរិមាណ ដូចជាតារាង ក្រាហ្វិក ត្រូវបានយកមកប្រើប្រាស់សម្រាប់គាំទ្របន្ថែមដល់ការវិភាគ។

ជំពូកទី២. ស្ថានភាពទូទៅវិស័យសុខាភិបាល និងសមិទ្ធកម្មនៃមន្ទីរពេទ្យខេត្តកំពង់ចាម

២.១. បរិបទរួមនៃការកែទម្រង់

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីនយោបាយ ដោយឈរលើគោលការណ៍គ្រឹះសំខាន់ៗ ក្នុងនោះមានការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាជនគ្រប់ផ្នែក គ្រប់ថ្នាក់ និងគ្រប់មជ្ឈដ្ឋានឱ្យកាន់តែប្រសើរឡើងទាំងគុណភាព ប្រសិទ្ធភាព និងវិសាលភាព ពោលគឺជាសេវាសាធារណៈដែលនៅកៀកជាមួយប្រជាជន និងទទួលបានការជឿទុកចិត្តពីប្រជាជន[៣]។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បាននិងកំពុងបន្តជំរុញដំណើរការកែទម្រង់ស៊ីជម្រៅ និងទូលំទូលាយ ដែលរួមមាន÷ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងជាពិសេសដោយផ្តោតសំខាន់លើវិស័យអប់រំ និងសុខាភិបាល សំដៅធ្វើឱ្យសេវាសាធារណៈកាន់តែមានភាពឆ្លើយតប ប្រសិទ្ធភាព ប្រសិទ្ធផល និងជំនឿទុកចិត្តពីប្រជាជន។

ជាលទ្ធផល រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានសមិទ្ធផលធំៗជាច្រើន ជាពិសេសការសម្រេចបាននូវគោលដៅនៃសូចនាករផ្នែកសង្គមកិច្ច ទាំងក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ ជាក់ស្តែង សុខភាពសាធារណៈត្រូវបានកែលម្អជាលំដាប់ ក្នុងនោះរាជរដ្ឋាភិបាលកម្ពុជា សម្រេចបានស្ទើរទាំងស្រុងនូវគោលដៅអភិវឌ្ឍសហស្សវត្សកម្ពុជា២ទៅ៣ឆ្នាំ មុនកាលវិភាគកំណត់ទាក់ទងនឹងការកាត់បន្ថយអត្រាមរណភាពមាតា ទារកនិងកុមារ ការកាត់បន្ថយបន្ទុកជំងឺឆ្លង ដូចជា ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺរបេង ជំងឺមិនឆ្លង និងកត្តាហានិភ័យនានាដែលមានផលប៉ះពាល់ដល់សុខភាពប្រជាជន ជាពិសេសទទួលបានជោគជ័យក្នុងការលុបបំបាត់ជំងឺកញ្ជ្រិលទាំងស្រុងនៅឆ្នាំ២០១៦[៤]។ បើយើងក្រឡេកមើលអាយុកាលសង្ឃឹមរស់ជាមធ្យមរបស់ប្រជាជនបានកើនពី ៥៦,៧ឆ្នាំ នៅឆ្នាំ១៩៩៨ ដល់

[៣] រាជរដ្ឋាភិបាលកម្ពុជា, កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥, ២០១៣, ទំព័រ ៥។

[៤] រាជរដ្ឋាភិបាលកម្ពុជា, ឆ្នាំ២០១៩ របាយការណ៍វឌ្ឍនភាពគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៦-២០៣០

៧០,៦ឆ្នាំ នៅឆ្នាំ២០១៨។ ម៉្យាងទៀត រាជរដ្ឋាភិបាលបានបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុ ក្នុងគោលបំណងផ្តល់ការគាំពារផ្នែកហិរញ្ញវត្ថុក្នុងការប្រើប្រាស់សេវាថែទាំសុខភាពរបស់ប្រជាជនតាមយន្តការគាំពារសុខភាពសង្គម ដែលកំពុងត្រូវបានអនុវត្ត ដូចជាកម្មវិធីមូលនិធិសមធម៌ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារមានអាយុក្រោម២ឆ្នាំ។ តាមការប៉ាន់ប្រមាណនៅឆ្នាំ២០១៩ ប្រជាជន ៣៨,៥% នៃប្រជាជនកម្ពុជាសរុបជាង ១៦លាននាក់ ត្រូវបានគ្របដណ្តប់ដោយមូលនិធិសមធម៌ និងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព (ដោយមិនរាប់បញ្ចូលការធានារ៉ាប់រងសុខភាពឯកជន) ដោយកើនឡើងពី ៣៥,៧% នៅឆ្នាំ២០១៨[៥]។

ប្រការនេះបានធ្វើឱ្យស្ថានភាពទូទៅរបស់ប្រជាជនកាន់តែប្រសើរឡើង តាមរយៈការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រកបដោយសមធម៌ក្នុងចំណោមប្រជាជនដែលមានស្ថានភាពសេដ្ឋកិច្ចខុសៗគ្នា និងរវាងប្រជាជនរស់នៅទីប្រជុំជន និងតំបន់ជនបទ[៦]។

២.២. ទិដ្ឋភាពរួមនៃប្រព័ន្ធសុខាភិបាល

២.២.១. ប្រព័ន្ធសុខាភិបាល

ក្នុងក្របខណ្ឌនៃការកែទម្រង់ រាជរដ្ឋាភិបាលកម្ពុជា បានគិតគូរយ៉ាងយកចិត្តទុកដាក់ក្នុងការកែលម្អប្រព័ន្ធសុខាភិបាលតាមរយៈការធ្វើកំណែទម្រង់ជាដំណាក់កាលៗ ចាប់តាំងពីឆ្នាំ១៩៩៤ ដោយផ្តោតលើ«ការកែលម្អ និងពង្រឹកការថែទាំសុខភាពបឋម តាមរយៈការអនុវត្តអភិក្រមប្រព័ន្ធសុខាភិបាលស្រុក» សំដៅឆ្លើយតបទៅនឹងតម្រូវការផ្នែកសុខភាពជាសារវន្តរបស់ប្រជាពលរដ្ឋ។ ការធ្វើកំណែទម្រង់វិស័យសុខាភិបាល បាននាំមកនូវការផ្លាស់ប្តូរជាបណ្តើរៗចំពោះវិស័យសុខាភិបាលកម្ពុជា ដោយបានប្រែក្លាយប្រព័ន្ធសុខាភិបាលកម្ពុជាពី«ការរៀបចំប្រព័ន្ធសុខាភិបាលឈរលើរចនាសម្ព័ន្ធរដ្ឋបាល ទៅរកប្រព័ន្ធសុខាភិបាលផ្នែកលើលក្ខណៈវិនិច្ឆ័យចំនួនប្រជាជន និងលទ្ធភាពមកទទួលយកសេវា

[៥] របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ ២០១៩។

[៦] ក្រសួងសុខាភិបាល, ឆ្នាំ២០១៦ ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០។

សុខភាព»។ ជាលទ្ធផល ប្រព័ន្ធសុខាភិបាលកម្ពុជាបច្ចុប្បន្នត្រូវបានរៀបចំជា៣ថ្នាក់ រួមមាន÷ ថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត និងថ្នាក់ស្រុក(រូបភាព ២.១)។ តួនាទីនិងមុខងារនៃថ្នាក់នីមួយៗត្រូវបានពិនិត្យ និងកំណត់ច្បាស់លាស់សាជាថ្មីឡើងវិញ[៧]។

រូបភាព ២.១ ស្តីពីថ្នាក់ទាំង៣ នៃប្រព័ន្ធសុខាភិបាលសាធារណៈ



ប្រភព÷ ក្រសួងសុខាភិបាល ឆ្នាំ២០១៦

ក្នុងបរិបទនេះ ប្រព័ន្ធសុខាភិបាល បានផ្តោតជាសំខាន់ទៅលើការអនុវត្តផែនការគ្របដណ្តប់ សុខាភិបាល (ផ.គ្រ.ស) ដែលជាក្របខណ្ឌសម្រាប់អភិវឌ្ឍបណ្តាញហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យពីររួមគ្នា÷ ចំនួនប្រជាជន និងលទ្ធភាពទទួលបានសេវាសុខភាព (តារាង ២.១) ព្រមទាំងគិតគូរហ្មត់ចត់អំពីគុណភាពនៃការថែទាំ និងធនធានដែលមាន។ ជាលទ្ធផល រហូតដល់ឆ្នាំ២០១៩ មូលដ្ឋានសុខាភិបាល

[៧] ក្រសួងសុខាភិបាល, ឆ្នាំ២០១៦ ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០។

សាធារណៈទូទាំងប្រទេសរួមមាន÷ មណ្ឌលសុខភាពចំនួន ១.២២១កន្លែង ប៉ុស្តិ៍សុខភាព ចំនួន១២៧កន្លែង និងមន្ទីរពេទ្យចំនួន១២៦កន្លែង។ ក្នុងចំណោមមន្ទីរពេទ្យ១២៦ មាន មន្ទីរពេទ្យជាតិចំនួន៩ មន្ទីរពេទ្យបង្អែករាជធានី/ខេត្តចំនួន២៥ និងមន្ទីរពេទ្យបង្អែកស្រុក ប្រតិបត្តិចំនួន៩២ ស្ថិតក្នុងស្រុកប្រតិបត្តិ១០៣ ក្នុងរាជធានី/ខេត្តទាំង២៥[៨]។

២.២.២. ផែនការគ្រប់ដណ្តប់សុខាភិបាល

ផែនការគ្រប់ដណ្តប់សុខាភិបាលគឺជាក្របខណ្ឌសម្រាប់អភិវឌ្ឍបណ្តាញហេដ្ឋារចនា-សម្ព័ន្ធសុខាភិបាល ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យពីររួមគ្នា÷ ចំនួនប្រជាជន និងលទ្ធភាព ទទួលបានសេវាសុខភាព ព្រមទាំងគិតគូរហ្មត់ចត់អំពីគុណភាពនៃការថែទាំ និងធនធាន ដែលមាន ក្នុងគោលបំណងដើម្បី÷ ១)អភិវឌ្ឍសេវាសុខភាពដោយកំណត់លក្ខណៈវិនិច្ឆ័យ សម្រាប់ទីតាំង និងតំបន់ទទួលខុសត្រូវរបស់មូលដ្ឋានសុខាភិបាល ២)បែងចែកធនធាន ហិរញ្ញវត្ថុ និងធនធានមនុស្សប្រកបដោយសមធម៌ ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃ ការប្រើប្រាស់ធនធានទាំងនោះ និង៣)ធានាថាសេចក្តីត្រូវការផ្នែកសុខភាពរបស់ប្រជា ពលរដ្ឋត្រូវបានឆ្លើយតបប្រកបដោយសមធម៌តាមរយៈការគ្របដណ្តប់នៃសេវាសុខភាព លើប្រជាពលរដ្ឋទាំងអស់[៩]។

តារាង ២.១ ស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់បង្កើតមូលដ្ឋានសុខាភិបាល

មូលដ្ឋានសុខាភិបាល	ចំនួនប្រជាជន (នាក់)	លទ្ធភាពទទួលបានសេវា
មណ្ឌលសុខភាព	ចំនួនសមស្រប ១០.០០០ ប្រែប្រួលពី ៨.០០០-១២.០០០	ក្នុងរង្វង់១០គ.ម ឬធ្វើដំណើរជាអតិបរមា ២ម៉ោង ដោយថ្មើរជើងក្នុងតំបន់ ទទួលខុសត្រូវរបស់មណ្ឌលសុខភាព

[៨] ក្រសួងសុខាភិបាល, របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០១៩។

[៩] ក្រសួងសុខាភិបាល, ឆ្នាំ២០១៦ ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០។

មន្ទីរពេទ្យបង្អែក	ចំនួនសមស្រប ១០០.០០០ ប្រែប្រួលពី ៦០.០០០-២០០.០០០+	ក្នុងតំបន់មានប្រជាជនរស់នៅច្រើន÷ ធ្វើដំណើរ ២ម៉ោងដោយរថយន្ត ឬ កាណូត។ក្នុងតំបន់ជនបទ: ធ្វើដំណើរ មិនលើសពី៣ម៉ោងដោយរថយន្ត ឬកាណូត
ប៉ុស្តិ៍សុខភាព	ប្រែប្រួលពី ២.០០០-៣.០០០	ចម្ងាយពីឃុំ/ភូមិទៅមណ្ឌលសុខភាព ជិតបំផុត លើសពី ១៥ គ.ម ហើយ មានរបាំងភូមិសាស្ត្រ (ទន្លេ ភ្នំ ឬ ស្ថានភាពផ្លូវពិបាក)

ប្រភព÷ ក្រសួងសុខាភិបាល ឆ្នាំ២០១៦

២.២.៣. ប្រព័ន្ធផ្តល់សេវាសុខាភិបាល

ក្រសួងសុខាភិបាលបាននិងកំពុងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់នូវអភិក្រមសមា-ហរណកម្មនៃការផ្តល់សេវាសុខាភិបាល រួមមាន សេវាបង្ការ អប់រំលើកកម្ពស់គុណភាពសុខភាព ការធ្វើរោគវិនិច្ឆ័យ ព្យាបាលនិងថែទាំជំងឺ និងស្តារនីតិសម្បទា តាមរយៈការផ្តល់សេវាមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព នៅតាមមូលដ្ឋានសុខាភិបាល ពង្រឹងប្រព័ន្ធបញ្ជូនអ្នកជំងឺ និងការចុះផ្តល់សេវាតាមភូមិឃុំ ជាពិសេសនៅក្នុងតំបន់ជនបទដែលប្រជាពលរដ្ឋពិបាកមកទទួលយកសេវា។ ប្រព័ន្ធនៃការផ្តល់សេវាសុខាភិបាលបានផ្តោតជាចម្បងលើការផ្តល់សេវាឬអន្តរាគមន៍សុខភាពសាធារណៈជាច្រើនដែលទាក់ទងផ្ទាល់នឹងបញ្ហាសុខភាពរបស់ប្រជាពលរដ្ឋផង និងទាក់ទងនឹងកត្តាសង្គមនានាដែលមានផលប៉ះពាល់លើសុខភាពផង។ ការផ្តល់សេវាទាំងអស់នោះមានគោលដៅកាត់បន្ថយថែមទៀត នូវការឈឺនិងស្លាប់របស់មាតា ទារក និងកុមារ បន្ថយបន្ទុកនៃជំងឺឆ្លង ជំងឺមិនឆ្លង និងជំងឺរ៉ាំរ៉ៃ ព្រមទាំងបញ្ហាសុខភាពសាធារណៈចម្បងៗដទៃទៀត[90]។

[90] ក្រសួងសុខាភិបាល, ឆ្នាំ២០២០ ស្តីពីប្រព័ន្ធសុខាភិបាល, គេហទំព័រ www.moh.gov.kh។

រូបភាព ២.២ ស្តីពីប្រព័ន្ធផ្តល់សេវាសុខាភិបាល



មន្ទីរពេទ្យជាតិ

ផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់កម្រិត៣

និងសេវាឯកទេសខ្ពស់



មន្ទីរពេទ្យបង្អែករាជធានីខេត្ត

ផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់កម្រិត២ឬកម្រិត៣

មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ

ផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់កម្រិត១ឬកម្រិត២



មណ្ឌលសុខភាព

ផ្តល់សេវាសំណុំសកម្មភាពអប្បរមា

ការផ្តល់សេវាតាមភូមិឃុំ ប្រព័ន្ធបញ្ជូនអ្នកជំងឺ





ប្រភព÷ ក្រសួងសុខាភិបាល ឆ្នាំ២០២០

២.៣. ស្ថានភាពទូទៅរបស់មន្ទីរពេទ្យខេត្តកំពង់ចាម

២.៣.១. ភូមិសាស្ត្រមន្ទីរពេទ្យខេត្តកំពង់ចាម

ខេត្តកំពង់ចាមមានផ្ទៃដីសរុប៤.៥៤៨,០៩គម២ មានក្រុងចំនួន១ គឺក្រុងកំពង់ចាម និងស្រុកមានចំនួន៩ គឺស្រុកបាធាយ ចំការលើ ជើងព្រៃ កំពង់សៀម កងមាស កោះសូទិន ព្រៃឈរ ស្រីសន្ធរ និងស្ទឹងត្រង់ ព្រមទាំងមានឃុំចំនួន១០៥ សង្កាត់ចំនួន៤ ភូមិចំនួន៩១៦។ នៅឆ្នាំ២០១៩ ខេត្តមានប្រជាជនចំនួន ១.១០៧.៦០៥នាក់ ក្នុងនោះស្រីមានចំនួន ៥៦៦.៦៧៨នាក់ និងចំនួនគ្រួសារសរុប ២៧៤.០០៩គ្រួសារ ដោយមានដង់ស៊ីតេប្រជាជន ២៤៣នាក់ក្នុង១គីឡូម៉ែត្រក្រឡា។ ជាមួយគ្នាដែរ ខេត្តមានមន្ទីរពេទ្យខេត្តចំនួន១ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន៩ មន្ទីរពេទ្យបង្អែកស្រុកចំនួន៦ មណ្ឌលសុខភាពចំនួន ៩១[99]។

មន្ទីរពេទ្យខេត្តកំពង់ចាមស្ថិតនៅក្បែរសាលាខេត្តកំពង់ចាម នៅទល់មុខនឹងសាលាក្រុងកំពង់ចាម ដែលស្ថិតនៅភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម ខាងមុខ (ខាងជើង) ទល់នឹងវិថីព្រះកេតុមាលា ខាងកើតទល់នឹងវិថីព្រះបាទសុរិយាវរ្ម័នទី២ ខាងលិចទល់នឹងសាលាមធ្យមសិក្សាសុខាភិ-បាលភូមិភាគកំពង់ចាម ខាងត្បូងទល់នឹងវិថីជ័យវរ្ម័នទី៧ និងមានផ្ទៃដីសរុប៣៧ ២៥៣,៧៥ ម៉ែត្រក្រឡា។

២.៣.២. ប្រវត្តិមន្ទីរពេទ្យខេត្តកំពង់ចាម

មន្ទីរពេទ្យខេត្តកំពង់ចាមត្រូវបានកសាងឡើងក្នុងអំឡុងឆ្នាំ១៩៣០ នៅក្នុងសម័យកាលដែលប្រទេសកម្ពុជាស្ថិតនៅក្រោមអាណានិគមបារាំង ហើយដែលពេលនោះមន្ទីរពេទ្យនេះមានឈ្មោះថា «មន្ទីរពេទ្យខេត្តកំពង់ចាម»។ កាលពីចាប់ផ្តើមដំបូង មន្ទីរពេទ្យនេះមានអគារចំនួន៦។ ក្រោយៗមក អគារថ្មីមួយចំនួនត្រូវបានសាងសង់ឡើងដើម្បីជំនួសអគារចាស់ៗមួយចំនួនដែលចាស់ទ្រុឌទ្រោមមិនអាចប្រើប្រាស់បាន។ រហូតមកឆ្នាំ២០២០នេះ មន្ទីរពេទ្យ

[99] មន្ទីរសុខាភិបាលខេត្តកំពង់ចាម របាយការណ៍សមិទ្ធផលការងារវិស័យសុខាភិបាលឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០។

នៅសល់តែអគារចាស់មួយប៉ុណ្ណោះដែលនៅជាភស្តុតាង គឺអគារជំងឺឆ្លង[១២]។

នៅសម័យសង្គមរាស្ត្រនិយម មន្ទីរពេទ្យទទួលបានអគារចំនួន៤បន្ថែមទៀត។ អគារ១ ក្នុងចំណោមអគារអស់ទាំងនោះ គឺជាជំនួយរបស់ប្រទេសប៉ូឡូញ ដោយប្រើជាអគារសម្រាប់ផ្នែកវះកាត់ ដែលបច្ចុប្បន្ននៅមានវត្តមាននៅឡើយ។ ចំណែកអគារ៣ទៀត គឺជាអគារសំរាកព្យាបាល អគារសម្រាប់បណ្តុះបណ្តាលមន្ត្រីសុខាភិបាល និងអគារឱសថបាយ។ នៅឆ្នាំ២០០៨ អគារសាលារៀនសម្រាប់បណ្តុះបណ្តាលមន្ត្រីសុខាភិបាល ត្រូវបានប្តូរទៅនៅជាមួយសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគវិញ ហើយអគារនេះត្រូវបានរុះរើដើម្បីសាងសង់អគារដាក់អ្នកជំងឺដែលផ្តល់ដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (Japan International Cooperation Agency: JICA)។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ មន្ទីរពេទ្យនេះត្រូវបានប្រើប្រាស់ ធ្វើជាមន្ទីរពេទ្យសម្រាប់បម្រើឱ្យភូមិភាគ[១៣]។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ មន្ទីរពេទ្យនេះត្រូវបានបើកទ្វារឱ្យដំណើរការឡើងវិញនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៩ គឺជាមន្ទីរពេទ្យខេត្តទី២ បន្ទាប់ពីមន្ទីរពេទ្យខេត្តទី១ នៅឃុំស្នង ស្រុកត្បូងឃ្មុំ (បច្ចុប្បន្នក្រុងស្នង) ដែលបានបើកទ្វារនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ នៅក្នុងកិច្ចដំណើរការរបស់ខ្លួន មន្ទីរពេទ្យបានទទួលការគាំទ្រទាំងផ្នែកបច្ចេកទេសទាំងសម្ភារពីកងទ័ពនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨២ និងជំនួយបច្ចេកទេសពីសាធារណៈរដ្ឋប៉ូឡូញពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨១។ បន្ទាប់មកទៀត មន្ទីរពេទ្យក៏បានទទួលការឧបត្ថម្ភគាំទ្រលើផ្នែកសម្ភារនិងបច្ចេកទេសពីអង្គការកាកបាទក្រហមអន្តរជាតិនៃប្រទេសស្វីសពីឆ្នាំ១៩៨១ រហូតដល់ឆ្នាំ១៩៨៥[១៤]។

នៅឆ្នាំ១៩៨៦ អគារជំងឺកុមារត្រូវបានកសាងឡើង ក្រោមការឧបត្ថម្ភនិងគាំទ្រពីឯកឧត្តម **ហ៊ុន ណេង** អភិបាលខេត្តកំពង់ចាម។ បន្ទាប់មកទៀត អគារជំងឺទូទៅក៏បាន

[១២] ទិន្នន័យទទួលបានពីសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្ត នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០។
[១៣] -ជ-
[១៤] -ជ-

កសាងហើយរួចរាល់នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៩១។ អគារនេះក៏ជាគំនិតផ្តួចផ្តើម និងការជួយឧបត្ថម្ភពី ឯកឧត្តម **ហ៊ុន ណេង** អភិបាលខេត្តកំពង់ចាម ហើយអគារនេះបានសាងសង់លើអគារចាស់ដែលជាកេរ្តិ៍ដំណែលរបស់អាណានិគមបារាំង។ ក្រោយមកទៀត នៅឆ្នាំ១៩៩៨ ឯកឧត្តម **ហ៊ុន ណេង** ក៏បានសាងសង់អគារ១ទៀតសម្រាប់ព្យាបាលសុខភាពមាត់ធ្មេញ ច្រមុះ ត្រចៀក និងបំពង់ក[១៥]។

បន្ទាប់មកទៀត មន្ទីរពេទ្យបានទទួលការឧបត្ថម្ភគាំទ្រពីអង្គការគ្រូពេទ្យគ្មានព្រំដែន បារាំងពីឆ្នាំ ១៩៩០ រហូតដល់ឆ្នាំ១៩៩៤ ហើយបានបន្តជួយលើផ្នែករបេងរហូតដល់ឆ្នាំ ១៩៩៩ និងបានសាងសង់អគាររបេងមួយ ដែលធ្វើពីឈើប្រក់ស៊ីប្រូស៊ីម៉ង់ត៍សម្រាប់មន្ទីរពេទ្យ។ ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៥ អង្គការកិច្ចសហប្រតិបត្តិការបច្ចេកទេសបែលហ្ស៊ិក (Belgium Technical Cooperation:BTC) ក៏បានចូលរួមក្នុងការកសាងហេដ្ឋារចនសម្ព័ន្ធសម្រាប់មន្ទីរពេទ្យផងដែរ មានជាអាទិ៍ ការចាក់សាបផ្លូវនៅមុខអគារកុមារ ការកសាងសួនកុមារ អគារឃ្លាំងឱសថ និងបង្គន់អនាម័យជាដើម។ ជាមួយគ្នាដែរ អង្គការនេះបានបន្តជួយមន្ទីរពេទ្យខេត្តកំពង់ចាមសម្រាប់អ្នកជំងឺអេដស៍[១៦]។

នៅមុនឆ្នាំ២០០៨ មន្ទីរពេទ្យខេត្តកំពង់ចាមធ្លាប់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិកំពង់ចាម-កំពង់សៀម។ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៨ មន្ទីរពេទ្យនេះបានស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់មន្ទីរសុខាភិបាល ដោយមានឈ្មោះជាមន្ទីរពេទ្យខេត្តកំពង់ចាម ដែលអនុវត្តសំណុំសកម្មភាពបង្ក្រប់កម្រិត៣ (CPA3)។ នៅពេលនោះមន្ទីរពេទ្យបានផ្តល់នូវសេវាជូនអតិថិជនតាមសេចក្តីណែនាំស្តីពីសំណុំសកម្មភាពបង្ក្រប់សម្រាប់អភិវឌ្ឍន៍មន្ទីរពេទ្យរបស់ក្រសួងសុខាភិបាលមានដូចជា÷ ១)ផ្នែកវះកាត់ ២)ផ្នែកជំងឺទូទៅនិងសង្គ្រោះបន្ទាន់ ៣)ផ្នែកជំងឺទឹកនោមផ្អែម ៤)ផ្នែកជំងឺឆ្លង ៥)ផ្នែកជំងឺរបេង ៦)ផ្នែកជំងឺឃ្លង់ ៧)ផ្នែកជំងឺកុមារ ៨)ផ្នែកសម្ភពនិងរោគស្ត្រី ៩)ផ្នែក

[១៥] ទិន្នន័យទទួលបានពីសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្ត នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០។
[១៦] - ជ-

ជំងឺច្រមុះ ត្រចៀក និងបំពង់ក ១០)ផ្នែកសុខភាពមាត់ធ្មេញ ១១)ផ្នែកសុខភាពផ្លូវចិត្ត ១២)ផ្នែកចក្ខុរោគ ១៣)ផ្នែកមន្ទីរពិសោធន៍ ១៤)ផ្នែកផ្តល់ឈាម និង ១៥)ផ្នែកថតឆ្អុះ (កាំរស្មីអ៊ិច ស្កានែរ អេកូ និង ផ្នែកឆ្អុះក្រពះ)[១៧]។

សកម្មភាពរបស់មន្ទីរពេទ្យមានការកើនឡើងជាលំដាប់ទៅតាមបណ្តាឆ្នាំ ជាពិសេសកំណើនគួរឱ្យកត់សំគាល់គឺក្នុងអំឡុងពេលដែលមន្ទីរពេទ្យអនុវត្តមូលនិធិសមធម៌ ដោយមានការសហការជាមួយអង្គការ BTC។ នៅឆ្នាំ២០០៨ អ្នកជំងឺចូលមកសំរាកព្យាបាលជាមធ្យមប្រចាំខែមានប្រហែលពី៩០០ ទៅ១១០០ នាក់ ដែលអត្រាប្រើប្រាស់គ្រែស្មើរតែ១០០ ភាគរយ។ អ្នកជំងឺសំរាកជាមធ្យមប្រចាំថ្ងៃមានពី២៥០ ទៅ២៧០នាក់។ ចំនួននេះបើប្រៀបធៀបទៅបណ្តាឆ្នាំមុនៗ មានការកើនឡើងយ៉ាងច្រើន ជាពិសេសមុនឆ្នាំ១៩៩៩ អ្នកជំងឺសំរាកជាមធ្យមប្រចាំថ្ងៃមានមិនដល់១០០នាក់ ក្នុង១ថ្ងៃ ហើយ អត្រាប្រើប្រាស់គ្រែពេលនោះមានមិនដល់៥០ ភាគរយ[១៨]។

ដោយពិនិត្យឃើញសកម្មភាពចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយឆ្នាំទៅមួយឆ្នាំ និង រួមផ្សំអគារសំរាកព្យាបាលចាស់ទ្រុឌទ្រោមស្ទើរប្រើការលែងកើតផងនោះ ទើបក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលខេត្តកំពង់ចាម ដោយមានការសហការជាមួយអង្គការ JICA របស់រាជរដ្ឋាភិបាលជប៉ុន មានការចាប់អារម្មណ៍ និងសម្រេចចិត្តផ្តល់ន្ធវអគារចំនួន២ គឺអគារដាក់អ្នកជំងឺវះកាត់ អ្នកជំងឺសម្ភពនិងរោគស្ត្រី និងអគារសង្គ្រោះបន្ទាន់វះកាត់ ក្រោយវះកាត់ សល្យាគារ និងផ្នែកថតឆ្អុះ។ អគារទាំង២បានដំណើរការសាងសង់នៅឆ្នាំ២០០៨ និងបានសម្ពោធដាក់ឱ្យដំណើរការនាថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**[១៩]។

នៅឆ្នាំ២០០៩ រាជរដ្ឋាភិបាលបានបង្កើតនិងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាលចំនួន៣០ ក្នុងនោះមានមន្ទីរពេទ្យបង្អែកខេត្តចំនួន៨ និង

[១៧] ទិន្នន័យទទួលបានពីសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្ត នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០។

[១៨] -ជ-

[១៩] -ជ-

ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន២២។ ក្នុងចំណោមមន្ទីរពេទ្យបង្អែកខេត្តទាំង ៨នោះមាន មន្ទីរពេទ្យខេត្តកំពង់ចាមផងដែរ។

ក្រោយមកទៀត នៅឆ្នាំ២០១៥ មានអគារចំនួន៣ទៀត (អគារមណ្ឌលផ្តល់ឈាម អគារមន្ទីរពិសោធ៍ និងអគាររបេងធ្វើពីបេតុងប្រក់ក្បឿង) ក៏ត្រូវបានសាងសង់ក្រោមការឧបត្ថម្ភដោយអង្គការ US PACOM; NAMRU II និងMSF បារាំង ដែលបានសម្ពោធដាក់ឱ្យដំណើរការនៅដើមឆ្នាំ២០១៦[២០]។

ជាបន្តបន្ទាប់ មន្ទីរពេទ្យក៏ទទួលបានការគាំទ្រពីអង្គការ និងដៃគូមួយចំនួនទៀត រួមមាន÷ ១)អង្គការ MSF បារាំង ជួយលើផ្នែកជំងឺអេដស៍ ២)អង្គការ IRIS ជួយលើផ្នែកជំងឺភ្នែក ៣)អង្គការ MICADO ជួយលើផ្នែកស្រាវជ្រាវជំងឺមហារីកមាត់ស្បូន ៤)អង្គការ DOULEUR SANS FRONTIERE ជួយលើឱសថព្យាបាលសំរាន់ ៥)មន្ទីរពេទ្យដៃគូមកពីប្រទេសបារាំង មានមន្ទីរពេទ្យ SAINT BRIEUC និងមន្ទីរពេទ្យ AVICENNES បានជួយជាសម្ភារៈមួយចំនួន និងជួយលើផ្នែកបច្ចេកទេស ៦)អង្គការ JICA បានជួយជាសម្ភារៈមួយចំនួនធំសម្រាប់ផ្នែកពិសោធន៍ និងអ្នកស្ម័គ្រចិត្តម្នាក់ផងដែរ ៧)អង្គការ CIOMAL បានជួយលើឱសថ និងប្រាក់លើកទឹកចិត្តសម្រាប់ផ្នែកជំងឺឃ្លង់ ៨)អង្គការសុខភាពពិភពលោក (WHO) បានជួយធ្វើការបណ្តុះបណ្តាលបុគ្គលិក ៩)មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ (UNICEF) បានជួយជួសជុលអគារសម្រាប់ថែទាំអេដស៍កុមារ ១០)អង្គការ URC បានជួយជួសជុលអគារសម្រាប់ជំងឺផ្តាសាយបក្សី និងបំពាក់សម្ភារមួយចំនួនធំ ១១)អង្គការ BTC ដែលជាអង្គការដៃគូដ៏ធំរបស់មន្ទីរពេទ្យបានជួយដល់មន្ទីរពេទ្យយ៉ាងច្រើនលើផ្នែកមូលនិធិសមធម៌ ប្រាក់លើកទឹកចិត្តបុគ្គលិក ឱសថ អាហារអ្នកជំងឺ សម្ភារបរិក្ខារ និងអគារជាដើម ១២)ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (Korea International Cooperation Agency: KOICA) បានជួយផ្តល់អ្នកស្ម័គ្រចិត្តមួយចំនួន និងជួយបំពាក់សម្ភារសម្រាប់មន្ទីរពេទ្យ មានដូចជា ឧបករណ៍ឆ្លុះក្រពះមួយសម្រាប់ និងសម្ភារសម្រាប់

[២០] ទិន្នន័យទទួលបានពីសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្ត នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០។

ផ្នែកថែទាំទារក[២១]។

នៅពេលបច្ចុប្បន្ននេះ មានអង្គការដៃគូចំនួន១១ដែលកំពុងបំពេញបេសកកម្មនៅមន្ទីរពេទ្យខេត្តកំពង់ចាម រួមមាន÷ ១)អង្គការ JICA ២)អង្គការ NANUM International ៣)មូលនិធិប្រជាជនរបស់អង្គការសហប្រជាជាតិ (United Nation Population Fund: UNFPA) ៤)មូលនិធិជំនួយសុខភាព (Aids Healthcare Foundation: AHF) ៥)អង្គការសកម្មភាពសុខុមាលភាពស្ត្រីកម្ពុជា (Kampuchea Women"s Welfare Action: KWWA) ៦)អង្គការគ្រីស្ទ បរិសុទ្ធនៃថ្ងៃចុងក្រោយ (Last Day Saint Charities: LDSC) ៧)កម្មវិធីអភិវឌ្ឍន៍ការធ្វើរោគវិនិច្ឆ័យមីក្រូជីវសាស្ត្រ (Diagnosis Microbiology Development Program: DMDP) ៨)ផ្នែកស្រាវជ្រាវវេជ្ជសាស្ត្រកងទ័ពជើងទឹកទី២ (Naval Medical Research Unit 2: NAMRU-2) ៩)ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (German Agency for International Cooperation: GIZ) ១០) គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហមកម្ពុជា (International Committee of Red Cross Cambodia: ICRC) និង ១១) អង្គការ NEXTSTEP[២២]។

២.៣.៣. ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

២.៣.៣.១. ចក្ខុវិស័យ

មន្ទីរពេទ្យខេត្តកំពង់ចាមផ្តល់ការព្យាបាលនិងថែទាំសុខភាព ប្រកបដោយគុណភាពល្អនិងសុវត្ថិភាពដើម្បីកាត់បន្ថយអត្រាឈឺ និងអត្រាស្លាប់របស់ប្រជាជនទូទៅ។

២.៣.៣.២. បេសកកម្ម

លើកកម្ពស់ការផ្តល់សេវាព្យាបាលនិងថែទាំសុខភាព ប្រកបដោយគុណភាពល្អ ប្រសិទ្ធភាព សុវត្ថិភាព និងសមធម៌ ដល់អ្នកជំងឺ និងប្រជាជនទូទៅ ជាពិសេសប្រជាជនក្រីក្រនិងងាយរងគ្រោះ។

[២១] ទិន្នន័យទទួលបានពីសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្ត នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០។
[២២] - ជ-

២.៣.៣.៣. គុណតម្លៃ

- ក្រមសីលធម៌វិជ្ជាជីវៈ
- ការគោរព ស្មោះត្រង់
- សមធម៌ មិនរើសអើង
- ឧត្តមភាព។

២.៣.៤. ទម្លាប់ធម៌របស់មន្ទីរពេទ្យ

គណៈគ្រប់គ្រងមន្ទីរពេទ្យ និងបុគ្គលិកនៃមន្ទីរពេទ្យខេត្តកំពង់ចាមមានទម្លាប់ឬវប្បធម៌នៅក្នុងការបំពេញការងារដូចខាងក្រោម÷

- ការចូលរួម
- ភាពលះបង់និងចែករំលែក
- សាមគ្គីភាព
- តម្លាភាព
- ភាពរួសរាយរាក់ទាក់
- ភាពប្រឡងប្រណាំង
- ការគោរពភាពជារៀមច្បង។

២.៣.៥. រចនាសម្ព័ន្ធមន្ទីរពេទ្យ

ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤មក មន្ទីរពេទ្យខេត្តកំពង់ចាមដឹកនាំនិងគ្រប់គ្រងដោយប្រធាន១រូប និងមានអនុប្រធានចំនួន៦រូប ដែលមានការងារនិងការទទួលខុសត្រូវរៀងៗខ្លួនទៅតាមការកំណត់ដោយប្រធាន។ មន្ទីរពេទ្យមានគណៈកម្មការចំនួន៧ រួមមាន÷ គណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ គណៈកម្មការហិរញ្ញប្បទាន គណៈកម្មការបច្ចេកទេស គណៈកម្មការថែទាំ គណៈកម្មការវិន័យ គណៈកម្មការត្រួតពិនិត្យការការពារការចម្លងរោគ និងគណៈកម្មការសម្រិតសម្រាំង សណ្តាប់ធ្នាប់ សោភ័ណភាព ស្តង់ដា និងស្ថិរភាព។ ផ្សេងពីនោះ មន្ទីរពេទ្យមានក្រុមការងារចំនួន៣ទៀតគឺ ក្រុមការងារគ្រប់គ្រងគ្លីនិក ឱសថ និងការ

ព្យាបាល ក្រុមការងារត្រួតពិនិត្យសុវត្ថិភាពឈាម និងក្រុមការងារលើកកម្ពស់គុណភាពសេវា។

ជាមួយគ្នាដែរ មន្ទីរពេទ្យខេត្តកំពង់ចាមមានផ្នែកបច្ចេកទេស និងផ្នែកគាំទ្រសរុបចំនួន ២៦ រួមមានផ្នែក÷ ១) រដ្ឋបាល ២) គណនេយ្យ ៣) បច្ចេកទេស ៤) ជំងឺកុមារ ៥) ជំងឺរបេង ៦) ហង់សិន ៧) ជំងឺឱកាសនិយមនិងពន្យារជីវិត ៨) ពិគ្រោះជំងឺក្រៅនិងបែងចែកជំងឺ ៩) រថយន្តសង្គ្រោះ ១០) មាត់ធ្មេញ ១១) ត្រចៀក ច្រមុះ និងបំពង់ក ១២) ជំងឺទឹកនោមផ្អែម ១៣) ជំងឺភ្នែក ១៤) ជំងឺផ្លូវចិត្ត ១៥) មន្ទីរពិសោធន៍ ១៦)X-ray Scanner និងUltrasound ១៧) ផ្តល់ឈាម ១៨) ព្យាបាលដោយចលនា ១៩) ជំងឺទូទៅ ២០) ឱសថ ២១) សង្គ្រោះបន្ទាន់ទូទៅនិង Fibro-endoscopy ២២) សង្គ្រោះបន្ទាន់វះកាត់ ២៣) សល្យាគារ ២៤) សម្ភពនិងរោគស្ត្រី ២៥) ជំងឺវះកាត់ (ក) និង ២៦) ជំងឺវះកាត់ (ខ)[២៣]។

[២៣] ដកស្រង់ពីបញ្ជីរាយនាមមន្ត្រីរាជការ របស់មន្ទីរពេទ្យខេត្តកំពង់ចាមឆ្នាំ២០២០។

គំនូសតាង ២.១ ស្តីពីរចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រងមន្ទីរពេទ្យខេត្តកំពង់ចាម



ប្រភព៖ *មន្ទីរពេទ្យខេត្តកំពង់ចាម, ដើមឆ្នាំ២០២០*

ជំពូកទី២

២.៣.៦. បុគ្គលិកមន្ទីរពេទ្យ

គិតមកដល់ដើមឆ្នាំ២០២០ មន្ទីរពេទ្យខេត្តកំពង់ចាមមានមន្ត្រីបម្រើការសរុបចំនួន ៣៨៥នាក់ (ស្ត្រី ២០៤ នាក់) ក្នុងនោះមានមន្ត្រីក្របខណ្ឌចំនួន២៨៩នាក់ មន្ត្រីកិច្ចសន្យាចំនួន២៤នាក់ មន្ត្រីជួលចំនួន២២នាក់ និងកម្មករជួលចំនួន៥០នាក់។

ក្រាហ្វិក ២.១ ស្តីពីចំនួនមន្ត្រីបម្រើការនៅមន្ទីរពេទ្យខេត្តកំពង់ចាម ដើមឆ្នាំ២០២០



ប្រភព÷ មន្ទីរពេទ្យខេត្តកំពង់ចាម, ដើមឆ្នាំ២០២០

ក្នុងចំណោមមន្ត្រីក្របខណ្ឌចំនួន២៨៩នាក់នោះមាន÷ ១)វេជ្ជបណ្ឌិតឯកទេសចំនួន ១៤នាក់ ២)វេជ្ជបណ្ឌិតទូទៅចំនួន៤៨នាក់ ៣)ឆ្មបចំនួន៥៤នាក់ ៤)គិលានុបដ្ឋាកចំនួន ១២៥នាក់ និង ៥)ជំនាញផ្សេងៗទៀតចំនួន៤៨នាក់។

ក្រាហ្វិក ២.២ ស្តីពីកម្រិតជំនាញមន្ត្រីបម្រើការនៅមន្ទីរពេទ្យខេត្តកំពង់ចាម



ប្រភព÷ មន្ទីរពេទ្យខេត្តកំពង់ចាម, ដើមឆ្នាំ២០២០

ក្នុងចំណោមមន្ត្រីជួលចំនួន២២នាក់នោះមាន÷ ១)វេជ្ជបណ្ឌិតឯកទេសចំនួន១នាក់

២)វេជ្ជបណ្ឌិតទូទៅចំនួន១នាក់ ៣)ឆ្មបមធ្យមចំនួន១នាក់ ៤)គិលានុបដ្ឋាកមធ្យមចំនួន ២នាក់ ៥)គិលានុបដ្ឋាកបឋមចំនួន២នាក់ និង ៦)ជំនាញផ្សេងៗទៀត (គណនេយ្យ កុំព្យូទ័រ...) ចំនួន១៥នាក់។

ចំនួនមន្ត្រីក្របខណ្ឌទាំង២៨៩នាក់ ត្រូវបានបែងចែកទៅតាមផ្នែកនីមួយៗដូចមាន ក្នុងតារាង ២.២។ នៅក្នុងការបំពេញការងារមានផ្នែកចំនួន៤ដែលនៅខ្វះខាតធនធានមនុស្ស រួមមាន ផ្នែកសង្គ្រោះបន្ទាន់ ផ្នែកថែទាំទារក ផ្នែកទទួលជំងឺជំបួង និងផ្នែកបញ្ជូនជំងឺ។ ដើម្បី ដោះស្រាយបញ្ហាខ្វះខាតធនធានមនុស្ស គណៈគ្រប់គ្រងមន្ទីរពេទ្យបានធ្វើការ ១)បណ្តុះ បណ្តាល ២)កៀរគរធនធានមនុស្សពីផ្នែកដទៃមកជួយផ្នែកដែលខ្វះខាត ៣)កែសម្រួល សង្វាក់ការងារ ដូចជាដំណើរការនៃការចុះឈ្មោះ និង ៤)បន្ថែមកន្លែងចុះឈ្មោះថ្មីមួយ ទៀត[២៤]។

តារាង ២.២ ស្តីពីចំនួនមន្ត្រីរាជការនៅតាមផ្នែក

ល.រ	ផ្នែក	ចំនួន		
		ប្រុស	ស្រី	សរុប
១	ថ្នាក់ដឹកនាំ	៦	១	៧
២	រដ្ឋបាល	២	២	៤
៣	គណនេយ្យ	០	៧	៧
៤	បច្ចេកទេស	២	២	៤
៥	ជំងឺឱកាសនិយមនិងបន្សាជីវិត	៤	៥	៩
៦	ពិគ្រោះជំងឺក្រៅនិងបែងចែកជំងឺ	៨	៦	១៤
៧	ជំងឺកុមារ	៧	១៥	២២
៨	ជំងឺទូទៅ	៦	៧	១៣
៩	សម្ភពនិងរោគស្ត្រី	៥	៤១	៤៦
១០	ជំងឺវះកាត់ (ខ)	១២	៣	១៥

[២៤] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី ១៣/០៧/ ២០២០។

១១	ត្រចៀក ច្រមុះ និងបំពង់ក	១	២	៣
១២	ផ្នែក X-ray, Scanner and Ultrasound	៤	០	៤
១៣	មាត់ធ្មេញ	៣	៣	៦
១៤	សង្គ្រោះបន្ទាន់វះកាត់	១៦	៥	២១
១៥	សល្យាគារ	៨	៤	១២
១៦	ជំងឺផ្លូវចិត្ត	៥	៣	៨
១៧	ជំងឺរបេង	៥	២	៧
១៨	ព្យាបាលដោយចលនា	២	១	៣
១៩	ឱសថ	៤	៤	៨
២០	មន្ទីរពិសោធន៍	៦	១៥	២១
២១	ផ្តល់ឈាម	៥	៤	៩
២២	សង្គ្រោះបន្ទាន់ទូទៅនិង Fibro-endoscopy	១៣	៧	២០
២៣	ជំងឺវះកាត់ (ក)	៤	៦	១០
២៤	ជំងឺទឹកនោមផ្អែម	៣	៣	៦
២៥	ជំងឺភ្នែក	៥	១	៦
២៦	ជម្ងឺហាង់សិន	៣	០	៣
២៧	រថយន្តសង្គ្រោះ	១	០	១
	សរុបរួម	១៤០	១៤៩	២៨៩

ប្រភព÷ មន្ទីរពេទ្យខេត្តកំពង់ចាម ស្តីពីបញ្ជីរាយនាមមន្ត្រីរបស់មន្ទីរពេទ្យខេត្តកំពង់ចាម ឆ្នាំ២០២០។

២.៣.៧. ចំនួនអគាររបស់មន្ទីរពេទ្យ

តាមរយៈប្រវត្តិរបស់មន្ទីរពេទ្យខេត្តកំពង់ចាម ដែលបានរៀបរាប់ខាងលើបានបង្ហាញថា ពេលកកើតដំបូងមន្ទីរពេទ្យមានអគារចំនួន៦ បន្ទាប់មកទៀតនៅសម័យសង្គមរាស្ត្រនិយមមានអគារចំនួន៤ទៀត ត្រូវបានកសាងឡើង។

ដោយឆ្លងកាត់សង្គ្រាម និងអាយុកាលនៃការប្រើប្រាស់ធ្វើឱ្យអគារមួយចំនួនមាន

សភាពចាស់ទ្រុឌទ្រោមដែលទាមទារឱ្យមានការជួសជុលឬធ្វើការសាងសង់ជាថ្មី។ ជាមួយគ្នាដែរ ដោយមានការវិវឌ្ឍនៃសង្គមជាតិចាប់ពីក្រោយថ្ងៃ៧មករា ឆ្នាំ១៩៧៩ ជាពិសេសនៅក្រោយឆ្នាំ១៩៩៨ ដែលកម្ពុជាមានសុខសន្តិភាពពេញផ្ទៃប្រទេសមក បានធ្វើឱ្យបរិមាណនិងគុណភាពអគាររបស់មន្ទីរពេទ្យមានភាពប្រែប្រួលយ៉ាងឆាប់រហ័ស។ គិតមកដល់ឆ្នាំ ២០១៩ មន្ទីរពេទ្យមានអគារសរុបចំនួន១៩ ដែលក្នុងនោះមានអគារសល់ពីសម័យមុន និងអគារថ្មីៗដែលកើតចេញពីការចូលរួមគាំទ្ររបស់រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំខេត្ត ថ្នាក់ដឹកនាំមន្ទីរសុខាភិបាល ដៃគូអភិវឌ្ឍ សប្បុរសជន និងការចូលរួមរបស់ថ្នាក់ដឹកនាំនិងបុគ្គលិកមន្ទីរពេទ្យផងដែរ។

អគារទាំង១៩ ត្រូវបានប្រើប្រាស់ជាប្រយោជន៍ដូចខាងក្រោម[២៥]÷

១. អគារជំងឺឆ្លង (សាងសង់តាំងពីសម័យអាណានិគមបារាំង) បានប្រើប្រាស់សម្រាប់ជាក់អ្នកជំងឺអេដស៍

២. អគារវះកាត់ចាស់ (សាងសង់សម័យសង្គមរាស្ត្រនិយម) បានប្រើប្រាស់សម្រាប់បន្ទប់វះកាត់៣ និងស្តាំនៃរ១

៣. អគារសង្គ្រោះបន្ទាន់វះកាត់ចាស់ (សាងសង់ដោយសមាគមគ្រូពេទ្យសណ្តាំនិងប្រពោធកម្មបារាំង ១៩៩៣)

៤. អគារជំងឺទូទៅ បានប្រើប្រាស់សម្រាប់ផ្នែកជំងឺទូទៅ ផ្នែកសង្គ្រោះបន្ទាន់ ផ្នែកឆ្អឹងក្រពះ និង អេកូសាស្ត្រ

៥. អគារឃ្លាំងឱសថ

៦. អគាររដ្ឋបាល បានប្រើប្រាស់ជាការិយាល័យថ្នាក់ដឹកនាំមន្ទីរពេទ្យ ផ្នែករដ្ឋបាល ផ្នែកបច្ចេកទេស និងផ្នែកគណនេយ្យ

៧. អគារជំងឺកុមារបានប្រើប្រាស់សម្រាប់ផ្នែកជំងឺកុមារ ផ្នែកជំងឺឱកាសនិយម ជំងឺកាមរោគនិងផ្នែកជំងឺដាច់ដោយឡែក

[២៥] ទិន្នន័យទទួលបានពីសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្ត នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០។

៨. អគារជំងឺរបេង (អំណោយរបស់គ្រូពេទ្យគ្មានព្រំដែនបារាំង)

៩. អគារសាលប្រជុំធំ

១០. អគារជំងឺផ្លូវចិត្ត បានប្រើប្រាស់សម្រាប់ផ្នែកជំងឺផ្លូវចិត្តនិងបំពានគ្រឿងញៀន ផ្នែកជំងឺទឹកនោមផ្អែម និងកន្លែងចុះឈ្មោះទី២

១១. អគារជំងឺភ្នែក

១២. អគារមាត់ ធ្មេញ (ផ្តល់ដោយ ឯកឧត្តម ហ៊ុន ណេង នៅឆ្នាំ១៩៩៨ ហើយបានជួសជុលឡើងវិញដោយអង្គការ NANUM International នៅឆ្នាំ២០១៨) បានប្រើប្រាស់សម្រាប់ផ្នែកមាត់ ធ្មេញ ផ្នែកត្រចៀក ច្រមុះ និងបំពង់ក

១៣. អគារជប៉ុន (សាងសង់ដោយJICA នៅឆ្នាំ២០១០) បានប្រើប្រាស់សម្រាប់ផ្នែកសម្ភព រោគស្ត្រី ផ្នែកវះកាត់ពោះ ផ្នែកវះកាត់តឆ្អឹង ផ្នែកសង្គ្រោះបន្ទាន់វះកាត់ ផ្នែកសល្យាគារ និងផ្នែករូបភាពវេជ្ជសាស្ត្រ

១៤. អគារមេកានិច (សាងសង់ដោយ JICA នៅឆ្នាំ២០១០) បានប្រើប្រាស់សម្រាប់ជាអាងស្តុកទឹកនិងម៉ាស៊ីនបូមទឹក ម៉ាស៊ីនភ្លើង និងរោងជាង

១៥. អគារមន្ទីរពិសោធន៍ (សាងសង់ដោយអង្គការ NAMRU នៅឆ្នាំ២០១៦)

១៦. អគារបណ្តុះបណ្តាល (សាងសង់ដោយអង្គការ Kusanone នៃប្រទេសជប៉ុន នៅឆ្នាំ២០១៣)

១៧. អគារផ្តល់ឈាម (សាងសង់ដោយអង្គការ USPACOM នៅឆ្នាំ២០១៦)

១៨. អគារតម្កល់សព (សាងសង់ដោយអង្គការ BTC នៅឆ្នាំ២០០៥-២០០៦)

១៩. អគារបែងចែកជំងឺ (សាងសង់ឆ្នាំ២០១៨) បានប្រើប្រាស់សម្រាប់ជាកន្លែងចុះឈ្មោះទី១ និងផ្នែកពិនិត្យជំងឺនិងបែងចែកជំងឺ។

២.៤. សមិទ្ធផលនៃការផ្តល់សេវាសុខាភិបាលរបស់មន្ទីរពេទ្យខេត្តកំពង់ចាម

២.៤.១. ចំនួនអ្នកជំងឺពិគ្រោះ

តារាង ២.៣ ស្តីពីសកម្មភាពពិនិត្យ ព្យាបាលជំងឺ សម្រាកពេទ្យតាមឆ្នាំ (២០១៥ ដល់ ២០១៩)

ល.រ	សកម្មភាព	ឆ្នាំ				
		២០១៥	២០១៦	២០១៧	២០១៨	២០១៩
១	ជំងឺពិគ្រោះសរុប	៤៧.៤៤៧	៣៨.៥៥៩	៣៦.០២៨	៣៨.៧៩៦	៤៣.៩៧១
២	ជំងឺសម្រាកសរុប	២១.០២៧	២០.២២២	២០.២៥៥	២៤.៩១៦	៣២.៦៥១
៣	អ្នកជំងឺចេញសរុប	២០.៧៨៨	១៨.៤៤៤	១៩.៥១៤	២៤.០៧៦	៣២.៣៦៦
៤	អត្រាប្រើប្រាស់គ្រែ	១២៤,៦៧	១០៧,៧១	១១៧,០៧	១០៦,៦៧	១២៧,៣៥
៥	រយៈពេលសម្រាកពេទ្យជាមធ្យម	៥,២៥	៥,១២	៥,១៥	៤,១៥	៣,៨៦
៦	សម្រាលកូន	៤.០៨០	៤.៥៦២	៤.៧៤១	៥.០៤៦	៥.៦៧៥
៧	វះកាត់សរុប	៣.៨០២	៣.៩៦៦	៤.១៨៨	៥.១៨៩	៩.០៤៦
៨	អត្រាស្លាប់	១,៤៥	១,៩០	១,៨២	១,១៥	០,៩៥

ប្រភព÷ មន្ទីរពេទ្យខេត្តកំពង់ចាម ស្តីពីសកម្មភាពពិនិត្យ ព្យាបាលជំងឺ សម្រាកពេទ្យតាមឆ្នាំ២០០៩-២០១៩

ក្រាហ្វិក ២.៣ ស្តីពីជំងឺពិគ្រោះសរុប ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩



តាមទិន្នន័យនៅតារាង ២.៣ និងក្រាហ្វិក ២.៣ ឃើញថា ជំងឺពិគ្រោះសរុបនៅឆ្នាំ ២០១៥ មានចំនួន ៤៧.៤៤៧ ករណី។ ចំនួននេះមានការថយចុះបន្តិចនៅឆ្នាំ២០១៦ ឆ្នាំ២០១៧ និងឆ្នាំ២០១៨។ ចំណែកឯនៅឆ្នាំ២០១៩ មានចំនួន ៤៣.៩៧១ករណី បើធៀប ទៅនឹងឆ្នាំ២០១៨ មានការកើនឡើងចំនួន ៤.៩៩៥ ករណី។ ការកើនឡើងនេះដោយសារ មន្ទីរពេទ្យមាន÷ ១)ការពិនិត្យនិងពិគ្រោះជំងឺទូទៅ និង ២)ការពិនិត្យនិងព្យាបាលភ្នែក ដែលមានគ្រូពេទ្យមកពីប្រទេសចិន[២៦]។

២.៤.២. ចំនួនអ្នកជំងឺសម្រាកពេទ្យ

ក្រាហ្វិក ២.៤ ស្តីពីជំងឺសម្រាកសរុបពីឆ្នាំ២០១៥-២០១៩ (គិតជានាក់)



[២៦] ការជួបសម្ភាសន៍ជាមួយវេជ្ជបណ្ឌិត ម៉ី មុនីបូរិន្ទ អនុប្រធានមន្ទីរពេទ្យកំពង់ចាម នៅថ្ងៃទី១៣/ ០៧/ ២០២០។

តាមទិន្នន័យនៅតារាង ២.៣ និងក្រាហ្វិក ២.៤ ឃើញថា ជំងឺសម្រាកសរុបនៅឆ្នាំ ២០១៥ មានចំនួន២១.០២៧នាក់។ ចំនួននេះមានការកើនឡើងនៅឆ្នាំ២០១៨ និងឆ្នាំ ២០១៩ ដែលឆ្នាំ២០១៨ មានចំនួន២៤.៩១៦នាក់ និងឆ្នាំ២០១៩ មានចំនួន៣២.៦៥១ នាក់។ ការកើនឡើងនេះដោយសារ÷ ១)អ្នកជំងឺមកព្យាបាលភ្នែក និង ២)មានការផ្ទុះឡើង នូវជំងឺគ្រុនឈាម[២៧]។

២.៤.៣. អត្រាប្រើប្រាស់គ្រែ

ក្រាហ្វិក ២.៥ ស្តីពីអត្រាប្រើប្រាស់គ្រែពីឆ្នាំ២០១៥-២០១៩ (គិតជា%)



នៅមុនឆ្នាំ២០២០ មន្ទីរពេទ្យខេត្តមានគ្រែសរុបចំនួន២៦០ លុះមកដល់ឆ្នាំ២០២០ នេះ មន្ទីរពេទ្យមានគ្រែសរុបចំនួន២៨០ គឺមានការកើនឡើងចំនួន២០គ្រែ។ ការកើនឡើង នេះដោយសារអត្រាប្រើប្រាស់គ្រែមានការកើនឡើង។ យោងតាមទិន្នន័យនៅតារាង ២.៣ និងក្រាហ្វិក ២.៥ បានបង្ហាញថា ការប្រើប្រាស់គ្រែក្នុងរយៈពេល៥ឆ្នាំ កន្លងមកនេះ មាន អត្រាលើសពី១០០ភាគរយ ជាពិសេសនៅឆ្នាំ២០១៩ ដែលអត្រាប្រើប្រាស់គ្រែបានកើន ដល់ ១២៧,៣៥ភាគរយ។ ការកើនឡើងនេះដោយសារចំនួនអ្នកសម្រាកពេទ្យបានកើន ឡើង។ នៅក្នុងការដោះស្រាយបញ្ហានេះ គណៈគ្រប់គ្រងមន្ទីរពេទ្យបានកែប្រែចំនួនគ្រែ នៅតាមផ្នែកមួយចំនួន ដូចជា នៅផ្នែករបេងមានការកាត់បន្ថយចំនួនគ្រែជាបន្តបន្ទាប់គឺ

[២៧] ការជួបសម្ភាសន៍ជាមួយវេជ្ជបណ្ឌិត ម៉ី មុនីបូរិន្ទ អនុប្រធានមន្ទីរពេទ្យកំពង់ចាម នៅថ្ងៃទី១៣/ ០៧/ ២០២០។

ពី៦០គ្រែ មក៣០គ្រែ បន្ទាប់មកទៀតពី៣០គ្រែ មកត្រឹម១២គ្រែ និងបន្តកាត់បន្ថយមកត្រឹម៨គ្រែ។ ចំណែកនៅផ្នែកសង្គ្រោះបន្ទាន់មានការបង្កើនពី១២គ្រែ ទៅ២០គ្រែ[២៨]។

២.៤.៤. រយៈពេលសម្រាកពេទ្យជាមធ្យម

ក្រាហ្វិក ២.៦ ស្តីពីរយៈពេលសម្រាកពេទ្យជាមធ្យមពីឆ្នាំ២០១៥-២០១៩ (គិតជាថ្ងៃ)



តាមទិន្នន័យនៅតារាង ២.៣ និងក្រាហ្វិក ២.៦ យើញថា រយៈពេលសម្រាកពេទ្យជាមធ្យមមានការថយចុះពីមួយឆ្នាំទៅមួយឆ្នាំ។ នៅឆ្នាំ២០១៥ ការសម្រាកពេទ្យជាមធ្យមមានចំនួន៥,២៥ ថ្ងៃឬអាចនិយាយបានថា មានចំនួន៥ថ្ងៃលើសបន្តិច។ ចំនួននេះមានការថយចុះជាបន្តនៅឆ្នាំបន្តបន្ទាប់រហូតដល់ឆ្នាំ២០១៩ មានចំនួន ៣,៨៦ថ្ងៃឬអាចនិយាយបានថា មានចំនួនជិត៤ថ្ងៃ។ ការថយចុះនេះដោយសារ÷ ១)ការខិតខំរបស់គណៈគ្រប់គ្រងមន្ទីរពេទ្យនិងបុគ្គលិកក្នុងការកែលម្អការផ្តល់សេវា ២)គណៈគ្រប់គ្រងមន្ទីរពេទ្យបានពិនិត្យឡើងវិញទៅលើដំណើរការនៃការចេញពីមន្ទីរពេទ្យរបស់អ្នកជំងឺ និង ៣)អ្នកជំងឺរបេងអ្នកជំងឺអេដស៍ មានចំនួនកាន់តែថយចុះ ដោយសារនៅតាមស្រុកមានមន្ទីរពេទ្យ និងមណ្ឌលសុខភាពដែលអាចថែទាំនិងព្យាបាលបាន[២៩]។

[២៨] ការជួបសម្ភាសន៍ជាមួយវេជ្ជបណ្ឌិត ម៉ី មុនីបូរិន្ទ អនុប្រធានមន្ទីរពេទ្យកំពង់ចាម នៅថ្ងៃទី១៣/ ០៧/ ២០២០។
[២៩] -ជ-

២.៤.៥. ចំនួនអ្នកសម្រាលកូន

ក្រាហ្វិក ២.៧ ស្តីពីចំនួនអ្នកសម្រាលកូនពីឆ្នាំ២០១៥-២០១៩ (គិតជានាក់)



តាមទិន្នន័យនៅតារាង ២.៣ និងក្រាហ្វិក ២.៧ ឃើញថា ចំនួនអ្នកសម្រាលកូនមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ នៅឆ្នាំ២០១៥ អ្នកសម្រាលកូនមានចំនួន៤.០៨០នាក់ នៅឆ្នាំ២០១៦ មានចំនួន៤.៥៦២នាក់ បន្ទាប់មកទៀតនៅឆ្នាំ២០១៩ មានការកើនឡើងរហូតដល់ចំនួន៥.៦៧៥នាក់។ ការកើនឡើងនេះដោយសារ÷ ១)មន្ទីរពេទ្យមានអគារថ្មី ឧបករណ៍ និងសម្ភារ ដែលជាជំនួយរបស់រដ្ឋាភិបាលជប៉ុន និង ២)មន្ទីរពេទ្យមានវេជ្ជបណ្ឌិតឯកទេស ដូចជា វះកាត់ រោគស្ត្រី និងកុមារ[៣០]។

២.៤.៦. ចំនួនវះកាត់សរុប

ក្រាហ្វិក ២.៨ ស្តីពីចំនួនវះកាត់សរុបពីឆ្នាំ២០១៥-២០១៩ (គិតជាករណី)



[៣០] ការជួបសម្ភាសន៍ជាមួយវេជ្ជបណ្ឌិត ម៉ី មុនីបូរិន្ទ អនុប្រធានមន្ទីរពេទ្យកំពង់ចាម នៅថ្ងៃទី១៣/ ០៧/ ២០២០។

តាមទិន្នន័យនៅតារាង ២.៣ និងក្រាហ្វិក ២.៨ ឃើញថា ចំនួនវះកាត់មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ នៅឆ្នាំ២០១៥ មានចំនួន៣.៨០២ករណី ហើយបន្តកើនឡើងនៅឆ្នាំបន្តបន្ទាប់ រហូតដល់ឆ្នាំ២០១៨ បានកើនឡើងដល់ចំនួន៥.១៨៩ករណី។ បន្ទាប់មកទៀត ចំនួននេះបានកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ២០១៩ គឺមានចំនួន៩.០៤៦ករណី បើធៀបទៅនឹងឆ្នាំ២០១៨ មានការកើនឡើងទ្វេដង។ ការកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំជាប់គ្នាដោយសារមន្ទីរពេទ្យមាន÷ ១)ធនធានមនុស្សគ្រប់គ្រាន់ (ជំនាញច្បាស់លាស់ និងក្រមសីលធម៌ល្អ) ២)សេវាវះកាត់ស្ទើរតែគ្រប់ជំនាញ ប្រហាក់ប្រហែលមន្ទីរពេទ្យថ្នាក់ជាតិមួយចំនួន ៣)សេវាល្អ (ជាឧទាហរណ៍វះកាត់ទាន់ពេលវេលា) និងតម្លៃសមរម្យ ៤)កន្លែងវះកាត់ និងក្រោយវះកាត់មានអនាម័យ ៥)កម្រិតជំនាញខ្ពស់ជាងមន្ទីរពេទ្យនៅជុំវិញ និង ៦)ទីធ្លាធំទូលាយ បរិស្ថានល្អ អនាម័យស្អាត។ បន្ថែមលើនេះ នៅឆ្នាំ២០១៩ ចំនួនវះកាត់មានការកើនឡើងយ៉ាងខ្លាំងដោយសារ÷ ១)មន្ទីរពេទ្យមានទស្សនវិស័យច្បាស់លាស់ ២)មន្ត្រីរាជការមានជំនឿទុកចិត្តលើការដឹកនាំរបស់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ៣)មន្ទីរពេទ្យមានការអភិវឌ្ឍបន្ថែមទៀត ទាំងបច្ចេកទេស ទាំងហេដ្ឋារចនាសម្ព័ន្ធ ទាំងបរិស្ថាននិងអនាម័យ ៤)ការផ្លាស់ប្តូរឥរិយាបថរបស់មន្ត្រីរាជការ ៥)ការជឿទុកចិត្តពីអតិថិជនកាន់តែកើនឡើងជាលំដាប់ និង ៦)ក្រោយពីដាក់ឱ្យមានការប្រឡងប្រណាំងអង្គភាពផ្តល់សេវាសាធារណៈគំរូនាឆ្នាំ២០១៨-១៩ មន្ទីរពេទ្យមានការកែលម្អចំណុចខ្វះខាតរបស់ខ្លួន ពិសេសក្រោយពីទទួលបានជ័យលាភីចំណាត់ថ្នាក់លេខ១ទូទាំងប្រទេស[៣១]។

[៣១] ទិន្នន័យទទួលបានពីសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្ត នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០។

២.៤.៧. អត្រាស្លាប់

ក្រាហ្វិក ២.៩ ស្តីពីអត្រាស្លាប់ពីឆ្នាំ២០១៥-២០១៩ (គិតជា%)



តាមទិន្នន័យនៅតារាង ២.៣ និងក្រាហ្វិក ២.៩ ឃើញថា អត្រាស្លាប់នៅឆ្នាំ២០១៥ មានចំនួន១,៤៥ភាគរយ។ ចំនួននេះបានកើនទៅដល់១,៩ភាគរយ នៅឆ្នាំ២០១៦ ប៉ុន្តែមានការថយចុះបន្តិចវិញនៅឆ្នាំ២០១៧ គឺមានចំនួន១,៨២ភាគរយ។ បន្ទាប់មកទៀត អត្រាស្លាប់បានបន្តថយចុះមកត្រឹម១,១៥ភាគរយនៅឆ្នាំ២០១៨ និងបន្តថយមកត្រឹម០,៩ ភាគរយនៅឆ្នាំ២០១៩។ ការថយចុះនៃអត្រាស្លាប់នេះដោយសារមានការ ១)បង្កើនបច្ចេក-ទេស ២)បង្កើនសវនកម្មករណីស្លាប់ និង ៣)បញ្ជូនទាន់ពេលទៅសេវាដែលមានកម្រិតខ្ពស់ជាង[៣២]។

[៣២] ការជួបសម្ភាសន៍ជាមួយវេជ្ជបណ្ឌិត ម៉ី មុនីហ្វរិន្ទ អនុប្រធានមន្ទីរពេទ្យកំពង់ចាម នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០។

ជំពូកទី៣. បទពិសោធន៍ជោគជ័យរបស់មន្ទីរពេទ្យខេត្តកំពង់ចាម

នៅជំពូកនេះ មានការលើកឡើងអំពីបទពិសោធន៍ជោគជ័យរបស់មន្ទីរពេទ្យខេត្តកំពង់ចាម ក្នុងការអនុវត្តតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាគុំរូក្នុងចំណោមមន្ទីរពេទ្យបង្អែករាជធានីខេត្តដែលអនុវត្តសំណុំសកម្មភាពបង្ក្រប់កម្រិត៣ (CPA3)។ ការសិក្សានេះបានផ្តោតទៅលើសូចនាករគោលចំនួន៨ រួមមាន÷ ១) ស្តង់ដាសេវាសាធារណៈ ២) និយាមនៃការផ្តល់សេវាសាធារណៈរបស់អង្គភាព ៣) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព ៤) ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព ៥) ការរៀបចំនិងកែលម្អបរិស្ថានអង្គភាព ៦) ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ ៧) ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋនិងសហគមន៍ និង ៨) ការផ្តួចផ្តើមគំនិតថ្មីៗនិងនវានុវត្តន៍ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ។

៣.១. ស្តង់ដាសេវាសាធារណៈ

នៅចំណុចនេះមានការលើកឡើងអំពី÷ ១) គុណភាពព័ត៌មាន ២) ភាពងាយស្រួលក្នុងការទទួលយកសេវា ៣) ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា ៤) ការផ្តល់សេវាតាមគោលការណ៍កំណត់និងអភិបាលកិច្ចល្អ និង ៥) យន្តការព័ត៌មានត្រឡប់និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា។

៣.១.១. គុណភាពព័ត៌មាន

គុណភាពព័ត៌មាន សំដៅដល់ព័ត៌មានដែលបានផ្តល់ជូនអ្នកប្រើប្រាស់សេវាត្រូវមានលក្ខណៈងាយយល់ ច្បាស់លាស់ ត្រឹមត្រូវ មានបច្ចុប្បន្នភាព និងងាយទទួលយក។ សូចនាករគោលនេះមានលក្ខណៈវិនិច្ឆ័យដូចជា÷ ១) បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេវា ២) ព័ត៌មានដែលត្រូវផ្សព្វផ្សាយ និង ៣) មធ្យោបាយផ្សព្វផ្សាយ។

៣.១.១.១. បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេវា

ដើម្បីបង្កនូវភាពងាយស្រួលនិងរបៀបរៀបរយក្នុងការបំពេញការងារក្នុងអង្គភាព និងបង្កើនទំនុកចិត្តរបស់អ្នកជំងឺ គ្រួសារអ្នកជំងឺ ក៏ដូចជាប្រជាពលរដ្ឋទូទៅ មន្ទីរពេទ្យខេត្តកំពង់ចាមបានរក្សាទុកនូវបទដ្ឋានគតិយុត្តទាំងអស់ពាក់ព័ន្ធនឹងដំណើរការនៃការផ្តល់សេវារបស់អង្គភាពនៅក្នុងក្រុងទៅតាមប្រភេទឯកសារ ឆ្នាំ ដែលមានភាពងាយស្រួលក្នុងការប្រើប្រាស់។ ឯកសារទាំងនោះមានតម្កល់ទុកនៅផ្នែកជួរមុខ និងនៅផ្នែករដ្ឋបាល។

នៅក្នុងការពង្រឹងវិន័យ សណ្តាប់ធ្នាប់ និងអនាម័យក្នុងអង្គភាព មន្ទីរពេទ្យបានបង្កើតនូវបទបញ្ជាផ្ទៃក្នុងសម្រាប់អ្នកជំងឺ និងគ្រួសារអ្នកជំងឺដែលមានជាទម្រង់ផ្ទាំងទំហំប្រមាណ ៥០សង់ទីម៉ែត្រគុណនឹង៧០សង់ទីម៉ែត្រ (50cmX70cm) ហើយបានបិទផ្សាយនៅផ្នែកជួរមុខ (កន្លែងចុះឈ្មោះអ្នកជំងឺ) និងនៅតាមបណ្តាផ្នែករបស់មន្ទីរពេទ្យ។ ជាមួយគ្នាដែរមន្ទីរពេទ្យក៏បានបង្កើតនូវបទបញ្ជាផ្ទៃក្នុងសម្រាប់បុគ្គលិកផងដែរ។

៣.១.១.២. ពំតិមានដែលផ្សព្វផ្សាយ

ការផ្សព្វផ្សាយគឺជាកត្តាមួយក្នុងចំណោមកត្តាផ្សេងៗដែលធ្វើឱ្យអ្នកប្រើប្រាស់សេវាឬក្រុមគោលដៅឬភាគីពាក់ព័ន្ធទទួលបានព័តិមាននិងងាយស្រួលក្នុងការអនុវត្តតាម។ ពាក់ព័ន្ធនឹងការផ្សព្វផ្សាយនេះ មន្ទីរពេទ្យបានធ្វើការផ្សព្វផ្សាយនូវ ប្រភេទនិងតម្លៃសេវា ឯកសារតម្រូវ និងលក្ខខណ្ឌក្នុងការទទួលបានសេវាសាធារណៈ ម៉ោងពេលបំពេញការងារ មធ្យោបាយទំនាក់ទំនងជាមួយមន្ទីរពេទ្យ នីតិវិធីនៃការផ្តល់សេវា និងរយៈពេលនៃការចុះឈ្មោះអ្នកជំងឺ។

នៅក្នុងការផ្សព្វផ្សាយនូវប្រភេទនិងតម្លៃសេវា មន្ទីរពេទ្យបានរៀបចំឱ្យមានតារាងប្រភេទសេវានិងតម្លៃសេវាជាទម្រង់ផ្ទាំងធំដែលបានបិទផ្សាយនៅផ្នែកជួរមុខ (កន្លែងចុះឈ្មោះអ្នកជំងឺ) និងមានជាទម្រង់ផ្ទាំងតូចៗ(A3) ផ្សេងទៀតដែលបានបិទផ្សាយនៅតាមបណ្តាផ្នែក។ បន្ថែមលើនេះ មន្ទីរពេទ្យក៏បានបិទផ្សាយនូវប្រភេទសេវានៅក្បែរច្រកទ្វារធំចេញចូលមន្ទីរពេទ្យដែលមានទម្រង់ជាផ្ទាំងធំមួយមានទំហំប្រមាណ២ ម៉ែត្រគុណនឹង៣

ម៉ែត្រ (2mX3m)។ ពាក់ព័ន្ធទៅនឹងប្រភេទសេវានេះ មន្ទីរពេទ្យមានសេវាជាច្រើនដែល ក្នុងនោះមានសេវាឯកទេសមួយចំនួនដូចជា÷ ១)ឯកទេសចក្ខុរោគ ២)ឯកទេសច្រមុះ និងបំពង់ក ៣)ផ្នែកថែទាំទារក ៤)ឯកទេសមាត់ធ្មេញ ៥)សុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀន ៦)វះកាត់ឆ្អឹងបាក់ ៧)វះកាត់គ្រោះក្នុងផ្លូវនោមដោយឧបករណ៍ទំនើប និង ៨)វះកាត់ប្រព័ន្ធប្រសាទ[៣៣]។

ពាក់ព័ន្ធនឹងការផ្សព្វផ្សាយនេះដែរ មន្ទីរពេទ្យក៏បានផ្សព្វផ្សាយនូវឯកសារតម្រូវក្នុងការទទួលបានសេវា ជូនដល់អ្នកប្រើប្រាស់សេវា តាមរយៈការរៀបចំឱ្យមានជាទម្រង់ផ្ទាំងក្រដាសទំហំ A3 អក្សរដែលសរសេរនៅក្នុងផ្ទាំងមានភាពងាយស្រួលអាន និងបានបិទផ្សាយនៅផ្នែកជួរមុខ (កន្លែងចុះឈ្មោះអ្នកជំងឺ)និងនៅតាមអគាររបស់មន្ទីរពេទ្យ។

ជាមួយគ្នាដែរ មន្ទីរពេទ្យក៏បានធ្វើការផ្សព្វផ្សាយផងដែរនូវម៉ោងពេលបំពេញការងារ ដែលមានជាទម្រង់ផ្ទាំងទំហំប្រមាណ៥០សង់ទីម៉ែត្រ គុណនឹង៧០សង់ទីម៉ែត្រ (50cmX70cm) ដោយបានបិទផ្សាយនៅផ្នែកជួរមុខ នៅតាមបណ្តាផ្នែក និងនៅខាងមុខក្បែរច្រកទ្វារធំចេញចូលមន្ទីរពេទ្យ។ នៅក្នុងផ្ទាំងនោះមានការកំណត់ច្បាស់អំពី÷ ១)ម៉ោងបម្រើសេវាគឺ២៤ម៉ោងលើ២៤ម៉ោង ២)ម៉ោងការងាររដ្ឋបាល ៣)ថ្ងៃឈប់សម្រាក និង ៤)ពេលម៉ោងយាមប្រចាំការ។

ដោយមានបំណងបង្កភាពងាយស្រួលដល់អ្នកជំងឺ ឬគ្រួសារអ្នកជំងឺឬសាធារណជន ក្នុងការធ្វើទំនាក់ទំនងជាមួយមន្ទីរពេទ្យ ក៏ដូចជាក្នុងការទទួលព័តិមានត្រឡប់ពីអ្នកជំងឺឬគ្រួសារអ្នកជំងឺឬសាធារណជន ពាក់ព័ន្ធទៅនឹងដំណើរការនៃការផ្តល់សេវារបស់ខ្លួន មន្ទីរពេទ្យបានធ្វើការផ្សព្វផ្សាយនូវមធ្យោបាយសម្រាប់ទំនាក់ទំនងជាមួយមន្ទីរពេទ្យ រួមមាន÷ ១)បណ្តាញសង្គម (មានឈ្មោះថា មន្ទីរពេទ្យខេត្តកំពង់ចាម) ២)Messenger (មានឈ្មោះថា មន្ទីរពេទ្យខេត្តកំពង់ចាម) ៣)WhatsApp (មានឈ្មោះថា Kg Cham Provincial Hospital) 4) ប្រព័ន្ធ Telegram (មានឈ្មោះថា ក្រុមប្រឆាំងភាពសាំនឹងមេរោគ) និងលេខ

[៣៣] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី០១/ ០៧/ ២០២០

ទូរស័ព្ទនៅតាមបណ្តាផ្នែកមានចំនួន៨ខ្សែ ព្រមទាំងលេខទូរស័ព្ទឡានសង្គ្រោះបន្ទាន់មានចំនួន២ខ្សែ។ ការផ្សព្វផ្សាយបានធ្វើឡើងតាមរយៈការរៀបចំឱ្យមានជាទម្រង់ផ្ទាំងក្រដាសទំហំ A3 អក្សរដែលសរសេរនៅក្នុងផ្ទាំងមានភាពងាយស្រួលអាន និងបានបិទផ្សាយនៅផ្នែកជួរមុខ (កន្លែងចុះឈ្មោះអ្នកជំងឺ) និងនៅតាមអគាររបស់មន្ទីរពេទ្យ។

ក្នុងការជួយសម្រួលដល់ដំណើរការនៃការផ្តល់សេវារបស់អង្គភាពនិងការទទួលយកសេវារបស់អ្នកប្រើប្រាស់សេវា មន្ទីរពេទ្យបានរៀបចំឱ្យមានគំនូសបង្ហាញអំពីចរន្ត ឬរំហូរនៃការផ្តល់សេវាជាទម្រង់ផ្ទាំងមានទំហំប្រមាណ១០០សង់ទីម៉ែត្រ គុណនឹង១៥០សង់ទី-ម៉ែត្រ (100cm X 150cm) និងបានបិទផ្សាយនៅក្បែរច្រកទ្វារធំចេញចូលផ្នែកខាងក្នុង និងមានទំហំប្រមាណ៥០សង់ទីម៉ែត្រ គុណនឹង៧០សង់ទីម៉ែត្រ (50cm X 70cm) បានបិទផ្សាយនៅផ្នែកជួរមុខ (កន្លែងចុះឈ្មោះអ្នកជំងឺ) ទាំង២កន្លែងរបស់មន្ទីរពេទ្យ។

ទន្ទឹមនឹងការផ្សព្វផ្សាយនូវបណ្តាព័ត៌មានខាងលើ មន្ទីរពេទ្យក៏បានផ្សព្វផ្សាយផងដែរនូវរយៈពេលនៃការចុះឈ្មោះអ្នកជំងឺ តាមរយៈការកំណត់រយៈពេលនៃការចុះឈ្មោះអ្នកជំងឺប្រមាណពី៥ទៅ១០នាទី។ ការផ្សព្វផ្សាយនេះ បានធ្វើឡើងតាមរយៈការរៀបចំឱ្យមានជាទម្រង់ផ្ទាំងក្តារមានទំហំប្រមាណ ១៥សង់ទីម៉ែត្រគុណនឹង ៣០សង់ទីម៉ែត្រ (15cm X 30cm) ហើយបានបិទផ្សាយនៅផ្នែកជួរមុខ (កន្លែងចុះឈ្មោះអ្នកជំងឺ) ទាំង២កន្លែងរបស់មន្ទីរពេទ្យ។

៣.១.១.៣. មធ្យោបាយផ្សព្វផ្សាយ

ក្នុងការផ្សព្វផ្សាយព័ត៌មាននានាដែលពាក់ព័ន្ធនឹងការផ្តល់សេវា និងសកម្មភាពផ្សេងៗរបស់មន្ទីរពេទ្យជូនអ្នកជំងឺឬសាធារណជន មន្ទីរពេទ្យបានប្រើប្រាស់មធ្យោបាយផ្សព្វផ្សាយតាមរយៈ បណ្តាញប្រកាស រដ្ឋបាលមូលដ្ឋាន សហគមន៍ និងការផ្សាយនៅនឹងកន្លែង (ការប្រជុំណែនាំ និងការចាក់ផ្សាយតាមទូរទស្សន៍ LED)។ ផ្សេងពីនោះមន្ទីរពេទ្យក៏បានប្រើប្រាស់មធ្យោបាយផ្សព្វផ្សាយផ្សេងទៀតតាមរយៈ ទូរទស្សន៍ វិទ្យុ ជាពិសេសបណ្តាញសង្គមរបស់មន្ទីរពេទ្យ។ ព័ត៌មានដែលបានផ្សព្វផ្សាយទាំងនោះមានលក្ខណៈប្រកបដោយបច្ចុប្បន្នភាព។

៣.១.២. តារាងបាយស្រួលក្នុងការទទួលយកសេវា

ភាពងាយស្រួលក្នុងការទទួលយកសេវា សំដៅដល់អ្នកផ្តល់សេវាសាធារណៈសម្រួលដល់អ្នកប្រើប្រាស់សេវាសាធារណៈលើនីតិវិធី ទំនាក់ទំនង ការបំពេញបែបបទ និងការទទួលយកសេវាទៅប្រើប្រាស់។ សូចនាករគោលនេះមានលក្ខណៈវិនិច្ឆ័យដូចជា ១)ទីតាំង និងហេដ្ឋារចនាសម្ព័ន្ធ និង ២)នីតិវិធីនិងលក្ខខណ្ឌនៃការផ្តល់និងទទួលយកសេវា។

៣.១.២.១. ទីតាំង និងហេដ្ឋារចនាសម្ព័ន្ធមន្ទីរពេទ្យ

មន្ទីរពេទ្យខេត្តកំពង់ចាមមានទីតាំងនៅកណ្តាលក្រុងកំពង់ចាម នៅក្បែរសាលាខេត្តកំពង់ចាម នៅទល់មុខនឹងសាលាក្រុងកំពង់ចាម ដែលព័ទ្ធជុំវិញទៅដោយ អគាររដ្ឋបាលគ្រឹះស្ថានបណ្តុះបណ្តាលមណ្ឌលពាណិជ្ជកម្ម សណ្ឋាគារ ផ្ទះសំណាក់ និងផ្លូវខ្វែងខ្វាត់។ មន្ទីរពេទ្យមានរបងពណិពងមាន់ព័ទ្ធជុំវិញ មានច្រកទ្វារចេញចូលចំនួន៣ ក្នុងនោះមានច្រកទ្វារចំនួន១ដែលមានខ្លោងទ្វារស្រស់ស្អាតនិងមានចម្លាក់ជាអក្សរថា «មន្ទីរពេទ្យខេត្តកំពង់ចាម» និងច្រកទ្វារចំនួន២ទៀតមានផ្ទាំងស្លាកឈ្មោះមន្ទីរពេទ្យខេត្តកំពង់ចាមដែលបានឆ្លាក់លើថ្មម៉ាបជាប់នៅនឹងរបងក្បែរច្រកទ្វារចេញចូល។ នៅតាមផ្លូវនៃច្រកទ្វារចេញចូលនីមួយៗ និងផ្លូវតភ្ជាប់ពីអគារមួយទៅអគារមួយ ត្រូវបានក្រាលដោយបេតុងនិងអមដោយសួនច្បារស្រស់ស្អាត។

មន្ទីរពេទ្យមានអគារចំនួន១៩ ក្នុងនោះមានអគារពិនិត្យ ពិគ្រោះ និងបែងចែកជំងឺ អគាររដ្ឋបាល អគារផ្តល់ឈាម អគារជំងឺមាត់ធ្មេញ អគារសម្ភព អគារវះកាត់ អគារជំងឺឆ្លង អគារមន្ទីរពិសោធន៍ អគារបណ្តុះបណ្តាល អគារជំងឺកុមារ អគារសម្រាប់ប្រជុំធំចំនួន១ ។ល។ នៅក្នុងកិច្ចដំណើរការនៃការផ្តល់សេវា ចំនួនអគារដែលមន្ទីរពេទ្យមានគឺហាក់ដូចជាមិនទាន់បានឆ្លើយតបទៅនឹងចំនួនអ្នកជំងឺ ព្រោះមានអ្នកជំងឺមួយចំនួនស្នាក់នៅក្រៅបន្ទប់ (ផ្នែកសម្ភព)។ ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធពិសេសអគាររបស់មន្ទីរពេទ្យ លោកប្រធានមន្ទីរពេទ្យបានលើកឡើងថា «ក្នុងអំឡុងពេល៥ឆ្នាំមុនចំនួនអគារបានឆ្លើយតបទៅនឹងចំនួនអ្នកជំងឺ ប៉ុន្តែក្នុងអំឡុងពេល៥ឆ្នាំក្រោយនេះចំនួនអគារមិនបានឆ្លើយតបទៅនឹងចំនួនអ្នក

ជំងឺទេ ព្រោះកំណើនអ្នកជំងឺកើនឡើងខ្លាំងជាងកំណើនអគារ»[៣៤]។

ទោះបីមានការខ្វះខាតអគារមួយចំនួនក៏ដោយ ក៏គណៈគ្រប់គ្រងមន្ទីរពេទ្យបានសហការជាមួយនឹងមន្ទីរសុខាភិបាលនិងភាគីពាក់ព័ន្ធដទៃទៀតក្នុងការរិះរកមធ្យោបាយដើម្បីដោះស្រាយបញ្ហា និងធ្វើឱ្យបរិយាកាសរបស់មន្ទីរពេទ្យមានលក្ខណៈប្រកបដោយជាសុកភាព។ មន្ទីរពេទ្យមានអគារដែលមានពន្លឺនិងខ្យល់អាកាសចេញចូលបានល្អ មានផ្លូវបេតុងតភ្ជាប់ពីអគារមួយទៅអគារមួយ មានអនាម័យ មិនមានក្លិនស្អុយ មានកន្លែងសមរម្យសម្រាប់អង្គុយរង់ចាំដើម្បីទទួលបានការចុះឈ្មោះ ការពិនិត្យ និងការព្យាបាលជំងឺ ព្រមទាំងមានកន្លែងអង្គុយលំហែកាយដែលអមទៅដោយដើមឈើនិងស្មនច្បារ។

ផ្សេងពីការធ្វើឱ្យបរិស្ថានរបស់មន្ទីរពេទ្យមានលក្ខណៈប្រសើរ គណៈគ្រប់គ្រងមន្ទីរពេទ្យក៏បានជួយសម្រួលដល់អ្នកជំងឺ ឬសាធារណជន ក្នុងការស្វែងរកអគារ ឬផ្នែកផ្តល់សេវានីមួយៗ តាមរយៈការបិទបង្ហាញប្លង់និងទីតាំងរបស់មន្ទីរពេទ្យនៅក្បែរនឹងច្រកទ្វារចេញចូលនីមួយៗ ដែលមានទម្រង់ជាផ្ទាំង ប៉ាណូទំហំប្រមាណ២ម៉ែត្រ គុណនឹង៣ម៉ែត្រ (2mX3m)។ នៅក្នុងការជួយសម្រួលនេះដែរ គណៈគ្រប់គ្រងមន្ទីរពេទ្យក៏បានបិទសញ្ញាចង្អុលបង្ហាញទៅតាមផ្នែក ឬកន្លែងនីមួយៗនៅតាមទីកន្លែងជាយុទ្ធសាស្ត្រក្នុងបរិវេណមន្ទីរពេទ្យ និងបានបិទស្លាកឈ្មោះនៅគ្រប់ផ្នែកឬបន្ទប់ផ្តល់សេវាទាំងអស់។

ដើម្បីជួយសម្រួលដល់ការចុះឈ្មោះ និងការផ្តល់ព័ត៌មានផ្សេងៗជូនដល់អ្នកជំងឺ និងសាធារណជន គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំឱ្យមានកន្លែងចុះឈ្មោះចំនួន២ កន្លែង គឺកន្លែងចុះឈ្មោះអ្នកជំងឺទូទៅ និងកន្លែងចុះឈ្មោះអ្នកជំងឺទឹកនោមផ្អែម។ នៅកន្លែងចុះឈ្មោះអ្នកជំងឺទូទៅមាន÷ ១)មន្ត្រីផ្តល់ព័ត៌មាននិងជួយបំពេញបែបបទចំនួន៥នាក់ ២)មន្ត្រីចុះឈ្មោះចំនួន១០នាក់ ក្នុងនោះមាន៥នាក់បម្រើការក្នុងពេលម៉ោងធ្វើការ និង៥នាក់ទៀតយាមតាមវេន និង ៣)មន្ត្រីទទួលប្រាក់ចំនួន៧នាក់ ក្នុងនោះមាន៣នាក់បម្រើការក្នុងពេលម៉ោងធ្វើការ និង៤នាក់ទៀតយាមតាមវេន។ នៅកន្លែងចុះឈ្មោះអ្នកជំងឺ

[៣៤] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី០១/ ០៧/ ២០២០។

ទឹកនោមផ្ទែមមាន÷ ១)មន្ត្រីផ្តល់ព័ត៌មាននិងជួយបំពេញបែបបទចំនួន៣នាក់ ២)មន្ត្រីចុះឈ្មោះចំនួន១នាក់ និង ៣)មន្ត្រីទទួលប្រាក់ចំនួន១នាក់[៣៥]។

៣.១.២.២. នីតិវិធីនិងលក្ខខណ្ឌ

ផ្សេងពីការបង្កនូវភាពងាយស្រួលមួយចំនួនដូចបានរៀបរាប់នៅចំណុចខាងលើ មន្ទីរពេទ្យក៏បានបង្កនូវភាពងាយស្រួលមួយចំនួនទៀតដូចជា ការកែលម្អនីតិវិធីនិងលក្ខខណ្ឌនៃការទទួលយកសេវារបស់អ្នកប្រើប្រាស់សេវា ការទប់ស្កាត់មិនឱ្យមានអន្តរការីនៅក្នុងដំណើរការផ្តល់និងទទួលយកសេវា និងការកាត់បន្ថយរយៈពេលរង់ចាំចុះឈ្មោះរបស់អ្នកជំងឺ។

នៅក្នុងការកែលម្អនីតិវិធីនិងលក្ខខណ្ឌនៃការទទួលយកសេវារបស់អ្នកប្រើប្រាស់សេវា មន្ទីរពេទ្យបានធ្វើឱ្យទម្រង់ពាក្យស្នើសុំមានលក្ខណៈងាយបំពេញ ឯកសារតម្រូវឬឯកសារភ្ជាប់មានចំនួនតិច និងនីតិវិធីមិនស្មុគស្មាញ។ ជាក់ស្តែង ករណីចូលសម្រាកពេទ្យ អ្នកជំងឺគ្រាន់តែបំពេញព័ត៌មានលើលិខិតអនុញ្ញាតចូលសម្រាកពេទ្យ ដែលព័ត៌មានទាំងនោះមានដូចជា ឈ្មោះ ភេទ អាយុ អាសយដ្ឋាន ទូរស័ព្ទទំនាក់ទំនង និងមុខរបរ ហើយចុងបញ្ចប់មានការចុះហត្ថលេខាពីគ្រូពេទ្យ និងប្រធានមន្ទីរពេទ្យ។

នៅក្នុងការរក្សាសណ្តាប់ធ្នាប់ និងការទប់ស្កាត់អំពើអសកម្មផ្សេងៗ គណៈគ្រប់គ្រងមន្ទីរពេទ្យបានធ្វើការទប់ស្កាត់មិនឱ្យមានអន្តរការីនៅក្នុងដំណើរការផ្តល់និងទទួលយកសេវា។ ការទប់ស្កាត់ធ្វើឡើងតាមរយៈ÷ ១)ការបិទផ្សាយនូវតម្លៃសេវា ២)ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយនៅនឹងកន្លែង(តាមទូរទស្សន៍LED) ៣)ការជួបដោយផ្ទាល់ជាមួយអ្នកជំងឺនិងអ្នកកំដរអ្នកជំងឺ២ដងក្នុង១សប្តាហ៍ ៤)អប់រំដល់បុគ្គលិក និង ៥)ការជ្រើសរើសភ្នាក់ងារសន្តិសុខ ដើម្បីរក្សាសណ្តាប់ធ្នាប់និងសុវត្ថិភាពក្នុងមន្ទីរពេទ្យ[៣៦]។ ជាលទ្ធផលមន្ទីរពេទ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយ មិនមានម៉ូតូឌុបឬរឺម៉កកង់បីអូសទាញអ្នកជំងឺ

[៣៥] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្ត នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០។

[៣៦] -ដ- នៅថ្ងៃទី០១/០៧/២០២០

ទៅព្យាបាលនៅគ្លីនិកឯកជនឡើយ គឺមានតែម៉ូតូឌុបឬរ៉ឺម៉កកង់បីចំនួនតិចតួចដែលចត នៅម្ខាងនៃផ្លូវថ្នល់ ដើម្បីរង់ចាំដឹកភ្ញៀវចេញពីមន្ទីរពេទ្យ។

ក្នុងគោលបំណងជួយសម្រួលដល់អ្នកជំងឺមិនឱ្យចំណាយពេលយូរក្នុងការរង់ចាំដើម្បីទទួលបានការចុះឈ្មោះ គណៈគ្រប់គ្រងមន្ទីរពេទ្យបាន÷ ១)កំណត់រយៈពេលចុះឈ្មោះពី៥ទៅ១០នាទី ២)បង្កើនកន្លែងចុះឈ្មោះពី១កន្លែងទៅ២កន្លែង ៣)ប្រើប្រាស់ប្រព័ន្ធចុះឈ្មោះនិងគ្រប់គ្រងអ្នកជំងឺ (Patient Management Registration System: PMRS) នៅក្នុងការចុះឈ្មោះអ្នកជំងឺ ដែលចាប់ផ្តើមអនុវត្តនៅឆ្នាំ២០១៦ ៤)កៀរគរធនធានមនុស្សពីផ្នែកដទៃមកជួយផ្នែកដែលមានអ្នកជំងឺច្រើន ៥)បង្កើនទ្វារចំនួនឧបករណ៍សម្រាប់បំពេញការងារ ដូចជាកុំព្យូទ័រជាដើម[៣៧]។ ជាលទ្ធផល ការចុះឈ្មោះអ្នកជំងឺមានរយៈពេលដូចការកំណត់ដែលបានផ្សព្វផ្សាយ ចំណែកឯការរង់ចាំដើម្បីទទួលបានការចុះឈ្មោះរបស់អ្នកជំងឺគឺមានរយៈពេលឆាប់រហ័ស (ចន្លោះពី១០ទៅ២០នាទី) នៅផ្នែកចុះឈ្មោះអ្នកជំងឺទូទៅ និងមាន រយៈពេលយូរជាងបន្តិចនៅផ្នែកចុះឈ្មោះអ្នកជំងឺទឹកនោមផ្អែម ដោយសារមន្ត្រីចុះឈ្មោះមានចំនួនតិច ផ្ទុយទៅវិញអ្នកជំងឺមានចំនួនច្រើននិងមកទទួលយកសេវានៅមន្ទីរពេទ្យក្នុងពេលព្រឹកតែមួយ។

៣.១.៣. ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា

ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវាសំដៅសមត្ថភាពរបស់ក្រសួងស្ថាប័ន និងអ្នកផ្តល់សេវាសាធារណៈ ក្នុងការប្រើប្រាស់មធ្យោបាយ និងនីតិវិធីការងារដើម្បីដោះស្រាយឬឆ្លើយតបទៅនឹងសំណូមពររបស់អ្នកប្រើប្រាស់សេវា។ សូចនាករគោលនេះមានលក្ខណៈវិនិច្ឆ័យដូចជា ១)ការទទួលអ្នកប្រើប្រាស់សេវា ២)យន្តការសម្របសម្រួល និង ៣)វិធានការកែលម្អ។

៣.១.៣.១. ការទទួលអ្នកប្រើប្រាស់សេវា

នៅក្នុងការទទួលឬការធ្វើបដិសណ្ឋារកិច្ចចំពោះអ្នកជំងឺឬសាធារណជន គណៈគ្រប់-

[៣៧] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី០១/ ០៧/ ២០២០។

គ្រងមន្ទីរពេទ្យបានខិតខំអប់រំដល់គ្រូពេទ្យនិងបុគ្គលិកអនាម័យទាំងអស់ ឱ្យមានភាពរួសរាយរាក់ទាក់និងមានសិរិយាបថល្អ។ តាមរយៈទិន្នន័យដែលទទួលបាន[៣៨] បានបង្ហាញឱ្យឃើញថា គ្រូពេទ្យ មន្ត្រីរដ្ឋបាល បុគ្គលិកអនាម័យ និងមន្ត្រីសន្តិសុខ ចំនួនភាគច្រើន (ជាង៨០ ភាគរយ) មានភាពរួសរាយរាក់ទាក់ និងមានសិរិយាបថល្អចំពោះសាធារណជនដែលបានមកទទួលសេវាពីមន្ទីរពេទ្យ។

នៅក្នុងការទទួលឬការធ្វើបដិសណ្ឋារកិច្ចចំពោះអ្នកជំងឺឬសាធារណជននេះដែរ គណៈគ្រប់គ្រងមន្ទីរពេទ្យក៏បានរៀបចំឱ្យមានកន្លែងសម្រាប់ជួយបំពេញបែបបទ និងផ្តល់ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសេវាសាធារណៈរបស់អង្គភាព ដែលមានមន្ត្រីប្រចាំការសរុបចំនួន៨នាក់ ក្នុងនោះមន្ត្រីចំនួន៥នាក់ប្រចាំការនៅកន្លែងចុះឈ្មោះទី១ (កន្លែងចុះឈ្មោះអ្នកជំងឺទូទៅ) និងមន្ត្រីចំនួន៣នាក់ប្រចាំការនៅកន្លែងចុះឈ្មោះទី២ (កន្លែងចុះឈ្មោះអ្នកជំងឺទឹកនោមផ្អែម)។

ដើម្បីរក្សាអនាម័យ ទប់ស្កាត់អំពើអសកម្ម និងបង្កភាពងាយស្រួលជូនអ្នកជំងឺ ឬសាធារណជនក្នុងការកំណត់អត្តសញ្ញាណគ្រូពេទ្យនិងមន្ត្រីដទៃទៀត គណៈគ្រប់គ្រងមន្ទីរពេទ្យបានតម្រូវឱ្យគ្រូពេទ្យ មន្ត្រីរដ្ឋបាល បុគ្គលិកអនាម័យ អ្នកបើកបររថយន្តសង្គ្រោះ និងភ្នាក់ងារសន្តិសុខទាំងអស់ពាក់ឯក សណ្ឋាននិងស្លាកឈ្មោះសម្គាល់ខ្លួនជាប្រចាំ ដោយក្នុង១ឆ្នាំៗមន្ទីរពេទ្យបានផ្តល់នូវឯកសណ្ឋានចំនួន២កំផ្លេ ដល់គ្រូពេទ្យនិងមន្ត្រីទាំងអស់។ នៅក្នុងការអនុវត្ត គ្រូពេទ្យ មន្ត្រីរដ្ឋបាល បុគ្គលិកអនាម័យ អ្នកបើកបររថយន្តសង្គ្រោះ និងភ្នាក់ងារសន្តិសុខទាំងអស់បានពាក់ឯកសណ្ឋានទៅតាមប្រភេទឯកសណ្ឋានដែលមន្ទីរពេទ្យបានផ្តល់ និងបានពាក់ស្លាកឈ្មោះសម្គាល់ខ្លួនជាប់ជាប្រចាំផងដែរ។

៣.១.៣.២. យន្តការសម្របសម្រួល

ពាក់ព័ន្ធនឹងភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា ឬអ្នកជំងឺ ឬ

[៣៨] ឯកសាររបស់គណៈកម្មការបច្ចេកទេសដែលបានធ្វើការវាយតម្លៃមន្ទីរពេទ្យការជួបប្រជុំជាមួយរដ្ឋបាលខេត្ត ថ្នាក់ដឹកនាំមន្ទីរសុខាភិបាល រដ្ឋបាលក្រុង ការិយាល័យជំនាញជំវិញក្រុង និងសហគមន៍ ព្រមទាំងការជួបសម្ភាសន៍ជាមួយអ្នកជំងឺនិងអតីតអ្នកជំងឺ។

សាធារណជន ជាពិសេសសម្រាប់ជនពិការ ជនចាស់ជរា ស្ត្រីមានក្មួនតូចឬមានផ្ទៃពោះ មន្ទីរពេទ្យបានរៀបចំឱ្យមាន ជំរាលសម្រាប់ជនពិការ បន្ទប់ទឹកសម្រាប់ជនពិការ រទេះអ្នកជំងឺ និងមានក្រុមមន្ត្រីសម្របសម្រួលសម្រាប់សម្រួលដល់ការលំបាករបស់អ្នកជំងឺ ឬសាធារណជន។ ដូចជាក្នុងករណីអ្នកជំងឺមិនអាចដើរបាន និងមិនមានអ្នកកំដរឬក្រុមគ្រួសារគឺមានក្រុមសម្របសម្រួលជួយគ្រា ឬរញ៉ារទេះ។

៣.១.៣.៣. ទិដ្ឋភាពកែលម្អ

នៅក្នុងការបង្កើនទំនុកចិត្តពីអ្នកប្រើប្រាស់សេវាឬពីប្រជាជន មន្ទីរពេទ្យបានខិតខំធ្វើការកែលម្អគុណភាពសេវារបស់ខ្លួនតាមរយៈ÷ ១)ការធ្វើបច្ចុប្បន្នកម្មប្រភេទនិងតម្លៃសេវា និងនីតិវិធីការងារ ២)ការបង្កើតយន្តការផ្តល់ព័តិមានត្រឡប់និងបណ្តឹងតវ៉ាពីអ្នកប្រើប្រាស់សេវា និង៣) ការបង្កើតក្រុមការងារលើកកម្ពស់គុណភាពសេវា[៣៩]។

ពាក់ព័ន្ធនឹងការធ្វើបច្ចុប្បន្នកម្មប្រភេទនិងតម្លៃសេវា និងនីតិវិធីការងារ គណៈគ្រប់គ្រងមន្ទីរពេទ្យបាន÷ ១)រៀបចំប្រភេទនិងតម្លៃសេវាដែលកំពុងប្រើនាពេលបច្ចុប្បន្ននៅឆ្នាំ២០១៥ ២)រៀបចំរំហូរការងារឬរំហូរអ្នកជំងឺដែលកំពុងប្រើនាពេលបច្ចុប្បន្ននៅឆ្នាំ២០១៧។ នាពេលខាងមុខ គណៈគ្រប់គ្រងមន្ទីរពេទ្យនឹងធ្វើបច្ចុប្បន្នកម្មទៅលើ ១)ប្រភេទនិងតម្លៃសេវា ដោយរៀបចំដាក់បញ្ចូលនូវប្រភេទសេវាថ្មីៗមួយចំនួនរបស់មន្ទីរពេទ្យ និង ២)រំហូរការងារឬរំហូរអ្នកជំងឺថ្មី[៤០]។

ដើម្បីទទួលបានព័តិមានពាក់ព័ន្ធនឹងការផ្តល់សេវារបស់មន្ទីរពេទ្យ គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំឱ្យមានយន្តការទទួលព័តិមានត្រឡប់និងបណ្តឹងតវ៉ាពីអ្នកជំងឺនិងសាធារណជន តាមរយៈប្រអប់សំបុត្រ ការជួបដោយផ្ទាល់ ទូរស័ព្ទ បណ្តាញសង្គម អាជ្ញាធរមូលដ្ឋាន សហគមន៍ និងដៃគូសុខា-ភិបាល (ក្រុមការងារមូលនិធិសមធម៌ ក្រុមទីភ្នាក់ងារបញ្ជាក់ចំណាយ)។

---

[៣៩] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី០១/ ០៧/ ២០២០។

[៤០] -ដ-

ក្នុងគោលបំណងលើកកម្ពស់គុណភាពសេវារបស់មន្ទីរឱ្យកាន់តែប្រសើរឡើងថែមទៀត ក៏ដូចជាការដោះស្រាយបញ្ហានិងសំណូមពរមួយចំនួនពីអ្នកជំងឺនិងសាធារណជន គណៈគ្រប់គ្រងមន្ទីរពេទ្យបានបង្កើតក្រុមការងារលើកកម្ពស់គុណភាពសេវាប្រចាំមន្ទីរពេទ្យ និងក្រុមការងារលើកកម្ពស់គុណភាពសេវានៅតាមបណ្តាផ្នែក។ ក្រុមការងារលើកកម្ពស់គុណភាពសេវាប្រចាំមន្ទីរពេទ្យខេត្ត ត្រូវបានបង្កើតឡើងតាមសេចក្តីសម្រេចរបស់មន្ទីរពេទ្យខេត្តលេខ៤៨៩/១៧ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧។ ក្រុមការងារលើកកម្ពស់គុណភាពសេវានៅតាមបណ្តាផ្នែក ត្រូវបានបង្កើតឡើងតាមសេចក្តីសម្រេចរបស់មន្ទីរពេទ្យខេត្តលេខ៦៧៣/១៧ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧។

៣.១.៤. ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអតិថិជនកិច្ចល្អ

សេវាផ្តល់តាមគោលការណ៍កំណត់ និងមានអភិបាលកិច្ចល្អ សំដៅដល់អង្គភាពផ្តល់សេវា សាធារណៈត្រូវមានសមត្ថភាពក្នុងការអនុវត្តការងារឱ្យទទួលបានលទ្ធផលខ្ពស់ដោយប្រើប្រាស់ធនធានដែលមានស្រាប់ឱ្យអស់លទ្ធភាព។ សូចនាករគោលនេះមានលក្ខណៈវិនិច្ឆ័យដូចជា ១)សេវាផ្តល់តាមគោលការណ៍កំណត់ និង ២)សេវាផ្តល់តាមអភិបាលកិច្ចល្អ។

៣.១.៤.១. ផ្តល់សេវាតាមគោលការណ៍កំណត់

នៅក្នុងដំណើរការនៃការផ្តល់សេវា មន្ទីរពេទ្យបានខិតខំបំពេញការងាររបស់ខ្លួនទៅតាមគោលការណ៍ណែនាំនិងពិធីសារជាតិរបស់ក្រសួងសុខាភិបាល ព្រមទាំងបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសេវារបស់មន្ទីរពេទ្យ។ ជាក់ស្តែង ពាក់ព័ន្ធនឹងការអនុវត្តតាមតារាងតម្លៃសេវា (ការទប់ស្កាត់ការទារយកថ្លៃសេវាបន្ថែមក្រៅផ្លូវការ) មន្ទីរពេទ្យបាន÷ ១)រៀបចំឱ្យមានគណៈកម្មការហិរញ្ញប្បទានមន្ទីរពេទ្យ ២)រៀបចំឱ្យមានគណៈកម្មការវិន័យនិងនិយ័តកម្មមន្ទីរពេទ្យ ៣)ផ្សព្វផ្សាយតាមបណ្តាផ្នែកនូវច្បាប់ហិរញ្ញប្បទានមិនឱ្យយកថ្លៃសេវាបន្ថែមក្រៅផ្លូវការ ៤)អប់រំអ្នកជំងឺឱ្យយល់ដឹងពីការបង់ប្រាក់តាមតម្លៃសេវាដែលមានបិទផ្សព្វផ្សាយតាមផ្នែកនីមួយៗ ៥)ផ្សព្វផ្សាយដល់បុគ្គលិកដែលយកថ្លៃ

សេវាក្រៅផ្លូវការថា នឹងត្រូវពិន័យដោយកាត់ប្រាក់លើកទឹកចិត្តប្រចាំខែ និងក្នុងករណីមិនរាងចាលនឹងបញ្ជូនឈ្មោះទៅមន្ទីរសុខាភិបាល ៦) ផ្សព្វផ្សាយបទបញ្ជាផ្ទៃក្នុងដោយសង្កត់ធ្ងន់លើចំណុចទី១៣ នៃបទបញ្ជាផ្ទៃក្នុង[៤១] ៧) ឱ្យអ្នកជំងឺឬអ្នកកំដរបង់ថ្លៃសេវាដោយខ្លួនឯង ៨) បិទផ្សាយតារាងតម្លៃសេវាតាមបណ្តាផ្នែក និង៩) បើកចំហរ ទទួលគ្រប់ការចូលរួមទិតៀនកែលម្អពីគ្រប់មជ្ឈដ្ឋាន។ ផ្សេងពីនោះ មន្ទីរពេទ្យក៏មានការចូលតាមដានត្រួតពិនិត្យពីអង្គការ និងអាជ្ញាធរមូលដ្ឋានផងដែរ រួមមាន÷ ១) ទីភ្នាក់ងារបញ្ជាក់ការចំណាយ ២) គណៈកម្មាធិការនាយកហិរញ្ញប្បទានសុខាភិបាលដែលមានអភិបាលរងខេត្តមួយរូបជាប្រធាន ដោយមានការប្រជុំរៀងរាល់៣ខែម្តង[៤២]។

ការខិតខំបំពេញការងាររបស់ថ្នាក់ដឹកនាំនិងបុគ្គលិករបស់មន្ទីរពេទ្យ និងការចូលរួមគាំទ្រពីរដ្ឋបាលខេត្ត រដ្ឋបាលក្រុង មន្ទីរសុខាភិបាល និងពីភាគីពាក់ព័ន្ធនាពេលកន្លងមក បានក្លាយជាកម្លាំងចលករធ្វើឱ្យមន្ទីរពេទ្យសម្រេចបាននូវលទ្ធផលជាច្រើន ដែលជាហេតុនាំឱ្យមន្ទីរពេទ្យទទួលបានវិញ្ញាបនបត្រនិងប័ណ្ណសរសើរជាច្រើនរួមមាន វិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាក្នុងផ្នែកផ្តល់ឈាមពី Africa Society for Blood Transfusion (AfSBT) និងពី US INDOPACOM Blood Safety Program និងទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាក្នុងផ្នែកមន្ទីរពិសោធន៍ពី Pacific Pathology Training Centre; វិទ្យាស្ថានជាតិសុខភាពសាធារណៈជាមួយនឹង Sysmex; និងពីវិទ្យាស្ថានជាតិសុខភាពសាធារណៈ។ ជាមួយគ្នាដែរ មន្ទីរពេទ្យខេត្តក៏ទទួលបានប័ណ្ណសរសើរពាក់ព័ន្ធនឹងការផ្តល់សេវាពីក្រសួងសុខាភិបាល រដ្ឋបាលខេត្តកំពង់ចាម អាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀនផងដែរ។

ដើម្បីដឹងពីគុណភាពសេវាដែលអង្គភាពបានផ្តល់ គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំឱ្យមានការចូលរួមវាយតម្លៃពីអ្នកជំងឺ អ្នកកំដរអ្នកជំងឺ និងភាគីពាក់ព័ន្ធតាមរយៈ÷

[៤១] បានចែងថា ហាមទារប្រាក់ពីអ្នកជំងឺក្រៅពីការកំណត់របស់សេវាហិរញ្ញប្បទានមន្ទីរពេទ្យ។

[៤២] ការសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០។

១) ប្រអប់សំបុត្រ ២) ទីភ្នាក់ងារបញ្ជាក់ការចំណាយ (PCA) របស់ក្រសួងសុខាភិបាល ៣) វេទិកាសាធារណៈ ៤) Page របស់មន្ទីរពេទ្យ ៥) ថ្នាក់ដឹកនាំមន្ទីរពេទ្យចុះទៅតាមសហគមន៍ ៦) ក្រុមវាយតម្លៃរបស់គម្រោងលើកកម្ពស់គុណភាពនិងសមធម៌សុខាភិបាល (Health Equity and Quality Improvement Project: H-EQIP) រាល់៣ខែម្តង និង ៧) ទូរស័ព្ទពីអ្នកប្រើប្រាស់សេវាឬប្រជាពលរដ្ឋមកថ្នាក់ដឹកនាំមន្ទីរពេទ្យផ្ទាល់[៤៣]។

៣.១.៤.២. សេវាផ្តល់មានអតិថិជនកិច្ចល្អ

ក្នុងការបង្កើននូវប្រសិទ្ធភាពនៅក្នុងដំណើរការនៃការផ្តល់សេវា គណៈគ្រប់គ្រងមន្ទីរពេទ្យបានខិតខំប្រើប្រាស់ធនធានរបស់អង្គភាពឱ្យអស់លទ្ធភាពតាមរយៈ÷ ១) ការបណ្តុះបណ្តាលជំនាញបន្ថែមដល់បុគ្គលិក ២) ការកៀរគរធនធានមនុស្សពីផ្នែកដទៃទៅជួយផ្នែកដែលមានការងារច្រើន ដោយធ្វើការបង្រៀននូវជំនាញចាំបាច់មួយចំនួន ៣) ការធ្វើសមាហរណកម្មបណ្តាផ្នែក ដូចជាផ្នែកជំងឺអេដស៍បូកបញ្ចូលជាមួយផ្នែកគ្លីនិកគ្រួសារ បង្កើតបានជាផ្នែកថ្មីមួយគឺផ្នែកព្យាបាលជំងឺឱកាសនិយម។ ពាក់ព័ន្ធនឹងការចូលរួម មន្ទីរពេទ្យក៏បានផ្តល់ឱកាសនិងជំរុញឱ្យអ្នកជំងឺ អ្នកកំដរអ្នកជំងឺ និងភាគីពាក់ព័ន្ធដទៃទៀតចូលរួមនៅក្នុងដំណើរការនៃការផ្តល់សេវារបស់អង្គភាព មានដូចជា÷ ១) ការកំណត់ថ្លៃសេវា ២) ការកែលម្អតិរិយាបថមន្ត្រី ៣) ការលើកកម្ពស់អនាម័យនិងបរិស្ថាន និង ៤) ការចូលរួមក្នុងរូបភាពជាឧបករណ៍និងបច្ចេកទេស[៤៤]។

[៤៣] ការសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០។
[៤៤] ការសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី០២/០៧/ ២០២០។



មន្ទីរពេទ្យថតពីលើអាកាស



ខ្លោងទ្វារមន្ទីរពេទ្យ (ច្រកទ្វារធំ)



កន្លែងចុះឈ្មោះ (ទី១) និងបែងចែកជំងឺ



កន្លែងចុះឈ្មោះ (ទី២)អ្នកជំងឺទឹកនោមផ្អែម





ការផ្សព្វផ្សាយព័ត៌មាននៅទីឯកន្លែង









ការផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក

៣.២. និយាមនៃការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យខេត្តកំពង់ចាម

៣.២.១. ការដឹកនាំ និងការគ្រប់គ្រងមន្ទីរពេទ្យខេត្តកំពង់ចាម

នៅក្នុងការពិនិត្យមើលបទពិសោធន៍ជោគជ័យលើការដឹកនាំ និងគ្រប់គ្រងមន្ទីរពេទ្យខេត្តកំពង់ចាម សូចនាករពាក់ព័ន្ធត្រូវបានវាយតម្លៃរួមមាន÷ ១)ការរៀបចំផែនការ និងការអនុវត្តផែនការការងារ ២)ការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាល និង ៣)ការគ្រប់គ្រងមន្ទីរពេទ្យខេត្តកំពង់ចាម។

៣.២.១.១. ការរៀបចំផែនការ និងការអនុវត្តផែនការការងារ

មន្ទីរពេទ្យខេត្តកំពង់ចាមបានរៀបចំជាផែនការយុទ្ធសាស្ត្រប្រចាំឆ្នាំ ដោយបានរំលេចនូវចក្ខុវិស័យ បេសកកម្ម គុណតម្លៃ និងមានគោលដៅច្បាស់លាស់។ ក្នុងគោលដៅនីមួយៗ មន្ទីរពេទ្យបានរំលេចនូវយុទ្ធសាស្ត្រលម្អិត ដើម្បីជាមូលដ្ឋានដល់ការអនុវត្តគោលដៅនីមួយៗឱ្យសម្រេចប្រកបដោយប្រសិទ្ធភាព។ ឯកសារយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយមានការគាំទ្រពីមន្ទីរសុខាភិបាលរាជធានី ខេត្ត និងមានការចងក្រង និងចុះហត្ថលេខាច្បាស់លាស់ពីប្រធានមន្ទីរពេទ្យ។ ក្នុងនោះ មន្ទីរពេទ្យខេត្តកំពង់ចាមបានរំលេចនូវ÷

- ចក្ខុវិស័យ÷ មន្ទីរពេទ្យខេត្តកំពង់ចាម ផ្តល់ការព្យាបាល និងថែទាំសុខភាព ប្រកបដោយគុណភាពល្អ ដើម្បីកាត់បន្ថយអត្រាឈឺ និងអត្រាស្លាប់របស់ប្រជាពលរដ្ឋទូទៅ។
- បេសកកម្ម÷ លើកកម្ពស់ការផ្តល់សេវាព្យាបាល និងថែទាំមានគុណភាព ប្រសិទ្ធភាព និងប្រកបដោយសមធម៌ដល់អ្នកជំងឺ និងប្រជាពលរដ្ឋទូទៅ ជាពិសេសប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។
- គុណតម្លៃ÷ ក្រមសីលធម៌វិជ្ជាជីវៈ ការគោរព ស្មោះត្រង់ សមធម៌ មិនរើសអើង និងឧត្តមភាព។
- គោលដៅ÷ មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាមបានរៀបចំគោលដៅចំនួន១២ ដើម្បីធានាថាការបម្រើសេវាសុខាភិបាលអាចធានាបានប្រសិទ្ធភាពខ្ពស់។

ដើម្បីសម្រេចគោលដៅទាំង១២នោះ មន្ទីរពេទ្យបានដាក់ចេញនូវយុទ្ធសាស្ត្រលម្អិតចំនួន១០២។ គោលដៅនីមួយៗត្រូវបានប្រើដោយយុទ្ធសាស្ត្រលម្អិតមួយចំនួន។ ជាក់ស្តែងនៅគោលដៅទី១ ស្តីពីផ្តល់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបតាមតម្រូវការក្នុងការបម្រើសេវាទាន់ពេលវេលា មានគោលដៅលម្អិតចំនួន៨ រួមមាន÷ ១)ធានាប្រតិបត្តិការមុខងារមន្ទីរពេទ្យ ប្រកបដោយភាពជោគជ័យ ដើម្បីសម្រេចបេសកកម្មរបស់មន្ទីរពេទ្យ ២)ធានាធនធាន និងទ្រព្យសម្បត្តិរបស់មន្ទីរពេទ្យត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព ៣)ធានាគុណភាពសេវាព្យាបាល និងថែទាំអ្នកជំងឺ ដោយរៀបចំឱ្យមានកម្មវិធីលើកកម្ពស់គុណភាព និងយន្តការគុណភាពជាប្រចាំ ៤)ធានាថាមន្ត្រី/បុគ្គលិកទាំងអស់អនុវត្តយ៉ាងហ្មត់ចត់នូវក្រមសីលធម៌វិជ្ជាជីវៈ ៥)ធានាប្រតិបត្តិការរបស់មន្ទីរពេទ្យស្របទៅនឹងស្តង់ដាដែលបានកំណត់ និងអភិបាលកិច្ចល្អ ៦)អភិវឌ្ឍន៍ និងបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងផែនការប្រតិបត្តិ ហើយធានារាល់ការសម្រេចចិត្ត និងអនុវត្តសកម្មភាព គឺស្របតាមផែនការ ៧)តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ កម្មវិធី និងស្តង់ដា ឆ្លើយតបទៅនឹងអាទិភាព និងគោលដៅរបស់មន្ទីរពេទ្យ និង ៨)កៀរគរធនធានហិរញ្ញវត្ថុ និងបច្ចេកទេស ដើម្បីអភិវឌ្ឍន៍មន្ទីរពេទ្យ ពិសេសការលើកកម្ពស់គុណភាពសេវាថែទាំ និងព្យាបាល។

មន្ទីរពេទ្យខេត្តកំពង់ចាមបានរៀបចំផែនការខាងលើដោយមានការចូលរួមពីភាគីពាក់ព័ន្ធ រួមមាន÷ គណៈគ្រប់គ្រងមន្ទីរពេទ្យ ប្រធានផ្នែក បុគ្គលិកជំនាញ និងតំណាងមន្ទីរសុខាភិបាល ដោយផ្តោតទៅលើការប្រមូលទិន្នន័យតាមផ្នែកនីមួយៗ ការបញ្ចូលទិន្នន័យក្នុងផែនការរួម និងពង្រាងផែនការប្រចាំឆ្នាំ ជាមួយនឹងការរៀបចំជាកំណត់ហេតុអង្គប្រជុំច្បាស់លាស់។ មន្ទីរពេទ្យក៏បានផ្សារភ្ជាប់កិច្ចដំណើរការរៀបចំផែនការនេះទៅនឹងសហគមន៍ តាមរយៈការបញ្ចូលសំណូមពរពីអាជ្ញាធរមូលដ្ឋាន និងការចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់មន្ទីរសុខាភិបាលខេត្ត ដើម្បីរៀបចំជាផែនការរួម និងអាចដោះស្រាយបញ្ហា

ប្រឈមរបស់ខេត្ត និងសហគមន៍ទាំងមូល[៤៥]។

ក្រៅពីផែនការយុទ្ធសាស្ត្រ មន្ទីរពេទ្យក៏បានរៀបចំជាផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ និងបានចងក្រងជាឯកសារ និងរក្សាទុកច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការតាមដាន។ មន្ទីរពេទ្យបានរៀបចំផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំនេះ ជាតារាងដោយចែងលម្អិតពីសកម្មភាព អ្នកទទួលខុសត្រូវលើការអនុវត្ត ពេលវេលាលើការអនុវត្ត ផែនការថវិកា រួមជាមួយនឹងសូចនាករលទ្ធផល និងគោលដៅច្បាស់លាស់។ ជាមួយគ្នានេះដែរ មន្ទីរពេទ្យក៏បានរៀបចំជាមធ្យោបាយផ្ទៀងផ្ទាត់ តាមរយៈការរៀបចំជារបាយការណ៍នៅចុងគ្រា ក៏ដូចជាការចងក្រងឯកសារទុក ដើម្បីធានាការអនុវត្តការងារបានត្រឹមត្រូវតាមផែនការ។ ផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំនេះ ជាមូលដ្ឋានដ៏សំខាន់របស់មន្ទីរពេទ្យក្នុងការតាមដានការអនុវត្តជាប្រចាំខែ និងប្រចាំត្រីមាសរបស់មន្ទីរពេទ្យ។

ជាក់ស្តែង មន្ទីរពេទ្យបានរៀបចំជាសកម្មភាពលើការពង្រឹងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបតាមតម្រូវការក្នុងការបម្រើសេវាបានទាន់ពេលវេលា ដោយបានកំណត់ការអនុវត្តសកម្មភាពចំនួន៩ មានដូចជា ការរៀបចំផែនការប្រចាំឆ្នាំ ការរៀបចំផែនការធនធានមនុស្សប្រចាំឆ្នាំ ការរៀបចំផែនការថវិកា ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំផែនការលទ្ធកម្ម ក៏ដូចជាផែនការផ្តល់ការលើកទឹកចិត្តផ្អែកលើលទ្ធផលនៃការវាយតម្លៃជាដើម។

បន្ទាប់ពីការរៀបចំជាផែនការ មន្ទីរពេទ្យក៏បានអនុវត្តនូវការតាមដាន និងត្រួតពិនិត្យតាមរយៈការរៀបចំកិច្ចប្រជុំបូកសរុបការងារ និងសមិទ្ធផលប្រចាំត្រីមាស និងប្រចាំឆ្នាំ និងមានកំណត់ហេតុច្បាស់លាស់ក្រោមការចូលរួមពីថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់របស់មន្ទីរពេទ្យខេត្តកំពង់ចាម។ របបប្រជុំនេះ បានផ្តោតលើចំណុចសំខាន់ៗ រួមមាន÷ ១)របាយការណ៍ថវិកា ២)ស្ថានភាពពិនិត្យ និងព្យាបាលជំងឺនៅក្នុងត្រីមាស និងក្នុងឆ្នាំ

[៤៥] ដកស្រង់ចេញពីរបាយការណ៍ស្តីពីការប្រជុំពិភាក្សានិងរៀបចំផែនការរបស់មន្ទីរពេទ្យខេត្តកំពង់ចាម សម្រាប់ឆ្នាំ២០១៨។

៣)វឌ្ឍនភាពសកម្មភាពសំខាន់ៗធៀបនឹងសូចនាករតាមផែនការ ៤)ចំណុចខ្លាំង ៥)ចំណុចខ្សោយ និង៦)អនុសាសន៍កែលម្អ រួមជាមួយនឹងផែនការសកម្មភាពអភិវឌ្ឍន៍នាពេលបន្ទាប់។

៣.២.១.២. ការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាល

ប្រព័ន្ធព័ត៌មានសុខាភិបាលជាប្រព័ន្ធផ្តុំកទិន្នន័យ ស្តីពីការគ្របដណ្តប់នៃសេវាសុខាភិបាលដែលមន្ទីរពេទ្យត្រូវបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ តាមគេហទំព័រ ជាទៀងទាត់មួយខែម្តងចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១៥នៃខែបន្ទាប់ លើគ្រប់ចំណុចនៃទិន្នន័យទាំងអស់ និងមានសង្គតិភាពនឹងគ្នា។

ក្នុងការគ្រប់គ្រងនេះ មន្ទីរពេទ្យខេត្តកំពង់ចាមបានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល (Health Information Management System: HIMS) ដែលជាប្រព័ន្ធដែលរៀបចំ និងគ្រប់គ្រងដោយក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលរាជធានី ខេត្ត។ ប្រព័ន្ធនេះមានផ្តុំកនូវព័ត៌មាននៃសកម្មភាពសេវាសុខភាពប្រចាំថ្ងៃ និងទិន្នន័យសុខភាពពីគ្រប់លំដាប់ថ្នាក់នៃប្រព័ន្ធថែទាំសុខភាពជាតិ រួមបញ្ចូលទាំងទិន្នន័យអ្នកជំងឺដែលអនុញ្ញាតឱ្យមន្ទីរពេទ្យពិនិត្យស្វែងយល់ពីស្ថានភាពរួម នៃអ្នកជំងឺរបស់មន្ទីរពេទ្យទាំងមូល។

ក្នុងការគ្រប់គ្រង និងបញ្ចូលទិន្នន័យ មន្ទីរពេទ្យខេត្តកំពង់ចាមបានបញ្ចូលទិន្នន័យពេញលេញ និងទាន់ពេលទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលរបស់ក្រសួងសុខាភិបាល យោងទៅតាមព័ត៌មានដែលទទួលបានពីគ្រប់ផ្នែកទាំងអស់នៃមន្ទីរពេទ្យ និងតាមរយៈការកំណត់មន្ត្រីដែលមានតួនាទីបញ្ចូលទិន្នន័យច្បាស់លាស់ និងទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ដើម្បីធានាថាព័ត៌មានដែលបញ្ចូលមានភាពត្រឹមត្រូវច្បាស់លាស់ និងអាចប្រើប្រាស់បាន។ មន្ទីរពេទ្យបានបញ្ចូលទិន្នន័យនៃសេវាសុខភាពប្រចាំខែ តាមកាលបរិច្ឆេទបានពេញលេញ និងទិន្នន័យមានសង្គតិភាព។

មន្ទីរពេទ្យបានប្រើប្រាស់ប្រព័ន្ធចុះឈ្មោះ និងគ្រប់គ្រងអ្នកជំងឺ (Patient Management Registration System: PMRS) សម្រាប់គ្រប់គ្រងទិន្នន័យអ្នកជំងឺ ដូចគ្នាទៅ

នឹងមន្ទីរពេទ្យផ្សេងៗដែរ។ គួរកត់សម្គាល់ថា ប្រព័ន្ធ PMRS គឺជាកម្មវិធីអ៊ីនធឺណិតមួយ ដែលប្រើប្រាស់ដោយមូលដ្ឋានសុខាភិបាលសាធារណៈ សម្រាប់គ្រប់គ្រងទិន្នន័យអ្នកជំងឺ ម្នាក់ៗ ដោយប្រើប្រាស់ប្រព័ន្ធអត្តលេខអ្នកជំងឺដាច់ដោយឡែក និងគ្រប់គ្រងព័ត៌មានពិស្តារ ផ្ទាល់ខ្លួនរបស់អ្នកជំងឺ។ នាពេលបច្ចុប្បន្ន មន្ទីរពេទ្យខេត្តកំពង់ចាម តែងពិនិត្យមើលទិន្នន័យ ក្នុងប្រព័ន្ធខាងលើ ដើម្បីធ្វើការប្រៀបធៀប សិក្សា និងវិភាគពីបម្រែបម្រួលទិន្នន័យអ្នកជំងឺ ប្រចាំខែផងដែរ។

មន្ទីរពេទ្យខេត្តកំពង់ចាមក៏មានការពិនិត្យលទ្ធផលប្រចាំត្រីមាសរបស់មន្ទីរពេទ្យ តាមរយៈការរៀបចំជាកិច្ចប្រជុំគណៈគ្រប់គ្រង និងកិច្ចប្រជុំក្រុមការងារបច្ចេកទេសតាម ផ្នែក ដោយមានការធ្វើបទបង្ហាញលើវឌ្ឍនភាពនៃការអនុវត្តសកម្មភាព និងលទ្ធផលតាម ផ្នែកនីមួយៗ តាមត្រីមាស ដោយធ្វើការប្រៀបធៀបនឹងផែនការសូចនាករ និងលទ្ធផល នៅឆ្នាំមុន ដើម្បីពិនិត្យវឌ្ឍនភាពតាមផ្នែកនីមួយៗ។ កិច្ចប្រជុំ និងការរៀបចំបទបង្ហាញ នេះហើយ ដែលអាចធ្វើឱ្យមន្ទីរពេទ្យខេត្តកំពង់ចាមអាចធ្វើការវិភាគលទ្ធផលប្រចាំត្រីមាស ពីចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈម តាមផ្នែកនីមួយៗ និងស្វែងរកដំណោះស្រាយ សម្រាប់អនុវត្តនៅត្រីមាសបន្ត តាមរយៈការផ្តល់មតិយោបល់ពីអង្គប្រជុំទាំងមូល។

ជាគោលការណ៍ និងការអនុវត្តជាក់ស្តែង ការពិនិត្យលទ្ធផលប្រចាំត្រីមាស ជាការ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ក្នុងបំណងពង្រឹងការផ្សារភ្ជាប់គ្នារវាងធនធាន និង សកម្មភាព ឬអន្តរាគមន៍នៃផែនការដែលត្រូវអនុវត្ត និងផ្សារភ្ជាប់ទៅនឹងលទ្ធផល ពោល គឺគោលដៅចំណុចនៃគោលដៅយុទ្ធសាស្ត្រ និងគោលបំណងអភិវឌ្ឍសុខភាព។ ជារួម មន្ទីរពេទ្យពិនិត្យមើលវឌ្ឍនភាពផង និងវាស់វែងលទ្ធផលដែលសម្រេចបានផង និងកំណត់ ផែនការសកម្មភាពបន្ទាប់ផង។

៣.២.១.៣. ការគ្រប់គ្រងមន្ទីរពេទ្យ

នៅក្នុងការគ្រប់គ្រង មន្ទីរពេទ្យបានរៀបចំជាកិច្ចប្រជុំតាមដាន រួមមាន÷ ១)កិច្ចប្រជុំ ប្រចាំខែនៃគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ ២)កិច្ចប្រជុំប្រចាំខែនៃគណៈកម្មការបច្ចេក-

ទេស និង ៣)កិច្ចប្រជុំប្រចាំខែនៃគណៈកម្មការហិរញ្ញប្បទាន។

ក្នុងនោះ មន្ទីរពេទ្យខេត្តកំពង់ចាមបានរៀបចំជាកិច្ចប្រជុំប្រចាំខែ នៃគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ ដែលដឹកនាំដោយលោកប្រធានមន្ទីរពេទ្យតែម្តង។ កិច្ចប្រជុំប្រចាំខែនេះបានផ្តោតលើរបៀបវារៈមួយចំនួនដូចជា÷ ១)ការពិនិត្យតាមដានការអនុវត្តសេចក្តីសម្រេចនានាដែលបានអនុម័តក្នុងកិច្ចប្រជុំលើកមុន ២)ការអនុវត្តអនុសាសន៍ និងការសម្រេចចិត្តដែលបានអនុម័តក្នុងកិច្ចប្រជុំលើកមុន ៣)ការពិភាក្សាដើម្បីពង្រឹងការងាររបស់ក្រុមកែលម្អគុណភាពសេវាមន្ទីរពេទ្យខេត្តកំពង់ចាម ៤)កំណត់កាលវិភាគសម្រាប់កម្មវិធីប្រជុំរបស់កុម្រកែលម្អគុណភាពសេវាមន្ទីរពេទ្យខេត្តកំពង់ចាម ៥)ពិភាក្សាបង់លេខគ្រែអ្នកជំងឺនៅតាមផ្នែកនីមួយៗរបស់មន្ទីរពេទ្យ ៦)ពិនិត្យឡើងវិញលើឧបករណ៍វាយតម្លៃសម្រាប់ចូលរួមប្រឡងប្រណាំងមន្ទីរពេទ្យ ៧)ពិភាក្សាអំពីតុល្យការហិរញ្ញវត្ថុ និង៨)សេចក្តីសម្រេច និងអនុសាសន៍។ រាល់របៀបវារៈនីមួយៗ សុទ្ធតែបញ្ជាក់នូវវឌ្ឍនភាព ចំណុចពិភាក្សា មូលហេតុនៃបញ្ហា ដំណោះស្រាយ ឬសេចក្តីសម្រេច រួមទាំងអ្នកទទួលខុសត្រូវលើការអនុវត្តផងដែរ ជាមួយនឹងថេរវេលាច្បាស់លាស់។

ក្រៅពីកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ មន្ទីរពេទ្យខេត្តកំពង់ចាមក៏បានរៀបចំកិច្ចប្រជុំប្រចាំខែនៃក្រុមការងារផ្សេងៗផងដែរ។ តួយ៉ាង កិច្ចប្រជុំក្រុមការងារលើកកម្ពស់គុណភាពមន្ទីរពេទ្យ ដែលដឹកនាំដោយលោកអនុប្រធានមន្ទីរពេទ្យ និងផ្តោតលើរបៀបវារៈសំខាន់ចំនួន៣ រួមមាន÷ ១)ការពិនិត្យសកម្មភាពដែលអនុវត្តក្នុងខែកន្លងទៅតាមផ្នែកនីមួយៗ ដើម្បីសម្រេចបាននូវការលើកកម្ពស់តាមផ្នែកនីមួយៗ ២)ការវាយតម្លៃលើការលើកកម្ពស់គុណភាពសេវា និងការវិភាគលើព័ត៌មានដែលទទួលបានពីប្រអប់សំបុត្រតាមផ្នែក និង ៣)ការរៀបចំជាឯកសារលាយលក្ខណ៍អក្សរសម្រាប់ផ្តល់ព័ត៌មានត្រឡប់តាមផ្នែកនីមួយៗវិញ។

ជាមួយគ្នានេះដែរ មន្ទីរពេទ្យខេត្តកំពង់ចាមក៏មានរៀបចំកិច្ចប្រជុំមួយចំនួនទៀតដូចជា÷ ១)កិច្ចប្រជុំប្រចាំខែនៃគណៈកម្មការហិរញ្ញប្បទានមន្ទីរពេទ្យ ២)កិច្ចប្រជុំប្រចាំ

ខែនៃក្រុមការងារលើកកម្ពស់គុណភាពនិងសុវត្ថិភាពក្នុងមន្ទីរពេទ្យ និង ៣)កិច្ចប្រជុំប្រចាំខែនៃក្រុមការងារថែទាំជំងឺក្នុងមន្ទីរពេទ្យ ដោយពិនិត្យវឌ្ឍនភាពទៅតាមផ្នែកនីមួយៗ លើកពីបញ្ហាប្រឈម និងដំណោះស្រាយ រួមទាំងផែនការសកម្មភាពនាពេលបន្ទាប់ផងដែរ។ កិច្ចប្រជុំនីមួយៗបានរៀបចំជាកំណត់ហេតុច្បាស់លាស់ មានបញ្ជីវត្តមាន និងមានការពិភាក្សាបញ្ហានិងដំណោះស្រាយតាមរបៀបវារៈនីមួយៗយ៉ាងលម្អិត ជាមួយនឹងការចុះហត្ថលេខាពីអនុប្រធានមន្ទីរពេទ្យដែលជាប្រធានអង្គប្រជុំផងដែរ។

ចំពោះករណីមរណភាពបានកើតឡើង គណៈកម្មការបច្ចេកទេសរបស់មន្ទីរពេទ្យបានសិក្សា និងរៀបចំជារបាយការណ៍និងបែបបទស្តីពីការចុះអង្កេតមរណភាព ដោយរៀបរាប់ពីព័ត៌មានទូទៅ និងមូលហេតុដែលនាំឱ្យមានករណីនេះកើតឡើង។ ពេលខ្លះ កិច្ចការនេះតម្រូវឱ្យមានការចុះពិនិត្យជាក់ស្តែង និងធ្វើការសម្ភាសន៍គ្រួសារជនរងគ្រោះដល់សហគមន៍ផ្ទាល់ផងដែរ។ គួរបញ្ជាក់ថា របាយការណ៍អង្កេតមរណភាពត្រូវបានរៀបចំដោយមន្ទីរពេទ្យ និងមានការពិនិត្យនិងចុះហត្ថលេខាពីប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ចាមផងដែរ។

ពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងស្តុកឱសថ គណៈគ្រប់គ្រងមន្ទីរពេទ្យខេត្តបានរៀបចំឱសថស្ថានឱ្យមានភាពស្អាត អនាម័យ និងសណ្តាប់ធ្នាប់ស្របតាមគោលការណ៍កំណត់ដើម្បីធានាគុណភាព និងងាយស្រួលតាមដានស្តុកឱសថ។ ក្នុងនោះ ក្រុមការងារបានពិនិត្យឃើញថា ១)ផ្នែកម្រាល ពិដាន ជញ្ជាំង បង្អួច និងទ្វារ មានភាពស្អាត ហើយនៅលើផ្នែកម្រាលគ្មានសំរាម ២)ធ្នើរដាក់ឱសថ ប្រអប់ឱសថ និងបរិក្ខារមានភាពស្អាត ៣)ការរៀបចំទុកដាក់ឱសថតាមលំដាប់អក្សរ និងសីតុណ្ហភាពកំណត់មានទែម៉ូម៉ែត្រនៅក្នុងឱសថស្ថាន ៤)ប្រព័ន្ធត្រជាក់ដំណើរការល្អ និងមានការតាមដានសីតុណ្ហភាពពីបុគ្គលិកមន្ទីរពេទ្យ និង៥)ឯកសារគ្រប់គ្រងឱសថ និងបញ្ជីឱសថមានបច្ចុប្បន្នភាព។

មន្ទីរពេទ្យខេត្តកំពង់ចាមក៏មានបញ្ជី Excel ដើម្បីកត់ត្រាលើបម្រែបម្រួលឱសថនៅក្នុងឱសថស្ថាន និងមានការរៀបចំជារបាយការណ៍ប្រចាំខែផងដែរ និងមានការសង្ខេបទិន្នន័យលើស្ថានភាពស្តុក ក្នុងករណីមានតម្រូវការឱសថបន្ថែម។ ក្នុងនោះឱសថត្រូវបាន

បែងចែកទៅតាមការស្នើរបស់ផ្នែកនីមួយៗដោយឆ្លងកាត់ការឯកភាពពីប្រធានមន្ទីរពេទ្យ ខេត្តកំពង់ចាម។

ចំណែកក្នុងកិច្ចការគ្រប់គ្រងឧបករណ៍វេជ្ជសាស្ត្រ ការធ្វើបច្ចុប្បន្នភាពបញ្ជីសារពើ-ភណ្ឌឧបករណ៍វេជ្ជសាស្ត្រ និងបរិក្ខារពេទ្យជាទៀងទាត់ រួមទាំងការថែទាំជាប្រចាំ ជាចំណុចសំខាន់ និងចាំបាច់ដើម្បីធានានិរន្តរភាពនៃដំណើរការផ្តល់សេវាសុខភាពរបស់មន្ទីរពេទ្យ។ ក្នុងន័យនេះ មន្ទីរពេទ្យក៏មានប្រព័ន្ធគ្រប់គ្រងឧបករណ៍វេជ្ជសាស្ត្រ និងបានរៀបចំជារបាយការណ៍គ្រប់គ្រងឧបករណ៍វេជ្ជសាស្ត្រប្រចាំឆមាស ដោយមានរបាយការណ៍សង្ខេប និងរបាយការណ៍លម្អិតស្តីពីឧបករណ៍វេជ្ជសាស្ត្រដែលល្អ សភាពមធ្យម សភាពខ្វះខាត និងឧបករណ៍វេជ្ជសាស្ត្រចូលថ្មី រួមជាមួយនឹងការកត់សម្គាល់បញ្ហាលើការគ្រប់គ្រង និងផ្នែកបច្ចេកទេស សម្រាប់ផ្ញើជូនប្រធាននាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាលពិនិត្យ ដោយមានការចុះហត្ថលេខាពីប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ចាមផងដែរ។ បន្ថែមពីនេះ មន្ទីរពេទ្យក៏បានរៀបចំជាផែនការត្រួតពិនិត្យ និងថែទាំឧបករណ៍វេជ្ជសាស្ត្រ របាយ-ការណ៍ឧបករណ៍វេជ្ជសាស្ត្រតាមផ្នែក និងកំណត់ត្រាថែទាំសេវាកម្មឧបករណ៍បរិក្ខារពេទ្យ តាមផ្នែកនីមួយៗផងដែរ។

ចំណែកក្នុងកិច្ចការស្តុកឈាម មន្ទីរពេទ្យខេត្តកំពង់ចាមបានរៀបចំជាប្រព័ន្ធទិន្នន័យលើការប្រមូលឈាម មានរៀបចំជាផែនការ របាយការណ៍ប្រមូលឈាម របាយការណ៍ចំនួនអ្នកស្ម័គ្រចិត្តបរិច្ចាគឈាមតាមក្រុមចល័ត ចំនួនអ្នកបរិច្ចាគឈាមតាមអាយុ ជាមួយនឹងរបាយការណ៍ប្រចាំខែនៃការប្រើប្រាស់ឈាម។ អគារស្តុកឈាមនេះ ត្រូវបានចាត់ទុកថាមានលក្ខណៈស្តង់ដាខ្ពស់ ហើយព័ត៌មាននៃការប្រើប្រាស់ឈាមនេះ ក៏មានការសរសេរលើក្តារខៀន សម្រាប់បង្ហាញក្នុងអគារស្តុកឈាមផងដែរ។

៣.២.២. ការបង្ការ ការត្រួតពិនិត្យការចម្លងរោគ និងអនាម័យ

យោងតាមក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជាការត្រួតពិនិត្យការចម្លងរោគ និងអនាម័យមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវបរិស្ថានថែទាំសុខភាព ប្រកបដោយ

សុវត្ថិភាពសម្រាប់អ្នកជំងឺ និងបុគ្គលិកសុខាភិបាលនៅក្នុងផ្នែកថែទាំគ្រប់ផ្នែកទាំងអស់[៤៦]។

ក្នុងន័យខាងលើនេះ មន្ទីរពេទ្យខេត្តកំពង់ចាមបានបង្កើតក្រុមត្រួតពិនិត្យ និងបង្ការការចម្លងរោគ (Infection Prevention and Control Team)[៤៧] ដែលរួមមាន÷ គណៈកម្មការ និងអនុគណៈកម្មការត្រួតពិនិត្យ និងបង្ការការចម្លងរោគ (Infection Prevention and Control Committee and Infection and Control Team Link)។ ការបង្កើតក្រុមការងារនេះមានគោលបំណងដើម្បីបង្ការ និងចាត់វិធានការណ៍ឱ្យមានប្រសិទ្ធភាព ដើម្បីប្រឆាំងទប់ស្កាត់ការចម្លងរោគក្នុងមន្ទីរពេទ្យ បន្ទាប់មកគឺស្វែងយល់ពីស្ថានភាពបច្ចុប្បន្ននៃការងារត្រួតពិនិត្យនិងបង្ការចម្លងរោគក្នុងមន្ទីរពេទ្យ ព្រមទាំងមានវិធានការណ៍ជាក់លាក់ក្នុងការបង្ការផងដែរ[៤៨]។ ក្រៅពីក្រុមការងារខាងលើ មន្ទីរពេទ្យក៏បានបង្កើតក្រុមការងារសម្រាប់ចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការការពារការចម្លងរោគមន្ទីរពេទ្យខេត្តកំពង់ចាម ហើយក្រុមការងារមានភារកិច្ចចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារការពារការចម្លងរោគប្រចាំមន្ទីរពេទ្យ។ ក្រុមការងារនេះត្រូវបានចែកជា ៥ក្រុម ដែលក្រុមនីមួយៗមានប្រធានក្រុមចំនួន០១រូប និងសមាជិកចំនួន០៤រូប[៤៩]។

នៅក្នុងការពិនិត្យមើលការបង្ការ ការត្រួតពិនិត្យការចម្លងមេរោគ និងអនាម័យ នៅមន្ទីរពេទ្យខេត្តកំពង់ចាម មានសូចនាករពាក់ព័ន្ធផ្នែកសំខាន់ ត្រូវបានវាយតម្លៃ រួមមាន÷ ១) ការបង្ការ និងការត្រួតពិនិត្យការចម្លងមេរោគ ២) ការអនុវត្តអនាម័យដៃរបស់បុគ្គលិកពេទ្យ អ្នកជំងឺសម្រាកពេទ្យ និងគ្រួសារអ្នកជំងឺ និង ៣) សុវត្ថិភាពចំណីអាហារសម្រាប់អ្នកជំងឺ

[៤៦] សៀវភៅគោលការណ៍ណែនាំស្តីពី ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគសម្រាប់មូលដ្ឋានព្យាបាល និងថែទាំសុខភាព បោះពុម្ពឆ្នាំ២០១៧។

[៤៧] មន្ទីរពេទ្យខេត្តកំពង់ចាម, លិខិតបង្គាប់ការស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យនិងបង្ការការចម្លងរោគ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

[៤៨] មន្ទីរពេទ្យខេត្តកំពង់ចាម, ឯកសារស្តីពីតួនាទីរបស់ក្រុមត្រួតពិនិត្យនិងការបង្ការការចម្លងរោគ។

[៤៩] មន្ទីរពេទ្យខេត្តកំពង់ចាម, លិខិតបង្គាប់ការស្តីពីការបង្កើតក្រុមការងារសម្រាប់ចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារការពារការចម្លងរោគប្រចាំមន្ទីរពេទ្យ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨។

សម្រាកពេទ្យ។

៣.២.២.១. ការបង្ការ និងការត្រួតពិនិត្យការចម្លងមេរោគ

នៅចំណុចនេះមានការលើកឡើងអំពី ១)កន្លែងស្មើរលនិងផ្តត់ផ្តង់កណ្តាល ២)ការចាក់ថ្នាំមានសុវត្ថិភាព ៣)ការប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់គ្រប់គ្រងសំណល់ពីមូលដ្ឋានសុខាភិបាល និង ៤)ការអនុវត្តផែនការគ្រប់គ្រងសំណល់របស់មន្ទីរពេទ្យ។

នៅក្នុងការអនុវត្តន្វវការបង្ការនិងទប់ស្កាត់ការចម្លងរោគមន្ទីរពេទ្យមានផ្នែកស្មើរល (Stérile) និងផ្តត់ផ្តង់កណ្តាលមួយកន្លែងដែលជាជំនួយរបស់ប្រទេសជប៉ុន មានស្តង់ដាអនាម័យ និងមានទីតាំងនៅក្បែរផ្នែកវះកាត់ ប្រើប្រាស់សម្រាប់ការធ្វើស្មើរល និងផ្តត់ផ្តង់សម្ភារស្មើរល និងរក្សាទុកន្វវបរិក្ខារសម្រាប់វះកាត់នៅមន្ទីរពេទ្យ។ សព្វថ្ងៃនេះ មន្ទីរពេទ្យមានស្មើរលអូតូក្លាវតូច ស្មើរលអូតូក្លាវជប៉ុន និងស្មើរលអូតូក្លាវធំ នៅផ្នែកស្មើរលនិងផ្តត់ផ្តង់កណ្តាល។ សម្រាប់រយៈពេល (ការដុត ការស្មើរល និងការសម្ងួត) និងកម្តៅប្រើប្រាស់សម្រាប់ឧបករណ៍ទាំងបីមានដូចជា ស្មើរលតូចត្រូវប្រើរយៈពេល១ម៉ោង២០នាទី ក្រោមកម្តៅ១២០អង្សា ស្មើរលអូតូក្លាវជប៉ុនប្រើរយៈពេល១ម៉ោង០៥នាទី ក្រោមសីតុណ្ហភាព ២បារ និងស្មើរលធំប្រើរយៈពេល២ម៉ោង២០នាទី ក្រោមកម្តៅ១២០អង្សារ។ ឧបករណ៍ទាំងបីនេះ ត្រូវបានប្រើប្រាស់ទៅតាមដំហានផ្សេងៗគ្នា ហើយឯកសារណែនាំពីរយៈពេល កម្តៅ សីតុណ្ហភាពក៏ផ្សេងគ្នាដែរ[៥០]។ ដើម្បីជាជំនួយស្មារតីបន្ថែមសម្រាប់គ្រូពេទ្យនៅផ្នែកនេះ មន្ទីរពេទ្យបានបិទផ្ទាំងក្រដាសស្តីពីដំហាននៃការធ្វើស្មើរលនៅលើជញ្ជាំងនៃផ្នែកស្មើរលផ្ទាល់។

ពាក់ព័ន្ធទៅនឹងចំណុចការបង្ការ និងទប់ស្កាត់ការចម្លងរោគនេះដែរ មន្ទីរពេទ្យក៏មានកន្លែងបោកគក់កណ្តាលនៅដាច់ដោយឡែកពីកន្លែងធ្វើឱ្យស្ងួត (សម្ងួត) និងវេចខ្ចប់សម្ភារស្មើរលផងដែរ។ គ្រប់ផ្នែកនៃមន្ទីរពេទ្យបានយកបរិក្ខារទាំងអស់ដែលត្រូវធ្វើស្មើរលមក

[៥០] ការចុះប្រមូលទិន្នន័យ និងការសម្ភាសន៍លោកស្រីវេជ្ជបណ្ឌិត ចាប់ ច័ន្ទធិតា អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ថ្ងៃទី០១ និងទី០២ ខែកក្កដា ឆ្នាំ២០២០ នៅមន្ទីរពេទ្យខេត្តកំពង់ចាម។

ផ្នែកស្នេរីល និងផ្គត់ផ្គង់កណ្តាល ហើយបន្ទប់ផ្តល់និងទទួលសម្ភារស្នេរីលមានទីតាំងនៅបន្ទប់ដាច់ដោយឡែកពីគ្នា។ មន្ទីរពេទ្យអនុវត្តទៅតាមជំហាននៃទម្រង់ការដើម្បីបង្ការការឆ្លងរាលដាលនៃការចម្លងរោគពីបរិក្ខារ និងឧបករណ៍ដែលយកមកប្រើឡើងវិញដោយជំហានទាំងនោះរួមមាន÷ ការត្រាំជម្រះមេរោគ ការលាងសម្អាត ការសម្ងួត ការវេចខ្ចប់ ការធ្វើស្នេរីល ការទុកឱ្យត្រជាក់ និងការរក្សាទុកសម្ភារ។ សម្ភារប្រអប់អាចរក្សាទុកបាន ១ខែ ហើយសម្ភារកញ្ចប់ ឬក្រណាត់ រក្សាទុកបាន១សប្តាហ៍។ ករណីហួសពេលដែលកំណត់នេះ បុគ្គលិកមន្ទីរពេទ្យនឹងយកសម្ភារទាំងនោះមករំងាប់មេរោគជាថ្មីឡើងវិញ។

ចំពោះការចាក់ថ្នាំដែលមានសុវត្ថិភាព មន្ទីរពេទ្យបានអនុវត្តតាមមគ្គទេសក៍ស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំរបស់ក្រសួងសុខាភិបាល[៥១]។ ដើម្បីធានាឱ្យបាននូវការចាក់ថ្នាំមានសុវត្ថិភាព មុនចាក់ថ្នាំ បុគ្គលិកមន្ទីរពេទ្យខេត្តកំពង់ចាមបានផ្ទៀងផ្ទាត់តាមភាពត្រឹមត្រូវទាំងដប់នៃការចាក់ថ្នាំ ដែលរួមមាន÷ ១)អ្នកជំងឺត្រឹមត្រូវ ២)ឱសថត្រឹមត្រូវ ៣)រូបមន្តត្រឹមត្រូវ ៤)ឧបករណ៍សម្រាប់ចាក់ត្រឹមត្រូវ ៥)កម្រិតប្រើត្រឹមត្រូវ ៦)ពេលវេលាត្រឹមត្រូវ ៧)ផ្លូវចាក់ត្រឹមត្រូវ ៨)កត់ត្រាត្រឹមត្រូវ ៩)ការរក្សាទុកត្រឹមត្រូវ និង១០)ការបោះចោលត្រឹមត្រូវ ។ ជាពិសេសទៅទៀត មន្ទីរពេទ្យក៏បានបិទវិធាននៃភាពត្រឹមត្រូវទាំង១០ នៃការចាក់ថ្នាំនៅតាមបន្ទប់ចាក់ថ្នាំនីមួយៗ។

ការគ្រប់គ្រងសំណល់ដែលកើតចេញពីសេវាថែទាំសុខភាព ជាកិច្ចការអាទិភាពមួយរបស់មូលដ្ឋានព្យាបាលនិងថែទាំសុខភាពដើម្បីឈានទៅកាត់បន្ថយការចម្លងរោគនៅនឹងកន្លែង និងនៅក្នុងសហគមន៍។ នៅចំណុចនេះ មន្ទីរពេទ្យបានរៀបចំជារបាយការណ៍បញ្ជីផ្ទៀងផ្ទាត់សំណល់ប្រចាំខែនីមួយៗ ដោយមានរៀបរាប់ពីប្រភេទសំណល់ បរិមាណនៃការប្រើប្រាស់តាមផ្នែកនីមួយៗ និងជាពិសេសមានបរិមាណជាគីឡូក្រាម និងជាលីត្រ[៥២]។ ជាក់ស្តែងនៅក្នុងខែមករា ឆ្នាំ២០២០ បរិមាណសំណល់មន្ទីរពេទ្យខេត្តកំពង់ចាម ដូចមាន

[៥១] សៀវភៅកម្មវិធីសិក្សាស្តីអំពី សុវត្ថិភាពនៃការចាក់ថ្នាំ (ការចាក់បញ្ចូលតាមសរសៃវៃន) សម្រាប់សិក្ខាកាម និងសៀវភៅកម្មវិធីសិក្សាស្តីពី សុវត្ថិភាពនៃការចាក់ថ្នាំ សម្រាប់សិក្ខាកាម បោះពុម្ពនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧។

[៥២] មន្ទីរពេទ្យខេត្តកំពង់ចាម, របាយការណ៍សំណល់ ប្រចាំឆ្នាំ២០១៨។

រៀបរាប់ក្នុងតារាង ៣.១។

តារាង ៣.១ ស្តីពីសំណល់នៅមន្ទីរពេទ្យខេត្តកំពង់ចាម ប្រចាំខែមករា ឆ្នាំ២០២០

ល.រ	ប្រភេទសំណល់	គីឡូក្រាម	លីត្រ
១	សំណល់ទូទៅ	៩៣៨០	៤
២	សំណល់ឆ្លងរោគ (រាវ និងរឹង)	១២៥១	៤០២
៣	សំណល់ពីសរីរាង្គ	៤៦៧	០
៤	សំណល់មុតស្រួច	៨១៥៦	០
៥	សំណល់ឱសថ	៧៥០៥	០
៦	សំណល់គីមី	៤៨	៦០

ប្រភព÷ មន្ទីរពេទ្យខេត្តកំពង់ចាម. របាយការណ៍សំណល់ប្រចាំខែមករា ឆ្នាំ២០២០

ជារួម បញ្ជីផ្ទៀងផ្ទាត់នេះជួយឱ្យមន្ទីរពេទ្យរៀបចំផែនការគ្រប់គ្រងសំណល់និងការកម្ទេចសំណល់ វិជ្ជសាស្ត្របានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

បន្ថែមពីលើបញ្ជីផ្ទៀងផ្ទាត់គ្រប់គ្រងសំណល់ មន្ទីរពេទ្យបានរៀបចំនូវផែនការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ និងសំណល់ទូទៅក្នុងមូលដ្ឋានសុខាភិបាលជាប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ[៥៣]។ ក្នុងផែនការនេះ មន្ទីរពេទ្យបានបញ្ជាក់ពីសកម្មភាព អ្នកទទួលខុសត្រូវ ពេលវេលា និងប្រភពធនធាន។ សម្រាប់សកម្មភាពគ្រប់គ្រងសំណល់រួមមាន÷ ១)ការញែកសំណល់ ២)ការប្រមូលសំណល់ចេញពីបន្ទប់ ៣)ការរក្សាទុកកាកសំណល់បណ្តោះអាសន្ន និង ៤)ការដុត និងបោះចោលចុងក្រោយ។ ចំពោះការញែកសំណល់ មន្ទីរពេទ្យបែងចែកសំណល់ចេញជា ៦ ប្រភេទ រួមមាន÷ សំណល់ទូទៅ សំណល់ឆ្លងរោគ (រាវ និងរឹង) សំណល់ពីសរីរាង្គ សំណល់មុតស្រួច សំណល់ឱសថ និងសំណល់គីមី។

មន្ទីរពេទ្យបានរៀបចំនូវធុងដាក់សំណល់ទៅតាមប្រភេទនីមួយៗ ក្នុងនោះធុងពណិ

[៥៣] មន្ទីរពេទ្យខេត្តកំពង់ចាម, ផែនការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ មន្ទីរពេទ្យខេត្តកំពង់ចាម ឆ្នាំ២០១៨ និងផែនការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ និងសំណល់ទូទៅក្នុងមូលដ្ឋានសុខាភិបាល ត្រីមាសទី១ ឆ្នាំ២០១៩។

បៃតងសម្រាប់សំណល់ទូទៅ និងមានថង់ពណ៌ខ្មៅនៅពីក្នុងធុង ធុងពណ៌លឿងសម្រាប់សំណល់ឆ្លងរោគ និងមានថង់ប្លាស្ទិកពណ៌លឿង និងសរសេរអក្សរខ្មៅថា «ឆ្លងរោគ» ទាំងនៅលើធុង ទាំងនៅលើថង់។ ចំពោះសំណល់ពីសរីរាង្គមនុស្ស មន្ទីរពេទ្យប្រើប្រាស់ធុងពណ៌លឿង មានថង់ប្លាស្ទិកពណ៌លឿងសរសេរអក្សរពណ៌ក្រហមថា «សរីរាង្គ» ទាំងនៅលើធុង និងនៅលើថង់។ រីឯសំណល់មុតស្រួច មន្ទីរពេទ្យបានរៀបចំដាក់ក្នុងប្រអប់ក្រដាសស្ងិត ធន់នឹងការមុត មានសុវត្ថិភាព និងដាក់ក្នុងធុងពណ៌លឿង ឬពណ៌ស និងសរសេរអក្សរថា «មុតស្រួច»។ ដោយហេតុថាមន្ទីរពេទ្យមិនមានប្រអប់សុវត្ថិភាពគ្រប់គ្រាន់តាមតម្រូវការ មន្ទីរពេទ្យបានកែច្នៃឡាំងក្រដាស និងពីដុងជំរាជាប្រអប់សុវត្ថិភាពសម្រាប់បំពេញការខ្វះខាតនេះ។

ក្រៅពីកិច្ចការលើកឡើងខាងលើ មន្ទីរពេទ្យបានបិទប័ណ្ណណែនាំពីការញែកសំណល់និងខិតខំយ៉ាងណាធានាឱ្យបាននូវការញែកសំណល់នៅគ្រប់ផ្នែក គ្រប់បន្ទប់ និងដាក់ធុងសំរាម និងថង់ខាងក្នុងគ្រប់គ្រាន់នៅតាមសាលនីមួយៗ។

រីឯការប្រមូលសំណល់ចេញពីបន្ទប់ ជាទូទៅមន្ទីរពេទ្យបានប្រមូលសំណល់ចេញពីបន្ទប់យ៉ាងតិចមួយដងក្នុងមួយថ្ងៃ ឬប្រមូលចេញភ្លាមៗក្រោយពីធ្វើទម្រង់ការវេជ្ជសាស្ត្រ ឬនៅពេលសំណល់ជិតពេញធុង ឬពេញប្រអប់សុវត្ថិភាពបាន ៣/៤នៃធុង ឬប្រអប់។ បុគ្គលិកអនាម័យបានប្តូរធុងថ្មី និងមិនផ្ទេរសំណល់ចេញពីធុងមួយទៅធុងមួយទៀតទេ ទោះបីជាប្រភេទសំណល់ដូចគ្នាក្តី។ រាល់ពេលបំពេញការងារ បុគ្គលិកអនាម័យបានប្រើប្រាស់ឧបករណ៍ការពារខ្លួនទៅតាមវិធានអនាម័យ។

ចំណែកឯការរក្សាទុកកាកសំណល់បណ្តោះអាសន្ន ក្នុងករណីដែលមិនអាចបោះចោលឱ្យបានឆាប់ មន្ទីរពេទ្យបានរក្សាទុកសំណល់មួយរយៈមុននឹងចោល។ ការទុកបណ្តោះអាសន្នមានរយៈពេលខ្លី ពោលគឺមួយថ្ងៃ ឬពីរថ្ងៃប៉ុណ្ណោះ។ មន្ទីរពេទ្យបានរក្សាទុកសំណល់បណ្តោះអាសន្ន នៅក្នុងរោងដែលមានជំបូល ជញ្ជាំង និងរបងព័ទ្ធជុំវិញ ហើយសំណល់ទូទៅ និងសំណល់វេជ្ជសាស្ត្រត្រូវបានរក្សាទុកនៅទីតាំងដាច់ដោយឡែកពីគ្នា។

ចំពោះការបោះចោលចុងក្រោយ គឺជាដំណើរការនៃការដឹកជញ្ជូនសំណល់ទូទៅមិនឆ្លងរោគចេញពីមន្ទីរពេទ្យ និងកាកសំណល់ឆ្លងរោគដើម្បីកម្ទេចចោល។ សម្រាប់សំណល់ទូទៅ មន្ទីរពេទ្យបានយកទៅចោលនៅកន្លែងរោងសំរាមរបស់មន្ទីរពេទ្យផ្ទាល់ដែលមានទ្វារបិទ និងរង់ចាំក្រុមហ៊ុនប្រមូលសំរាមស៊ីនទ្រីដឹកចេញ។ ជារៀងរាល់ឆ្នាំ មន្ទីរពេទ្យបានធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនស៊ីនទ្រី។ កិច្ចសន្យានេះជួយធានានូវការប្រមូលសំណល់ទូទៅពីមន្ទីរពេទ្យបានទៀងទាត់ និងទាន់ពេលវេលា។ ចំណែកឯសំណល់វេជ្ជសាស្ត្រត្រូវបានប្រមូលពីផ្នែកនានាដាក់ក្នុងរោងសុវត្ថិភាព ដើម្បីត្រៀមដុតកម្ទេចក្នុងឡដុតសំណល់ទំនើបមួយ។ ឡដុតសំណល់នេះផលិតមកមានស្តង់ដាគ្រប់គ្រាន់ និងអាចដុតកម្តៅខ្ពស់លើសពី ៨០០ អង្សារ។ ចំពោះសំណល់សុកវិញ មន្ទីរពេទ្យបានរៀបចំទុកដាក់ក្នុងរណ្តៅសុកដែលមានទីតាំងក្នុងបរិវេណផ្នែកខាងក្រោយនៃមន្ទីរពេទ្យ និងនៅដាច់ដោយឡែកពីគេ។

ដើម្បីធានាការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រមានសុវត្ថិភាព មន្ទីរពេទ្យតែងធ្វើការតាមដាន ត្រួតពិនិត្យ ការចាត់ចែងសំណល់ដោយប្រើបញ្ជីផ្ទៀងផ្ទាត់២ដងក្នុងមួយសប្តាហ៍ មានការប្រជុំផ្សព្វផ្សាយការចាត់ចែងសំណល់ដល់បុគ្គលិក និស្សិតចុះកម្មសិក្សា អ្នកជំងឺ និងគ្រួសារអ្នកជំងឺនៅពេលព្រឹក ជារៀងរាល់ថ្ងៃ។ គួរបញ្ជាក់ថា មន្ទីរពេទ្យបានរៀបចំវគ្គបណ្តុះបណ្តាលរំលឹកស្តីពីការគ្រប់គ្រង និងការចាត់ចែងសំណល់នៅតាមផ្នែកនីមួយៗផងដែរ[៥៤]។

៣.២.២.២. ការអនុវត្តអនាម័យដៃរបស់បុគ្គលិកពេទ្យ អ្នកជំងឺសម្រាកពេទ្យ និងអ្នកកំសរ

អនាម័យដៃគឺជាផ្នែកសំខាន់មួយនៃការងារបង្ការការចម្លងមេរោគនៅក្នុងមូលដ្ឋានព្យាបាល និង ថែទាំសុខភាព។ មន្ទីរពេទ្យតែងបានរៀបចំកម្មវិធីបណ្តុះបណ្តាលដល់បុគ្គលិកថ្មី កម្មវិធីបណ្តុះបណ្តាលបន្ថែមសម្រាប់បុគ្គលិកចាស់ និងមានកម្មវិធីផ្សព្វផ្សាយពីអនាម័យ

[៥៤] មន្ទីរពេទ្យខេត្តកំពង់ចាម, ផែនការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ និងសំណល់ទូទៅក្នុងមូលដ្ឋានសុខាភិបាល ត្រីមាសទី១ ឆ្នាំ២០១៩។

ដៃដល់អ្នកជំងឺ និងគ្រួសារអ្នកជំងឺនៅរៀងរាល់សប្តាហ៍។ ជារៀងរាល់ខែ ក្រុមត្រួតពិនិត្យ និងបង្ការការចម្លងរោគក្នុងមន្ទីរពេទ្យ បានចុះពិនិត្យលើការអនុវត្តរបស់បុគ្គលិកផ្ទាល់ចំនួន២ដង ដើម្បីធានាថាបុគ្គលិកអនុវត្តអនាម័យដៃបានល្អ។ បុគ្គលិកមន្ទីរពេទ្យមិនអនុញ្ញាតឱ្យពាក់គ្រឿងលំអនៅម្រាមដៃ (ចិញ្ចៀន) ទុកក្រចកដៃវែង ក្រចកកខ្វក់ និងលាបក្រចកដៃទេ។ ជាមួយគ្នានេះដែរ បុគ្គលិកគោរពគោលការណ៍នៃការលាងដៃតាមជំហាននីមួយៗ និងគោរពអនុវត្តទៅតាមពេលវេលាទាំង៥ សម្រាប់ការធ្វើអនាម័យដៃ ដែលរួមមាន÷ ១) មុនពេលប៉ះអ្នកជំងឺ ២) មុនពេលធ្វើទម្រង់ការអាសិបទិក ៣) ក្រោយពេលប្រឈមនឹងការប៉ះវត្ថុរាវចេញពីអ្នកជំងឺ ៤) ក្រោយពេលប៉ះអ្នកជំងឺ និង ៥) ក្រោយពេលប៉ះវត្ថុជុំវិញអ្នកជំងឺ។

ក្រៅពីនេះ រៀងរាល់ឆ្នាំ នៅចុងខែឧសភា ឬដើមខែមិថុនា មន្ទីរពេទ្យបានរៀបចំទិវា «អនាម័យដៃ»។ ដើម្បីជំរុញឱ្យទិវានេះកាន់តែមានន័យ និងទទួលបានការចូលរួមយ៉ាងសកម្ម មន្ទីរពេទ្យបានរៀបចំការប្រកួតប្រជែងលើប្រធានបទអនាម័យដៃសម្រាប់បុគ្គលិកមន្ទីរពេទ្យគ្រប់ផ្នែក។ ផ្នែកនីមួយៗបានជ្រើសរើសបុគ្គលិកឆ្នើមរបស់ខ្លួននិងបញ្ជូនសមាសភាពចូលរួមការប្រកួតនៅថ្ងៃប្រារព្ធទិវា។ មន្ទីរពេទ្យក៏បានបង្កើតគណៈកម្មការវាយតម្លៃមួយសម្រាប់ការជ្រើសរើសរកបុគ្គលិកមន្ទីរពេទ្យដែលចងចាំនូវទ្រឹស្តី នៃការលាងដៃស្អាតបានល្អ និងអនុវត្តការលាងដៃបានលឿន និងបានស្អាតជាងគេ។ ចំពោះជ័យលាភី មន្ទីរពេទ្យបានជូនជាប័ណ្ណសរសើរ និងថវិកាលើកទឹកចិត្ត។

បន្ថែមពីនេះ នៅគ្រប់ផ្នែកទាំងអស់មានរៀបចំកន្លែងលាងដៃសម្រាប់អ្នកជំងឺ មានប្រភពទឹកស្អាតពីក្បាលរ៉ូប៊ីណេ មានសាប៊ូទឹក ក្រដាសស្អាតជូតដៃ មានអាកុលយ៉ាងតិច ១/៤ នៃដប និងមានបិទឯកសារវិធាននៃការលាងដៃស្អាតនៅក្បែរនោះ។

៣.២.២.៣. សុវត្ថិភាពចំណីអាហារ

មន្ទីរពេទ្យខេត្តកំពង់ចាម បានរៀបចំន្លូវផ្ទះបាយមួយកន្លែងមានទំហំធំល្មមសមរម្យនៅបរិវេណមន្ទីរពេទ្យផ្នែកខាងក្រោយ។ បុគ្គលិកផ្ទះបាយមានចំនួន៩រូប ក្នុងនោះមាន

ប្រធានរោងបាយម្នាក់មាន តួនាទីពិនិត្យតាមដានជាប្រចាំចំពោះវិធានអនាម័យនៅក្នុងផ្ទះបាយ។ បុគ្គលិកទាំង៩នាក់រៀបចំអាហារចំនួន២ពេលក្នុងមួយថ្ងៃសម្រាប់អ្នកជំងឺសម្រាកនៅមន្ទីរពេទ្យ។ មន្ទីរពេទ្យបានណែនាំបុគ្គលិកផ្ទះបាយឱ្យរៀបចំសម្អាតផ្ទះបាយ សម្អាតសម្ភារ និងឯកសណ្ឋានការងារឱ្យបានស្អាត និងមានអនាម័យ។ មន្ទីរពេទ្យបានរៀបចំប្រព័ន្ធបង្ហូរទឹកចេញពីក្បាលរ៉ូប៊ីណេ និងមានសាប៊ូ កន្សែងជូតដៃ កន្លែងបង្ហូរសំណល់សមស្រប។ យោងទៅតាមតម្រូវការប្រចាំថ្ងៃ ផលិតផលធ្វើពីសាច់ និងទឹកដោះគោត្រូវបានប្រើប្រាស់អស់ មិនមានការទុកឆ្លងយប់ឡើយ។ បុគ្គលិកផ្ទះបាយយកចិត្តទុកដាក់ចំពោះសុវត្ថិភាពចំណីអាហារ ដូចជា ការទុកដាក់ចំណីអាហារ ពួកគាត់បានដាក់នៅលើធ្នើរ មិនដាក់លើឥដ្ឋ ឬលើដីឡើយ។

៣.២.៣. ការលើកកម្ពស់គុណភាពសេវាក្នុងមន្ទីរពេទ្យ

នៅក្នុងការលើកកម្ពស់គុណភាពនៅមន្ទីរពេទ្យខេត្តកំពង់ចាម សូចនាករ៤ ផ្នែកសំខាន់ត្រូវបានវាយតម្លៃដែលរួមមាន÷ ១) ការរៀបចំការលើកកម្ពស់គុណភាព ២) ការកែលម្អគុណភាពផ្នែកសម្ភព ៣) ការកែលម្អគុណភាពផ្នែកទារកទើបកើត/ជំងឺកុមារ និង ៤) ការកែលម្អគុណភាពផ្នែកវះកាត់។

៣.២.៣.១. ការរៀបចំការលើកកម្ពស់គុណភាព

មន្ទីរពេទ្យបានរៀបចំផែនការលើកកម្ពស់គុណភាពប្រចាំឆ្នាំ[៥៥] និងមានការពិនិត្យផែនការនោះឡើងវិញជារៀងរាល់ខែ។ នៅក្នុងផែនការសកម្មភាពមានបញ្ជាក់ពី ១) កាលានុវត្តភាពនៃការកែលម្អ ២) សកម្មភាពដើម្បីឆ្លើយតបនឹងកាលានុវត្តភាព ៣) អ្នកទទួលខុសត្រូវផ្ទាល់ និងរួម ៤) កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ ៥) ធនធាន/ថវិកា និង ៦) សូចនាករ/លទ្ធផលរំពឹងទុក។

មន្ទីរពេទ្យបានបង្កើតក្រុមការងារលើកកម្ពស់គុណភាព (Quality Improvement

[៥៥] មន្ទីរពេទ្យខេត្តកំពង់ចាម, ពង្រាងផែនការសកម្មភាពកែលម្អគុណភាពសម្រាប់មន្ទីរពេទ្យ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩។

: QI)។ ក្រុមការងារនេះត្រូវអនុវត្តតាមគោលបំណង តួនាទី និងការទទួលខុសត្រូវរបស់ខ្លួនឱ្យបានប្រសើរទៅតាមសេចក្តីណែនាំស្តីពីសំណុំសកម្មភាពបង្ក្រប់សម្រាប់អភិវឌ្ឍមន្ទីរពេទ្យឆ្នាំ២០១៤ ដើម្បីឆានាដល់ការផ្តល់សេវារបស់មន្ទីរពេទ្យខេត្តកំពង់ចាមឱ្យមានគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពដល់អ្នកជំងឺ[៥៦]។

បន្ថែមពីលើក្រុមការងារខាងលើ មន្ទីរពេទ្យក៏បានបង្កើតក្រុមការងារលើកកម្ពស់គុណភាពតាមបណ្តាផ្នែក[៥៧]។ ក្រុមការងារតាមផ្នែកនីមួយៗមានសមាសភាព ប្រធានផ្នែកជាប្រធានក្រុម និងសមាជិកមួយចំនួននៅក្នុងនោះ។ ក្រុមការងារនេះមានភារកិច្ចអនុវត្តការងារកែលម្អផ្នែករបស់ខ្លួនឱ្យបានល្អប្រសើរ។

ដើម្បីជាមូលដ្ឋាននៃការលើកកម្ពស់គុណភាព មន្ទីរពេទ្យមានពិធីសារនៃការព្យាបាលនិងគោលការណ៍ណែនាំ រក្សាទុកសម្រាប់ប្រើប្រាស់ជាប្រចាំនៅតាមផ្នែក ក្នុងនោះមានសៀវភៅគោលការណ៍ណែនាំជាតិស្តីពីការណែនាំការអនុវត្តគ្លីនិកសម្រាប់កុមារ សៀវភៅគោលការណ៍ណែនាំជាតិស្តីពីការណែនាំការអនុវត្តគ្លីនិកផ្នែកវេជ្ជសាស្ត្រ[៥៨]។

លើសពីនេះ តាមផ្នែកនីមួយៗបានរៀបចំដាក់ប្រអប់សំបុត្រនៅជញ្ជាំងតាមផ្លូវចេញចូលក្នុងអគារមន្ទីរពេទ្យ។ នៅអំឡុងពេលនៃការផ្សព្វផ្សាយ អប់រំសុខភាព និងអនាម័យអ្នកជំងឺ និងគ្រួសារអ្នកជំងឺ មន្ទីរពេទ្យបានពន្យល់ប្រាប់អ្នកជំងឺពីរបៀបប្រើប្រាស់ប្រអប់សំណូមពរខាងលើ ជាពិសេសជំរុញលើកទឹកចិត្តពួកគាត់ឱ្យសរសេរសំណូមពរដាក់ក្នុងប្រអប់សំបុត្រផងដែរ។ នៅចុងខែនីមួយៗ បន្ទាប់ពីការវិភាគព័ត៌មានពីប្រអប់សំណូមពរ ក្រុមការងារលើកកម្ពស់គុណភាពនៅតាមផ្នែកបានរៀបចំកិច្ចប្រជុំដែលមានរបៀបវារៈ

[៥៦] មន្ទីរពេទ្យខេត្តកំពង់ចាម, លិខិតបង្គាប់ការបង្កើតក្រុមការងារលើកកម្ពស់គុណភាព ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧។

[៥៧] មន្ទីរពេទ្យខេត្តកំពង់ចាម, លិខិតបង្គាប់ការបង្កើតក្រុមការងារលើកកម្ពស់គុណភាពតាមផ្នែក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧។

[៥៨] សៀវភៅ Clinical Practice Guideline for Pediatric និងសៀវភៅ Clinical Practice Guideline for Medicine របស់ក្រសួងសុខា-ភិបាល បោះពុម្ពខែមេសា ឆ្នាំ ២០១៣។

មួយចំនួនដូចជា÷ ១)រៀបរាប់ពីសកម្មភាពដែលបានអនុវត្តនៅខែកន្លងមក ដើម្បីសម្រេចបាននូវការលើកកម្ពស់គុណភាព ២)របាយការណ៍និងដំណោះស្រាយពីការបើកប្រអប់សំបុត្រប្រចាំខែ ៣)ការវាយតម្លៃការលើកកម្ពស់សេវាប្រចាំខែ ៤)សេចក្តីសន្និដ្ឋាន ការសម្រេចចិត្ត និងអនុសាសន៍ដើម្បីកែលម្អគុណភាព ៥)ការរៀបចំឯកសារជាលាយលក្ខណ៍អក្សរសម្រាប់ប្រជុំជាមួយគណៈកម្មការបច្ចេកទេស ឬគណៈកម្មការផ្សេងៗ និង៦)ផ្សេងៗ (ព័ត៌មានត្រឡប់ពីគណៈកម្មការបច្ចេកទេស/ គណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ គណៈកម្មការផ្សេងៗ នាខែកន្លងមក)។ ចំពោះបញ្ហាដែលក្រុមការងារលើកកម្ពស់គុណភាពនៅតាមផ្នែកមិនអាចដោះស្រាយបាន នឹងត្រូវស្នើសុំទៅគណៈកម្មការបច្ចេកទេស ឬគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យដើម្បីដោះស្រាយបន្ត។

៣.២.៣.២. ការកែលម្អគុណភាពផ្នែកសម្ភព

បច្ចុប្បន្ន ដោយមានការអនុញ្ញាត និងទទួលស្គាល់ពីក្រសួងសុខាភិបាល សិក្ខាកាមមកពី១១ ខេត្តបានអញ្ជើញមកទទួលការបណ្តុះបណ្តាលផ្នែកឆ្មបនៅមន្ទីរពេទ្យខេត្តកំពង់ចាម។ ជាមួយគ្នានេះ មន្ទីរពេទ្យបានរៀបចំនូវឯកសារសម្រាប់ពេទ្យឆ្មប និងរៀបចំកែសម្រួលឯកសារមួយចំនួនឱ្យមានភាពងាយស្រួលយល់ ងាយស្រួលបំពេញ និងមានព័ត៌មានអ្នកជំងឺពេញលេញ។ ចំពោះការសម្រាលកូនធម្មតាមន្ទីរពេទ្យបានពិនិត្យនិងរៀបចំឯកសារអ្នកជំងឺ។ ឯកសារទាំងនោះរួមមាន÷ ឯកសារទម្រង់សិទ្ធិអតិថិជននិងកិច្ចសន្យាទទួលសេវាដែលមានចុះហត្ថលេខារបស់គ្រូពេទ្យ អ្នកជំងឺ និងមានលេខទូរស័ព្ទយ៉ាងតិច ១លេខ ឯកសារស្ត្រីសម្រាលកូនមានទិន្នន័យតាមស្តង់ដា មានការពិនិត្យគ្លីនិកនិងការតាមដានសភាពជំងឺនិងការព្យាបាលជាប្រចាំថ្ងៃ មានការសុំធ្វើតេស្តមន្ទីរពិសោធន៍និងការពិនិត្យផ្សេងៗទៀតសម្រាប់ការធ្វើរោគវិនិច្ឆ័យគ្លីនិក និងមានឯកសារប៉ាតូក្រាហ្វ[៥៥]។

[៥៥] យោងតាមឯកសារលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគុំរូ ក្នុងវិស័យសុខាភិបាល សម្រាប់មន្ទីរពេទ្យដែលអនុវត្តសំណុំសកម្មភាពបង្ក្រប់កម្រិត៣ (CPA3)និងការសម្ភាសន៍លោកស្រីវេជ្ជបណ្ឌិត ចាប់ ច័ន្ទធិតា អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម ទទួលបន្ទុកផ្នែកវះកាត់ សម្ភព រោគស្ត្រី និងការចម្លងរោគ នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

ចំពោះការសម្រាលកូនពិបាក មន្ទីរពេទ្យបានពិនិត្យ និងរៀបចំឯកសារអ្នកជំងឺដូចជាការសម្រាលកូនធម្មតាដែរ ប៉ុន្តែគ្រាន់តែបន្ថែមឯកសារអំណះអំណាងនៃរោគវិនិច្ឆ័យ និងរៀបរាប់លម្អិតពីដំណើរការនៃការព្យាបាល។

ចំណែកឯការសម្រាលកូនដោយវះកាត់ មន្ទីរពេទ្យបានពិនិត្យ និងរៀបចំឯកសារអ្នកជំងឺដូចជាការសម្រាលកូនធម្មតា និងសម្រាលកូនពិបាកដែរ ប៉ុន្តែបានបំពេញបន្ថែមពីលើឯកសារខាងលើនូវរបាយការណ៍នៃការវះកាត់យកកូនដោយប្រើពិធីសារវះកាត់ (Operation Protocol) និងរបាយការណ៍នៃការដាក់ថ្នាំសណ្តំដោយប្រើពិធីសារដាក់ថ្នាំសណ្តំ (Anesthesia Protocol)។

៣.២.៣.៣. ការកែលម្អគុណភាពផ្នែកទារកទើបកើត/ដំណឹកុមារ

ដើម្បីធានាការកែលម្អគុណភាពផ្នែកទារក មន្ទីរពេទ្យមានផ្នែកថែទាំទារក និងបានអនុវត្តន្វការថែទាំជាសារវន្តលើទារកទើបកើតជាប្រចាំ។ ចំពោះករណីធ្ងន់ធ្ងរនៃទារកទើបកើត មន្ទីរពេទ្យមានបរិក្ខារសម្រាប់សង្គ្រោះបន្ទាន់ ដែលបរិក្ខារទាំងនោះរួមមាន÷ ១) ម៉ាសបញ្ចូលខ្យល់ (ventilation mask) ២) កែវចិញ្ចឹមទារក (incubator) ៣) ម៉ាស៊ីនសម្រួលការដកដង្ហើម (nasal CPAP) ៤) បំពង់អុកស៊ីសែន (oxygen cylinder) ៥) បំពង់ខ្យល់ដង្ហើម (Endotracheal tube) ៦) ម៉ាស៊ីនព្យាបាលដោយពន្លឺ (phototherapy) ៧) ម៉ាស៊ីនតាមដានស្ថានភាពជំងឺ (patient monitor) ៨) ម៉ាស៊ីនវាស់កម្រិតអុកស៊ីសែន (pulse oximetry) ៩) ការព្យាបាលដោយប្រើថ្នាំadrenaline និង ១០) ម៉ាស៊ីនកម្តៅទារក (Warmer)។

ក្រៅពីបរិក្ខារដែលបានរៀបរាប់ខាងលើ មន្ទីរពេទ្យក៏មានសម្ភារថែទាំទារកដែលរក្សាទុកក្នុងប្រអប់ ងាយយកមកប្រើ និងស្ថានភាពល្អ។ សម្ភារចាំបាច់ទាំងនោះរួមមាន÷ ១) ស្រោមដៃ៣គូ ២) កន្សែងឬក្រណាត់៤ផ្ទាំង (២សម្រាប់សម្ងួត ២សម្រាប់កន្លែងសង្គ្រោះ) ៣) ប្រដាប់បូមស្លេស ៤) បាឡុងសប់ខ្យល់ និងម៉ាស់ ២ (លេខ០ និងលេខ១) ៥) ស្តេតូស្កូប ៦) មួកទារក និង ៧) ដង្កៀប ឬខ្សែចងផ្ចិត។ មន្ទីរពេទ្យពិនិត្យ ថែទាំសម្ភារខាងលើជាប្រចាំ

និងធានាថានៅគ្រប់ បន្ទាប់ពីបានប្រើប្រាស់រួច។

ចំណែកឯការថែទាំជំងឺផ្នែកកុមារ មន្ទីរពេទ្យបានពិនិត្យនិងរៀបចំឯកសារអ្នកជំងឺ ដែលឯកសារទាំងនោះរួមមាន ឯកសារទម្រង់សិទ្ធិអតិថិជន និងកិច្ចសន្យាទទួលសេវា ឯកសារអ្នកជំងឺមានទិន្នន័យ តាមស្តង់ដានិងព្យាបាលប្រចាំថ្ងៃ ឯកសារធ្វើតេស្តមន្ទីរពិសោធន៍ និងការពិនិត្យផ្សេងៗទៀត និងមានអំណះអំណាងនៃរោគវិនិច្ឆ័យគ្លីនិក និងការរៀបរាប់លម្អិតពីដំណើរការព្យាបាល។

៣.២.៣.៤. ការកែលម្អគុណភាពផ្នែកវះកាត់

សម្រាប់ការកែលម្អគុណភាពផ្នែកវះកាត់ ក្រៅពីពិនិត្យនិងរៀបចំឯកសារទូទៅសម្រាប់អ្នកជំងឺ មន្ទីរពេទ្យបានបំពេញអំណះអំណាងគ្លីនិកនៃការវះកាត់ ឬយុទ្ធសាស្ត្រនៃការព្យាបាល មានរបាយការណ៍នៃការវះកាត់ និងរបាយការណ៍ដាក់ថ្នាំសណ្តំដែលប្រើប្រាស់នូវទម្រង់ស្តង់ដារ និងមានការតាមដានសភាពជំងឺ និងការព្យាបាលជាប្រចាំថ្ងៃ។ មន្ទីរពេទ្យក៏បានកត់ត្រាទុកនូវមុខរបួសក្រោយការវះកាត់ទោះបីមានការបង្ករោគ ឬមិនមានការបង្ករោគក្តី។

ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាព ក្រុមវះកាត់នីមួយៗបានហាត់សមសមត្ថភាពជាប្រចាំក្នុងការប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ថ្នាក់ជាតិស្តីពីសុវត្ថិភាពនៃការវះកាត់ (មុនពេលដាក់ថ្នាំសណ្តំ មុនពេលវះកាត់ និងមុនពេលបញ្ជូនអ្នកជំងឺចេញពីបន្ទប់វះកាត់)[៦0] និងបានពិនិត្យតាមដានជាប្រចាំនូវការអនុវត្តសុវត្ថិភាពនៃការវះកាត់ក្នុងបន្ទប់វះកាត់ ក្រោមការត្រួតពិនិត្យពីប្រធានក្រុមវះកាត់។

៣.២.៤. លទ្ធផលនៃការអនុវត្តការលើកកម្ពស់គុណភាពសេវាក្នុងមន្ទីរពេទ្យ

តាមទិន្នន័យដែលទទួលបាន[៦1]បង្ហាញថា អ្នកគ្រូ លោកគ្រូពេទ្យនៅមន្ទីរពេទ្យខេត្តកំពង់ចាម÷ ១) មានភាពរួសរាយរាក់ទាក់ និងសិរិយាបថល្អក្នុងការបំពេញវិជ្ជាជីវៈ ២) បាន

[៦0] មន្ទីរពេទ្យខេត្តកំពង់ចាម, បញ្ជីផ្ទៀងផ្ទាត់សុវត្ថិភាពនៃការវះកាត់។

[៦1] របាយការណ៍វាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យសុខាភិបាល និងការសម្ភាសន៍អ្នកជំងឺ/គ្រួសារអ្នកជំងឺផ្ទាល់ និងតាមរយៈទូរស័ព្ទ ចំនួន ២២នាក់ នៅផ្នែក ជំងឺកុមារ ជំងឺទូទៅ ផ្នែកវះកាត់ និងផ្នែកសម្ភព នាថ្ងៃទី៣0 ខែមិថុនា ឆ្នាំ២0២0 ថ្ងៃទី0១ ខែកក្កដា ឆ្នាំ២0២0 នៅមន្ទីរពេទ្យខេត្តកំពង់ចាម។

វាស់កម្តៅ និងពិនិត្យរាងកាយអ្នកជំងឺទៀងទាត់ ៣)បានពន្យល់ពីស្ថានភាពជំងឺក្បោះក្បាយ ៤)បានពន្យល់ពីវិធានការការពារដល់អ្នកជំងឺ ៥)បានផ្តល់ឱកាសដល់អ្នកជំងឺ/គ្រួសារអ្នកជំងឺសាកសួរពីអាការៈជំងឺ និង ៦)ផ្តល់សេវាបានល្អ និងមានតម្លៃសមរម្យ។

បន្ថែមពីនេះទៀត អ្នកជំងឺស្នាក់នៅមន្ទីរពេទ្យមានការពេញចិត្តចំពោះអនាម័យនៅក្នុងបន្ទប់ និងនៅក្រៅបន្ទប់ ព្រោះហេតុផលថា បុគ្គលិកអនាម័យសម្អាតជាញឹកញាប់ មានបង្គន់ បន្ទប់ងូតទឹកគ្រប់គ្រាន់ បន្ទប់បោកគក់នៅដាច់ដោយឡែកពីគ្នា និងជាពិសេសមានកន្លែងហាលសំលៀកបំពាក់អ្នកជំងឺ។

បើទោះមានចំណុចវិជ្ជមានជាច្រើនដូចការរៀបរាប់ខាងលើ មានអ្នកជំងឺដែលធ្លាប់ស្នាក់នៅមន្ទីរពេទ្យមួយចំនួនក៏បានលើកឡើងពីចំណុចខ្វះខាតតិចតួចដូចជា ផ្នែកជំងឺកុមារពេលប្តូរវេនយាមពេលយប់ គ្រូពេទ្យមានការយឺតយ៉ាវក្នុងការមកពិនិត្យ។ ត្រង់ចំណុចនេះមន្ទីរពេទ្យទទួលស្គាល់ថា សព្វថ្ងៃនេះបើទោះបីជាមន្ទីរពេទ្យប្រឹងប្រែងបម្រើសេវាជូនប្រជាពលរដ្ឋ ក៏មន្ទីរពេទ្យជៀសមិនផុតពីបញ្ហាតូចៗដែលកើតមានឡើងក្នុងមូលដ្ឋានរបស់ខ្លួន។ ជាដំណោះស្រាយ មន្ទីរពេទ្យតែងលើកទឹកចិត្តអ្នកជំងឺឱ្យចូលរួមប្រើប្រាស់ប្រអប់សំបុត្រសំណូមពរដែលជាមូលដ្ឋានដល់ផ្នែកពាក់ព័ន្ធធ្វើការកែលម្អសេវាគុណភាពមន្ទីរពេទ្យឱ្យកាន់តែល្អបន្ថែមទៀត។





មជ្ឈមណ្ឌលផ្តល់ឈាម



មន្ទីរពិសោធន៍



ឧបករណ៍នៅផ្នែកស្តេរីលនិងផ្តត់ផ្តង់កណ្តាល



ឧបករណ៍នៅផ្នែកថែទាំទារក



សកម្មភាពនៅផ្នែកចក្ខុរោគ



ការអប់រំស្តីពីអនាម័យដល់អ្នកកំដរនិងអ្នកជំងឺ



ការអនុវត្តអនាម័យដៃរបស់បុគ្គលិកពេទ្យ

៣.៣. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់មន្ទីរពេទ្យខេត្តកំពង់ចាម

រាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ[៦២] ជាកម្មវិធីកែទម្រង់រយៈពេលវែង ដែលមានចក្ខុវិស័យប្រកបដោយមហិច្ឆតា និងប្រាកដនិយម គឺផ្លាស់ប្តូរប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាឆ្ពោះទៅស្តង់ដាអន្តរជាតិ។ ការផ្លាស់ប្តូរប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ មាន ន័យថា ការផ្លាស់ប្រព័ន្ធហិរញ្ញវត្ថុដែលមានលក្ខណៈបែបមជ្ឈការ/ ផ្តោតលើធាតុចូលឆ្ពោះទៅប្រព័ន្ធហិរញ្ញវត្ថុបែបវិមជ្ឈការ/ ផ្តោតលើសមិទ្ធកម្ម។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះត្រូវ ប្រកាន់ខ្ជាប់តាមអភិក្រមជាខឿន និងបែងចែកចេញជាបួនដំណាក់កាល រួមមាន÷

- ដំណាក់កាលទី១ “ភាពជឿទុកចិត្តបាននៃថវិកា” ពីឆ្នាំ២០០៥-២០០៨
- ដំណាក់កាលទី២ “គណនេយ្យភាពហិរញ្ញវត្ថុ” ពីឆ្នាំ២០០៩-២០១៥
- ដំណាក់កាលទី៣ “ការផ្សារភ្ជាប់ថវិកានិងគោលនយោបាយ” ពីឆ្នាំ២០១៦-២០២០
- ដំណាក់កាលទី៤ “គណនេយ្យភាពសមិទ្ធកម្ម” ពីឆ្នាំ២០២១-២០២៥។

ក្នុងន័យនេះ ការវាយតម្លៃមន្ទីរពេទ្យបង្អែកគំរូ ត្រូវបានរៀបចំឡើង ដើម្បីរួមចំណែកក្នុងការសម្រេចបាននូវទិសដៅរួមចំនួន៣ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន÷

- ***ប្រុណាភាពវិន័យថវិកា*** ត្រូវបានឆ្លុះបញ្ចាំងតាមរយៈវិសាលភាពគ្របដណ្តប់នៃឯកសារថវិកា និងលទ្ធភាពនៃវិភាជន៍ថវិកាទៅតាមផែនការ។
- ***ប្រសិទ្ធភាពនៃថវិកា*** ទាំងក្នុងផ្នែកវិភាជន៍ ទាំងផ្នែកប្រតិបត្តិការ ឆ្លុះបញ្ចាំងពីការប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយភាពសន្សំសំចៃ ការគ្រប់គ្រងត្រឹមត្រូវ និងការប្រើប្រាស់ចំ គោលដៅ ដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយ និងកម្មវិធីរបស់ក្រសួងស្ថាប័ន និងរាជរដ្ឋាភិបាលកម្ពុជា។
- ***សំភ្ជិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ*** ឆ្លុះបញ្ចាំងធនធានសមស្រប ដើម្បីផ្តល់សេវាសាធារណៈស្របតាមតម្រូវការប្រជាពលរដ្ឋ។

[៦២] កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្នុងន័យនេះ ការវាយតម្លៃលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់មន្ទីរពេទ្យខេត្តកំពង់ចាម ត្រូវបានកំណត់ដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យរងចំនួន២ រួមមាន÷ ១)ការរៀបចំ និងអនុវត្តផែនការថវិកា និង ២)ការរៀបចំបញ្ជីសារពើភណ្ឌកត់ត្រាចំណូលចំណាយ និងរបាយការណ៍ហិរញ្ញវត្ថុ។

៣.៣.១. ការរៀបចំ និងអនុវត្តផែនការថវិកា

ការរៀបចំ និងអនុវត្តថវិកា ជាដំណើរការ២ ដាច់ដោយឡែកពីគ្នា។ ក្នុងនោះ ការរៀបចំផែនការ គឺត្រូវរៀបផែនការទាំងផ្នែកចំណូល និងចំណាយ ដោយពិនិត្យទៅលើលទ្ធភាពនៃថវិកា និងគោលដៅ ដែលត្រូវសម្រេច។ ចំណែកខាងអនុវត្តថវិកា សំដៅលើការអនុវត្តប្រតិបត្តិការថវិកា ស្របតាមផែនការដែលបានគ្រោង និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។ ដូច្នេះ ការសិក្សាទៅលើមន្ទីរពេទ្យខេត្តកំពង់ចាម បានផ្តោតលើសមាសធាតុសំខាន់២គឺ÷ ១)ការរៀបចំផែនការថវិកាទាំងផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រចាំឆ្នាំ និង ២)ការអនុវត្តថវិកា ដែលផ្តោតលើកម្មវិធីចំណូល ចំណាយតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

៣.៣.១.១. ការរៀបចំផែនការថវិកា

ការរៀបចំផែនការថវិកាជាដំណើរការនៃការរៀបចំកញ្ចប់ថវិកា សម្រាប់ការអនុវត្តនៅឆ្នាំបន្ទាប់ ដែលត្រូវផ្សារភ្ជាប់នឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងផែនការប្រតិបត្តិប្រចាំឆ្នាំ។ ក្នុងន័យនេះ ការរៀបចំផែនការថវិកា ត្រូវឆ្លុះបញ្ចាំងពីគោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ដោយផ្សារភ្ជាប់ជាមួយលទ្ធផលក្នុងឆ្នាំ សូចនាករសមិទ្ធកម្មគន្លឹះ និងគោលដៅ ដែលបានកំណត់ដោយក្រសួងសុខាភិបាល។

ការរៀបចំផែនការថវិកានេះ ត្រូវអនុលោមតាមសារាចរណែនាំប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំ និងការណែនាំលម្អិតពីក្រសួងសុខាភិបាលនិងមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

អនុលោមតាមសារាចរណែនាំប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រថវិកា ជា÷ ១) ឧបករណ៍សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ២) ការរៀបចំអាទិភាពចំណាយឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ៣) ការធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ ៤) មូលដ្ឋានសម្រាប់ពន្យល់ និងបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់អនុវត្តគោលនយោបាយ និង ៥) មូលដ្ឋានសម្រាប់ការរៀបចំនិងវិភាជន៍ថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។ ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិកាត្រូវតែឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួងសុខាភិបាល កម្មវិធីច្បាស់លាស់ សូចនាករ និងគោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តកម្មវិធីសមស្របនឹងទំហំថវិកា និងលទ្ធភាពថវិកាដែលមាន។

ក្នុងនោះ គំរូផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិលបានគ្របដណ្តប់៦ផ្នែកសំខាន់ៗ រួមមាន÷ ១) សេចក្តីផ្តើម ២) គោលបំណងគោលនយោបាយ ៣) កម្មវិធី ៤) ការកំណត់សូចនាករនិងគោលដៅសូចនាករសម្រាប់តាមដាននិងវាស់លទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធីនីមួយៗ ៥) ការកំណត់ធនធាន និង ៦) សេចក្តីសន្និដ្ឋាន។

ប៉ុន្តែក្នុងចំណុចនេះ មន្ទីរពេទ្យខេត្តកំពង់ចាមមិនទាន់បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិលនេះទេ ដោយមន្ទីរពេទ្យបានលើកឡើងថា ផែនការយុទ្ធសាស្ត្រថវិកានេះត្រូវបានរៀបចំឡើងដោយមន្ទីរសុខាភិបាលខេត្តកំពង់ចាមជារៀងរាល់ឆ្នាំ។ ទោះជាយ៉ាង-ណាក៏ដោយ មន្ទីរពេទ្យក៏បានរៀបចំជាផែនការយុទ្ធសាស្ត្រ ដោយបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ដូចបានរៀបរាប់ក្នុងចំណុចនៃការរៀបចំផែនការខាងលើ។

ការរៀបចំផែនការថវិកាប្រចាំឆ្នាំ ត្រូវបានរៀបចំស្របតាមទម្រង់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមការពិភាក្សាជាមួយគ្រប់ផ្នែកទាំងអស់របស់មន្ទីរពេទ្យ។ មុនពេលរៀបចំជាផែនការថវិកាប្រចាំឆ្នាំ មន្ទីរពេទ្យខេត្តកំពង់ចាមបានប្រមូលទិន្នន័យពីគ្រប់ផ្នែកទាំងអស់

របស់មន្ទីរពេទ្យលើផែនការ និងតម្រូវការនាឆ្នាំបន្ទាប់ និងបានរៀបចំជាកិច្ចប្រជុំរៀបចំផែនការ ក្រោមការដឹកនាំដោយលោកប្រធានមន្ទីរពេទ្យ និងមានការចូលរួមពីបុគ្គលិកគ្រប់ផ្នែកទាំងអស់របស់មន្ទីរពេទ្យ។ បន្ទាប់ពីកិច្ចប្រជុំ មន្ទីរពេទ្យបានរៀបចំជាកំណត់ហេតុ និងចាប់ផ្តើមរៀបចំផែនការថវិកា ស្របតាមទម្រង់ដែលបានណែនាំដូចក្នុងសារាចរណែនាំរបស់រាជរដ្ឋាភិបាល។

ដំណាក់កាលនៃការរៀបចំផែនការថវិការបស់មន្ទីរពេទ្យខេត្តកំពង់ចាម



នៅក្នុងផែនការថវិកាប្រចាំឆ្នាំ មន្ទីរពេទ្យបានរៀបចំជាផែនការចំណូល ចំណាយតាមទម្រង់ដូចមានកំណត់ក្នុងសារាចរណែនាំលើការរៀបចំថវិកា ក៏ដូចជារៀបចំកម្មវិធីអនុកម្មវិធី ចង្កោមសកម្មភាព អង្គភាពទទួលខុសត្រូវ សូចនាករលទ្ធផលក្នុងឆ្នាំ គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ ស្របទៅតាមទម្រង់នៃថវិកាកម្មវិធី។ មិនតែប៉ុណ្ណោះ ក្នុងគម្រោងថវិកា មន្ទីរពេទ្យបានរៀបចំជាគម្រោងចំណាយលម្អិត តាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី លម្អិតទៅដល់ចង្កោមសកម្មភាព។ ប្រសិទ្ធភាពនៃការរៀបចំផែនការថវិកានេះ ត្រូវបានវាយតម្លៃលើបែបបទ ទម្រង់ និងភាពគ្រប់ជ្រុងជ្រោយនៃកញ្ចប់ថវិកាប្រចាំឆ្នាំ។

ក្រៅពីផែនការថវិកាប្រចាំឆ្នាំ មន្ទីរពេទ្យក៏បានរៀបចំផងដែរនូវផែនការប្រតិបត្តិប្រចាំឆ្នាំទៅតាមកម្មវិធីដែលរួមបញ្ចូលទាំងផែនការថវិកា អ្នកទទួលបន្ទុកអនុវត្ត សូចនាករ

លទ្ធផល គោលដៅ និងមធ្យោបាយផ្សៀងផ្ទាត់។ ជាឧទាហរណ៍ មន្ទីរពេទ្យបានផ្តោតការអនុវត្តកម្មវិធីទី១ របស់ក្រសួងសុខាភិបាល ស្តីពីសុខភាពបន្តពូជ យុវវ័យ មាតា ទារក កុមារ និងអាហារូបត្ថម្ភ ដោយកំណត់យកអនុកម្មវិធីទី៥ ស្តីពីការងារគាំទ្រកម្មវិធីទី១ សម្រាប់ថ្នាក់រាជធានី-ខេត្ត ក្នុងចង្កោមសកម្មភាពទី៣ ស្តីពីសុខភាពមាតា និងទារក។ មន្ទីរពេទ្យក៏បានផ្ញើផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ ទៅមន្ទីរសុខាភិបាលខេត្តកំពង់ចាមបានទាន់ពេលវេលាផងដែរ[៦៣]។

ដោយផ្អែកលើផែនការដែលទទួលបានការអនុម័ត មន្ទីរពេទ្យខេត្តកំពង់ចាមក៏បានរៀបចំកម្មវិធីចំណូលចំណាយប្រចាំត្រីមាស និងស្នើទាន់ពេលវេលាផងដែរ ទៅតាមទម្រង់ដែលបានដាក់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការចុះហត្ថលេខាត្រឹមត្រូវពីប្រធានគណនេយ្យ និងប្រធានមន្ទីរពេទ្យផងដែរ។

៣.៣.១.២. ការអនុវត្តថវិកា និងប្រព័ន្ធរបាយការណ៍

ការអនុវត្តថវិកាមានប្រសិទ្ធភាពឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាពនៃការវិភាជន៍ថវិកា ស្របតាមយុទ្ធសាស្ត្រអាទិភាព និងប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងការពិនិត្យមើលគម្លាតថវិកា ដោយប្រៀបធៀបរវាងចំណូល-ចំណាយសរុបជាក់ស្តែង ធៀបនឹងថវិកាដែលបានអនុម័តប្រចាំឆ្នាំ។ ជារួម មន្ទីរពេទ្យខេត្តកំពង់ចាមបានអនុវត្តថវិការដ្ឋចន្លោះពី ៩៥%-១០០% ធៀបនឹងផែនការថវិកាក្នុងរយៈពេល៣ឆ្នាំចុងក្រោយ។

[៦៣] យោងតាមការសម្ភាសន៍ប្រធានមន្ទីរពេទ្យ និងប្រធានគណនេយ្យរបស់មន្ទីរពេទ្យ។

តារាង ៣.២ ស្តីពីចំណូល-ចំណាយរបស់មន្ទីរពេទ្យខេត្តកំពង់ចាមប្រចាំត្រីមាសទី២ ឆ្នាំ២០១៩

ឯកតា: ពាន់រៀល

ល.រ	អធិប្បាយ	សរុប	រាជរដ្ឋាភិបាល		ចំណូលពីសេវា					ផ្សេងៗ
			សាច់ប្រាក់	ឱសថ និងបរិក្ខារ	មូលនិធិសមធម៌	អ្នកជំងឺបង់ថ្លៃ	ក្រៅប្រព័ន្ធ	PKMI	បរិស	
១	សមតុល្យ សាច់ប្រាក់	៤៩៨.០០៤	-	-	១៧០.៩៨៩	២០៥.៩២០	២.៧១០	៣៤	១០៧.៧៦៣	១០.៥៨៨
២	សរុបចំណូល ក្នុងគ្រា	៦.២៤៨.០៦៦	១.៨៩០.៩៧២	២.៤៤៦.៥៨២	៦៣៩.៥៥៦	១.០៦៦.៧៤០	១១.១៤៨	២២៨	១៨៦.៨៤០	៦.០០០
៣	សរុបចំណាយ ក្នុងគ្រា	៦.១៦៩.៦៥៥	១.៨៩០.៩៧២	២.៤៤៦.៥៨២	៦៣១.៣២៥	១.០៤៧.០៣៧	៩.៧០១	១៧២	១៣៨.៨៣៤	៥.០៣២
៤	សមតុល្យ ចុងគ្រា	៥៧៦.៤១៥	-	-	១៧៩.២២០	២២៥.៦២៣	៤.១៥៧	៩០	១៥៥.៧៦៩	១១.៥៥៦

ប្រភព÷ មន្ទីរពេទ្យខេត្តកំពង់ចាម, របាយការណ៍ហិរញ្ញប្បទានសុខាភិបាលប្រចាំត្រីមាសទី២ ឆ្នាំ២០១៩

សម្រាប់មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម ក៏ដូចជាការវាយតម្លៃជារួម ផ្នែកអនុវត្តថវិកានេះ ក្រុមការងារបានពិនិត្យមើលលើសូចនាករលម្អិតចំនួន៥។ កិច្ចការដំបូងដែលត្រូវពិនិត្យ គឺការអនុវត្តចំណូលចំណាយថវិកាស្របតាមផែនការសកម្មភាព។ កម្មវិធីចំណូល-ចំណាយជាឧបករណ៍សម្រាប់កំណត់តម្រូវការធនធានប្រចាំត្រីមាស ដើម្បីផ្សារភ្ជាប់រវាងការអនុវត្តផែនការសកម្មភាពទៅនឹងគម្រោងចំណូល- ចំណាយថវិកា។ ជាទូទៅកម្មវិធីចំណូល-ចំណាយត្រូវបានរៀបចំឡើងតាមមាតិកាថវិកា។ ប៉ុន្តែសម្រាប់ការរៀបចំកម្មវិធីចំណូល-ចំណាយរបស់មន្ទីរពេទ្យ ដែលអនុវត្តថវិកាកម្មវិធី ត្រូវរៀបចំកម្មវិធីចំណូល-ចំណាយនេះ ផ្អែកទៅលើមាតិកាថវិកាផង និងផែនការសកម្មភាពផង ជា៤ត្រីមាស ដោយគម្រោងចំណូល-ចំណាយត្រូវរៀបចំទៅតាមសកម្មភាព ចង្កោមសកម្មភាពនៃអនុកម្មវិធីដោយផ្សារភ្ជាប់ជាមួយនឹងមាតិកាថវិកា។ ក្នុងករណីនេះ មន្ទីរពេទ្យខេត្តកំពង់ចាមបានរៀបចំជាគម្រោងចំណូល-ចំណាយថវិការដ្ឋជាត្រីមាស តាមមាតិកាថវិកា ដោយរំលេចនូវផែនការចំណាយជាក់ស្តែងទៅតាមត្រីមាស និងមានការចុះហត្ថលេខាទទួលស្គាល់ពីប្រធានមន្ទីរពេទ្យនៅក្នុងខែមករា។



ពាក់ព័ន្ធនឹងការអនុវត្តថវិកា កិច្ចបញ្ជិកាគណនេយ្យជាដំណើរការកត់ត្រាប្រតិបត្តិការ ហិរញ្ញវត្ថុឆ្លុះបញ្ចាំងរាល់ប្រតិបត្តិការទាំងអស់ ទាំងប្រតិបត្តិការចំណូល-ចំណាយ ទាំងការ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវបានគ្រប់គ្រងតាមរយៈការរៀបចំការកត់ត្រាត្រឹមត្រូវ និងច្បាស់លាស់ក្នុងប្រព័ន្ធកំព្យូទ័រ ក្នុងសៀវភៅគោល និងការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។ ការកត់ត្រាត្រូវបានអនុវត្តតាមមូលដ្ឋានសាច់ប្រាក់ ដោយកត់ត្រាគ្រប់ប្រតិបត្តិការដែលកើតឡើងទាក់ទងនឹងការហូរចូល និងហូរចេញសាច់ ប្រាក់ ដោយប្រើប្រាស់ប្រព័ន្ធគណនេយ្យកុំព្យូទ័រ។

ក្នុងករណីនេះ មន្ទីរពេទ្យខេត្តកំពង់ចាមបានរៀបចំជាតារាង Excel ច្បាស់លាស់ក្នុង ការកត់ត្រាប្រតិបត្តិការចំណូល និងចំណាយ ដោយបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ស្របតាម និយាមគណនេយ្យ សាធារណៈ។ តារាង Excel របស់មន្ទីរពេទ្យបានបែងចែកជាសន្លឹក (Sheet) រួមមាន÷ ១) បញ្ជីតាមដានសាច់ប្រាក់ប្រចាំថ្ងៃ ដោយកត់ត្រាទៅនឹងប្រតិបត្តិការ ចំណូល ចំណាយលម្អិត ដោយបញ្ជាក់ពីកាលបរិច្ឆេទ ខ្ទង់ចំណាយ ទំហំទឹកប្រាក់ ទៅតាម លំដាប់លំដោយនៃប្រតិបត្តិការ និង ២) បញ្ជីសាច់ប្រាក់ក្នុងធនាគារ ដោយកត់ត្រាអំពីលំហូរ ប្រតិបត្តិការហិរញ្ញវត្ថុ នៅក្នុងគណនីធនាគាររបស់មន្ទីរពេទ្យ។ តាមការអង្កេតជាក់ស្តែង បញ្ជីទាំងពីរខាងលើត្រូវបានបូកសរុប និងផ្ទៀងផ្ទាត់ច្បាស់លាស់នៅចុងគ្រានីមួយៗ និង អាចផ្តល់ជាមូលដ្ឋានក្នុងការកត់ត្រានៅគ្រាបន្ទាប់។ ក្នុងការអនុវត្តកិច្ចការហិរញ្ញវត្ថុនេះ មន្ទីរពេទ្យក៏បានបង្កើតជាផែនការ និងក្រុមការងារលទ្ធកម្ម យោងទៅតាមប្រកាសរបស់ ក្រសួងសុខាភិបាល ជាមួយនឹងការអនុវត្តតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុដែលបាន កំណត់ជាធរមាន។

បន្ថែមពីកិច្ចបញ្ជិកាគណនេយ្យ គ្រប់អង្គភាពត្រូវរៀបចំឯកសារទូទាត់ឱ្យបានច្បាស់ លាស់។ ក្នុងន័យនេះ មន្ទីរពេទ្យខេត្តកំពង់ចាមបានរៀបចំឯកសារទូទាត់បានច្បាស់លាស់ ដោយមានឯកសារភ្ជាប់ រក្សាទុក និងមានចុះហត្ថលេខាបានត្រឹមត្រូវ ជាមួយនឹងកាលបរិច្ឆេទ ច្បាស់លាស់នៃការចុះប្រតិបត្តិការ។ ក្នុងនោះ បំណុលចំណូល ចំណាយត្រូវបានកត់ត្រា និង

រក្សាទុកត្រឹមត្រូវ តាមលំដាប់លំដោយនៃការកត់ត្រា ជាមួយនឹងការកត់ត្រាចូលបញ្ជីបេឡា ជាប្រចាំថ្ងៃ តាមប្រព័ន្ធកំព្យូទ័រ និងអាចទាញចេញយកមកពិនិត្យ និងផ្ទៀងផ្ទាត់បាន។ ឯកសារ ហិរញ្ញវត្ថុទាំងនោះ ត្រូវបានរក្សាតាមក្រុណ្ឌទៅតាមលំដាប់ និងមានភាពងាយស្រួលសម្រាប់ ការប្រើប្រាស់។

ដោយសារមានកិច្ចបញ្ជិកាគណនេយ្យច្បាស់លាស់ និងមានឯកសារទូទាត់ពេញលេញ នៅក្នុងប្រតិបត្តិការនីមួយៗ មន្ទីរពេទ្យខេត្តកំពង់ចាមបានកត់ត្រាចំណូល ចំណាយបាន ច្បាស់លាស់ ជាពិសេសមានការបូកសរុបតួលេខចំណូល ចំណាយ នៅចុងការិយបរិច្ឆេទ ត្រឹមត្រូវ និងមានការចុះហត្ថលេខាទទួលស្គាល់ច្បាស់លាស់ពីប្រធានមន្ទីរពេទ្យ

ក្នុងការអនុវត្តថវិកាតាមថវិកាកម្មវិធី អង្គភាពនីមួយៗក៏តម្រូវឱ្យរៀបចំផងដែរនូវ របាយការណ៍សមិទ្ធកម្ម។ របាយការណ៍សមិទ្ធកម្មជារបាយការណ៍ ដែលឆ្លុះបញ្ចាំងពី លទ្ធផលដែលមន្ទីរពេទ្យអនុវត្តបានប្រចាំឆមាស និងប្រចាំឆ្នាំ ដោយត្រូវឆ្លុះបញ្ចាំងពីការ អនុវត្តថវិកាធៀបនឹងផែនការ សមិទ្ធកម្មសម្រេចបានធៀបនឹងសូចនាករដែលបានកំណត់ បញ្ហាប្រឈមលើការរៀបចំថវិកា និងអនុវត្តថវិកា ព្រមទាំងអនុសាសន៍សម្រាប់កែលម្អ សំដៅដោះស្រាយបញ្ហាប្រឈមទាំងឡាយដែលមាន។

ក្នុងការអនុវត្តជាក់ស្តែង មន្ទីរពេទ្យខេត្តកំពង់ចាមបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមាន÷ ១)របាយការណ៍អនុវត្តថវិកាប្រចាំខែ ២)របាយការណ៍អនុវត្តថវិកាប្រចាំ ត្រីមាស និង៣)របាយការណ៍អនុវត្តថវិកាប្រចាំឆ្នាំ ហើយបានផ្ញើទៅមន្ទីរសុខាភិបាលបាន ទៀងទាត់។ ដោយឡែក មន្ទីរពេទ្យមានការខ្វះចន្លោះលើការរៀបចំរបាយការណ៍សមិទ្ធកម្ម និងរបាយការណ៍លទ្ធផល ដោយលោកប្រធានមន្ទីរពេទ្យគ្រោងនឹងរៀបចំរបាយការណ៍ សមិទ្ធកម្មឱ្យបាននៅក្នុងឆ្នាំនេះ។ នេះបានសេចក្តីថា មន្ទីរពេទ្យមានតែរបាយការណ៍ចំណាយ ថវិកាតាមកម្មវិធីទៅតាមត្រីមាស របាយការណ៍ចំណូល-ចំណាយថវិកាហិរញ្ញប្បទានប្រចាំ ត្រីមាស បញ្ជីវិភាគតាមប្រភពថវិកា និងរបាយការណ៍ហិរញ្ញប្បទានសុខាភិបាល ដែលរួម បញ្ចូលទិន្នន័យបុគ្គលិក ព័ត៌មានអំពីការប្រើប្រាស់សេវា ព័ត៌មានហិរញ្ញវត្ថុ និងការវិភាគ

ព័ត៌មានចំណូល-ចំណាយ ដោយមិនមានរំលេចពីការអនុវត្តន៍នូវសូចនាករថវិកាកម្មវិធី ដូចក្នុងផែនការដែលបានគ្រោង។

ក្នុងការអនុវត្តថវិកានេះដែរ មន្ទីរពេទ្យមានក្តារខៀនទំហំ ១,៥ម៉ែត្រ គុណនឹង ២,៥ម៉ែត្រ សម្រាប់ ផ្តល់ព័ត៌មានផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងតួលេខថវិកាហិរញ្ញប្បទានប្រចាំខែ សម្រាប់ផ្សព្វផ្សាយជាសាធារណៈ។

៣.៣.២. ការរៀបចំបញ្ជីសារពើភណ្ឌ

ក្នុងការកត់ត្រាបញ្ជីសារពើភណ្ឌ សូចនាករចំនួន ២ ត្រូវបានសិក្សា រួមមាន÷ ១) ការកត់ត្រា និងការអនុវត្តតាមនីតិវិធីនិងគោលការណ៍ច្បាប់ជាធរមាន និង ២) ការអនុវត្តការជម្រះបញ្ជីទៅតាមគោលការណ៍ច្បាប់ជាធរមាន។

នៅក្នុងការកត់ត្រា មន្ទីរពេទ្យខេត្តកំពង់ចាមបានរៀបចំជាសៀវភៅសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋគោល ស្របតាមទម្រង់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការបញ្ជាក់ច្បាស់លាស់អំពីការកើនឬថយនៃទ្រព្យសម្បត្តិរដ្ឋ។ ក្នុងករណីនេះ មន្ទីរពេទ្យបានរៀបចំជាតារាងប្រៀបធៀប កើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋ ដោយរួមបញ្ចូលឧបសម្ព័ន្ធលម្អិត ដូចជាសម្ភារ និងគ្រឿងសង្ហារឹម គ្រឿងចក្រ និងលិខិតប្រគល់-ទទួលជាដើម ស្របតាមទម្រង់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ទន្ទឹមនេះ មន្ទីរពេទ្យខេត្តកំពង់ចាមបានអនុវត្តតាមគោលការណ៍ត្រឹមត្រូវលើការជម្រះទ្រព្យសម្បត្តិ ដោយការជម្រះបញ្ជីធ្វើឡើងដោយមានការចូលរួមពីមន្ទីរសុខាភិបាលខេត្ត រដ្ឋបាលខេត្ត តំណាងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត និងតំណាងក្រសួងសុខាភិបាល និងមានការកត់ត្រា ក៏ដូចជាបញ្ជាក់ពីរូបភាពច្បាស់លាស់ដែលបង្ហាញពីការខូចខាតទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវជម្រះបញ្ជី។



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរសុខាភិបាលខេត្តកំពង់ចាម

មន្ទីរពេទ្យខេត្ត

គម្រោងថែទាំឆ្នាំ២០១៩

ឯកសារដួចនៅ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



អង្គភាព

មន្ទីរពេទ្យខេត្ត **បង្កាន់ដៃចំណូល** លេខ.....001.....

ថ្ងៃទី...29...ខែ...01.....ឆ្នាំ ២០19.

ទទួលពី ...ឈ្មោះ ឆាយ ស្រីលាង មុខងារ .....

ចំនួនប្រាក់ជាអក្សរ ...បីរយលានរៀល.....

.....

អត្ថន័យចំណូល៖ ថ្លៃសេវាដំណើរការលើកទី ១ ថ្ងៃទី ...1/01/19

ភ្ជាប់ជាមួយ បង្កាន់ដៃបង់ប្រាក់ធនាគារ លេខ .....0339648.....សក្ខីបត្រដើម ។

ឥណពន្ធ :

ឥណទាន :

ចំនួនទឹកប្រាក់ជាលេខ

300.000.000.៛

ប្រធានមន្ទីរពេទ្យ **អ្នកពិនិត្យ** **អ្នកទទួលប្រាក់**

សាស្ត្រ. យិន ស៊ីណាត ចាន់ ឌីណា ចេង ចំណម៉ាំង្ហែន



អង្គភាព

សុខាភិបាល **បង្កាន់ដៃចំណាយ** លេខ.....1164.....

ថ្ងៃទី...04...ខែ...03...ឆ្នាំ ២០19.....

បើកជូនលោក ផ្លែ ណូដិ ស្នាងការ មុខងារ ប៉ូលិស.....

ចំនួនប្រាក់ជាអក្សរ ប្រាំរយបាតបីបួនពាន់ប្រាំពីរសែនរៀល-

.....ជាប្រាំពីរសែនរៀល.....

អត្ថន័យចំណាយ : ថ្លៃសេវាដំណើរការលើកទី ២ ថ្ងៃទី ...03/03/19

ភ្ជាប់ជាមួយ : លេខសារណ៍ចំណាយ ចុះថ្ងៃទី...03...ខែ...03... ឆ្នាំ...2019

ឥណពន្ធ : ៤៧.៣

ឥណទាន : ៥៣

ចំនួនទឹកប្រាក់ជាលេខ

៨៥៤.៥០០.[illegible]

ប្រធានមន្ទីរពេទ្យ **អ្នកពិនិត្យ** **អ្នកប្រគល់ប្រាក់** **អ្នកទទួលប្រាក់**

សាស្ត្រ. យិន ស៊ីណាត ចាន់ ឌីណា ចេង ចំណម៉ាំង្ហែន ជួន សុជាតិ

៣.៤. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព

ភាពជោគជ័យ និងភាពខ្លាំងរបស់មន្ទីរពេទ្យ អាស្រ័យលើការដឹកនាំ គ្រប់គ្រង និងចាត់ចែងធនធានមនុស្សបានល្អប្រសើរ និងមានគុណភាព។ ក្នុងន័យនេះ មន្ទីរពេទ្យខេត្តកំពង់ចាម បានផ្តោតទៅលើកត្តាធនធានមនុស្សជាចម្បង ដោយបានរៀបចំនូវយន្តការនៃការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅក្នុងមន្ទីរពេទ្យ ដើម្បីជំរុញឱ្យមន្ត្រីម្នាក់ៗបំពេញការងារកាន់តែស្ងាហាប់ មានប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។

៣.៤.១. ការគ្រប់គ្រងធនធានមនុស្ស

មន្ទីរពេទ្យបានគិតគូរអំពីការធ្វើផែនការធនធានមនុស្ស ដោយរាប់បញ្ចូលការសិក្សាវិភាគអំពីតម្រូវការធនធានមនុស្ស និងការគិតគូរពីចម្ងាយក្នុងការរៀបចំផែនការដាក់បុគ្គលិកពេទ្យ និងគ្រូពេទ្យឱ្យចូលនិវត្តន៍ ដើម្បីធានាបាននូវដំណើរការងារ ពិសេសនិរន្តរភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋ។ ទន្ទឹមនឹងការរៀបចំផែនការធនធានមនុស្សនេះដែរ មន្ទីរពេទ្យក៏បានរៀបចំនូវប្រព័ន្ធគ្រប់គ្រងគុណផល និងធ្វើការវាយតម្លៃលើលក្ខណៈវិនិច្ឆ័យមួយចំនួនដោយបានផ្សារភ្ជាប់ទៅនឹងប្រព័ន្ធលើកទឹកចិត្ត។

៣.៤.១.១. ការធ្វើផែនការធនធានមនុស្ស

ចំពោះការធ្វើផែនការធនធានមនុស្ស មន្ទីរពេទ្យបានធ្វើការវិភាគអំពីតម្រូវការនៃធនធានមនុស្សជាប្រចាំឆ្នាំ ដោយបានរៀបចំជាតារាងស្ថានភាពមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ទៅតាមជំនាញ និងផ្នែក ដូចជា ជំនាញវេជ្ជបណ្ឌិតឯកទេស ជំនាញវេជ្ជបណ្ឌិត ជំនាញគិលានុបដ្ឋាកមធ្យម ជំនាញព័ត៌មានវិទ្យា ជំនាញគណនេយ្យឧត្តម និងជំនាញមន្ទីរពិសោធន៍[៦៤]។ ការរៀបចំផែនការនេះ គឺអាចរក្សាបាននូវស្ថានភាពចំនួនបុគ្គលិកនាពេលបច្ចុប្បន្ននិងអនាគត និងអាចគ្រប់គ្រងបាននូវហានិភ័យសម្រាប់តម្រូវការជំនាញនិងផ្នែកដែលខ្វះមន្ត្រីបំពេញការងារ ដែលបណ្តាលមកពី មន្ត្រីត្រូវចូលនិវត្តន៍ ស្ថិតនៅក្នុងភាព

[៦៤] ស្ថានភាពមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងតម្រូវការផែនការធនធានមនុស្សសម្រាប់បំពេញការងារនៅមន្ទីរពេទ្យខេត្តកំពង់ចាម ឆ្នាំ២០១៩

ទំនេរគ្មានបៀវត្ស សុំផ្លាស់ចេញ និងត្រូវបន្តការសិក្សារយៈពេលវែងជាដើម។

ក្រៅពីការរៀបចំផែនការធនធានមនុស្ស មន្ទីរពេទ្យ ក៏បានរៀបចំបញ្ជីតារាងចំនួនមន្ត្រីដែលនឹងត្រូវចូលនិវត្តន៍ទៅតាមកាលបរិច្ឆេទមួយជាក់លាក់ជាប្រចាំឆ្នាំ ដោយគោរពតាមគោលការណ៍កំណត់ និងជូនដំណឹងដល់សាមីខ្លួនបានជ្រាបជាមុន ដើម្បីត្រៀមខ្លួនអភិវឌ្ឍសមត្ថភាពអ្នកបន្តវេន និងចាត់ចែងការងារនិងពេលវេលាដែលនៅសល់នាពេលខាងមុខ។ ចំពោះមន្ត្រីដែលត្រូវចូលនិវត្តន៍ មន្ទីរពេទ្យបានយកចិត្តទុកដាក់ដោយផ្តល់អត្ថប្រយោជន៍ផ្សេងៗដល់បុគ្គលិកពេទ្យ និងគ្រូពេទ្យដែលបានខិតខំបំពេញការងារយ៉ាងសកម្មជាមួយមន្ទីរពេទ្យតាំងពីចាប់ផ្តើមចូលបម្រើការងាររហូតដល់បញ្ចប់ទៅវិញ។ អត្ថប្រយោជន៍ដែលមន្ទីរពេទ្យបានប្រគល់ជូនដល់បុគ្គលិកពេទ្យ និងគ្រូពេទ្យចូលនិវត្តន៍ មានពីរប្រភេទ រួមមានដូចខាងក្រោម÷

ទី១. អត្ថប្រយោជន៍ជាកាតព្វកិច្ច÷ ឧបត្ថម្ភនូវថវិកាចំនួន ១.០០០.០០០ (មួយលានរៀល) និងសម្ភារមួយចំនួនដូចជាកន្សែងជូតខ្លួន សាប៊ូ ច្រាសដុសធ្មេញ និងថ្នាំដុសធ្មេញជាដើម ព្រមទាំងមេដាយការងារ។

ទី២. អត្ថប្រយោជន៍ជាជម្រើស÷ ផ្តល់ឱកាសឱ្យមន្ត្រីដែលត្រូវចូលនិវត្តន៍ បន្តបំពេញការងាររហូតដល់បំណាច់ឆ្នាំ តាមរយៈការវាយតម្លៃគុណផលមន្ត្រីដោយគណៈគ្រប់គ្រង មន្ទីរពេទ្យ ក្នុងគោលបំណងរក្សាទុកមន្ត្រីចូលនិវត្តន៍ដែលមានសមត្ថភាពខ្ពស់ ដើម្បីចែករំលែកចំណេះដឹង និងបណ្តុះបណ្តាលបន្តដល់បុគ្គលិកផ្សេងៗទៀត[៦៥]។

៣.៤.១.២. ការគ្រប់គ្រងគុណផល

ដើម្បីលើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពការងាររបស់បុគ្គលិកពេទ្យ និងគ្រូពេទ្យ មន្ទីរពេទ្យបានបង្កើតឱ្យមានន្ទវប្រព័ន្ធគ្រប់គ្រងគុណផល ដោយបានរៀបចំប្រព័ន្ធវាយតម្លៃដើម្បីវាស់វែងអំពីសមត្ថភាពបំពេញការងាររបស់មន្ត្រី និងផ្តល់ការលើកទឹកចិត្តដើម្បីគាំទ្រ

[៦៥] ការសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យ នាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០

ដល់ស្មារតីបំពេញការងារ ព្រមទាំងការបង្កើតនូវប្រព័ន្ធគ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា។ ទន្ទឹមនេះ មន្ទីរពេទ្យបានរៀបចំនូវរចនាសម្ព័ន្ធគ្រប់គ្រងមួយដែលមានសមាសភាពរាប់ចាប់ពីប្រធានមន្ទីរពេទ្យ អនុប្រធានមន្ទីរពេទ្យ ប្រធានផ្នែក និងនាយសាល ព្រមទាំងមានការកំណត់អំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវច្បាស់លាស់[៦៦]។ លើសពីនេះ មន្ទីរពេទ្យបានរៀបចំនូវសម្រង់បញ្ជីវត្តមានដែលតម្រូវឱ្យបុគ្គលិកម្នាក់ៗត្រូវចុះហត្ថលេខាពីរពេល គឺពេលព្រឹក និងពេលរសៀលទាំងម៉ោងចូលធ្វើការ និងម៉ោងចេញធ្វើការ (ការចុះហត្ថលេខា សរុប៤ដងក្នុង១ថ្ងៃ) ដើម្បីត្រួតពិនិត្យនូវវត្តមានរបស់បុគ្គលិកដែលមកបំពេញការងារប្រចាំថ្ងៃ ក្នុងគោលបំណង ឆ្ពោះទៅរកផលិតភាព និងប្រសិទ្ធភាពនៃការបំពេញការងារ។

នៅក្នុងការគ្រប់គ្រងគុណផលនេះដែរ មន្ទីរពេទ្យ ក៏បានរៀបចំឧបករណ៍វាយតម្លៃថ្នាក់ដឹកនាំមន្ទីរពេទ្យ គ្រូពេទ្យ និងបុគ្គលិកពេទ្យ ទៅតាមប្រភេទខុសៗគ្នា រួមមាន÷ ១)ការវាយតម្លៃបីកម្រិត ២)ការវាយតម្លៃទៅលើការប្រឡងប្រណាំងផ្ទៃក្នុង និង ៣)ការវាយតម្លៃផ្នែកលើវត្តមាននិងបទបញ្ជាផ្ទៃក្នុង។

ចំពោះប្រភេទទី១ “ការវាយតម្លៃបីកម្រិត” ត្រូវបានធ្វើឡើងរៀងរាល់បីខែម្តង ដែលក្នុងនោះមាន÷ ១)កម្រិតគណៈគ្រប់គ្រង ២)កម្រិតប្រធានផ្នែកនិងនាយសាល និង ៣)កម្រិតបុគ្គលិក។ កម្រិតទាំងបីនេះ ត្រូវបានវាយតម្លៃ ដោយអ្នកទទួលបន្ទុក និងទៅតាមឋានានុក្រម ដែលរួមមានដូចខាងក្រោម÷

ទី១. គណៈគ្រប់គ្រង÷ អនុប្រធានមន្ទីរពេទ្យ ត្រូវបានវាយតម្លៃគុណផលដោយប្រធានមន្ទីរពេទ្យ

ទី២. ប្រធានផ្នែក និងនាយសាល÷ ប្រធានផ្នែក អនុប្រធានផ្នែក នាយសាល និងនាយសាលរង ត្រូវបានវាយតម្លៃដោយថ្នាក់ដឹកនាំមន្ទីរពេទ្យទាំងអស់ និងមានការឯកភាពពីប្រធានមន្ទីរពេទ្យ

[៦៦] តារាងតួនាទីភារកិច្ចរបស់អនុប្រធានមន្ទីរពេទ្យ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨

ទី៣. បុគ្គលិក÷ បុគ្គលិក ត្រូវបានវាយតម្លៃដោយអនុប្រធានមន្ទីរពេទ្យទទួលបន្ទុក ប្រធានផ្នែក និងនាយសាលទទួលបន្ទុក

ឧបករណ៍វាយតម្លៃកម្រិតបីខាងលើ មានលក្ខណៈវិនិច្ឆ័យផ្សេងៗគ្នា។ កម្រិតទី១ ផ្តោតលើ៥ចំណុច រួមមាន÷ ១)ភាពជាអ្នកដឹកនាំ ២)ការទទួលខុសត្រូវលើការធ្វើផែនការ ការងារប្រចាំត្រីមាស និងប្រចាំឆ្នាំ ៣)ការទទួលខុសត្រូវលើលទ្ធផលការងារប្រចាំត្រីមាស ៤)ការធ្វើការងារជាក្រុមនិងការតាមដានការអនុវត្តការងារជាក្រុម និង៥) ប្រសិទ្ធភាព ការងារក្នុងតួនាទីនិងភារកិច្ច។ រីឯកម្រិតទី២ ផ្តោតលើ៦ចំណុច រួមមាន ១)សិរិយាបថ វិជ្ជាជីវៈ ២)សិរិយាបថការងារជាក្រុម ៣)សមត្ថភាពបច្ចេកទេសនិងភាពបត់បែនក្នុងម៉ោង ធ្វើការ ៤)ការអភិវឌ្ឍអាជីព ៥)សកម្មភាព ស៥ និង ៦)សកម្មភាពបង្ការនិងត្រួតពិនិត្យ ការចម្លងរោគ (IPC)។ ចំពោះកម្រិតទី៣ ផ្តោតលើ៦ចំណុចគឺ ១)សិរិយាបថវិជ្ជាជីវៈ ២)សិរិយាបថការងារជាក្រុម ៣)សមត្ថភាពបច្ចេកទេស និងភាពបត់បែនក្នុងម៉ោងធ្វើការ ៤)អនាម័យដៃ ៥)ការគ្រប់គ្រងសំណល់ និង ៦)ការសម្អាតបរិស្ថាន[៦៧]។

ចំពោះប្រភេទទី២ "ការវាយតម្លៃទៅលើការប្រឡងប្រណាំងផ្ទៃក្នុង" បានផ្តោតទៅលើ វិញ្ញាសាចំនួនបួនគឺ ១)ការបង្ការនិងត្រួតពិនិត្យការចម្លងរោគ ២)សកម្មភាពសម្រិតសម្រាំង សណ្តាប់ធ្នាប់ សោភ័ណភាព ស្តង់ដា និងស្ថិរភាព (ស៥) ៣)វិន័យ និង ៤)បរិស្ថាន។ ការ ប្រកួតប្រជែងនេះ ត្រូវបានវាយតម្លៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យខុសៗគ្នានៃវិញ្ញាសា ទាំងបួន[៦៨] និងវាយតម្លៃរៀងរាល់មួយខែម្តង លើកលែងតែវិញ្ញាសា ស៥ ដែលត្រូវបាន វាយតម្លៃរៀងរាល់៣ខែម្តង។

វិញ្ញាសាទី១ "ការបង្ការនិងត្រួតពិនិត្យការចម្លងរោគ" ផ្តោតលើ៤ចំណុចគឺ ១)ការធ្វើ អនាម័យដៃ ២)ការគ្រប់គ្រងកាកសំណល់ ៣)ការសម្អាតបរិស្ថាន/អនាម័យទូទៅ និង ៤)ការ អប់រំអំពីសុខភាព និងអនាម័យដល់អ្នកជំងឺ អ្នកកំដរអ្នកជំងឺ។ វិញ្ញាសាទី២ "សកម្មភាព

[៦៧] ឧបករណ៍វាយតម្លៃស្តាដែការងារសម្រាប់កម្រិតអនុប្រធានមន្ទីរពេទ្យ សម្រាប់កម្រិតប្រធាន អនុប្រធានផ្នែក នាយសាល នាយសាលរង និងសម្រាប់កម្រិតបុគ្គលិក

[៦៨] ទម្រង់វាយតម្លៃនៃវិញ្ញាសាទាំងបីប្រភេទ (ការបង្ការនិងត្រួតពិនិត្យការចម្លងរោគ 5S និងវិន័យ)

សម្រិតសម្រាំង សណ្តាប់ធ្នាប់ សោភ័ណភាព ស្តង់ដា និងស្ថិរភាព (ស៥)" ផ្តោតលើ៥ចំណុច គឺ ១) សម្រិតសម្រាំង ២) សណ្តាប់ធ្នាប់ ៣) សោភ័ណភាព ៤) ស្តង់ដារ និង៥) ស្ថិរភាព។ ចំណែកឯវិញ្ញាសាទី៣ "វិន័យ" ផ្តោតលើ៤ចំណុចគឺ ១) ម៉ោងបំពេញការងារ ២) អវត្តមានបំពេញការងារ ៣) អវត្តមានវេនប្រចាំការ និង៤) ឯកសណ្ឋាន។ ដោយឡែក វិញ្ញាសាទី៤ "បរិស្ថាន" ផ្តោតទៅលើការថែទាំសួនច្បារឱ្យបានល្អស្អាត និងស្រស់បំព្រង ដែលវិញ្ញាសានេះ ពុំទាន់បានកំណត់លក្ខណៈវិនិច្ឆ័យនៅឡើយទេ ព្រោះទើបតែបង្កើតក្នុងឆ្នាំ២០២០។

ចំពោះប្រភេទទី៣ "ការវាយតម្លៃដោយផ្អែកលើវត្តមាននិងបទបញ្ជាផ្ទៃក្នុង" មន្ទីរពេទ្យបានរៀបចំធ្វើឡើងជារៀងរាល់ខែ ដោយវាយតម្លៃលើការមកបំពេញការងារទៀងទាត់ រួមមាន÷ ការងារប្រចាំថ្ងៃ វេនយាម និងការងារចំថ្ងៃឈប់សម្រាក និងការគោរពវិន័យការងារដែលមានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង។

ជាមួយគ្នានឹងការវាយតម្លៃទាំងបីប្រភេទខាងលើ មន្ទីរពេទ្យក៏បានរៀបចំប្រព័ន្ធលើកទឹកចិត្ត ទៅតាមប្រភេទនៃការវាយតម្លៃ។ សម្រាប់ប្រភេទទី១ "ការវាយតម្លៃបីកម្រិត" បុគ្គលិក ត្រូវបានផ្តល់ប្រាក់រង្វាន់ដោយផ្អែកលើពិន្ទុសរុបនៃការវាយតម្លៃ ដែលថវិកាលើកទឹកចិត្តនេះ បានមកពីអង្គការដៃគូអភិវឌ្ឍនានា រួមមាន÷ ធនាគារពិភពលោក (World Bank) ធនាគារអភិវឌ្ឍន៍រដ្ឋាភិបាលអាល្លឺម៉ង់ (German Government-owned Development Bank: KFW) ទីភ្នាក់ងារកិច្ចសហប្រតិបត្តិអន្តរជាតិកូរ៉េ (KOICA) នាយកដ្ឋានពាណិជ្ជកម្មនិងទំនាក់ទំនងអន្តរជាតិ (Department of Foreign Affairs and Trade: DFAT) របស់អូស្ត្រាលី ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) និងអង្គការ Family Health International 360 (FHI 360) ជាដើម។ ការលើកទឹកចិត្តនេះ ត្រូវបានកំណត់ជាពីរប្រភេទ រួមមាន÷

- ការលើកទឹកចិត្តជាថវិកា÷ សម្រាប់ប្រចាំត្រីមាសនីមួយៗ ការផ្តល់បាក់រង្វាន់លើកទឹកចិត្តដល់បុគ្គលិក ត្រូវបានគិតទៅលើសន្ទស្សន៍ និងតម្លៃសន្ទស្សន៍នៃកាំប្រាក់ ព្រមទាំងផ្អែកលើតួនាទីរបស់បុគ្គលិក

- ការលើកទឹកចិត្តមិនមែនជាថវិកា÷ ការផ្តល់ប័ណ្ណសរសើរ មេដាយការងារ និងការស្នើសុំឡើងថ្នាក់ជូនបុគ្គលិក។

ចំពោះប្រភេទទី២ “ការវាយតម្លៃទៅលើការប្រឡងប្រណាំងផ្ទៃក្នុង” មន្ទីរពេទ្យបានឧបត្ថម្ភជាថវិកាមួយចំនួនដល់ផ្នែកដែលទទួលបានជ័យលាភី ដោយទទួលទឹកប្រាក់ឧបត្ថម្ភចាប់ពីសែសិបម៉ឺនរៀល ដល់ហាសិបម៉ឺនរៀល ដែលកម្មវិធីនេះត្រូវបានរៀបចំឡើងរៀងរាល់ឆ្នាំ[៦៩]។

សម្រាប់ប្រភេទទី៣ “ការវាយតម្លៃដោយផ្នែកលើវត្តមាននិងបទបញ្ជាផ្ទៃក្នុង” មន្ទីរពេទ្យបានផ្តល់នូវប្រាក់លើកទឹកចិត្តដល់បុគ្គលិកតាមរយៈចំណូលពីហិរញ្ញប្បទានជាប្រចាំខែ ដែលបានមកពីការបង់សេវារបស់អតិថិជន ដោយបានបែងចែកទៅតាមការកំណត់របស់រាជរដ្ឋាភិបាល ក្នុងនោះ ៦០% នៃចំណូលសេវាផ្តល់ទៅគ្រប់បុគ្គលិក ៣៩% សម្រាប់ដំណើរការរបស់មន្ទីរពេទ្យ និង ១% សម្រាប់បង់ចូលថវិកាជាតិ។ ថវិកា ៦០% នៃចំណូលសេវានេះ នឹងឧបត្ថម្ភដល់មន្ត្រីថ្នាក់ដឹកនាំអង្គភាព ថ្នាក់ការិយាល័យ គ្រូពេទ្យ បុគ្គលិកពេទ្យទូទៅ ដែលបានរួមចំណែកក្នុងកិច្ចការរបស់អង្គភាពឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព។ ការបែងចែកប្រាក់ឧបត្ថម្ភនេះ ក៏ត្រូវយោងទៅតាមតួនាទី ភារកិច្ច និងសមត្ថភាពជំនាញទទួលខុសត្រូវលើកិច្ចការ ដោយមានការឯកភាពនៅក្នុងផ្ទៃក្នុងរបស់អង្គភាពផ្ទាល់ ប៉ុន្តែគម្លាតទឹកប្រាក់ពីថ្នាក់ខ្ពស់បំផុតមកថ្នាក់ទាបបំផុតមិនឱ្យលើសពី២ទៅ៣ដងឡើយ[៧០]។

ដើម្បីងាយស្រួលដល់ការគ្រប់គ្រងបុគ្គលិក មន្ទីរពេទ្យបានរៀបចំការគ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា ដោយបញ្ចូលទិន្នន័យព័ត៌មានបុគ្គលិកទាំងអស់ទៅក្នុងប្រព័ន្ធ ដោយក្នុងនោះរួមមាន÷ ប្រវត្តិរូប ប្រវត្តិការងារ ប្រវត្តិការសិក្សា ការបណ្តុះបណ្តាលមេដាយការងារ និងការដាក់វិន័យផ្សេងៗ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យនេះ បានជួយដល់មន្ទីរពេទ្យឱ្យមានភាពងាយស្រួលដល់ការគ្រប់គ្រងចំនួនបុគ្គលិកដែលកំពុងបំពេញការងារ

[៦៩] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យ នាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០។
[៧០] សេចក្តីណែនាំស្តីពីការគ្រប់គ្រងសេវាហិរញ្ញប្បទានសុខាភិបាលនាខែមីនា ឆ្នាំ២០១១។

បានច្បាស់លាស់ និងក្តាប់បានទាំងជំនាញនិងសមត្ថភាពរបស់គ្រូពេទ្យនិងបុគ្គលិកពេទ្យ ប្រវត្តិការងារ និងការសិក្សាជាដើម។ ប្រព័ន្ធនេះ ក៏ជួយឱ្យមន្ទីរពេទ្យមានភាពងាយស្រួលនៅក្នុងការធ្វើបច្ចុប្បន្នភាព ការរក្សាទុកនូវប្រវត្តិនៃការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិក ការដាក់វិន័យ និងការស្វែងរកព័តិមានអំពីអតីតភាពការងាររបស់បុគ្គលិកម្នាក់ៗ ជាពិសេសមន្ទីរពេទ្យមានទិន្នន័យគ្រប់គ្រាន់ និងអាចស្វែងរកព័តិមានយ៉ាងឆាប់រហ័សចំពោះមន្ត្រីដែលត្រូវចូលនិវត្តន៍នាពេលបច្ចុប្បន្ន និងអនាគត។

៣.៤.២. ការអភិវឌ្ឍធនធានមនុស្ស

មន្ទីរពេទ្យមួយដែលរឹងមាំ ខ្លាំង គឺត្រូវការធនធានមនុស្សជាចាំបាច់។ ដូច្នេះ បុគ្គលិកពេទ្យ និងគ្រូពេទ្យ ត្រូវអភិវឌ្ឍសមត្ថភាពជាប្រចាំដើម្បីឆ្លើយតបទៅនឹងជំនាញបច្ចេកទេសដែលមានការវិវឌ្ឍថ្មីៗ។ ពាក់ព័ន្ធនឹងចំណុចនេះ មន្ទីរពេទ្យខេត្តកំពង់ចាមបានរៀបចំផែនការបណ្តុះបណ្តាលប្រចាំឆ្នាំ[៣១] និងការរៀបចំចាត់ចែងបុគ្គលិកឱ្យទៅបំពេញការងារសមស្របទៅតាមជំនាញ និងផ្នែកនីមួយៗ ព្រមទាំងផ្តល់ឱកាសដល់បុគ្គលិកពេទ្យ និងគ្រូពេទ្យ បានចូលរួមកម្មវិធីផ្សេងៗ និងអនុវត្តនូវសកម្មភាពនានាជាច្រើន។

៣.៤.២.១. ការរៀបចំផែនការបណ្តុះបណ្តាល

មន្ទីរពេទ្យបានធ្វើការសិក្សាទៅលើធនធានមនុស្សដែលកំពុងបំពេញការងារទៅតាមផ្នែកនីមួយៗ ដោយធ្វើការប្រមូលទិន្នន័យតាមផ្នែក និងតាមរយៈទិវាប្រចាំឆ្នាំរបស់មន្ទីរពេទ្យ ក្នុងនោះមានកិច្ចពិភាក្សាអំពីបញ្ហាប្រឈម និងចំណុចខ្សោយដែលមន្ទីរពេទ្យត្រូវដោះស្រាយ និងអភិវឌ្ឍបន្ថែម រួមទាំងជំនាញឯកទេសដែលមន្ទីរពេទ្យមានតម្រូវការផងដែរ។ ទាញចេញពីកិច្ចការងារនេះ មន្ទីរពេទ្យក៏បានរៀបចំផែនការបណ្តុះបណ្តាលប្រចាំឆ្នាំដោយកំណត់អំពីជំនាញបណ្តុះបណ្តាលដែលជាតម្រូវការចាំបាច់ និងពេលវេលាជាក់លាក់សម្រាប់ធ្វើការបណ្តុះបណ្តាលដល់គ្រូពេទ្យពាក់ព័ន្ធទាំងអស់។

ដោយផ្នែកទៅលើផែនការបណ្តុះបណ្តាលនេះ មន្ទីរពេទ្យបានរៀបចំនូវកម្មវិធី

[៣១] តារាងកាលវិភាគសម្រាប់ឆ្នាំ២០១៩ ស្តីពីការប្រជុំពិភាក្សាករណីគ្លីនិករបស់មន្ទីរពេទ្យខេត្តកំពង់ចាម។

បណ្តុះបណ្តាលរយៈពេលខ្លី។ (២ថ្ងៃ) ជារៀងរាល់ខែ ដោយផ្តោតលើផ្នែកវេជ្ជកម្ម សម្ភព រោគស្ត្រី ផ្នែកជំងឺទូទៅ និងផ្នែកសង្គ្រោះបន្ទាន់ជាដើម ដែលធ្វើបទឧទ្ទេសនាមដោយ សាស្ត្រាចារ្យជំនាញតាមផ្នែកនីមួយៗ។

ការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិក មិនត្រឹមតែធ្វើឡើងក្រោមរូបភាពកម្មវិធីបណ្តុះ-បណ្តាលនោះទេ គឺមន្ទីរពេទ្យបានប្រើប្រាស់គ្រប់មធ្យោបាយដើម្បីអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកបន្ថែម រួមមាន÷ ការរៀបចំសិក្ខាសាលា និងការប្រជុំរៀងរាល់ព្រឹកដែលមានរយៈពេលមួយម៉ោងទៅមួយម៉ោងកន្លះ ដើម្បីពន្យល់ណែនាំ និងជជែកពិភាក្សាអំពីបញ្ហាផ្សេងៗ ឬស្ថានភាពជំងឺណាមួយដែលត្រូវធ្វើការសិក្សារួមគ្នា។ ទន្ទឹមនេះ ក្រោមកិច្ចសហ-ប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ មន្ទីរពេទ្យបានរៀបចំកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលានានា ដើម្បីចែករំលែកជំនាញ ចំណេះដឹង និងបទពិសោធន៍ របស់គ្រូពេទ្យឯកទេសមកពីខាងក្រៅប្រទេសដូចជា បារាំង កូរ៉េ និងជប៉ុនជាដើម។ កម្មវិធីបណ្តុះបណ្តាលនេះមានរយៈពេលពីរទៅបីថ្ងៃ ដោយបានផ្តោតទៅលើផ្នែកឆ្អឹប ការថែទាំទារក និងពិសោធន៍... ។ ល។

៣.៤.២.២. ការអនុវត្តនៃការអភិវឌ្ឍធនធានមនុស្ស

មន្ទីរពេទ្យ បានយកចិត្តទុកដាក់លើសមត្ថភាពបុគ្គលិកពេទ្យ និងគ្រូពេទ្យគ្រប់កម្រិត ដោយបានគិតគូរអំពីការអភិវឌ្ឍសមត្ថភាពជាប្រចាំ តាមរយៈការបញ្ជូនគ្រូពេទ្យមួយចំនួនឱ្យទៅចូលរួមវគ្គបណ្តុះ បណ្តាលបន្ថែមទាំងក្នុងប្រទេស ទាំងក្រៅប្រទេស លើជំនាញវគ្គខ្លីៗពាក់ព័ន្ធនឹងការងារដែលទទួលបន្ទុក។ វគ្គបណ្តុះបណ្តាលក្នុងប្រទេសមានដូចជា ផ្នែកវេជ្ជសាស្ត្រ សល្យសាស្ត្រ កុមារ និងសម្ភព-រោគស្ត្រី។ រីឯវគ្គបណ្តុះបណ្តាលខ្លីៗក្រៅប្រទេសមានដូចជាការគ្រប់គ្រងសុខភាពមាតា សុខភាពទារក និងសុខភាពសហគមន៍ជាដើម[៧២]។

[៧២] វិញ្ញាបនបត្ររបស់លោកស្រី យន់ ស៊ីណេ ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលស្តីពីសុខភាពមាតា និងទារក នៅប្រទេសជប៉ុន ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ និងវិញ្ញាបនបត្ររបស់លោកស្រី ឃ្យឿង សុខណា បានបញ្ចប់វគ្គបណ្តុះបណ្តាលស្តីពីសុខភាពសហគមន៍ នៅប្រទេសជប៉ុន។

តារាង ៣.៣ ស្តីពីចំនួនអ្នកចូលរួមវគ្គបណ្តុះបណ្តាលពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩

ល.រ	ប្រភេទនៃការបណ្តុះបណ្តាល	ឆ្នាំ										សរុប	
		២០១៥		២០១៦		២០១៧		២០១៨		២០១៩			
		ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប
១	ការបណ្តុះបណ្តាលក្នុងប្រទេស	៣២	៧០	៣៩	៧៧	៤៨	១០២	៤៩	១១៨	៨៦	១៦៧	២៥៤	**៥៣៤**
២	ការបណ្តុះបណ្តាលក្រៅប្រទេស	៤	៦	១	៤	៣	៧	៣	១៣	៦	១៨	១៧	**៤៨**
សរុបរួម		៣៦	៧៦	៤០	៨១	៥១	១០៩	៥២	១៣១	៩៤	១៨៥	១៧១	**៥៨២**

ប្រភព÷ តារាងរៀបចំបង្កើតឡើងដោយក្រុមការងារតាមរយៈទិន្នន័យដែលទទួលបានពីមន្ទីរពេទ្យខេត្តកំពង់ចាម

តាមតារាង ៣.៣ បង្ហាញថា ក្នុងរយៈពេល៥ឆ្នាំ(២០១៥-២០១៩) មន្ទីរពេទ្យបានអភិវឌ្ឍសមត្ថភាពគ្រូពេទ្យតាមរយៈការបណ្តុះបណ្តាលក្នុងប្រទេស សរុបចំនួន៥៣៤នាក់ ស្ត្រី២៥៤នាក់ ក្នុងនោះឆ្នាំ២០១៥ មានចំនួន៧០នាក់ ស្ត្រី៣២នាក់ ឆ្នាំ២០១៦ មានចំនួន ៧៧នាក់ ស្ត្រី៣៩នាក់ ឆ្នាំ២០១៧ មានចំនួន ១០២នាក់ ស្ត្រី៤៨នាក់ ឆ្នាំ២០១៨ មានចំនួន ១១៨នាក់ ស្ត្រី៤៩នាក់ និងឆ្នាំ២០១៩ មានចំនួន ១៦៧នាក់ ស្ត្រី៨៦នាក់។ ចំពោះការបណ្តុះបណ្តាលនៅក្រៅប្រទេស មានចំនួនសរុប ៤៨នាក់ ស្ត្រី១៧នាក់ ក្នុងនោះ ឆ្នាំ២០១៥ មានចំនួន៦នាក់ ស្ត្រី៤នាក់ ឆ្នាំ២០១៦ ចំនួន ៤នាក់ ស្ត្រី១នាក់ ឆ្នាំ២០១៧ មានចំនួន ៧នាក់ ស្ត្រី៣នាក់ ឆ្នាំ២០១៨ មានចំនួន ១៣នាក់ ស្ត្រី៣នាក់ និងឆ្នាំ២០១៩ មានចំនួន ១៨នាក់ ស្ត្រី៦នាក់។

ចំពោះកម្មវិធីបណ្តុះបណ្តាលដែលមន្ទីរពេទ្យបានរៀបចំដោយផ្ទាល់ មន្ទីរពេទ្យបានរៀបចំការវាយតម្លៃលើការបណ្តុះបណ្តាលដើម្បីកែលម្អកម្មវិធីបណ្តុះបណ្តាល ដោយបាន

រៀបចំជាទម្រង់វាយតម្លៃមុន និងក្រោយការបណ្តុះបណ្តាល (Pre-test/Post-test)[៣៣] និងទម្រង់វាយតម្លៃកម្មវិធីបណ្តុះបណ្តាលទទួលព័ត៌មានត្រឡប់ (Feedback)[៣៤] ពីសិក្ខាកាមដែលទម្រង់ទាំងនេះបានឆ្លុះបញ្ចាំងអំពីសមត្ថភាពរបស់គ្រូពេទ្យក្នុងការទទួលយកចំណេះដឹង និងជំនាញក្នុងកម្រិតណាមួយ ឬតម្រូវការចំណេះដឹងឬជំនាញបន្ថែមទៀត ព្រមទាំងមតិយោបល់សំណូមពរនានាក្នុងការកែលម្អវគ្គនេះ ឱ្យកាន់តែល្អប្រសើរបន្ថែមទៀតនាពេលបន្ទាប់។

បន្ទាប់ពីបុគ្គលិកពេទ្យ និងគ្រូពេទ្យ បានទទួលការបណ្តុះបណ្តាលរួច គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំចាត់ចែង និងលើកទឹកចិត្ត ដោយផ្តល់ឱកាសឱ្យចូលរួមក្នុងកម្មវិធីផ្សេងៗមានដូចជា កិច្ចប្រជុំ និងសិក្ខាសាលានានាដើម្បីចែករំលែកនូវចំណេះដឹង ជំនាញ និងមេរៀនបទពិសោធន៍ដែលទទួលបានពីវគ្គបណ្តុះបណ្តាល។ លើសពីនេះ គណៈគ្រប់គ្រងមន្ទីរពេទ្យបានអនុញ្ញាតឱ្យគ្រូពេទ្យធ្វើជាគ្រូបង្គោលដើម្បី បណ្តុះបណ្តាលបន្ត ឬធ្វើគ្រូកម្មសិក្សាសម្រាប់និស្សិតពេទ្យ ឬជាក្រុមការងារវាយតម្លៃនៃគម្រោងលើកកម្ពស់គុណភាពនិងសមធម៌សុខាភិបាល (H-EQIP)។

[៣៣] ទម្រង់វាយតម្លៃវគ្គបណ្តុះបណ្តាលស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគនៅមន្ទីរពេទ្យ។
[៣៤] សំនួរវាយតម្លៃទិវាវេជ្ជសាស្ត្រ សល្យសាស្ត្រ មន្ទីរពេទ្យខេត្តកំពង់ចាម លើកទី៥។





ការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា

ការគ្រប់គ្រងវត្តមាន





ការបណ្តុះបណ្តាលធនធានមនុស្ស



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរសុខាភិបាលខេត្តកំពង់ចាម
មន្ទីរពេទ្យខេត្តកំពង់ចាម
លេខ.០៥៤/០៤.២៣៥៣

លិខិតសរសើរ

ទ្នាក់ជីកនាំមន្ទីរពេទ្យខេត្តកំពង់ចាម សូមធ្វើការសរសើរដល់ផ្នែក រដ្ឋបាល ដែលបានចូលរួម
ចំណែកក្នុងកិច្ចការ អភិវឌ្ឍន៍មន្ទីរពេទ្យ បានល្អប្រសើរក្នុងឆ្នាំ២០១៨នេះ។
សូមបន្តសកម្មភាព និង ស្នាដៃថ្មីៗថែមទៀតសំរាប់ឆ្នាំបន្តបន្ទាប់។

ថ្ងៃ.....ឆ្នាំ ច សំរឹទ្ធិស័ក ព.ស២៥៦២
កំពង្គចាម ថ្ងៃ.....ខ្នាំ ...ឆ្នាំ ២០១៩
ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម

សាស្ត្រ. ម៉ន.ស៊ីណាត

៣.៥. ការរៀបចំ និងកែលម្អបរិស្ថានរបស់មន្ទីរពេទ្យ

នៅសូចនាករគោលនេះមានការសិក្សាអំពី÷ ១)ការបញ្ជាបការយល់ដឹងពីបរិស្ថាន និងភាពស្អាត ២)ការរក្សាភាពស្អាតនៅក្នុងបរិវេណមន្ទីរពេទ្យ និងភាពបៃតង ៣)ការរៀបចំទីតាំងអង្គុយលំហែ និងចំណតយានជំនិះ ៤)ការគ្រប់គ្រងសំណល់រាវនៅបរិវេណមន្ទីរពេទ្យ ៥)ការប្រើប្រាស់ទឹកស្អាត ការបំពុលដោយក្លិន និងសម្លេង និង ៦)ការចាត់តាំងអនុវត្តការងាររបស់ក្រុមត្រួតពិនិត្យការបង្ការ និងការត្រួតពិនិត្យការចម្លងរោគក្នុងមន្ទីរពេទ្យ។

៣.៥.១. ការបញ្ជាបការយល់ដឹងពីបរិស្ថាន និងភាពស្អាត

ដើម្បីធានាឱ្យបាននូវការចូលរួមថែរក្សាបរិស្ថាននិងភាពស្អាតសម្រាប់បរិស្ថានបុគ្គល និងបរិស្ថានសង្គមរបស់មន្ទីរពេទ្យ គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំផែនការសកម្មភាពចំនួន២ រួមមាន÷ ១)ការអនុវត្តតាមឯកសារគោលសម្រាប់ការយល់ដឹងពីបរិស្ថាន និងភាពស្អាត និង ២)ការចូលរួមអនុវត្តយ៉ាងពេញលេញពីមន្ត្រីបុគ្គលិកមន្ទីរពេទ្យ និងអ្នកប្រើប្រាស់សេវាទាំងអស់។

៣.៥.១.១. ឯកសារគោលសម្រាប់ការយល់ដឹងពីបរិស្ថាន និងភាពស្អាត

ការបណ្តុះស្មារតីនិងការចូលរួមថែទាំបរិស្ថានស្អាត ត្រូវមានការបញ្ជាបការយល់ដឹងពីបរិស្ថានល្អដល់មន្ត្រីនិងអ្នកប្រើបាស្រ់សេវា ដែលជាផ្នែកមួយគាំទ្រដល់សុខុមាលភាពទាំងអស់គ្នា។ ការទទួលបានសុខភាពល្អមិនមែនផ្នែកទៅលើតែផ្នែកមួយចេញពីការព្យាបាលសុទ្ធសាធនោះទេ គឺមានន័យថា បរិស្ថានស្អាត និងមានអនាម័យក្នុងមន្ទីរពេទ្យជាផ្នែកមួយនៃគុណភាពសុខភាពរបស់មន្ត្រីមន្ទីរពេទ្យ និងអ្នកមកប្រើប្រាស់សេវាក្នុងមន្ទីរពេទ្យទាំង-អស់។ ក្នុងការអនុវត្តជាក់ស្តែង ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក បុគ្គលិកអនាម័យនៃមន្ទីរសុខាភិបាល និងមន្ទីរពេទ្យខេត្តកំពង់ចាមទាំងអស់ តែងតែរៀបចំកម្មវិធីផ្សព្វផ្សាយ និងយុទ្ធនាការសម្អាតបរិស្ថានមន្ទីរពេទ្យចំនួន២ ដងក្នុង១ ឆ្នាំដល់បុគ្គលិកមន្ទីរពេទ្យទាំងអស់ អ្នកប្រើប្រាស់សេវា និងអ្នកកំដរអ្នកជំងឺ ដើម្បីយល់ដឹងពីអត្ថប្រយោជន៍នៃបរិស្ថានស្អាត

ដោយបញ្ចូលនូវកម្មវិធី ការលាងសម្អាតដៃ ការទុកដាក់សំរាម និងការសម្អាតបរិស្ថាន[៧៥]។

បន្ថែមពីនេះ ដើម្បីធានាបាននូវការទទួលបានចំណេះដឹងបន្ថែមអំពីការរក្សាអនាម័យ ការថែទាំ បរិស្ថានស្អាត គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំឱ្យមាន ១)ផ្ទាំងរូបភាពធំៗ ស្តីពីការទុកដាក់សំរាមទៅតាមប្រភេទ ២)រូបភាពបង្ហាញពីគ្រោះថ្នាក់នៃកាកសំណល់វេជ្ជសាស្ត្រ និងកាកសំណល់គីមី និង ៣)ទ្រីស្តីស៥ជាដើម។ ជាទូទៅផ្ទាំងរូបភាពធំៗទាំងនេះត្រូវបានដាក់នៅចំកណ្តាលបរិវេណ ដែលមានទីតាំងផ្តល់ភាពងាយស្រួលដល់បុគ្គលិកពេទ្យ និងអ្នកប្រើប្រាស់សេវាមើលឃើញ និងជាផ្នែកមួយបង្ហាញពីសារអប់រំអំពីការថែទាំបរិស្ថាន និងអនាម័យ។ នៅក្នុងបរិវេណមន្ទីរពេទ្យ និងតាមបន្ទប់នៃផ្នែកនីមួយៗ មានបិទពាក្យស្លោកផ្សេងៗដោយមានភ្ជាប់រូបភាពដើម្បីណែនាំដល់បុគ្គលិកពេទ្យ អ្នកជំងឺ និងអ្នកកំដរអ្នកជំងឺចូលរួមអនុវត្តគាំទ្រការថែទាំអនាម័យតាមរយៈការអប់រំបរិស្ថានបុគ្គល[៧៦] និងការអប់រំបរិស្ថានសង្គម[៧៧] ដូចជា ១)អនាម័យសំខាន់សូមដាក់កាកសំណល់នៅក្នុងធុងសំរាម ២)មន្ទីរពេទ្យស្អាត ទាំងអស់គ្នាសប្បាយចិត្ត ៣)សូមថែរក្សាបរិស្ថានក្នុងមន្ទីរពេទ្យឱ្យបានស្អាតជានិច្ច ៤)បរិស្ថានស្អាតផ្តើមចេញពីយើងទាំងអស់គ្នា ៥)ខ្ញុំត្រូវការសំរាមរបស់អ្នក ៦)សូមលាងដៃក្រោយចេញពីបង្គន់អនាម័យ ៧)សូមកុំចោលសំរាមក្នុងបង្គន់ និង ៨)ហាមបន្ទោរបង់ក្នុងទីធ្លាមន្ទីរពេទ្យ។

លើសពីនេះ គណៈគ្រប់គ្រងមន្ទីរពេទ្យបានយកគោលការណ៍ស្តង់ដារការងារតាមទ្រីស្តីស៥ (5S) មកបិទផ្សព្វផ្សាយនៅក្នុងបដា និងតាមបន្ទប់នៃផ្នែកទាំងអស់របស់មន្ទីរពេទ្យ ដែលជាវិធីសាស្ត្រមូលដ្ឋាន និងជាប្រព័ន្ធសម្រាប់ការបង្កើនគុណភាព និងសុវត្ថិភាព

[៧៥] ការសម្ភាសន៍ជាមួយលោកស្រីវេជ្ជបណ្ឌិត ចាប់ ច័ន្ទធិតា អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

[៧៦] អប់រំបរិស្ថានបុគ្គលជាការអប់រំមន្ត្រីបុគ្គលិកពេទ្យ អ្នកប្រើប្រាស់សេវា អ្នកកំដរអ្នកជំងឺដើម្បីយល់ដឹងពីការអនាម័យខ្លួនប្រាណ និងបរិស្ថានក្នុងមន្ទីរពេទ្យ។

[៧៧] អប់រំបរិស្ថានសង្គមជាការអប់រំជាទូទៅដល់មន្ត្រីបុគ្គលិកពេទ្យ អ្នកប្រើប្រាស់សេវា អំពីបរិស្ថាន អនាម័យ ដើម្បីបំផុសស្មារតីឱ្យមានការចូលរួមថែទាំ និងស្រលាញ់បរិស្ថាន។

ក្នុងមន្ទីរពេទ្យ ដោយកំណត់ឱ្យមន្ត្រី បុគ្គលិកអនុវត្តជាប្រចាំក្នុងកិច្ចការតាមជំនាញ ដើម្បីធានាបានបរិស្ថានការងារល្អ រួមមាន÷ ១) សម្រិតសម្រាំងគឺមានន័យថា យកចេញរបស់របរដែលមិនចាំបាច់ចេញពីកន្លែងធ្វើការ ២) សណ្តាប់ធ្នាប់គឺមានន័យថា រៀបចំរបស់របរដាក់កន្លែងសមស្របដើម្បីងាយស្រួលក្នុងការស្វែងរកនិងរក្សាទុក ៣) សោភ័ណភាពគឺមានន័យថា រៀបចំសម្អាតកន្លែងធ្វើការ សម្ភារ និងរបស់របរផ្សេងៗ ៤) ស្តង់ដាគឺមានន័យថា បង្កើតឱ្យមានស្តង់ដា និងមានចរន្តការងារ និង ៥) ស្ថិរភាពគឺមានន័យថា បង្កើតជាទម្លាប់នៃនីតិវិធីក្នុងការថែទាំ។

៣.៥.១.២. ការអនុវត្តការបង្ហាញការយល់ដឹងពីបរិស្ថាន និងភាពស្អាត

ជារួម ភាពស្អាតរបស់បរិស្ថានមិនមែនកើតឡើងដោយគ្រាន់តែគិតហើយនិយាយនោះទេគឺ គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំជាពាក្យស្លោក និងរៀបចំផែនការដឹកនាំមន្ត្រីព្រមទាំងបុគ្គលិកអនាម័យក្នុងមន្ទីរពេទ្យដើម្បីធ្វើអនាម័យនៅក្នុងបរិវេណ និងក្រៅបរិវេណមន្ទីរពេទ្យក្នុងគោលបំណងរក្សាភាពស្អាតជានិច្ចនូវអនាម័យបរិស្ថាន និងបៃតង។

ជាទូទៅ គណៈគ្រប់គ្រងមន្ទីរសុខាភិបាល និងគណៈគ្រប់គ្រងមន្ទីរពេទ្យខេត្តកំពង់ចាមបានដឹកនាំមន្ត្រី និងបុគ្គលិកអនាម័យ ធ្វើការសម្អាតបរិស្ថានចំនួន២ដងក្នុង១ឆ្នាំ គឺនៅខែមិថុនា និងខែធ្នូជារៀងរាល់ឆ្នាំ ដើម្បីបំផុសឱ្យបុគ្គលិកមន្ទីរពេទ្យទាំងអស់ទទួលបានការយល់ដឹងអំពីអត្ថប្រយោជន៍នៃការថែទាំអំពីបរិស្ថានបុគ្គល និងបរិស្ថានសង្គមនៅក្នុងមន្ទីរពេទ្យ។ ដោយឡែក ដើម្បីធានានិរន្តរភាពបរិស្ថានស្អាត គណៈគ្រប់គ្រងមន្ទីរពេទ្យបានកំណត់ឱ្យប្រធានផ្នែក និងមន្ត្រីតាមផ្នែកនីមួយៗត្រូវអនុវត្តសកម្មភាពបង្ការ និងទប់ស្កាត់ការចម្លងរោគ តាមការកំណត់ក្នុងបញ្ជីវាយតម្លៃរបស់គណកម្មការត្រួតពិនិត្យនិងបង្ការការចម្លងរោគ ដែលរួមមាន÷[៧៨] ១) ការធ្វើអនាម័យដៃ ២) ការគ្រប់គ្រងសំណល់ក្នុងផ្នែក ៣) ការសម្អាតបរិស្ថាន ឬអនាម័យទូទៅទាំងក្រៅអគារ និងក្នុងអគារ (ផ្នែកបន្ទប់អ្នកជំងឺ ទីកន្លែងអ្នកជំងឺប្រើប្រាស់ ផ្នែកបុគ្គលិកពេទ្យ និងទីកន្លែងបុគ្គលិកពេទ្យប្រើប្រាស់) និង ៤) ការអប់រំ

[៧៨] ខ្លឹមសារនៃបញ្ជីវាយតំលៃតាមដានសកម្មភាពបង្ការនិងត្រួតពិនិត្យការចម្លងរោគមន្ទីរពេទ្យខេត្តកំពង់ចាម។

សុខភាព និងអនាម័យដល់អ្នកជំងឺ អ្នកកំដរ ឬសាច់ញាតិរបស់អ្នកជំងឺជារៀងរាល់សប្តាហ៍។

ទន្ទឹមគ្នានេះដែរ ការរក្សាបរិស្ថានស្អាតគឺពឹងផ្អែកលើការចូលរួមរបស់បុគ្គលិកមន្ទីរពេទ្យ ឬគណៈកម្មការថែទាំអនាម័យ និងការចូលរួមរបស់អ្នកប្រើប្រាស់។ នៅក្នុងកិច្ចការនេះ ថ្នាក់ដឹកនាំមន្ទីរពេទ្យបានរៀបចំវិធានជាឯកសារអប់រំទាក់ទងនឹងការសម្អាតបរិស្ថានមន្ទីរពេទ្យ ដោយកំណត់ឱ្យបុគ្គលិកមន្ទីរពេទ្យនៅតាមផ្នែកនីមួយៗធ្វើការផ្សព្វផ្សាយអប់រំ[៧៩] ទៅដល់អ្នកប្រើប្រាស់សេវាអំពីអនាម័យ និងបរិស្ថាន។ ដោយឡែក មន្ត្រីនៅតាមផ្នែកត្រូវមានកម្មវិធីអប់រំដល់អ្នកប្រើប្រាស់សេវានូវប្រធានបទខុសៗគ្នាពាក់ព័ន្ធនឹងការធ្វើអនាម័យទៅតាមប្រភេទជំងឺ ដែលស្ថិតនៅតាមផ្នែករបស់ពួកគាត់[៨០]។ រាល់ការផ្សព្វផ្សាយអប់រំខាងលើនេះ ប្រធានផ្នែក និងមន្ត្រីរបស់ខ្លួនបានរៀបចំកម្មវិធីចំនួន២ដងក្នុងមួយសប្តាហ៍ នៅរៀងរាល់ថ្ងៃពុធ និងថ្ងៃសុក្រ ទៅតាមប្រធានបទខុសៗគ្នាទាក់ទងនឹងប្រភេទការងារអនាម័យ និងបរិស្ថានរបស់ផ្នែកនីមួយៗ។ ស្របគ្នានេះដែរ ក្នុងកំឡុងពេលផ្សព្វផ្សាយអប់រំ ប្រធានផ្នែកនិងសហការីបានចែកនិងផ្សព្វផ្សាយបទបញ្ជាផ្ទៃក្នុងស្តីពីបរិស្ថានស្អាត និងឯកសារអប់រំនានាពាក់ព័ន្ធនឹងការថែទាំបរិស្ថានបុគ្គល និងបរិស្ថានសង្គមដល់អ្នកប្រើប្រាស់សេវា និងអ្នកកំដរទាំងអស់ ដើម្បីយល់ដឹងនិងចូលរួមអនុវត្ត។ ខ្លឹមសារជារួមពាក់ព័ន្ធនឹងវិធានផ្ទៃក្នុងខាងលើនេះ រួមមាន÷ ១)ត្រូវអនាម័យខ្លួនប្រាណ និងសំលៀកបំពាក់ ២)សូមរក្សានិងសម្អាតបរិស្ថានដោយការបោះសំរាមនៅក្នុងធុងពណ៌បៃតង និងម៉ាស់ដែលប្រើរួចនៅក្នុងធុងពណ៌លឿងដែលមានស្លាកពណ៌ខ្មៅ ៣)អាចប្រើប្រាស់ទឹកគ្រប់ក្បាលរ៉ូប៊ីណេនៅក្នុងមន្ទីរពេទ្យ ៤)ត្រូវមានអនាម័យដៃរៀងរាល់មុននិងក្រោយពិសាចំណីអាហារ ៥)ត្រូវអនាម័យដៃបន្ទាប់ពីប្រើប្រាស់បន្ទប់អនាម័យរួច ៦)ត្រូវលាងដៃមុននិងក្រោយទទួលទានអាហារ ៧)ត្រូវអនាម័យពេលចេញពីបង្គន់ ៨)ជួយសម្អាតបរិស្ថានដោយមិនត្រូវខាកស្តោះ

[៧៩] ការសម្ភាសន៍របស់លោកស្រីវេជ្ជបណ្ឌិត ចាប់ ច័ន្ទធិតា អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ និងខ្លឹមសារបញ្ជីវាយតម្លៃតាមដានសកម្មភាពបង្ការនិងត្រួតពិនិត្យការចម្លងរោគមន្ទីរពេទ្យខេត្តកំពង់ចាម ចំណុចទី៤។

[៨០] ជាសកម្មភាពអប់រំបរិស្ថានបុគ្គលសម្រាប់អ្នកប្រើប្រាស់សេវា។

និងចោលសំរាមពាសវាលពាសកាល ៩)មិនត្រូវជក់បារីក្នុងមន្ទីរពេទ្យ និង ១០)ហាមសេពគ្រឿងស្រវឹងនិងលេងល្បែងស៊ីសងក្នុងមន្ទីរពេទ្យ។

៣.៥.២. តាពស្អាតនៅក្នុងបរិវេណមន្ទីរពេទ្យ និងតាពបៃតង

នៅចំណុចនេះមានការលើកឡើងអំពី ១)ការណែនាំអំពីភាពស្អាតនៅក្នុងបរិវេណមន្ទីរពេទ្យ និងភាពបៃតង និង ២)ការអនុវត្តដើម្បីភាពស្អាតនៅក្នុងបរិវេណមន្ទីរពេទ្យ និងភាពបៃតង។

៣.៥.២.១. ការណែនាំពីតាពស្អាតនៅក្នុងបរិវេណមន្ទីរពេទ្យនិងតាពបៃតង

ការធានាបាននូវការចូលរួមពីបុគ្គលិករបស់មន្ទីរពេទ្យ និងអ្នកប្រើប្រាស់សេវាក្នុងការរក្សាឱ្យបាននូវភាពស្អាត និងភាពបៃតងក្នុងបរិវេណមន្ទីរពេទ្យ គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំវិធានជាបទបញ្ជាផ្ទៃក្នុងដើម្បីបរិស្ថានស្អាត និងសណ្តាប់ធ្នាប់ដោយកំណត់ការហាមឃាត់មួយចំនួន រួមមាន÷ ១)ហាមចោលសំរាមពាសវាលពាសកាល ២)ហាមខាកស្តោះក្នុងបរិវេណមន្ទីរពេទ្យ ៣)ហាមជក់បារីក្នុងបរិវេណមន្ទីរពេទ្យ ៤)ហាមចតយានយន្តពាសវាលពាសកាល ៥)ហាមប្រើប្រាស់គ្រឿងស្រវឹងក្នុងបរិវេណមន្ទីរពេទ្យ ៦)ហាមលេងល្បែងស៊ីសងក្នុងបរិវេណមន្ទីរពេទ្យ ៧)ហាមបង្កសំលេងរំខានខ្លាំងៗក្នុងបរិវេណមន្ទីរពេទ្យ ៨)ហាមបន្ទោរបង់ក្រៅបង្គន់អនាម័យ និង ៩)ហាមយកអាវុធជាតិផ្ទុះនានាចូលក្នុងបរិវេណមន្ទីរពេទ្យ។

ទន្ទឹមនឹងនេះ ដើម្បីធានាបាននូវនិរន្តរភាពនៃកិច្ចការសម្អាតបរិស្ថាន គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំកាលវិភាគសម្រាប់មន្ត្រី និងបុគ្គលិកអនាម័យក្នុងមន្ទីរពេទ្យទាំងអស់ដើម្បីចូលរួមរក្សាអនាម័យបរិស្ថានដោយផ្តោតលើកិច្ចការ៤សំខាន់គឺ ១)ការលាងដៃ ២)ការបោះចោលនិងទុកដាក់សំរាម ៣)ការអប់រំអ្នកកំដរ និង ៤)ការសម្អាតបរិស្ថានទាំងក្នុងអគារនិងបរិវេណមន្ទីរពេទ្យ។

បន្ថែមពីនេះ គណៈគ្រប់គ្រងមន្ទីរពេទ្យបានបែងចែកភារកិច្ច និងដែនសមត្ថកិច្ចសម្រាប់មន្ត្រីបម្រើការងារនៅតាមបណ្តាផ្នែកឱ្យទទួលខុសត្រូវក្នុងការថែរក្សាអនាម័យ

និងបរិស្ថាននេះផងដែរ។ ជារួម មន្ត្រីបម្រើការងារក្នុងផ្នែកនីមួយៗ ត្រូវបំពេញកិច្ចការទាំងបួនខាងលើនៅក្នុងបរិវេណនៃផ្នែករបស់ខ្លួន និងរក្សាអនាម័យនៅបរិវេណខាងក្រៅអគារនៃផ្នែកនីមួយៗ ដែលមានគម្លាតចេញពីជញ្ជាំងអគារចំនួនមួយម៉ែត្រកន្លះទៅពីរម៉ែត្រ។ ដោយឡែក ការងារថែទាំរក្សាអនាម័យបរិស្ថាន ដែលមិនស្ថិតក្នុងដែនសមត្ថកិច្ចរបស់មន្ត្រីតាមផ្នែកទទួលបន្ទុក គឺជាដែនសមត្ថកិច្ចរបស់គណៈកម្មការថែទាំ។ ការងារទាំងនោះមានដូចជា ការបោសសម្អាត ការប្រមូលកាកសំណល់ និងការថែទាំដើមឈើ និងសួនច្បារ។ បុគ្គលិកអនាម័យបម្រើការងារនៅក្នុងផ្នែកនីមួយៗ ត្រូវសម្អាតនិងប្រមូលកាកសំណល់ចំនួន២ដងក្នុងមួយថ្ងៃ ដោយអនុវត្តជាទៀតទាត់ចាប់ពីថ្ងៃច័ន្ទរហូតដល់ថ្ងៃសៅរ៍[៨១]។

ចំណែកឯការសម្អាតបន្ទប់បង្គន់ និងបន្ទប់ទឹកអនាម័យ គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំតារាងកម្មវិធីជាកាលវិភាគសម្រាប់បុគ្គលិកអនាម័យតាមផ្នែកនីមួយៗដើម្បីបោសសម្អាត និងអនាម័យជាប្រចាំ។ ទន្ទឹមនេះ ដើម្បីធានាឱ្យបាននូវនិរន្តរភាពក្នុងការសម្អាត គណៈកម្មការតាមដានត្រួតពិនិត្យ និងវាយតម្លៃ បានរៀបចំប្រព័ន្ធតាមដានដោយរៀបចំបញ្ជីវត្តមាន និងវេនអ្នកសម្អាត ព្រមទាំងបិទតារាងកាលវិភាគនៅមុខបន្ទប់នីមួយៗ។

ស្របជាមួយគ្នានេះ ដើម្បីធានាឱ្យបាននូវការអនុវត្តការងារប្រកបដោយការទទួលខុសត្រូវនៅ ក្នុងតារាងកាលវិភាគ បានកំណត់ការវាយតម្លៃលើកម្រិតអនាម័យ រួមមាន÷ កម្រិតប្រភេទ A គឺសម្អាតបានស្អាតល្អ កម្រិតប្រភេទ B គឺសម្អាតមិនសូវស្អាត និងកម្រិតប្រភេទ C គឺមិនបានសម្អាត។ បន្ថែមពីនេះទៀត គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំការប្រឡងប្រណាំងអំពីការថែទាំបរិស្ថាន ដោយមានគណៈកម្មការត្រួតពិនិត្យជាអ្នកវាយតម្លៃជាក់ពិន្ទុប្រចាំឆ្នាំលើគណៈកម្មការថែទាំ និងបុគ្គលិកអនាម័យក្នុងផ្នែកនីមួយៗ ដើម្បីជាក់ជូនគណៈគ្រប់គ្រងមន្ទីរពេទ្យពិនិត្យនិងសម្រេច។ សម្រាប់ផ្នែកដែលទទួលបានចំណាត់ថ្នាក់ចាប់ពីលេខ១ ដល់លេខ៣ លើការថែទាំបរិស្ថាននិងអនាម័យ ប្រធានផ្នែក មន្ត្រី និង

[៨១] ប្រសាសន៍លោកស្រីវេជ្ជបណ្ឌិត ចាប់ ច័ន្ទធិតា អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០

បុគ្គលិកអនាម័យទាំងអស់ដែលបម្រើការងារក្នុងផ្នែកនោះ នឹងទទួលបានការផ្តល់រង្វាន់ប្រចាំឆ្នាំជាថវិកាចំនួន១០ម៉ឺនរៀល និងប័ណ្ណសរសើរចំនួនមួយ[៨២]។

៣.៥.២.២. ការអនុវត្តដើម្បីភាពស្អាតនៅក្នុងបរិវេណមន្ទីរពេទ្យ និងភាពបៃតង

កិច្ចការអនាម័យ និងសណ្តាប់ធ្នាប់ល្អ ជាផ្នែកមួយក្នុងការធានាបាននូវសោភ័ណភាព ការទាក់ទាញអ្នកប្រើប្រាស់ និងការសម្រួលដល់ការផ្តល់សេវាផងដែរ។ ដើម្បីធានាបាននូវសណ្តាប់ធ្នាប់រៀបរយល្អក្នុងទីធ្លាមន្ទីរពេទ្យ គណៈគ្រប់គ្រងមន្ទីរពេទ្យ បានរៀបចំប្តង់ហេដ្ឋារចនាសម្ព័ន្ធដ៏រឹងមាំដោយមានការបែងចែកទីតាំងទៅតាមផែននីមួយៗរួមមាន សួនច្បារ ចំណតយានយន្តនិងម៉ូតូ កន្លែងទុកដាក់សំរាម កន្លែងអង្គុយលំហែ កន្លែងសួនកុមារកំសាន្ត ព្រមទាំងបន្ទប់ទឹកនិងបង្គន់អនាម័យសាធារណៈច្បាស់លាស់ ដែលផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់សេវា។

ស្របជាមួយគ្នានេះ ក្នុងគោលបំណងធានាការរក្សាបានបរិស្ថានស្អាតនិងសណ្តាប់-ធ្នាប់រៀបរយល្អ ព្រមទាំងឆ្លើយតបនឹងបទបញ្ជាផ្ទៃក្នុងរបស់មន្ទីរពេទ្យ គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំធុងសំរាមមានគម្របត្រឹមត្រូវនិងគ្រប់គ្រាន់ សម្រាប់គ្រប់គ្រងសំណល់ទូទៅនៅក្នុងបរិវេណនិងក្នុងអគារមន្ទីរពេទ្យ ទៅតាមទីតាំងចាំបាច់មួយចំនួនដូចជា ១)កន្លែងអង្គុយសម្រាកលំហែ ២)នៅខាងមុខបន្ទប់អ្នកជំងឺ ៣)នៅខាងមុខបន្ទប់ធ្វើការតាមផ្នែកនីមួយៗ និង ៤)នៅតាមបន្ទប់បង្គន់អនាម័យ ដោយមានការវេចខ្ចប់ត្រឹមត្រូវ។

ដើម្បីធានាបានស្តង់ដាសុវត្ថិភាពក្នុងការទុកដាក់សំណល់ទូទៅនិងសំណល់ផ្សេងទៀត គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំបិទរូបភាពអំពីប្រភេទធុងសំរាមនៅតាមជញ្ជាំងនៃផ្នែកនីមួយៗ និងរៀបចំធុងសំរាមតាមប្រភេទកាកសំណល់គ្រប់គ្រាន់ស្របតាមតម្រូវការជាក់ស្តែងរបស់ផ្នែកទាំងនោះ។ ជាទូទៅ យើងសង្កេតឃើញថា នៅប៉ែកខាងក្រៅបន្ទប់

[៨២] ការសម្ភាសន៍ជាមួយលោកស្រីវេជ្ជបណ្ឌិត ចាប់ ច័ន្ទធិតា អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ និងសេចក្តីសម្រេចស្តីពីតួនាទីរបស់ក្រុមត្រួតពិនិត្យនិងបង្ការការចម្លងរោគក្នុងមន្ទីរពេទ្យខេត្តកំពង់ចាម ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨

របស់អ្នកជំងឺមានដាក់ធុងសំរាមមានគម្របសម្រាប់ទុកដាក់កាកសំណល់ទូទៅ និងប្រភេទធុងសំរាមមានគម្របសម្រាប់ទុកដាក់កាកសំណល់ឆ្លងរោគ។ ដោយឡែក នៅក្នុងបន្ទប់តាមផ្នែកនីមួយៗដែលមានតម្រូវការចាំបាច់ទុកដាក់កាកសំណល់ផ្សេងពីប្រភេទខាងលើត្រូវបានបំពាក់ដោយធុងសំរាមសម្រាប់ទុកដាក់កាកសំណល់គីមី សំណល់ ឱសថ លោហៈធ្ងន់ និងកាកសំណល់វេជ្ជសាស្ត្របន្ថែមទៀត។ ការរៀបចំនិងកំណត់សម្គាល់ប្រភេទធុងសម្រាមគឺត្រូវបានបែងចែកទៅតាមចំណាត់ថ្នាក់ប្រភេទកាកសំណល់រឹងទាំង៤ ដែលមានគំរូរួមមាន÷ ១)ប្រភេទធុងពណ៌បៃតងមានអក្សរពណ៌ស និងស្បោងខាងក្នុងមានពណ៌ខ្មៅភ្ជាប់ដោយអក្សរពណ៌ស សម្រាប់ទុកដាក់ប្រភេទកាកសំណល់ទូទៅ ២)ប្រភេទធុងពណ៌លឿងមានអក្សរពណ៌ខ្មៅ និងស្បោងខាងក្នុងមានពណ៌ខ្មៅភ្ជាប់ដោយអក្សរពណ៌ខ្មៅ សម្រាប់ទុកដាក់ប្រភេទកាកសំណល់ឆ្លងរោគ ៣)ប្រភេទធុងពណ៌លឿងមានអក្សរពណ៌ក្រហម និងស្បោងខាងក្នុងមានពណ៌លឿងភ្ជាប់ដោយអក្សរពណ៌ក្រហម សម្រាប់ទុកដាក់ប្រភេទកាកសំណល់សរីរាង្គ និង ៤)ប្រភេទធុងពណ៌ត្នោតអក្សរពណ៌ខ្មៅភ្ជាប់ដោយរូបក្បាលខ្មោចច និងស្បោងខាងក្នុងពណ៌លឿង សម្រាប់ទុកដាក់ប្រភេទកាកសំណល់គីមី សំណល់ឱសថ លោហៈធ្ងន់។

បន្ថែមពីនេះទៀត យោងតាមតម្រូវការចាំបាច់ក្នុងការរៀបចំសណ្តាប់ធ្នាប់ក្នុងបរិវេណរបស់មន្ទីរពេទ្យខេត្តកំពង់ចាមឱ្យមានភាពប្រសើរឡើង គឺចាប់ពីចុងឆ្នាំ២០១៥មក គណៈគ្រប់គ្រងមន្ទីរពេទ្យបានសម្រេចកំណត់ឱ្យមានអ្នកម៉ៅការដេញថ្លៃលើការរក្សាសុវត្ថិភាពរបៀបរៀបរយយានជំនិះ និងយានយន្ត[៨៣]។ នៅក្នុងនោះ ចំណតយានយន្តនិងម៉ូតូក្នុងមន្ទីរពេទ្យជាផ្នែកមួយយ៉ាងសំខាន់ ដែលជួយដល់ការរៀបចំសណ្តាប់ធ្នាប់រៀបរយនិងសោភ័ណភាពរបស់មន្ទីរពេទ្យ ព្រមទាំងផ្តល់ឱ្យអ្នកប្រើប្រាស់សេវាមានភាពងាយស្រួលក្នុងការធ្វើដំណើរចេញចូល និងការចតយានយន្តបានត្រឹមត្រូវ។ លើសពីនេះ ដើម្បីឆ្លើយ

[៨៣] កិច្ចសន្យាលេខ២៧០ មពកច ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីសេវាផ្ទើរយានជំនិះ យានយន្ត និងអាហារដ្ឋាននៅមន្ទីរពេទ្យខេត្តកំពង់ចាម

តបនឹងបទបញ្ជាផ្ទៃក្នុងរបស់មន្ទីរពេទ្យ ដែលបានហាមឃាត់ការចតយានយន្តពាសវាលពាសកាល គណៈគ្រប់គ្រងមន្ទីរពេទ្យនិងអ្នកម៉ៅការ បានរៀបចំទីតាំងចំណតយានយន្តដែលមានគំនូសបែងចែកចំនួន១៦០គំនូស ដោយបែងចែកទៅតាមប្រភេទចំណត រួមមាន÷ ១)ចំណតរថយន្តរបស់ថ្នាក់ដឹកនាំនិងមន្ត្រីនៅតាមផ្នែកនីមួយៗ ២)ចំណតរថយន្តរបស់អតិថិជន ៣)ចំណតរថយន្តសង្គ្រោះ បន្ទាន់និងជីកសាកសព ៤)ចំណតរថយន្តសម្រាប់ការព្យាបាលភ្នែកចល័តដែលមានរោងទុកដាក់ត្រឹមត្រូវ និង៥)ចំណតម៉ូតូនិងកង់ដែលអាចផ្ទុកបានចំនួន១៥០គ្រឿង[៥៤]។

លើសពីនេះ នៅក្នុងបរិវេណនិងក្នុងអគារនៃផ្នែកនីមួយៗរបស់មន្ទីរពេទ្យ គណៈគ្រប់គ្រងបានធ្វើការបែងចែកបង្គន់អនាម័យ និងបន្ទប់ទឹកសាធារណៈសម្រាប់ប្រើប្រាស់នៅក្នុងបរិវេណមន្ទីរពេទ្យ ព្រមទាំងបង្គន់អនាម័យ និងបន្ទប់ទឹកប្រើប្រាស់នៅតាមអគារនៃផ្នែកនីមួយៗយ៉ាងត្រឹមត្រូវនិងគ្រប់គ្រាន់។ បង្គន់អនាម័យ និងបន្ទប់ទឹកសាធារណៈក្នុងបរិវេណមន្ទីរពេទ្យនិងតាមផ្នែកនីមួយៗត្រូវបានរៀបចំដាច់ដោយឡែកពីគ្នាទ្វបន្ទប់បង្គន់អនាម័យ និងបន្ទប់ទឹកសម្រាប់បុរស នារី ព្រមទាំងជនពិការ ហើយដូចគ្នាដែរគឺនៅតាមមុខបន្ទប់បង្គន់អនាម័យ និងបន្ទប់ទឹកត្រូវបានបែងចែកនិងបំពាក់ស្លាកសញ្ញាសម្គាល់សម្រាប់បុរស នារី និងជនពិការច្បាស់លាស់។ ជារួម មន្ទីរពេទ្យមានបន្ទប់បង្គន់អនាម័យសរុបចំនួន១០៩បន្ទប់ ដែលក្នុងនោះបន្ទប់បង្គន់សម្រាប់ស្ត្រីមានចំនួន៣៨បន្ទប់ និងបន្ទប់ទឹកសរុបចំនួន៧៨បន្ទប់ សម្រាប់ប្រើប្រាស់នៅតាមផ្នែក និងក្នុងបរិវេណមន្ទីរពេទ្យ។

បន្ថែមពីនេះ នៅតាមបន្ទប់បង្គន់អនាម័យទាំងអស់ត្រូវបានបំពាក់ដោយធុងសំរាមដែលមានគម្រប សម្រាប់ទុកដាក់កាកសំណល់ទ្វទៅយ៉ាងត្រឹមត្រូវ អនាម័យល្អ និងគ្មានក្លិន។ តាមរយៈការសង្កេតជាក់ស្តែង នៅតាមបន្ទប់បង្គន់អនាម័យនិងបន្ទប់ទឹកត្រូវបានរៀបចំឱ្យមានជញ្ជាំងព្រិលខាងលើ បង្អួច ដែលធ្វើឱ្យខ្យល់ចេញចូលគ្រប់គ្រាន់ដើម្បីកុំឱ្យមានក្លិនមិនល្អ និងរន្ធបង្ហូរនៅក្នុងបន្ទប់ទឹកនីមួយៗត្រូវបានបំពាក់បច្ចេកទេសខ្ទប់ក្លិន

[៥៤] ការសម្ភាសន៍ជាមួយលោក ឆៅ ច័ន្ទផល អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២០

យ៉ាងត្រឹមត្រូវ។ លើសពីនេះ ដើម្បីជៀសវាងក្លិនមិនល្អនៅក្នុងបន្ទប់ទឹក និងបន្ទប់បង្គន់អនាម័យទាំងនោះ គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំកាលវិភាគសម្រាប់បុគ្គលិកអនាម័យនៅតាមផ្នែកនីមួយៗសម្អាតជាប្រចាំ២ដងក្នុងមួយថ្ងៃ។

ដើម្បីអនុវត្តទៅតាមគោលការណ៍កំណត់ដោយឯកសារអប់រំទាក់ទងនឹងការសម្អាតបរិស្ថានក្នុងមន្ទីរពេទ្យដែលកំណត់ឱ្យអ្នកប្រើប្រាស់បន្ទប់អនាម័យត្រូវសម្អាតដៃក្រោយចេញពីបង្គន់ គណៈគ្រប់គ្រងមន្ទីរពេទ្យបានគិតគូរនិងរៀបចំទឹកន្លែងលាងដៃនៅគ្រប់ច្រកចេញពីបន្ទប់ទឹក ឬបង្គន់អនាម័យដោយប្រើប្រាស់ស្លាកសម្គាល់និងអក្សរណែនាំបញ្ជាក់ច្បាស់លាស់។ នៅតាមទីកន្លែងលាងដៃនីមួយៗមានសាប៊ូលាងដៃ កន្សែង ឬក្រដាសជូតដៃសម្រាប់អ្នកប្រើប្រាស់ ដើម្បីរក្សាអនាម័យឱ្យបានល្អ។ បន្ថែមពីនេះ នៅតាមបន្ទប់ទឹកនិងបង្គន់អនាម័យក្នុងអគារនៃផ្នែកនីមួយៗ ក៏ដូចជាបន្ទប់ទឹកនិងបន្ទប់បង្គន់សាធារណៈដែរ គឺត្រូវបានរៀបចំប្រព័ន្ធបណ្តាញទឹកស្អាត និងមានទឹកប្រើប្រាស់គ្រប់គ្រាន់។

ភាពជាអ្នកដឹកនាំនិងការច្នៃប្រឌិតរបស់គណៈគ្រប់គ្រងមន្ទីរពេទ្យ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការគ្រប់គ្រងនិងចាត់ចែងមន្ត្រីទាំងអស់ រួមមាន ប្រធានផ្នែក នាយសាលមន្ត្រីពេទ្យ និងគណៈកម្មការថែទាំ ចូលរួមថែរក្សាបរិស្ថាននៅក្នុងបរិវេណមន្ទីរពេទ្យឱ្យបានស្អាត និងមានភាពបៃតងជានិច្ច ដោយបានចាត់ចែងកិច្ចការដូចខាងក្រោម[៨៥]÷

- គណៈកម្មការថែទាំត្រូវគ្រប់គ្រងបុគ្គលិកអនាម័យចំនួន៦០នាក់ ដោយបែងចែកបុគ្គលិកអនាម័យចាប់ពីចំនួន១នាក់ដល់ចំនួន៤នាក់ សម្រាប់ផ្នែកនីមួយៗដោយអាស្រ័យនឹងតម្រូវការរបស់ផ្នែកទាំងនោះ និងកំណត់វេនបំពេញការងារវេនព្រឹកនិងវេនរសៀល
- នៅវេនព្រឹកចាប់ពីម៉ោង៧:០០នាទី ក្រុមបុគ្គលិកអនាម័យទទួលបន្ទុកការងារអនាម័យនៅតាមផ្នែកនីមួយៗរបស់មន្ទីរពេទ្យត្រូវទទួលភារកិច្ចក្នុងការរក្សាថែទាំ

[៨៥] ការសម្ភាសន៍ជាមួយលោកស្រីវេជ្ជបណ្ឌិត ចាប់ ច័ន្ទធិតា អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០

សម្អាត អនាម័យនៅតាមផ្នែករបស់ខ្លួនទាំងក្នុងអគារ និងបរិវេណជុំវិញអគារ ព្រមទាំងប្រមូលកាកសំណល់ទូទៅដោយទុកដាក់ក្នុងស្តុកបំរុងនីមួយៗ មុននឹងបញ្ជូនទៅកន្លែងស្តុកសំណល់រួម។

- នៅវេនរសៀលចាប់ពីម៉ោង២:០០នាទី ក្រុមបុគ្គលិកអនាម័យនៅតាមផ្នែកទាំងអស់ត្រូវប្រមូលផ្តុំគ្នានិងត្រូវបានបែងចែកជា២ក្រុម ឬពាក្រុម ដើម្បីធ្វើអនាម័យ បោសសម្អាត និងប្រមូលសំរាមទៅតាមផែនផ្សេងគ្នានៃទីធ្លាខាងមុខ និងខាងក្រោយដែលស្ថិតនៅក្នុងបរិវេណមន្ទីរពេទ្យ។ បន្ទាប់ពីបំពេញកិច្ចការនៅតាមផែននៃបរិវេណខាងលើនេះរួចរាល់ បុគ្គលិកអនាម័យទាំងនេះ ត្រូវត្រឡប់ទៅបំពេញកិច្ចការអនាម័យនៅតាមផ្នែកដែលពួកគាត់ទទួលបន្ទុកវិញ។
- គណៈកម្មការថែទាំបានបង្កើតយន្តការប្រមូលកាកសំណល់ ដោយមានបុគ្គលិកអនាម័យមួយក្រុមដោយឡែកផ្សេងទៀត ដែលមានភារកិច្ចប្រមូលកាកសំណល់ទូទៅនៅតាមធុងផ្តុកកាកសំណល់ក្នុងបរិវេណ និងកាកសំណល់នៅតាមស្តុកបំរុងយកទៅទុកដាក់ក្នុងស្តុកសំរាមរួម ដោយបំពេញកិច្ចការជាទៀងទាត់នៅរៀងរាល់វេនព្រឹក និងវេនរសៀលជាប្រចាំ។ បន្ថែមពីនេះ រាល់កាកសំណល់នៅក្នុងធុងសំរាមគឺមិនត្រូវឱ្យមានចំណុះលើសពី៣ ភាគ៤ នៃចំណុះសរុបនៃធុងសំរាមនីមួយៗនោះទេ ហើយប្រសិនបើលើសពីការកំណត់នេះបុគ្គលិកអនាម័យត្រូវប្រមូលទៅទុកដាក់ក្នុងស្តុកសំរាមរួម។

ករណីដោយឡែកចំពោះកាកសំណល់ឆ្លងរោគ កាកសំណល់វេជ្ជសាស្ត្រ កាកសំណល់គីមី សំណល់ឱសថ លោហៈធ្ងន់ និងកាកសំណល់សរីរាង្គ បុគ្គលិកអនាម័យដែលបម្រើការងារក្នុងផ្នែកនីមួយៗត្រូវយកដោយផ្ទាល់ទៅកាន់រោងដាក់សំណល់វេជ្ជសាស្ត្របណ្តោះអាសន្ន មុននឹងដាក់ចូលក្នុងឡដុតសំរាម ឬអាងស្តុកសំណល់សរីរាង្គ។

ដើម្បីធានានិរន្តរភាពនៃភាពស្អាតល្អនិងភាពបៃតងរបស់សួន ក្រៅពីកិច្ចការថែទាំនិងរក្សាអនាម័យបរិស្ថានជាប្រចាំថ្ងៃរបស់បុគ្គលិកអនាម័យ គណៈគ្រប់គ្រងមន្ទីរពេទ្យ

បានបែងចែកការទទួលខុសត្រូវថែទាំសួនច្បារទៅតាមផែននៃផ្នែកនីមួយៗ ដែលមានប្រធានផ្នែក នាយសាល មន្ត្រីពេទ្យ និងបុគ្គលិកអនាម័យទាំងអស់ទទួលបន្ទុកថែទាំសួនច្បារ តាមផែននៃផ្នែករបស់ពួកគាត់ ដោយត្រូវបំពេញកិច្ចការរួមគ្នាក្នុងការថែទាំ អភិវឌ្ឍធ្វើអនាម័យ សម្ងាតអគារ កាត់ស្មៅ និងដាំផ្កាក្នុងសួនបន្ថែម នៅរៀងរាល់៣ខែម្តង។

តារាង ៣.៤ ស្តីពីបំណែងចែកការថែទាំសួនច្បារក្នុងមន្ទីរពេទ្យខេត្តកំពង់ចាម

លរ	ផ្នែកទទួលបន្ទុកថែទាំនិងអនាម័យ	ការទទួលខុសត្រូវ
១	ផ្នែករដ្ឋបាល	ទទួលថែទាំសួនច្បារមុខអគាររដ្ឋបាល និងសួនច្បារខាងត្បូងសាលសហសិក្សា២
២	ផ្នែកផ្លូវចិត្ត	ទទួលថែទាំសួនច្បារខាងមុខអគារផ្លូវចិត្ត
៣	ផ្នែកមាត់ ធ្មេញ ត្រចៀក ច្រមុះ និងបំពង់ក	ទទួលថែទាំសួនច្បារខាងជើងអគាររត្រចៀក ច្រមុះ និងបំពង់ក
៤	ផ្នែករបេង	ទទួលថែទាំសួនច្បារជុំវិញអគាររបេង
៥	ផ្នែកមន្ទីរពិសោធន៍	ទទួលថែទាំសួនច្បារខាងមុខអគារមន្ទីរពិសោធន៍
៦	ផ្នែកកុមារ	ទទួលថែទាំសួនច្បារខាងមុខ និងខាងក្រោយអគារជំងឺកុមារ
៧	ផ្នែកពិគ្រោះ និងបែងចែកជំងឺ	ទទួលថែទាំសួនច្បារខាងមុខអគារពិគ្រោះ និងបែងចែកជំងឺ
៨	ផ្នែកសង្ត្រោះបន្ទាន់វះកាត់ (ICU)	ទទួលថែទាំសួនច្បារខាងកើតអគារសង្ត្រោះបន្ទាន់វះកាត់ (ICU)

ប្រភព÷ លិខិតលេខ៤៦២/២០ មព.កច ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ស្តីពីតារាងបែងចែកថែទាំសួនច្បារ, មន្ទីរពេទ្យខេត្តកំពង់ចាម

៣.៥.៣. ទីតាំងអង្គុយលំហែ និងចំណតយានជំនិះ

ការរក្សាសណ្តាប់ធ្នាប់រៀបរយ បរិស្ថានស្ងាត និងសុខមាលភាពក្នុងមន្ទីរពេទ្យគឺមិនមែនពឹងផ្នែកតែផ្នែកការរក្សាអនាម័យតែមួយផ្នែកនោះទេ ប៉ុន្តែកត្តារួមផ្សំក្នុងការ

គ្រប់គ្រងចាត់ចែងលើ ១)ទីតាំងអង្គុយលំហែ និង ២)ចំណតយានជំនិះ ក៏ជាផ្នែកមួយយ៉ាងសំខាន់ផងដែរ។

៣.៥.៣.១. ទីតាំងអង្គុយលំហែ

ដើម្បីរក្សាបានន្វវជាសុកភាពល្អ សម្រាប់មន្ត្រីបុគ្គលិករបស់មន្ទីរពេទ្យនិងអ្នកប្រើប្រាស់សេវាទាំងអស់ និងដើម្បីរក្សាសណ្តាប់ធ្នាប់និងសោភ័ណភាពនៅក្នុងបរិវេណមន្ទីរពេទ្យ គណៈគ្រប់គ្រងមន្ទីរពេទ្យ បានគិតគូរនិងរៀបចំទីធ្លាមានបង់អង្គុយសម្រាកលំហែស្ថិតនៅឆ្ងាយពីបន្ទប់អ្នកជំងឺ ដែលមានភាពស្រឡះទូលាយ មានដើមឈើផ្តល់ម្លប់ មានសួនច្បារព័ទ្ធជុំវិញទីធ្លាប្រកបដោយខ្យល់ចេញចូលគ្រប់គ្រាន់។ បន្ថែមពីនេះ នៅជុំវិញទីតាំងអង្គុយសម្រាកលំហែត្រូវបានរៀបចំឱ្យមានទីកន្លែងលាងសម្អាតនិងអនាម័យដៃត្រឹមត្រូវ។ ដើម្បីធានានិរន្តរភាពនៃអនាម័យ និងការរក្សាបរិស្ថាន ទីធ្លា និងកន្លែងអង្គុយឱ្យមានភាពស្អាតនិងបៃតងជានិច្ច គណៈកម្មការថែទាំ បានរៀបចំឱ្យបុគ្គលិកអនាម័យបោសនិងជូតសម្អាតបង់អង្គុយលំហែជាប្រចាំ ក្នុងមួយថ្ងៃចំនួន២ដង ព្រមទាំងរៀបចំធុងសំរាមមានគម្របត្រឹមត្រូវនៅក្បែរនោះ ដើម្បីអ្នកប្រើប្រាស់សេវាងាយនឹងទុកដាក់កាកសំណល់ទូទៅ[៨៦]។ ដោយឡែក អ្នកប្រើប្រាស់សេវានៅមន្ទីរពេទ្យជាខ្មែរអ៊ីស្លាម ឬអ្នកកាន់សាសនាអ៊ីស្លាម ដែលមានតម្រូវការចាំបាច់សម្រាកដើម្បីបំពេញកិច្ចក្នុងសាសនា គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំបន្ទប់ចំនួន១ កន្លែងដោយឡែកសម្រាប់ថ្វាយបង្គំព្រះដោយមានរៀបចំបិទស្លាកសញ្ញាត្រឹមត្រូវ។

៣.៥.៣.២. ចំណតយានជំនិះ

ដើម្បីរក្សាបានសណ្តាប់ធ្នាប់ល្អក្នុងមន្ទីរពេទ្យ គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំទីតាំងចំណតយានយន្ត ម៉ូតូ និងកង់ច្បាស់លាស់។ ទីតាំងចំណត មានការគូសគំនូសច្បាស់លាស់ទៅតាមគម្លាតពីរថយន្តមួយទៅរថយន្តមួយទៀតដែលផ្តល់ភាពងាយស្រួល

[៨៦] ការសម្ភាសន៍ជាមួយលោកស្រីវេជ្ជបណ្ឌិត ចាប់ ច័ន្ទធិតា អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០

ក្នុងការចេញចូល។ ជារួម គណៈគ្រប់គ្រងមន្ទីរពេទ្យ និងអ្នកម៉ៅការបានកំណត់រួមគ្នា ដោយធ្វើការបែងចែកចំណតនៅតាមទីតាំងជាប់នឹងអគារនៃផ្នែកនីមួយៗសម្រាប់ថ្នាក់ដឹកនាំមន្ទីរពេទ្យ មន្ត្រី បុគ្គលិក និងអ្នកប្រើប្រាស់សេវា ដែលមានគំនូសគំលាតរថយន្តអាចបើកទ្វារចេញចូលបានស្រួល និងមានស្លាកសញ្ញាអប់រំលើកទឹកចិត្តដល់អ្នកប្រើប្រាស់ចំណតដោយបញ្ជាក់ថា “ការចតរថយន្តតាមស្លាកសញ្ញា និងគំនូសជាពលរដ្ឋល្អ”។

ចំណែកឯ ទីតាំងចំណតនៅជាប់អគារ ដែលមិនត្រូវបានអនុញ្ញាតឱ្យរថយន្តចតគឺត្រូវបានគូសខ្វែងដោយគំនូសពណ៌លឿង ឬដាក់ស្លាកសញ្ញាហាមចត។ បន្ថែមពីនេះទៀត ដើម្បីជួយគាំទ្រដល់ភាពងាយស្រួលក្នុងការចតរបស់អ្នកប្រើប្រាស់សេវា គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំឱ្យមានបុគ្គលិកសន្តិសុខប្រចាំការសម្រាប់ជួយសម្របសម្រួលកិច្ចការចំណតនេះ។ ដោយឡែក ចំណតម៉ូតូ និងកង់ ត្រូវបានរៀបចំនៅផ្នែកខាងមុខក្នុងបរិវេណមន្ទីរពេទ្យដែលមានច្រកចូលមួយដោយឡែក ដើម្បីជៀសវាងការបើកបរគ្មានសណ្តាប់ធ្នាប់ក្នុងបរិវេណ និងបង្កជាសំលេងរំខានដល់អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ។ នៅក្នុងបរិវេណទូទៅ ក៏ដូចនៅជុំវិញចំណតយានយន្ត ត្រូវបានបោសសម្អាត ប្រមូលកាកសំណល់២ដងក្នុងមួយថ្ងៃដោយបុគ្គលិកអនាម័យ និងត្រូវបានរៀបចំធុងសំរាមគ្រប់គ្រាន់សម្រាប់ទុកដាក់កាកសំណល់ ដោយបំពាក់ស្លាកសញ្ញាហាមឃាត់ជក់បារីក្នុងបរិវេណនោះ ដើម្បីជៀសវាងការឆាបឆេះជាយថាហេតុ។ លើសពីនេះ គណៈកម្មការថែទាំធ្វើការត្រួតពិនិត្យ រៀបចំ និងគូសឡើងវិញជាប្រចាំរៀងរាល់៣ខែម្តងនូវរាល់គំនូសចំណតរថយន្ត ឬគំនូសខ្សែ ដែលរលុប ឬខូចខាត[៨៧]។

៣.៥.៤. ការគ្រប់គ្រងសំណល់រាវនៅបរិវេណមន្ទីរពេទ្យ

ការគ្រប់គ្រងសំណល់ក្នុងមន្ទីរពេទ្យ គឺមានការបែងចែកសំណល់ទៅតាមប្រភេទផ្សេងៗរួមមានសំណល់ធម្មតា សំណល់ឆ្លងរោគ សំណល់គីមី សំណល់វេជ្ជសាស្ត្រ សំណល់រាវ ហើយក្នុងនោះសំណល់រាវជាសំណល់មួយប្រភេទ ដែលត្រូវបានគ្រប់គ្រងយ៉ាងហ្មត់ចត់

[៨៧] ការសម្ភាសន៍ជាមួយលោក ឆៅ ច័ន្ទផល អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០

ប្រកបដោយបច្ចេកទេសត្រឹមត្រូវ។ នៅគ្រប់ហេដ្ឋារចនាសម្ព័ន្ធអគារទាំងអស់ ត្រូវបានរៀបចំប្រព័ន្ធលូខ្ទាត់ខ្ទែង ដែលរួមមាន ប្រព័ន្ធលូរួមសម្រាប់បង្ហូរសំណល់រាវទៅប្រព័ន្ធមេលូធំ និងទីតាំងសំរាមស្តុកសំណល់រាវ។ ចំណែកឯទីធ្លា និងបរិវេណត្រូវបានរៀបចំចាក់បេតុង និងសម្អាតមិនឱ្យមានភក់ជ្រាំ ឬដក់ទឹកភ្លៀងឡើយ។ ជាទូទៅសំណល់រាវក្នុងមន្ទីរពេទ្យត្រូវបានបែងចែកចេញជាពីរប្រភេទគឺ ប្រភេទទីមួយជាសំណល់រាវមិនឆ្លងរោគ ដែលហូរមកពីបរិវេណមន្ទីរពេទ្យដោយសារទឹកភ្លៀង បន្ទប់ទឹក បន្ទប់បង្គន់អនាម័យ និងប្រភេទទីពីរជាសំណល់រាវឆ្លងរោគ ដែលមានប្រភពចេញពីអគារនៃផ្នែកនីមួយៗ រួមមានសំណល់រាវសីរាង្គ ឬវេជ្ជសាស្ត្រ។ ជារួម សំណល់រាវក្នុងប្រភេទទីមួយ ត្រូវបានហូរចូលក្នុងប្រព័ន្ធលូរួមរបស់មន្ទីរពេទ្យ ហើយត្រូវបានបង្ហូរចូលផ្ទាល់ក្នុងអាងស្តុកសំណល់រាវដំណាក់កាលទី១ មានទំហំ១ ៧ ៥ ម៉ែត្រត្រីគុណមុននឹងឆ្លងកាត់អាងបន្សុទ្ធដំណាក់កាលទី២ មានទំហំ ១៩២,៥ម៉ែត្រត្រីគុណ បន្ទាប់មក ទឹកចម្រោះរួចត្រូវបានបង្ហូរចូលក្នុងអាងទឹកដំណាក់កាលទី៣មានទំហំ១៧៥ម៉ែត្រត្រីគុណ ដែលមានប្រព័ន្ធម៉ូទ័របូមទឹកស្វ័យប្រវត្តិ បូមចូលទៅក្នុងលូធំសាធារណៈ[៨៨]។ ផ្ទុយទៅវិញ សំណល់រាវស្ថិតក្នុងប្រភេទទីពីរវិញ ត្រូវឆ្លងកាត់ការសម្លាប់មេរោគដោយការត្រាំក្លរ ឬសារធាតុក្នុងរយៈពេល១៥នាទី ទៅ២០នាទី និងបន្ទាប់មកត្រូវបង្ហូរចូលទៅក្នុងប្រព័ន្ធលូមួយដោយឡែក ដើម្បីបង្ហូរទំលាក់ចូលក្នុងអាងស្តុកសំណល់រាវដំណាក់កាលទី១ និងឆ្លងកាត់ដំណាក់កាលចម្រោះបន្តបន្ទាប់ដូចករណីខាងលើនេះដែរ មុននឹងបូមចូលទៅក្នុងប្រព័ន្ធលូសាធារណៈ[៨៩]។ ប្រព័ន្ធអាងស្តុកសំណល់រាវនិងចម្រោះដែលបែងចែកជា៣ដំណាក់កាលខាងលើនេះ ត្រូវបានរៀបចំថែទាំដោយបូមសម្អាតកាកសំណល់ ដែលទុកក្នុងអាងស្តុកសំណល់រាវដំណាក់កាលទី១នៅរៀងរាល់៣ខែ ឬ៦ខែម្តង។

៣.៥.៥. ការប្រើប្រាស់ទឹកស្អាត ការបំពុលដោយកិន្នរ និងសម្លេង

តាមរយៈការលើកឡើងខាងលើ បានឆ្លុះបញ្ចាំងមួយផ្នែកក្នុងការរក្សាបរិស្ថានក្នុង

[៨៨] ការសម្ភាសន៍ជាមួយលោក មាន សុភ័ក្ត្រ មន្ត្រីបុគ្គលិកក្នុងផ្នែករដ្ឋបាល ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០
[៨៩] - ជ-

មន្ទីរពេទ្យឱ្យបានស្អាត ដោយឡែកបរិស្ថានខ្យល់ក៏ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការគាំទ្រដល់សុខុមាលភាពរបស់មន្ត្រី បុគ្គលិកនិងអ្នកប្រើប្រាស់សេវាផងដែរ ដែលរួមមានកត្តាមួយចំនួនដែលជាធាតុផ្សំក្នុងការធានាបាននូវបរិស្ថានខ្យល់ ឬបរិយាកាសល្អគឺ ១)ការប្រើប្រាស់ទឹកស្អាតគ្រប់គ្រាន់ និង ២)គ្មានការបំពុលដោយក្លិននិងសម្លេងផ្សេងៗ។

៣.៥.៥.១. ការប្រើប្រាស់ទឹកស្អាត

ដើម្បីធានាបានការផ្គត់ផ្គង់ការប្រើប្រាស់ទឹកគ្រប់គ្រាន់ និងមានស្តង់ដានៅក្នុងមន្ទីរពេទ្យ អង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាមជាដៃគូមួយ ដែលមានទំនុកចិត្តនិងធានាបានការត្រួតពិនិត្យគុណភាពស្តង់ដាត្រឹមត្រូវ។ យោងតាមការសង្កេតជាក់ស្តែង មុននឹងធ្វើការបែងចែកបណ្តាញទឹកទៅតាមអគារនីមួយៗ ប្រព័ន្ធមេទឹកស្អាតរបស់អង្គភាពរដ្ឋាករទឹកខាងលើត្រូវបានតភ្ជាប់ចូលក្នុងអាងស្តុកទឹកធំមួយរបស់មន្ទីរពេទ្យ ដែលមានចំណុះ១២៤ ម៉ែត្រគូប និងមានបន្ទប់ទុកដាក់អាងស្តុកត្រឹមត្រូវ ដើម្បីរក្សាអនាម័យ សីតុណ្ហភាព ក្នុងការធានាបានសុវត្ថិភាពនិងគុណភាពទឹក។ បន្ថែមពីនេះ ទឹកប្រើប្រាស់ក្នុងមន្ទីរពេទ្យត្រូវបានត្រួតពិនិត្យដោយមន្ត្រីជំនាញក្នុងផ្នែកពិសោធន៍របស់អង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម ដោយធ្វើតេស្តនៅក្នុងអង្គភាពដើម្បីពិនិត្យរកក្លរីសំណល់ និងកម្រិត PH នៅរៀងរាល់២ដងក្នុងមួយខែ ដើម្បីធានាបាននូវគុណភាពទឹក និងសុវត្ថិភាពក្នុងការប្រើប្រាស់ទូទៅ និងអាចទទួលទានបាន[៤០]។ បន្ថែមពីនេះទៀត ដើម្បីធានាបានថា ទឹកដែលត្រូវបានផ្គត់ផ្គង់ដោយអង្គភាពខាងលើមានគុណភាពសម្រាប់អ្នកប្រើប្រាស់ទទួលទានបាន ទឹកត្រូវបានធ្វើតេស្តនិងត្រួតពិនិត្យពីស្តង់ដាគុណភាពទឹកនៅរៀងរាល់៣ ខែម្តងមុននឹងបង្ហូរចូលទៅក្នុងអាងស្តុកទឹករបស់មន្ទីរពេទ្យ អំពីកម្រិតនៃសារធាតុចំនួន១៥ប្រភេទនៅក្នុងទឹកដូចជា Color, Turbidity, PH, Chlorine, Total Dissolved Solids, Manganese, Sulfate (S04), Chloride, Iron, Ammonia (NH3-N), E-Coli, Total Coliform, Aseanic, Alkalinity,

[៤០] ឯកសាររបស់អង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការធ្វើតេស្តរកក្លរីសំណល់ និង PH តាមផ្ទះ២ដងក្នុងមួយខែ។

and Conductivity[៥១]។ លើសពីនេះ ជាមធ្យមមន្ទីរពេទ្យទាំងមូលប្រើប្រាស់ទឹកស្អាតអស់ចំនួន៥៣៥០ម៉ែត្រត្រីគុណក្នុង១ខែ ហើយក្នុងករណីមានបញ្ហាដាច់ទឹកពីអាងស្តុកមេរបស់អង្គភាពរដ្ឋាករទឹកខាងលើ មន្ទីរពេទ្យមានអាងស្តុកទឹកទំហំ១២៤ម៉ែត្រត្រីគុណ និងអាងស្តុកទឹកបន្ទាប់នៅលើអគារផ្សេងទៀតទំហំ៩ម៉ែត្រត្រីគុណ ដើម្បីផ្គត់ផ្គង់ជាបណ្តោះ-អាសន្នសម្រាប់ការប្រើប្រាស់ក្នុងរយៈពេលចំនួន២ថ្ងៃបន្តទៀត[៥២]។ លើសពីនេះទៀត ដើម្បីធានានិរន្តរភាពនៃការថែទាំនិងការផ្គត់ផ្គង់ទឹកស្អាតក្នុងមន្ទីរពេទ្យ គណៈគ្រប់គ្រងមន្ទីរពេទ្យបានចាត់បុគ្គលិកក្នុងផ្នែករោងជាងសរុបចំនួន៣រូប ដោយបែងចែកវេនប្រចាំការទាំងថ្ងៃទាំងយប់ ដើម្បីទទួលរ៉ាប់រង តាមដាន ត្រួតពិនិត្យ ថែទាំ និងជួសជុលអាងស្តុកទឹកនិងបណ្តាញទឹកតាមអគារនៃផ្នែកនីមួយៗ។

ដោយឡែក ទឹកស្អាតសម្រាប់ផ្គត់ផ្គង់ដល់បុគ្គលិកពេទ្យ អ្នកជំងឺ និងអ្នកកំដរអ្នកជំងឺទទួលទាន មន្ទីរពេទ្យបានយកទឹកស្អាតខាងលើមកដាក់ក្នុងធុងទឹកចម្រោះ ដែលមាននៅតាមមុខបន្ទប់របស់ផ្នែកនីមួយៗ និងមុខបន្ទប់អ្នកជំងឺ ឬអ្នកប្រើប្រាស់សេវាក្នុងមន្ទីរពេទ្យ។ បន្ថែមពីនេះ ប្រធានផ្នែក និងបុគ្គលិកពេទ្យក្នុងផ្នែកនីមួយៗត្រូវមានកាតព្វកិច្ចពិនិត្យ ថែទាំ អនាម័យ និងរក្សាទឹកក្នុងធុងចម្រោះឱ្យមានជាប់ជានិច្ច[៥៣]។

៣.៥.៥.២. ការបំពុលដោយភ្លិន និងសម្លេង

ការរក្សាបរិស្ថានខ្យល់បរិសុទ្ធក៏ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការរក្សាបរិស្ថានស្អាតដែរ អាស្រ័យហេតុនេះ គណៈគ្រប់គ្រងមន្ទីរពេទ្យបានយកចិត្តទុកដាក់និងបានរៀបចំការគ្រប់គ្រងលើផ្នែកទាំងបីគឺ ការគ្រប់គ្រងការបំពុលដោយផ្សែង សម្លេង និងក្លិននៅក្នុង

[៥១] ឯកសាររបស់អង្គភាពរដ្ឋាករទឹកខេត្តកំពង់ចាម ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការធ្វើតេស្តលើប៉ារ៉ាម៉ែត្រទាំងអស់ (ធ្វើតេស្តរៀងរាល់៣ខែម្តង)។

[៥២] ការសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០។

[៥៣] ការសម្ភាសន៍ជាមួយលោកស្រីវេជ្ជបណ្ឌិត ចាប់ ច័ន្ទធិតា អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២០។

បរិវេណមន្ទីរពេទ្យ។ ដើម្បីធានាបាននូវការគ្រប់គ្រងប្រភពនៃការបំពុលបរិស្ថានខ្យល់ ដោយផ្តោតលើផ្នែកទាំងបីខាងលើឱ្យមានប្រសិទ្ធភាព មិនឱ្យមានផ្សែង មិនមានក្លិនអាក្រក់ និងមិនមានសំលេងរំខាន គណៈគ្រប់គ្រងបានប្រើប្រាស់យន្តការចំនួនប្រាំដូចខាងក្រោម÷

យន្តការទី១គឺការប្រើប្រាស់វិធានសម្រាប់ការណែនាំជាទូទៅនៅក្នុងមន្ទីរពេទ្យ រួមមានអត្ថបទអប់រំទាក់ទងនឹងការសម្អាតបរិស្ថានក្នុងមន្ទីរពេទ្យនិងបទបញ្ជាផ្ទៃក្នុង ដោយចែកជូនដល់អ្នកប្រើប្រាស់សេវា និងបិទផ្សព្វផ្សាយនៅតាមមុខបន្ទប់នៃផ្នែកនីមួយៗ ដែលមានខ្លឹមសារជារួម ១)ការទុកដាក់សំរាមក្នុងធុង ២)ការហាមមិនឱ្យជក់បារី ៣)ហាមមិនឱ្យមានការបង្កសំឡេងរំខានអ្នកដទៃ និង ៤)ការរៀបចំទុកដាក់ហាលសំលៀកបំពាក់នៅក្រោយអគារវះកាត់ជាដើម។ ដោយឡែកការប្រើប្រាស់វិធានសម្រាប់គ្រប់គ្រងអ្នកលក់នំចំណីអាហារ គណៈគ្រប់គ្រងបានរៀបចំជាលិខិតជូនដំណឹង[៩៤]ផ្សព្វផ្សាយដល់អ្នកលក់នំចំណីអាហារទាំងក្នុងនិងជុំវិញបរិវេណមន្ទីរពេទ្យ ដើម្បីឱ្យពួកគាត់ជួយអប់រំដល់អ្នកទិញអំពីការទុកដាក់សំរាមក្នុងធុង ការហាមជក់បារីក្នុងបរិវេណមន្ទីរពេទ្យ និងជួយថែរក្សាសម្អាតបរិស្ថានកុំឱ្យមានក្លិនអាក្រក់។

យន្តការទី២គឺការសម្អាតបរិស្ថានឬអនាម័យទូទៅ÷ គណៈកម្មការត្រួតពិនិត្យនិងបង្ការការចម្លងរោគបានជំរុញឱ្យគណៈកម្មការថែទាំ ធ្វើការគ្រប់គ្រង និងដឹកនាំបុគ្គលិកអនាម័យទាំងអស់អនុវត្តការងារអនាម័យទាំងនៅក្រៅអគារ ទាំងនៅក្នុងអគារ។ ជារួមចំពោះការងារអនាម័យក្រៅអគារ បុគ្គលិកអនាម័យត្រូវប្រមូលកាកសំណល់ទូទៅ សម្អាតស្មៅនៅក្នុងទីធ្លានិងសួនច្បារ និងត្រូវសម្អាតជញ្ជាំងខាងក្រៅអគារឱ្យស្អាត។ បន្ថែមពីនេះនៅក្នុងទីធ្លា សួនច្បារ និងជុំវិញអគារត្រូវបានថែទាំមិនឱ្យមានភក់ជ្រាំ លាមកសត្វ ឬមនុស្សកុំឱ្យមានក្លិនស្អុយក្នុងបរិវេណទាំងនោះ[៩៥]។ បន្ថែមពីនេះទៀតរាល់កាកសំណល់ទូទៅទាំងអស់ត្រូវរក្សាទុកនៅក្នុងទីកន្លែងស្តុកកាកសំណល់រួមរបស់មន្ទីរពេទ្យ មុននឹងរថយន្ត

[៩៤] លិខិតជូនដំណឹងរបស់មន្ទីរពេទ្យខេត្តកំពង់ចាម។

[៩៥] ខ្លឹមសារនៃបញ្ជីវាយតំលៃតាមដានសកម្មភាពបង្ការនិងត្រួតពិនិត្យការចម្លងរោគមន្ទីរពេទ្យខេត្តកំពង់ចាម។

របស់ក្រុមហ៊ុនសុិនទ្រីមកប្រមូលចេញ។ ការអនុវត្តជាក់ស្តែង កាកសំណល់ទូទៅគឺមិនត្រូវបានដុតកំទេចនៅក្នុងបរិវេណ ឬឡដុតសំរាមរបស់មន្ទីរពេទ្យនោះទេ។ កាកសំណល់ខាងលើនេះ ត្រូវបានដឹកចេញពីកន្លែងស្តុកបណ្តោះអាសន្នរួមរបស់មន្ទីរពេទ្យ ដែលក្នុងមួយថ្ងៃគឺរថយន្តសុិនទ្រីដឹកចេញម្តងទៅកាន់ទីកន្លែងស្តុកកាកសំណល់រួមរបស់ខេត្ត[៩៦]។ យន្តការនេះគឺជាផ្នែកមួយ ដែលមិនអាចឱ្យកាកសំណល់រលួយស្អុយ និងមិនមានផ្សែងក្នុងបរិវេណរបស់មន្ទីរពេទ្យបាននោះទេ។ យោងតាមការសង្កេតជាក់ស្តែង កាកសំណល់សរីរាង្គគឺត្រូវបានយកទៅកន្លែងស្តុកកាកសំណល់វេជ្ជសាស្ត្របណ្តោះអាសន្ន និងទំលាក់ចូលក្នុងអាងស្តុកកាកសំណល់សរីរាង្គ ដោយបានរៀបចំបិទជិតយ៉ាងត្រឹមត្រូវ និងមិនមានក្លិនស្អុយចេញមកខាងក្រៅបាន។ ចំណែកឯកាកសំណល់វេជ្ជសាស្ត្រ សំណល់គីមី និងលោហៈធ្ងន់ ក៏នឹងត្រូវយកទៅទុកដាក់ក្នុងកន្លែងស្តុកកាកសំណល់វេជ្ជសាស្ត្របណ្តោះអាសន្ន មុននឹងត្រូវបានដុតកំទេចដោយឡបរិស្ថានរបស់មន្ទីរពេទ្យ។ លើសពីនេះទៀតការអនាម័យក្នុងអគារដោយផ្តោតសំខាន់លើផ្នែកបន្ទប់អ្នកជំងឺ ឬកន្លែងអ្នកជំងឺប្រើប្រាស់ និងបន្ទប់ផ្នែកបុគ្គលិកពេទ្យឬទីកន្លែងបុគ្គលិកពេទ្យប្រើប្រាស់គឺនៅមុខបន្ទប់មានស្លាកឈ្មោះអ្នកទទួលខុសត្រូវម្នាក់ ដែលជាអ្នកដឹកនាំ និងគ្រប់គ្រងបុគ្គលិកនៅក្នុងផ្នែកនោះត្រូវបំពេញកិច្ចការអនាម័យមួយចំនួនដូចជាត្រូវសម្អាតអនាម័យជានិច្ចនូវទ្វារ បង្ហួច ជញ្ជាំង ពិដាន កង្ហារ គ្រែអ្នកជំងឺ និងកំរាលឥដ្ឋក្នុងបន្ទប់ ដើម្បីកាត់បន្ថយការឆ្លងរោគ និងក្លិនមិនល្អ។ រីឯបន្ទប់ទឹកនិងបង្គន់អនាម័យគឺពុំមានក្លិនមិនល្អនោះទេ ព្រោះមានទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ មានសាប៊ូ មានធុងសំរាមដែលមានគំរបត្រឹមត្រូវ និងមានកាលវិភាគសម្អាតទៀងទាត់[៩៧]។

យន្តការទី៣គឺការគ្រប់គ្រងកាកសំណល់ក្នុងផ្នែកនីមួយៗ÷ គណៈកម្មការត្រួតពិនិត្យ និងបង្ការការចម្លងរោគរបស់មន្ទីរពេទ្យបានពិនិត្យ និងផ្ទៀងផ្ទាត់រៀងរាល់ខែ ដោយវាយតម្លៃលើការងារក្នុងផ្នែកនីមួយៗដើម្បីធានាការរក្សាអនាម័យមិនឱ្យមានក្លិនស្អុយ ឬក្លិនមិនល្អ

[៩៦] ការសម្ភាសន៍ជាមួយលោកស្រីវេជ្ជបណ្ឌិត ចាប់ ច័ន្ទធិតា អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០។

[៩៧] -ជ-

ផ្សេងៗ។ បន្ថែមពីនេះ ដើម្បីជំរុញឱ្យអ្នកទទួលខុសត្រូវ នាយសាល និងមន្ត្រីក្នុងផ្នែកនីមួយៗអនុវត្តការងារគ្រប់គ្រងសំណល់បានល្អត្រឹមត្រូវគឺបុគ្គលិកនៅក្នុងផ្នែកទាំងអស់ត្រូវធានាឱ្យបានខ្ជាប់ខ្ជួននូវវិធាន រួមមាន÷ ១)ការរៀបចំធុងសំរាមនិងថង់សំណល់ប្រើប្រាស់បានគ្រប់គ្រាន់ ២)ធុងសំរាមត្រូវមានគំរបត្រឹមត្រូវ ៣)យកសំណល់ចេញពីធុងនៅពេលមានចំណុះពាក់ភាគ៤ ៤)សម្អាតទីកន្លែងទុកដាក់ធុងនិងថង់សំណល់ ៥)ទុកដាក់សំណល់នៅទីតាំងត្រឹមត្រូវដោយមិនត្រូវឱ្យពេញធុងនិងត្រូវវេចខ្ចប់ត្រឹមត្រូវ និង ៦)ត្រូវយកសំណល់ចេញពីផ្នែកជាទៀងទាត់មិនទុកយូរថ្ងៃនិងមិនមានក្លិនស្អុយ។

យន្តការទី៤គឺការគ្រប់គ្រងបញ្ហាផ្សេង÷ គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំបដាធំៗបង្ហាញរូបភាពហាមជក់បារីក្នុងបរិវេណមន្ទីរពេទ្យ ក៏ដូចជាការបិទស្លាកសញ្ញាហាមជក់បារី នៅតាមរបងមន្ទីរពេទ្យ និងជញ្ជាំងអគារទាំងក្នុងបន្ទប់ ទាំងក្រៅបន្ទប់នៃផ្នែកនីមួយៗ ដើម្បីជាការដាស់តឿនដល់បុគ្គលិកមន្ទីរពេទ្យ អ្នកកំដរអ្នកជំងឺ និងអ្នកជំងឺផងដែរ។ ចំណែកចង្ក្រានបាយរបស់មន្ទីរពេទ្យ ត្រូវបានរៀបចំនៅដាច់ដោយឡែកឆ្ងាយពីអគាររបស់អ្នកជំងឺ និងបុគ្គលិក ដោយមានការរៀបចំប្រព័ន្ធបំពង់ផ្សែងបង្ហុយទៅលើត្រឹមត្រូវ។ ចំណែកឡសម្អាតបរិស្ថានដែលជាឡដុតសំរាមវេជ្ជសាស្ត្រ កាកសំណល់ឆ្លងរោគ និងកាកសំណល់គីមី ជាឡមានបច្ចេកទេសខ្ពស់ ក៏ត្រូវបានរៀបចំទុកដាក់ក្នុងរោងត្រឹមត្រូវនៅដាច់ដោយឡែកឆ្ងាយពីអគារបុគ្គលិកពេទ្យ និងអ្នកជំងឺ។ បន្ថែមពីនេះ ឡសម្អាតបរិស្ថាននេះមានបច្ចេកទេសខ្ពស់ ដែលត្រូវបានរៀបចំឱ្យមានបំពង់ផ្សែងអង្កត់ផ្ចិត២៤០មម កំពស់ ៩ម៉ែត្រ ត្រូវបានបំពាក់ដោយធុងទឹកកំពស់១២០០មម អង្កត់ផ្ចិត៥០០មម និងមានចំណុះ ០.៣ម៉ែត្រគ្រឹតគុណ ដើម្បីជួយកាត់បន្ថយជាតិពុលក្នុងផ្សែង ព្រមទាំងបំពេញដោយចំហាយមានសីតុណ្ហភាព១០០អង្សារដល់១៥០អង្សារ និងកាត់បន្ថយផ្សែងពុល ព្រមទាំងធ្វើឱ្យកម្ទេចកម្ទីធ្លាក់ចុះទៅក្នុងទឹកដើម្បីកាត់បន្ថយសីតុណ្ហភាព។ បន្ថែមពីនេះទៀតប្រព័ន្ធឡមានទឹកត្រជាក់ ដែលបានពីការធ្វើរង្វិលពីទឹកនៅក្នុងធុងមកបូមស្រោចពីលើសម្រាប់កាត់បន្ថយសីតុណ្ហភាពនិងផ្សែង កម្ទេចកម្ទី និងក្លិន ហើយបន្ទាប់មកត្រូវបានភាយទៅ

ក្នុងបរិយាកាស[៩៨]។

យន្តការទី៥គឺការគ្រប់គ្រងសម្ភេងក្នុងបរិវេណមន្ទីរពេទ្យ÷ យោងតាមការសង្កេតជាក់ស្តែង ដើម្បីធានាសណ្តាប់ធ្នាប់មិនឱ្យមានសំលេងស៊ីផ្លេរបស់យានយន្តគ្រប់ប្រភេទរំខានដល់អ្នកជំងឺ គណៈគ្រប់គ្រងមន្ទីរពេទ្យ និងអាជ្ញាធរក្រុងបានរៀបចំស្ថាកសញ្ញាហាមស៊ីផ្លេរនៅផ្នែកខាងក្រៅបរិវេណមន្ទីរពេទ្យតាមបទដ្ឋានច្បាប់ចរាចរណ៍យ៉ាងត្រឹមត្រូវ។ ទន្ទឹមនឹងនេះ ការរៀបចំចំណតម៉ូតូនៅខាងក្នុងបរិវេណមន្ទីរពេទ្យមានច្រកចេញចូលតែមួយ ដើម្បីជៀសវាងការបើកបរចូលក្នុងបរិវេណមន្ទីរពេទ្យពាសវាលពាសកាលនិងការរំខានដោយសំលេង។ លើសពីនេះ ដើមឈើដែលបានដាំជុំវិញបរិវេណមន្ទីរពេទ្យ និងក្នុងបរិវេណមន្ទីរពេទ្យគឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការកាត់បន្ថយសម្ភេងបញ្ចេញដោយយានយន្ត ឬម៉ូតូ បើកបរតាមផ្លូវសាធារណៈ មិនឱ្យឮសម្ភេងរំខានចូលក្នុងបរិវេណមន្ទីរពេទ្យបាន។

៣.៥.៦. ការចាត់តាំងអនុវត្តការងាររបស់ក្រុមត្រួតពិនិត្យការបង្ការ និងការត្រួតពិនិត្យការចម្លងរោគក្នុងមន្ទីរពេទ្យ

ទោះបីជាមានវិធាន ធនធានមនុស្ស ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់យ៉ាងណាក៏ដោយ ប្រសិនបើក្នុងអង្គភាពនេះគ្មានការរៀបចំយន្តការក្នុងការគ្រប់គ្រង ដឹកនាំ ចាត់ចែង និងត្រួតពិនិត្យយ៉ាងហ្មត់ចត់នោះទេ ភាពជឿជាក់ពីអ្នកប្រើប្រាស់សេវាលើគុណភាព និងសុវត្ថិភាពក្នុងវិស័យសុខាភិបាលរបស់មន្ទីរពេទ្យខេត្តកំពង់ចាមនឹងត្រូវបាត់បង់។ អាស្រ័យដូចនេះហើយ យោងតាមសេចក្តីសម្រេចរបស់ប្រធានមន្ទីរពេទ្យ បានកំណត់ និងរៀបចំក្រុមត្រួតពិនិត្យការបង្ការ និងការត្រួតពិនិត្យការចម្លងរោគក្នុងមន្ទីរពេទ្យ សម្រាប់អនុវត្តការងារជាប្រចាំមួយចំនួន ដើម្បីធានាបានគុណភាព សុវត្ថិភាពក្នុងការព្យាបាល និងអនាម័យខ្ពស់។

ដើម្បីធានាបានការទប់ស្កាត់ការរាលដាលនៃការចម្លងរោគក្នុងមន្ទីរពេទ្យខេត្តកំពង់ចាម

[៩៨] សៀវភៅគោលស្តីពីដំណើរការបច្ចេកទេសឡសម្អាតបរិស្ថាន ECOLAND-50 និង ECOLAND-100។

និងធានាបាននិរន្តរភាពនៃការទប់ស្កាត់ខាងលើនេះឱ្យស្របទៅតាមគោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគនៅក្នុងមូលដ្ឋានព្យាបាល និងថែទាំសុខភាពរបស់ក្រសួងសុខាភិបាល សំដៅបង្ការនិងទប់ស្កាត់ជំងឺឆ្លងផ្សេងៗក្នុងមន្ទីរពេទ្យសម្រាប់សុវត្ថិភាពអ្នកជំងឺ ក្រុមគ្រួសារ និងបុគ្គលិកមន្ទីរពេទ្យទាំងមូល គណៈគ្រប់គ្រងមន្ទីរពេទ្យបានបង្កើតក្រុមត្រួតពិនិត្យនិងបង្ការចម្លងរោគ ដែលមានតួនាទីភារកិច្ចច្បាស់លាស់។ គណៈកម្មការត្រួតពិនិត្យនិងបង្ការការចម្លងរោគរបស់មន្ទីរពេទ្យកំពង់ចាមមានសមាសភាព÷ ១)អនុប្រធានមន្ទីរពេទ្យ០១រូប ជាប្រធាន ២)ប្រធានថែទាំ០១រូប ជាអនុប្រធាន ៣)ប្រធានផ្នែកវះកាត់០១រូប ជាអនុប្រធាន ៤)បុគ្គលិកផ្នែកបច្ចេកទេស០១រូប ជាលេខា ៥)ប្រធានផ្នែករដ្ឋបាល០១រូប ជាសមាជិក ៦)ប្រធានផ្នែកគណនេយ្យ០១រូប ជាសមាជិក ៧)ប្រធានផ្នែកមន្ទីរពិសោធន៍០១រូប ជាសមាជិក ៨)ប្រធានផ្នែក និងនាយសាលគ្រប់ផ្នែកទាំងអស់ជាសមាជិក[៩៩]។

ដោយឡែក ប្រធានផ្នែកនិងនាយសាលគ្រប់ផ្នែកទាំងអស់ ដែលជាសមាជិកអនុគណៈកម្មការត្រួតពិនិត្យនិងបង្ការការចម្លងរោគ ជួយគាំទ្រនិងបំពេញការងារជាមួយនឹងគណកម្មការខាងលើ និងបុគ្គលិកតាមផ្នែកនីមួយៗក្នុងមន្ទីរពេទ្យ។

លើសពីនេះ របៀបរបបការងាររបស់គណៈកម្មការខាងលើត្រូវមានភារកិច្ចពិភាក្សានិងការសម្រេចចិត្តរាល់បញ្ហា ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងបង្ការការចម្លងរោគក្នុងមន្ទីរពេទ្យ ដោយធ្វើការប្រជុំជាទៀងទាត់ប្រចាំខែជាមួយប្រធានមន្ទីរពេទ្យ និងអនុគណៈកម្មការត្រួតពិនិត្យនិងបង្ការការចម្លងរោគ[៩០០]។ បន្ថែមពីនេះ គណៈកម្មការត្រូវពិនិត្យតាមដានជាមួយអនុគណៈកម្មការខាងលើ ដើម្បីចុះទៅអភិបាលនិងវាយតម្លៃតាមផ្នែកនីមួយៗ ដោយអនុវត្តជាប្រចាំចំនួន២ដងក្នុង១ខែនៅរៀងរាល់ដើមសប្តាហ៍ទី១ និងចុងសប្តាហ៍ទី៣។ បន្ទាប់ពីធ្វើការវាយតម្លៃរួច គណៈកម្មការនេះ នឹងប្រជុំបូកសរុបលទ្ធផល

[៩៩] លិខិតបង្គាប់ការលេខ៥៣៣ មព.កច របស់មន្ទីរពេទ្យខេត្តកំពង់ចាម ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

[៩០០] សេចក្តីសម្រេចរបស់ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាមចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ ស្តីពីតួនាទីរបស់ក្រុមត្រួតពិនិត្យនិងបង្ការការចម្លងរោគក្នុងមន្ទីរពេទ្យខេត្តកំពង់ចាម។

វាយតម្លៃខាងលើជាទៀងទាត់រៀងរាល់ប្រចាំខែជាមួយប្រធានមន្ទីរពេទ្យ និងអនុគណៈកម្មការនេះ។ លើសពីនេះ បន្ទាប់ពីទទួលបានលទ្ធផលវាយតម្លៃរួច អនុគណៈកម្មការខាងលើនឹងប្រជុំជាទៀងទាត់ក្នុងផ្នែកនីមួយៗដើម្បីផ្តល់លទ្ធផលវាយតម្លៃ និងផ្តល់ព័ត៌មានត្រឡប់ទៅតាមបណ្តាផ្នែកដើម្បី ស្វែងរកបញ្ហា ធ្វើផែនការ និងមានវិធានការណ៍កែលម្អចំណុចខ្វះខាតឱ្យមានភាពប្រសើរឡើងវិញ និងធ្វើការណែនាំអប់រំបណ្តុះបណ្តាលបុគ្គលិកក្នុងផ្នែកនីមួយៗបន្ថែមទៀត។

ប៉ុន្តែក្នុងស្ថានភាពជាក់ស្តែងការអនុវត្តរបស់អនុគណៈកម្មការមិនមានភាពរលូន ដើម្បីឱ្យការបំពេញភារកិច្ចរបស់គណៈកម្មការត្រួតពិនិត្យខាងលើជំណើរការប្រសើរបាន គណៈកម្មការខាងលើបានបែងចែកក្រុមប្រតិបត្តិការងារតូចៗជា៥ ក្រុមដាច់ដោយឡែកផ្សេងគ្នា ដែលមានសមាសភាពក្នុងមួយក្រុមចំនួន៥នាក់ ហើយក្នុងចំណោមសមាសភាពរបស់ក្រុមត្រូវមានកម្រិតបច្ចេកទេសចាប់ពីគិលានុបដ្ឋាករហូតដល់កម្រិតវេជ្ជបណ្ឌិតដែលស្ថិតក្នុងឯកទេសពាក់ព័ន្ធនឹងសេវានៃផ្នែកទាំងនោះ[១០១]។

ជាក់ស្តែង ផ្នែកទាំង២៦ខាងលើ ត្រូវបានបែងចែកជា៥ចង្កោមសេវាច្បាស់លាស់សម្រាប់ក្រុមនីមួយៗទទួលបន្ទុកដោយឡែកពីគ្នា។ បន្ថែមពីនេះ ក្រុមប្រតិបត្តិការងារត្រូវទទួលបន្ទុកវាយតម្លៃដោយអនុវត្តជាប្រចាំចំនួន២ ដងក្នុង១ ខែនៅរៀងរាល់ដើមសប្តាហ៍ទី១ និងចុងសប្តាហ៍ទី៣[១០២] និងត្រូវរៀបចំបញ្ជីវាយតម្លៃទៅតាមផ្នែកនីមួយៗនូវក្រដាសលទ្ធផលផ្សេងពីគ្នា ដែលមានខ្លឹមសារ និងសូចនាករវាស់វែងពិន្ទុតាមវិស័យនីមួយៗ។ ជាទូទៅ ខ្លឹមសារសំខាន់នៃបញ្ជីវាយតម្លៃគឺជាសូចនាករវាស់វែងកិច្ចការបង្ការ និងទប់ស្កាត់ការចម្លងរោគនៅតាមផ្នែកនីមួយៗគឺផ្តោតសំខាន់ទៅលើការពិនិត្យ និងវាយតម្លៃដាក់ពិន្ទុខ្ពស់បំផុតចំនួន១០០ពិន្ទុ ដែលត្រូវបានបែងចែកទៅតាមវិស័យគឺ ១)ការ

[១០១] ប្រសាសន៍លោកស្រីវេជ្ជបណ្ឌិត ចាប់ ច័ន្ទធិតា អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០។

[១០២] បញ្ជីរាយនាមក្រុមដែលត្រូវវាយតម្លៃការត្រួតពិនិត្យនិងបង្ការការចម្លងរោគតាមបណ្តាផ្នែកក្នុងមន្ទីរពេទ្យខេត្តកំពង់ចាមលើកទី១ (សប្តាហ៍ទី១) និងទី២ (សប្តាហ៍ទី៣) ខែតុលា ឆ្នាំ២០១៨។

ធ្វើអនាម័យដៃ មានសូចនាករផ្តល់តម្លៃខ្ពស់បំផុត២៥ពិន្ទុ ២)ការគ្រប់គ្រងសំណល់ក្នុងផ្នែក ដោយពិនិត្យលើការរៀបចំឱ្យមានធុងសំរាម បែងចែកប្រភេទសំណល់ ការទុកដាក់ត្រឹមត្រូវ មានសូចនាករផ្តល់តម្លៃខ្ពស់បំផុត២៥ពិន្ទុ ៣)ការសម្អាតបរិស្ថាន អនាម័យទូទៅនៅក្រៅអគារនិងក្នុងអគារ (បន្ទប់អ្នកជំងឺ ទីកន្លែងអ្នកជំងឺប្រើប្រាស់ ផ្នែកបុគ្គលិកពេទ្យ និងទីកន្លែងបុគ្គលិកពេទ្យប្រើប្រាស់) មានសូចនាករផ្តល់តម្លៃខ្ពស់បំផុត២៥ពិន្ទុ និង ៤)ការអប់រំសុខភាព និងអនាម័យដល់អ្នកជំងឺ អ្នកកំដរ ឬសាច់ញាតិរបស់អ្នកជំងឺ ជាប្រចាំសប្តាហ៍ មានសូចនាករផ្តល់តម្លៃខ្ពស់បំផុត២៥ពិន្ទុ[១០៣]។

ជារួមពាក់ព័ន្ធនឹងការងារបរិស្ថាន ថ្នាក់ដឹកនាំមន្ទីរពេទ្យបាន រៀបចំផែនការ បែងចែកការទទួលខុសត្រូវ គ្រប់គ្រង តាមដានត្រួតពិនិត្យ និងបង្កើតឱ្យមានកម្មវិធីប្រឡងប្រណាំងនៅតាមផ្នែកនីមួយៗ។ ជាមួយគ្នាដែរ ក៏មានការចូលរួមពីបុគ្គលិកនៅតាមផ្នែកនីមួយៗ យ៉ាងសកម្ម ក្នុងការរៀបចំបរិស្ថានរបស់មន្ទីរពេទ្យទាំងមូលឱ្យមានភាពកាន់តែល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

[១០៣] យោង Indicator សម្រាប់ផ្តល់ពិន្ទុក្នុងបញ្ជីវាយតម្លៃតាមដានសកម្មភាពបង្ការនិងត្រួតពិនិត្យការចម្លងរោគមន្ទីរពេទ្យខេត្តកំពង់ចាម




ទីធ្លាបរិវេណមន្ទីរពេទ្យ



ផ្ទាំងប៉ាណូផ្សព្វផ្សាយស្តីពីបរិស្ថាន



ថ្នាក់ដឹកនាំនិងបុគ្គលិកមន្ទីរពេទ្យធ្វើអនាម័យ



រូបភាពខាងក្នុងអគារនៃមន្ទីរពេទ្យ



កន្លែងអង្គុយលំហែរនៅបរិវេណបន្ទីរពេទ្យ






បន្ទប់អនាម័យនៅមន្ទីរពេទ្យ

៣.៦. ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូរអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ

ភាពរឹងមាំ ខ្លាំង និងជោគជ័យរបស់មន្ទីរពេទ្យមួយ ពុំមែនផ្តោតតែលើការពង្រឹងការគ្រប់គ្រងផ្នែកខាងក្នុងប៉ុណ្ណោះទេ គឺត្រូវពង្រឹងផ្នែកខាងក្រៅផងដែរ តាមរយៈការបង្កើន និងពង្រីកការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អជាមួយអ្នកពាក់ព័ន្ធនានា ដូចជាប្រជាពលរដ្ឋ សហគមន៍ អង្គការសមាគម និងដៃគូអភិវឌ្ឍផ្សេងៗ ព្រមទាំងអាជ្ញាធរដែនដី ដើម្បីកៀរគរការគាំទ្រទាំងធនធាន ទាំង ជំនួយបច្ចេកទេស។ មន្ទីរពេទ្យខេត្តកំពង់ចាមបានអនុវត្តយន្តការពង្រឹងការទំនាក់ទំនងល្អពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីជួយជ្រោមជ្រែង និងគាំទ្រដល់ដំណើរការនៃការផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យប្រព្រឹត្តទៅដោយរលូន ប្រកបដោយគុណភាព និងប្រសិទ្ធភាព ព្រមទាំងការរៀបចំឱ្យមានគណៈកម្មាការ និងអនុគណៈកម្មការពាក់ព័ន្ធមួយចំនួនដើម្បីសម្រួលដល់កិច្ចដំណើរការការងាររបស់មន្ទីរពេទ្យ។

៣.៦.១. ការរៀបចំគណៈកម្មការ និងអនុគណៈកម្មការ

មន្ទីរពេទ្យបានរៀបចំសមាសភាពគណៈកម្មការគ្រប់គ្រងសេវាហិរញ្ញប្បទាន អនុគណៈកម្មការត្រួតពិនិត្យតាមដាននិងអនុគណៈកម្មការផ្តត់ផ្តង់និងលទ្ធកម្ម[១០៤] ដោយតួនាទី និងភារកិច្ចនៃគណៈកម្មការ អនុគណៈកម្មការនេះ បានផ្តោតជាសំខាន់ពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាមូលនិធិសមធម៌ ការពិនិត្យនិងផ្តល់យោបល់ ការលើកលែងបង់ថ្លៃចំពោះប្រជាជនក្រីក្រប្រកបដោយសមធម៌និងយុត្តិធម៌ ការដោះស្រាយរាល់ការងារមិនប្រក្រតី ការជួយកែលម្អគុណភាពសេវា ការតាមដានលើអាកប្បកិរិយារបស់បុគ្គលិកពេទ្យ និងការស្រាវជ្រាវនិងរិះរកវិធានការល្អៗជូនប្រធានមន្ទីរពេទ្យ[១០៥]។

---

[១០៤] លិខិតបង្គាប់ការស្តីពីការតែងតាំងសមាសភាពគណៈកម្មការគ្រប់គ្រងសេវាហិរញ្ញប្បទាន អនុគណៈកម្មការត្រួតពិនិត្យតាមដាន និងអនុគណៈ កម្មការផ្តត់ផ្តង់និងលទ្ធកម្ម ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ របស់មន្ទីរពេទ្យខេត្តកំពង់ចាម

[១០៥] សេចក្តីណែនាំស្តីពីការគ្រប់គ្រងសេវាហិរញ្ញប្បទានសុខាភិបាលនាខែមីនា ឆ្នាំ២០១១

៣.៦.២. ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ និងសហគមន៍

មន្ទីរពេទ្យបានគិតគូរដល់ការលើកលែងការបង់ថ្លៃសេវាដល់អ្នកជំងឺក្រីក្រ និងអ្នកជំងឺដែលមន្ទីរពេទ្យបានកំណត់រួមមាន ព្រះសង្ឃ ជនពិការ កុមារកំព្រា ជនអនាថា និងពិរុទ្ធជន ឬទណ្ឌិត[១០៦]។ មន្ទីរពេទ្យបានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់សាធារណជនទូទៅ ដែលមកទទួលសេវានៅមន្ទីរពេទ្យ និងប្រជាពលរដ្ឋនៅតាមមូលដ្ឋានដោយផ្តោតទៅលើគោលការណ៍សំខាន់ៗដូចជា ដំណើរការនៃការផ្តល់សេវា និងបញ្ហាសុខភាពជាដើម។ ទន្ទឹមនេះដែរ ក្រុមគ្រូពេទ្យបានចុះពិនិត្យ និងផ្តល់សេវាព្យាបាលជួយជនអនាថា និងអ្នកដែលមានសតិមិនគ្រប់ ដែលតាំងទីលំនៅមិនពិតប្រាកដ ដោយមានការផ្តល់ព័តិមានពីអាជ្ញាធរមានសមត្ថកិច្ច។

ក្រៅពីការលើកលែងការបង់ថ្លៃសេវាសម្រាប់ករណីខាងលើ គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍ស្តីពីតម្លៃសេវា ដោយទទួលបានមតិយោបល់អំពីតម្លៃសេវារបស់មន្ទីរពេទ្យ និងបញ្ហាផ្សេងៗ។ បន្ទាប់ពីការសម្រេចរបស់អង្គប្រជុំ និងការឯកភាពពីសហគមន៍ មន្ទីរពេទ្យបានផ្តល់ព័តិមានដល់សាធារណជនទូទៅដែលមកទទួលសេវាអំពីតម្លៃសេវារបស់មន្ទីរពេទ្យខេត្ត។ដោយឡែកសហគមន៍[១០៧]ក៏បានចូលរួមចំណែកផ្សព្វផ្សាយដល់ប្រជាពលរដ្ឋមូលដ្ឋានអំពីបញ្ហាសុខភាព និងបញ្ហាប្រឈមនានា ព្រមទាំងរាយការណ៍អំពីហិង្សាទៅអាជ្ញាធរមានសមត្ថកិច្ចផងដែរ ដើម្បីទប់ស្កាត់ស្ថានភាពគ្រោះថ្នាក់ផ្សេងៗដែលកើតឡើងជាយថាហេតុ។

តាមរយៈកិច្ចសហការ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត និងអាជ្ញាធរពាក់ព័ន្ធ បានចុះផ្សព្វផ្សាយរៀងរាល់ខែអំពីបញ្ហាសុខភាពជូនដល់សហគមន៍[១០៨]នៅតាមមូលដ្ឋាននិងពន្យល់ណែនាំអំពីការបង្ការ និងទប់ស្កាត់បញ្ហានានាដែលជាឬសគល់នាំឱ្យប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងព្យាបាលដោយមិនយកកម្រៃ។

[១០៦] សេចក្តីជូនព័តិមានស្តីពីការលើកលែងបង់ថ្លៃសេវារបស់មន្ទីរពេទ្យចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨

[១០៧] សហគមន៍ទ្រទ្រង់សុខភាព

[១០៨] សហគមន៍សុខភាពស្ត្រី និងសមាគមនារី

លើសពីនេះ ដើម្បីបំផុសឱ្យមានការចូលរួមពីប្រជាពលរដ្ឋ គណៈគ្រប់គ្រងមន្ទីរពេទ្យ បានបង្កើតនូវកម្មវិធីក្តីស្រឡាញ់ (១៤កុម្ភៈ) រៀងរាល់ឆ្នាំ ដោយប្រែក្លាយសេចក្តីស្នេហារវាងបុរសនិងនារី មកជាសេចក្តីអាណិត និងសេចក្តីស្រលាញ់ដល់ប្រជាពលរដ្ឋទូទៅដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ និងមិនរើសអើងនិន្នាការនយោបាយឡើយ ដោយការចូលរួមបរិច្ចាគឈាម ដើម្បីជួយសង្គ្រោះជីវិតរបស់អ្នកជំងឺដែលខ្វះខាតឈាម។ តាមរយៈកម្មវិធីនេះ មន្ទីរពេទ្យបានផ្តល់តម្លៃដល់អ្នកផ្តល់ឈាមដោយការប្រគល់ផ្កាមួយទងដ៏ស្រស់ស្អាត និងនំខួបកំណើតមួយប្រសិនបើចំថ្ងៃកំណើតរបស់អ្នកផ្តល់ឈាម ដើម្បីបញ្ជាក់អំពីសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកបរិច្ចាគឈាមក្នុងកម្មវិធីនេះ[១០៩]។

៣.៦.៣. ការទំនាក់ទំនងលួចាមួយអាជ្ញាធរពាក់ព័ន្ធ

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ បានផ្តល់ការគាំទ្រដល់មន្ទីរពេទ្យខេត្តកំពង់ចាម ទាំងផ្នែកខាងក្នុង និងផ្នែកខាងក្រៅ ក្នុងនោះរួមមាន ការរៀបចំសណ្តាប់ធ្នាប់ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានជុំវិញបរិវេណរបស់មន្ទីរពេទ្យ។ ទន្ទឹមនេះដែរ អាជ្ញាធរខេត្តបានផ្តល់អនុសាសន៍ណែនាំមួយចំនួនដើម្បីកែលម្អចំណុចខ្វះខាតរបស់មន្ទីរពេទ្យដូចជា ឥរិយាបថរបស់គ្រូពេទ្យ និងវិធានការវិន័យជាដើម។ លើសពីនេះ អាជ្ញាធរខេត្តក៏បានចុះទស្សនកិច្ចនៅមន្ទីរពេទ្យផ្ទាល់ដើម្បីបានជ្រាបអំពីព័ត៌មាននៃការផ្តល់សេវា និងតម្រូវការជាក់ស្តែងរបស់មន្ទីរពេទ្យ និងរបស់ប្រជាពលរដ្ឋ[១១០]។ បន្ថែមលើនេះ អាជ្ញាធរខេត្ត មន្ទីរសុខាភិបាល និងមន្ត្រីពាក់ព័ន្ធ បានរៀបចំវេទិកាសាធារណៈ ដើម្បីផ្សព្វផ្សាយអំពីបញ្ហាសុខភាព អប់រំ និងបរិស្ថានជូនដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឱ្យយល់ជ្រាប និងថែរក្សាសុខភាពឱ្យបានល្អ ព្រមទាំងការរស់នៅស្អាត។

អាជ្ញាធរក្រុងកំពង់ចាម បានផ្តល់កិច្ចសម្របសម្រួលជាមួយមន្ទីរពេទ្យ ក្នុងការបាញ់ថ្នាំមូស និងដាក់ថ្នាំអាល់បេត ជូនដល់ប្រជាពលរដ្ឋ និងផ្សព្វផ្សាយអំពីបញ្ហាសុខភាពផ្សេងៗ។

[១០៩] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០
[១១០] ការជួបសម្ភាសន៍ជាមួយឯកឧត្តម ហាន កុសល អភិបាលរងខេត្តកំពង់ចាម នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០

ពិសេសការថែទាំសុខភាព និងអនាម័យ។ ទន្ទឹមនេះ អាជ្ញាធរក្រុងក៏បានជួយសម្របសម្រួលដឹកជញ្ជូនអ្នកជំងឺក្រីក្រទៅកាន់មន្ទីរពេទ្យបានទាន់ពេលវេលា និងបានចុះសួរនាំភ្លាមៗ នៅពេលមានបណ្តឹងពាក់ព័ន្ធនឹងសេវាសុខាភិបាលនៅមន្ទីរពេទ្យ ព្រមទាំងជួយអន្តរាគមន៍ឆាប់រហ័សចំពោះបទល្មើសដែលបានកើតឡើងនៅមន្ទីរពេទ្យ ក៏ដូចនៅក្នុងក្រុងកំពង់ចាមទាំងមូល[១១១]។

ក្រៅពីនេះ មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាពទាំងឡាយនៃខេត្តកំពង់ចាមបានផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អតាមរយៈការបញ្ជូនអ្នកជំងឺបន្តទៅមន្ទីរពេទ្យខេត្តកំពង់ចាម ក្នុងស្ថានភាពជំងឺធ្ងន់ធ្ងរដែលពុំអាចព្យាបាលបានក្នុងកម្រិតមន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព។ បន្ថែមលើនេះ ការិយាល័យសុខុមាលភាពសង្គមនៃក្រុងកំពង់ចាម បានសហការជាមួយគ្រូពេទ្យនៃមន្ទីរពេទ្យខេត្ត និងមណ្ឌលសុខភាព បានចុះទៅសហគមន៍ ដើម្បីផ្សព្វផ្សាយអំពីសេវាសុខាភិបាលដល់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងជំងឺគ្រុនពោះវៀន ជំងឺឆ្នឹងត្រគាក ជំងឺភ្នែកឡើងបាយ បញ្ហាហៀរទឹកភ្នែក និងស្ថានភាពស្ត្រីមានផ្ទៃពោះជាដើម[១១២]។

មន្ទីរសុខាភិបាលខេត្ត បានផ្តល់ការគាំទ្រយ៉ាងសកម្មដល់មន្ទីរពេទ្យខេត្ត តាមរយៈសកម្មភាពមួយចំនួនរួមមាន ការជួសជុលអគារសង្គ្រោះបន្ទាន់និងជំងឺទូទៅ ជួសជុលរបងមន្ទីរពេទ្យ ផ្តល់ឧបករណ៍ឆ្លុះ (SCOPY) ព្រមទាំងជួយរៀបចំនិងកែលម្អកន្លែងកន្លែងបែងចែកអ្នកជំងឺជាដើម។ លើសពីនេះ មន្ទីរសុខាភិបាល បានចុះទៅពិនិត្យផ្ទាល់នៅមន្ទីរពេទ្យដើម្បីជ្រាបអំពីកង្វះខាតឧបករណ៍ និងតម្រូវការជាក់ស្តែងរបស់មន្ទីរពេទ្យផងដែរ។

៣.៦.៤. ការកៀរគរធនធាន និងសហការជាមួយដៃគូអភិវឌ្ឍ

មន្ទីរពេទ្យបានរៀបចំចាត់ចែងច្បាស់លាស់នូវការគ្រប់គ្រងចំណូលរបស់មន្ទីរពេទ្យ

[១១១] ប្រសាសន៍របស់លោក ចាន់ ផល្លី អភិបាលក្រុងកំពង់ចាម នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ នៅសាលប្រជុំសាលាក្រុងកំពង់ចាម

[១១២] ប្រសាសន៍របស់លោកស្រី អៀង សុភាបញ្ញាតិ ប្រធានការិយាល័យសង្គកិច្ច និងសុខុមាលភាព នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ នៅសាលប្រជុំសាលាក្រុងកំពង់ចាម

ដោយបានរៀបចំជាតារាងព័ត៌មានអំពីហិរញ្ញវត្ថុ និងផ្តោតលើចំណុចសំខាន់ៗចំនួន៤ រួមមាន÷ ១)ប្រភេទសេវា ២)ចំណូលជាក់ស្តែងបានទទួល ៣)ចំណូលពីគម្រោងមូលនិធិសមធម៌ និង ៤)ចំណូលពីបេឡាជាតិរបបសន្តិសុខសង្គម។ ចំណូលនីមួយៗទាំងនេះ ក៏បានកំណត់អំពីចំណូលពីគ្រាមុន ចំណូលក្នុងគ្រា និងសរុបចំណូលគិតត្រឹមគ្រា។ រីឯប្រភេទសេវា ដែលមានកំណត់ក្នុងតារាងនេះ រួមមាន÷ ចំនួនពិនិត្យជំងឺក្រៅ ជំងឺសំរាកពេទ្យ សំរាល សេវាអម សេវាបញ្ជូន និងក្រៅសេវាពីសេវា[១១៣]។

ចំពោះចំណូលក្រៅពីសេវាសុខភាព ដែលមន្ទីរពេទ្យទទួលបាន គឺតែចំនួនពីរប្រភេទប៉ុណ្ណោះ រួមមាន÷ ១)ចំណូលបានមកពីអាហារដ្ឋាន និង ២)ចំណូលបានមកពីចំណតម៉ូតូ។ ចំណូលទាំងនេះ មន្ទីរពេទ្យបានបញ្ចូលទៅក្នុងចំណូលហិរញ្ញប្បទានដែលបានមកពីការបង់សេវារបស់អ្នកជំងឺ។ ផ្អែកតាមសេចក្តីណែនាំស្តីពីការគ្រប់គ្រងសេវាហិរញ្ញប្បទានសុខាភិបាល នាខែមីនា ឆ្នាំ២០១១ ចំណូលក្រៅសេវាសុខភាព ២៥% សម្រាប់ជំនួយបង្កើនគុណភាពសេវា (មន្ទីរពេទ្យរក្សាទុក) និង៧៥% សម្រាប់បង់ចូលថវិកាជាតិ។

នៅក្នុងការកៀរគរធនធាននេះដែរ មន្ទីរពេទ្យបានធ្វើកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូអភិវឌ្ឍនានា ដែលរួមមាន÷ ១)ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ២)ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ៣)អង្គការសុខភាពពិភពលោក (WHO) ៤)អង្គការគ្រីស្តបរិសុទ្ធនៃថ្ងៃចុងក្រោយ ៥)ផ្នែកស្រាវជ្រាវវេជ្ជសាស្ត្រកងទ័ពជើងទឹកទី២របស់សហរដ្ឋអាមេរិក (U.S.NAMRU-2) ៦)មូលនិធិសកល (Global Fund) ៧)អង្គការ NANUM International ៨)កម្មវិធីអភិវឌ្ឍន៍បណ្តុះមេរោគក្នុងមន្ទីរពិសោធន៍ (DMDP) និងមូលនិធិប្រជាជនរបស់អង្គការសហប្រជាជាតិ (United Nation Population Fund: UNFPA) ជាដើម។ អង្គការទាំងនេះ បានចូលរួមយ៉ាងសកម្មក្នុងការជួយគាំទ្រដល់មន្ទីរពេទ្យខេត្តកំពង់ចាម ដោយបានផ្តល់នូវឧបករណ៍ សម្ភារ (ម៉ាស៊ីន X-Ray ឧបករណ៍បំបែកក្រួស កែវថែទាំទារក ឡដុតសំរាម និងបរិក្ខារផ្នែកធ្មេញជាដើម) និងជំនាញបច្ចេកទេស

[១១៣] ព័ត៌មានស្តីពីហិរញ្ញវត្ថុរបស់មន្ទីរពេទ្យពាក់ព័ន្ធព័ត៌មានអំពីចំណូល

តាមរយៈវគ្គបណ្តុះបណ្តាល កិច្ចប្រជុំពិគ្រោះយោបល់ និងសិក្ខាសាលានានា។ បន្ថែមពីនេះ អង្គការ JICA បានបញ្ជូនអ្នកស្ម័គ្រចិត្តជប៉ុនមួយចំនួនមកអភិវឌ្ឍ និងសិក្សាស្វែងយល់តាមរយៈកិច្ចសហប្រតិបត្តិការរវាងមន្ទីរពេទ្យ និងអង្គការ JICA។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការល្អរវាងមន្ទីរពេទ្យ និងអង្គការដៃគូ មន្ទីរពេទ្យមានយុទ្ធសាស្ត្រគន្លឹះមួយចំនួនដូចជា÷ ១)បង្កើនភាពស្និទ្ធស្នាលក្នុងអំឡុងពេលបំពេញការងារជាមួយអង្គការដៃគូ ២)មានការលះបង់ពេលវេលា និងខិតខំធ្វើការជាមួយអង្គការដៃគូ ៣)មានគោលបំណង គោលដៅច្បាស់លាស់ និងពិតប្រាកដជាមួយអង្គការដៃគូ ៤)ផ្តល់កិច្ចសហការសម្របសម្រួលដល់អង្គការដៃគូក្នុងការអនុវត្តសកម្មភាព ៥)មានពេលវេលាជួបជាមួយអង្គការដៃគូយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ និង ៦)សហការជាមួយមន្ទីរពាក់ព័ន្ធដើម្បីជួយរកអង្គការដៃគូឱ្យគាំទ្រដល់មន្ទីរពេទ្យ។

ផ្សេងពីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ មន្ទីរពេទ្យក៏បានកៀរគរសប្បុរសជននៅក្នុងការជួយជាសម្ភារ ការកសាងនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធរបវន្ត មានដូចជាគ្រែសម្រាប់អ្នកជំងឺ ការសាងសង់អគារពិនិត្យកុមារ ការជួសជុលអគារចាស់ៗ រថយន្តសង្គ្រោះអ្នកជំងឺ (Ambulance) និងការសាងសង់អគារមន្ទីរពិសោធន៍ជាដើម។

៣.៧. ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍

ដើម្បីឆ្លុះបញ្ចាំងពីគុណភាពសេវាដែលបានផ្តល់ និងដើម្បីមានព័ត៌មានសម្រាប់ធ្វើការកែលម្អគុណភាពសេវារបស់មន្ទីរពេទ្យឱ្យកាន់តែល្អប្រសើរឡើងថែមទៀត ព្រមទាំងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋនិងសហគមន៍ មន្ទីរពេទ្យបានរៀបចំឱ្យមានយន្តការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ាពីអ្នកជំងឺនិងសាធារណជន តាមរយៈប្រអប់សំបុត្រ ការជួបដោយផ្ទាល់ ទូរស័ព្ទ បណ្តាញទំនាក់ទំនងសង្គម អាជ្ញាធរមូលដ្ឋាន សហគមន៍និងដៃគូសុខាភិបាល (ក្រុមការងារមូលនិធិសមធម៌...)។ ទន្ទឹមនេះ ទីភ្នាក់ងារបញ្ជាក់ការចំណាយ (Payment Certification Agency: PCA) នៃក្រសួងសុខាភិបាល ក៏បានចុះស្ទង់មតិ (Survey) រៀងរាល់ខែ នៅតាមមូលដ្ឋានដោយសម្ភាសន៍ជាមួយប្រជាពលរដ្ឋ

ផ្ទាល់ ដើម្បីស្រង់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាសុខាភិបាលរបស់មន្ទីរពេទ្យ ជូនប្រជាពលរដ្ឋ និងរាយការណ៍ផ្តល់ព័ត៌មានត្រឡប់មកមន្ទីរពេទ្យវិញដើម្បីចាត់វិធានការ ដោះស្រាយនូវរាល់បញ្ហានានាដែលប្រជាពលរដ្ឋបានលើកឡើង។

បន្ទាប់ពីទទួលបានព័ត៌មានត្រឡប់និងបណ្តឹងតវ៉ាពីអ្នកជំងឺនិងសាធារណជនរួចមក មន្ទីរពេទ្យបានធ្វើការឆ្លើយតបឬជូនព័ត៌មានទៅវិញ តាមរយៈ÷ ១)រចនាសម្ព័ន្ធសុខាភិបាល ២)អាជ្ញាធរ ៣)ដៃគូអភិវឌ្ឍ ៤)សហគមន៍ ៥)វេទិកាសាធារណៈ និង៦)បណ្តាញទំនាក់ទំនងសង្គម។ ក្រោយពេលទទួលបានព័ត៌មាននិងធ្វើការឆ្លើយតបរួចមក មន្ទីរពេទ្យបានធ្វើការដោះស្រាយនូវព័ត៌មាន (ការទិតៀន និងសំណូមពរ) ដែលទទួលបានទាំងនោះតាមរយៈ÷ ១)ការធ្វើចំណាត់ថ្នាក់បញ្ហា ២)ការបញ្ជូននិងដោះស្រាយបញ្ហាទៅតាមឋានានុក្រមនៃរចនាសម្ព័ន្ធមន្ទីរពេទ្យ ៣)ការប្រជុំដោះស្រាយតាមផ្នែក១ខែម្តងដែលដឹកនាំដោយប្រធានផ្នែកឬអនុប្រធានមន្ទីរពេទ្យដែលទទួលបន្ទុក ៤)គណៈកម្មការវិន័យរបស់មន្ទីរពេទ្យ ៥)កិច្ចប្រជុំបច្ចេកទេសប្រចាំខែក្នុងមន្ទីរពេទ្យនិងនៅមន្ទីរសុខាភិបាលខេត្ត និង ៦)ក្នុងករណីមានបញ្ហាធ្ងន់ធ្ងរបញ្ជូនទៅមន្ទីរសុខាភិបាលខេត្តដើម្បីមានវិធានការបន្ត[១១៤]។

៣.៧.១. ការពិនិត្យ និងវិភាគលើមតិរបស់អ្នកជំងឺតាមរយៈប្រអប់សំបុត្រ

មន្ទីរពេទ្យខេត្តកំពង់ចាម បានរៀបចំដាក់ប្រអប់សំបុត្រនៅតាមផ្នែក និងប្រគល់ការទទួលខុសត្រូវឱ្យប្រធានផ្នែកនីមួយៗ ព្រមទាំងបែងចែកបុគ្គលិកសម្រាប់កាន់សោរប្រអប់សំបុត្រ។ មន្ទីរពេទ្យបានបើកប្រអប់នេះជារៀងរាល់១ខែម្តង ដោយមានការចូលរួមពី÷ ១)ប្រធានផ្នែក ២)ក្រុមការងារលើកកម្ពស់គុណភាព និង ៣)គណៈគ្រប់គ្រងមន្ទីរពេទ្យ។ ការបើកប្រអប់នេះមានកំណត់ហេតុដែលបានបញ្ជាក់អំពីកាលបរិច្ឆេទ សមាសភាពចូលរួម សរុបទិន្នន័យក្នុងប្រអប់ និងបញ្ហារកឃើញដោយការបើកប្រអប់សំបុត្រ ព្រមទាំងមានការទទួលស្គាល់ដោយប្រធានផ្នែក និងអនុប្រធានមន្ទីរពេទ្យទទួលបន្ទុក[១១៥]។

[១១៤] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យយិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាមនៅថ្ងៃទី០២/ ០៧/ ២០២០

[១១៥] - ជ-

មតិយោបល់និងសំណូមពររបស់អ្នកជំងឺ ក៍ដូចគ្រួសាររបស់អ្នកជំងឺផ្តោតលើបញ្ហាធំៗចំនួន៤ចំណុចគឺ ១)គរិយាបថរបស់គ្រូពេទ្យ និងការយកចិត្តទុកដាក់ ២)តម្លៃសេវា និងការយកលុយបន្ថែម ៣)អនាម័យ និង ៤)សម្ភារប្រើប្រាស់។ ចំពោះបញ្ហាមួយចំនួនដែលពាក់ព័ន្ធនឹងបុគ្គលិកពេទ្យ និងគ្រូពេទ្យ ពុំបានកំណត់អត្តសញ្ញាណច្បាស់លាស់ថាជាបុគ្គលិកពេទ្យ និងគ្រូពេទ្យ ណាមួយទេ។ ទោះបី ជាយ៉ាងណាក៍ដោយ បើពិនិត្យយ៉ាងម៉ត់ចត់លើបញ្ហាទាំងបួននេះ គឺពុំមានលក្ខណៈធ្ងន់ធ្ងរទេ ហើយបញ្ហាមួយចំនួនកើតឡើងដោយការយល់ច្រឡំពីអ្នកជំងឺ ដោយសារគ្រូពេទ្យពុំបានពន្យល់ក្បោះក្បាយអំពីព័ត៌មាននៃការបង់ថ្លៃសេវា[១១៦]។

មតិយោបល់ និងសំណូមពររបស់អ្នកជំងឺ និងគ្រួសារអ្នកជំងឺ ដែលមាននៅក្នុងកំណត់ហេតុ ត្រូវបានបញ្ជូនទៅក្រុមការងារលើកកម្ពស់គុណភាព ដើម្បីប្រជុំដោះស្រាយ។ កិច្ចប្រជុំនេះ ដឹកនាំដោយអនុប្រធានមន្ទីរពេទ្យ១រូប និងមានសមាសភាពចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធ។

តាមរយៈកំណត់ហេតុ មតិយោបល់និងសំណូមពររបស់អ្នកជំងឺ ក៍ដូចគ្រួសារអ្នកជំងឺបានលើកឡើងនូវបញ្ហា និងសំណូមពរមួយចំនួនដូចជា÷ ១)បុគ្គលិកពេទ្យមានគរិយាបថមិនសូវល្អជាក់អ្នកជំងឺ និងអ្នកកំដរ ២)មន្ទីរពេទ្យស្អាតតែបន្តប់ទឹកមានធុំក្លិនតិចៗ ៣)បុគ្គលិកពេទ្យបានចាក់ថ្នាំឈឺ។ ៤)សុំឱ្យគ្រូពេទ្យរួសរាយរាក់ទាក់ ពេលវះកាត់រួចរាល់ ៥)សុំឱ្យគ្រូពេទ្យផ្តល់សេវាបានល្អទាំងថ្ងៃធ្វើការ ទាំងថ្ងៃបុណ្យ ៦)សុំឱ្យគ្រូពេទ្យបង្កើនការថែទាំឱ្យបានច្រើន ៧)សុំឱ្យគ្រូពេទ្យជួយសង្គ្រោះជីវិតសិនទើបគិតការបង់ថ្លៃសេវាជាក្រោយ និង ៨)សុំឱ្យដាក់តម្លៃសេវានៅតាមសាលនីមួយៗដើម្បីងាយស្រួលមើល[១១៧]។

បន្ថែមលើនេះ ក្រៅពីមតិយោបល់របស់អ្នកជំងឺ ឬគ្រួសារអ្នកជំងឺ មន្ទីរពេទ្យ បានរៀបចំឱ្យមានយន្តការផ្តល់ព័ត៌មានត្រឡប់ពីបុគ្គលិកនៅគ្រប់ផ្នែក ដោយផ្តល់ជាមតិយោបល់

[១១៦] កំណត់ហេតុប្រជុំគណៈកម្មការធានាគុណភាពនៅផ្នែកវះកាត់ ផ្នែកកុមារ និងផ្នែកសម្ភពនិងរោគស្ត្រី ប្រចាំខែធ្នូ ឆ្នាំ២០១៨

[១១៧] កំណត់ហេតុប្រជុំគណៈកម្មការធានាគុណភាពនៅផ្នែកវះកាត់ប្រចាំខែមករា ឆ្នាំ២០១៩

តែលម្ហូលើបញ្ហានានាដែលបុគ្គលិកនីមួយៗបានជួបប្រទះ ក្នុងនោះមាន÷ ១)របួសក្តាយជារោគនៅកន្លែងវះកាត់ ២)ការបំពេញឯកសារនៅពុំទាន់ពេញលេញនៅពេលបញ្ជូនពីផ្នែកសង្គ្រោះបន្ទាន់ និង ៣)ផ្នែកសង្គ្រោះបន្ទាន់មិនមានម៉ាស៊ីន ECG។ លើសពីនេះបុគ្គលិកពេទ្យ ក៏បានសំណូមពរមួយចំនួន ដូចជា÷ ១)ស្នើសុំឱ្យមានការជួសជុលគ្រែ ២)ស្នើសុំរទេះរុញចាក់ថ្នាំបន្ថែមនៅផ្នែកសង្គ្រោះបន្ទាន់ និង ៣)សុំទុយោអុកស៊ីសែន និងទុយោសម្រាប់ម៉ាស៊ីន Ventilation។

បន្ទាប់ពីទទួលបានមតិលើកឡើងរបស់អ្នកជំងឺ និងគ្រួសារអ្នកជំងឺ ព្រមទាំងបុគ្គលិកពេទ្យខាងលើ មន្ទីរពេទ្យបានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំមន្ទីរពេទ្យភ្លាម ដើម្បីរកយន្តការដោះស្រាយបន្ទាន់ និងឆ្លើយតបទៅនឹងរបាយការណ៍របស់ក្រុមការងារបញ្ជាក់ចំណាយរបស់ក្រសួងសុខាភិបាល អំពីបញ្ហានានាដែលក្រុមការងារនេះរកឃើញនៅមូលដ្ឋាន។ មន្ទីរពេទ្យបានប្រើប្រាស់យន្តការដោះស្រាយមួយចំនួនប្រកបដោយប្រសិទ្ធភាព និងភាពជឿទុកចិត្តបាន ដែលធ្វើឱ្យប្រជាពលរដ្ឋមានការពេញចិត្ត និងបុគ្គលិកពេទ្យអាចទទួលយកបានទាំងការដោះស្រាយបញ្ហា និងសំណូមពរនានា[១១៨]។

៣.៧.២. វិធានការនិងដំណោះស្រាយ

នៅក្នុងការដោះស្រាយបញ្ហាដែលអ្នកជំងឺ និងគ្រួសារអ្នកជំងឺបានលើកឡើង ត្រូវបានចាត់ចំណាត់បញ្ហា ដែលត្រូវដោះស្រាយនៅក្នុងកម្រិតណាមួយ។ បញ្ហាមួយចំនួនត្រូវបានដោះស្រាយកម្រិតផ្នែក និងគណៈកម្មការវិន័យ និងបញ្ហាមួយចំនួនទៀត ត្រូវបានដោះស្រាយកម្រិតថ្នាក់ដឹកនាំមន្ទីរពេទ្យ ករណីបញ្ហាមានស្ថានភាពពិបាកដោះស្រាយ និងត្រូវឆ្លងការសម្រេចឯកភាពពីថ្នាក់ដឹកនាំមន្ទីរពេទ្យ។ យន្តការដោះស្រាយបញ្ហាទាំងនេះធ្វើឡើងតាមរយៈការជួបជាមួយបុគ្គលិកផ្ទាល់ និងតាមកិច្ចប្រជុំរួម។

ប្រសិនបើបញ្ហា ត្រូវបានរកឃើញច្បាស់លាស់ថាបុគ្គលិកពេទ្យ ឬគ្រូពេទ្យណាមួយបានប្រព្រឹត្តកំហុស ហើយស្ថានភាពពុំមានលក្ខណៈធ្ងន់ធ្ងរ នោះនាយសាល ប្រធានផ្នែក

[១១៨] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យ នាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០

និងអនុប្រធានមន្ទីរពេទ្យទទួលបន្ទុកផ្នែក រួមជាមួយគណៈកម្មការវិន័យ បានហៅមកសាកសួរផ្ទាល់ និងណែនាំជាលើកទី១។ ក្នុងករណីមិនរាងចាល ប្រព្រឹត្តកំហុសជាលើកទី២ បុគ្គលិកនោះនឹងត្រូវកាត់ប្រាក់លើកទឹកចិត្តចំនួន២ថ្ងៃ និងទទួលការណែនាំជាលាយ-លក្ខណ៍អក្សរពីប្រធានមន្ទីរពេទ្យដោយការផ្តិតមេដៃទទួលស្គាល់កំហុស និងសន្យាកែលម្អកំហុសនេះ ហើយករណីប្រព្រឹត្តកំហុសលើកទី៣ (កំហុសដដែលៗ) នោះរបាយការណ៍អំពីការប្រព្រឹត្តកំហុស នឹងត្រូវបញ្ជូនទៅថ្នាក់ដឹកនាំមន្ទីរសុខាភិបាលខេត្ត ដើម្បីសម្រេចដាក់ពិន័យ ឬស្នើបញ្ឈប់ពីការងារ[១១៩]។

ក្នុងករណីបញ្ហា ពុំត្រូវបានរកឃើញ ឬកំណត់អត្តសញ្ញាណថា បុគ្គលិក ឬគ្រូពេទ្យណាមួយ ប្រព្រឹត្តដូចមានក្នុងមតិរបស់អ្នកជំងឺ ឬគ្រួសាររបស់អ្នកជំងឺលើកឡើងទេ ប្រធានមន្ទីរពេទ្យ ឬអនុប្រធានទទួលបន្ទុកផ្នែកដឹកនាំកិច្ចប្រជុំរួមសម្រាប់ផ្នែកពាក់ព័ន្ធ ដើម្បីដោះស្រាយនូវបញ្ហា និងសំណូមពរទាំងនោះ។ ក្នុងកិច្ចប្រជុំនេះ ថ្នាក់ដឹកនាំមន្ទីរពេទ្យបានណែនាំក្រើនរំលឹកជារួម និងតម្រង់ទិសកែតម្រូវនូវកំហុសឆ្គងដែលកើតឡើងដោយចេតនាក្តី ឬអចេតនាក្តី ព្រមទាំងរកមធ្យោបាយដោះស្រាយនូវសំណូមពរដែលបានស្នើដោយអ្នកជំងឺ ឬគ្រួសារអ្នកជំងឺ។

ជាលទ្ធផល ដំណោះស្រាយរបស់មន្ទីរពេទ្យចំពោះបញ្ហា និងសំណូមពរដែលអ្នកជំងឺ ឬគ្រួសារអ្នកជំងឺ បានលើកឡើង មានដូចជា÷ ១)អញ្ជើញសាមីខ្លួនមកធ្វើការអប់រំណែនាំឱ្យកែសរិយាបថ និងគោរពក្រមសីលធម៌វិជ្ជាជីវៈឱ្យបានខ្ជាប់ខ្ជួន ២)បុគ្គលិកសម្អាត ត្រូវបង្កើនការសម្អាតរាល់២ទៅ៣ម៉ោងម្តង និងត្រូវសម្អាតភ្លាមៗ ក្នុងករណីមានការហៅពីបុគ្គលិក ៣)ប្តូរមកប្រើថ្នាំលេបជំនួសវិញចំពោះអ្នកជំងឺដែលមានការឆ្អួលស្រាលច្រើន ចៀសវាងការចាក់ថ្នាំដែលនាំឱ្យអ្នកជំងឺមានការឈឺចាប់ខ្លាំង ៤)ប្រធានផ្នែកបានធ្វើការណែនាំបន្ថែមទៀតចំពោះបុគ្គលិកជាញឹកញាប់អំពីវិន័យ និងសរិយាបថ ៥)បុគ្គលិកប្រចាំការ ត្រូវមានទំនួលខុសត្រូវខ្ពស់ដោយមានវត្តមាន២៤ម៉ោង មិនគិតថ្ងៃបុណ្យ ឬចុងសប្តាហ៍

[១១៩] បទបញ្ជាតិលេខ២៥៨/១៨ មព.កច ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨ របស់មន្ទីរពេទ្យខេត្តកំពង់ចាម

ឡើយ ៦) ប្រធានផ្នែកណែនាំឱ្យបុគ្គលិកប្រចាំការ តាមដានអ្នកជំងឺឱ្យបានដិតដល់ និង ត្រូវប្រញ៉ាប់រាយការណ៍ជូនគ្រូពេទ្យករណីមានបញ្ហា ៧) ត្រូវផ្តល់សេវាជូនដល់អ្នកជំងឺ ដោយគ្មានលក្ខខណ្ឌមុននឹងទូទាត់តម្លៃសេវា និង ៨) បានធ្វើសំណើទៅគណៈកម្មការធានា គុណភាពពីការដាក់តារាងតម្លៃសេវាក្នុងផ្នែកវះកាត់ (ក)[១២០]។

ដោយឡែកបញ្ហា និងសំណូមពររបស់គ្រូពេទ្យ និងបុគ្គលិក បានដោះស្រាយដូចតទៅ÷ ១) ធ្វើការស្រង់វត្ថុវិភាគដើម្បីបណ្តុះមេរោគ និងធ្វើការណែនាំនិងអប់រំអ្នកជំងឺធ្វើអនាម័យឱ្យបានខ្ជាប់ខ្ជួន ២) ផ្នែកសង្គ្រោះបន្ទាន់ (ICU) ត្រូវជួយបំពេញឯកសារមុនបញ្ជូនអ្នកជំងឺមកកន្លែងសំរាក ៣) ធ្វើសំណើរទៅ គណៈកម្មការធានាគុណភាពមន្ទីរពេទ្យដើម្បីស្នើសុំជួសជុលគ្រែ សុំរទេះរុញចាក់ថ្នាំ សុំទុយោអុកស៊ីសែននិងទុយោសម្រាប់ ម៉ាស៊ីន Ventilation និងស្នើសុំម៉ាស៊ីនធ្វើ ECG នៅផ្នែកសង្គ្រោះបន្ទាន់[១២១]។

[១២០] កំណត់ហេតុប្រជុំគណៈកម្មការធានាគុណភាពនៅផ្នែកវះកាត់ប្រចាំខែមករា ឆ្នាំ២០១៩

[១២១] - ជ-




សកម្មភាពទំនាក់ទំនងជាមួយសហគមន៍







កិច្ចសហការជាមួយដៃគូអភិវឌ្ឍ




សកម្មភាពទទួល និងដោះស្រាយសំណូមពរពីសាធារណជន

៣.៨. ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីធ្វើឱ្យអ្នកភាពមានដំណើរការកាន់តែប្រសើរ

៣.៨.១. ការបញ្ជ្រៀបអំពីប្រធានបទពាក់ព័ន្ធនឹងនវានុវត្តន៍ និងការច្នៃប្រឌិតធ្វើឱ្យអ្នកភាពដំណើរការកាន់តែប្រសើរ

នៅក្នុងការបញ្ជ្រៀបទស្សនាទានពាក់ព័ន្ធនឹងនវានុវត្តន៍ និងការច្នៃប្រឌិតនៅក្នុងការបំពេញការងារ គណៈគ្រប់គ្រងមន្ទីរពេទ្យបានកៀគរ និងសហការជាមួយដៃគូអភិវឌ្ឍដើម្បីធ្វើការបណ្តុះបណ្តាលនូវទ្រឹស្តីនិងជំនាញថ្មីៗ ព្រមទាំងបទពិសោធន៍ល្អៗជូនដល់បុគ្គលិករបស់មន្ទីរពេទ្យ។ ដៃគូអភិវឌ្ឍដែលជួយក្នុងការបណ្តុះបណ្តាលមានដូចជា÷ ១)កម្មវិធីអភិវឌ្ឍន៍បណ្តុះមេរោគក្នុងមន្ទីរពិសោធន៍ (DMDP) ជួយបណ្តុះបណ្តាលលើការងារមន្ទីរពិសោធន៍ ២)មូលនិធិប្រជាជនរបស់អង្គការសហប្រជាជាតិ (UNFPA) ជួយបណ្តុះបណ្តាលផ្នែកឆ្មបនិងទារក ៣)ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ជួយបណ្តុះបណ្តាលលើការងារថែទាំទារក ៤)NANUM International ជួយបណ្តុះបណ្តាលទូទៅ អាស្រ័យតាមការស្នើសុំរបស់មន្ទីរពេទ្យ[១២២]។

ជាមួយគ្នានេះដែរ មន្ទីរពេទ្យក៏បានធ្វើការបណ្តុះបណ្តាលផ្ទៃក្នុងរបស់ខ្លួន ទៅលើប្រធានបទមួយចំនួនដូចជា÷ ១)ការចម្លងរោគ ដែលបណ្តុះបណ្តាលដល់មន្ត្រីថ្មី ចំនួន ១ដងក្នុង១ឆ្នាំ និងមន្ត្រីចាស់៥ដងក្នុង១ឆ្នាំ ២)សកម្មភាពសម្រិតសម្រាំង សណ្តាប់ធ្នាប់ សោភ័ណភាព ស្តង់ដា ស្ថេរភាព (ស.ស.) ដល់ជនបង្គោល ១ឆ្នាំ១ដង ៣)ទិវាវេជ្ជសាស្ត្រ សល្យសាស្ត្រ ១ឆ្នាំ២ដង ៤)ទិវាវិទ្យាសាស្ត្រថែទាំ១ឆ្នាំ១ដង ៥)ការអភិវឌ្ឍវិជ្ជាជីវៈបន្តបានចំនួន៥វគ្គ ដែលវគ្គទី១ចាប់ផ្តើមនៅខែឧសភា ឆ្នាំ២០១៧[១២៣]។

[122] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី០១/ ០៧/ ២០២០

[123] -ដ- នៅថ្ងៃទី១៣/ ០៧/ ២០២០

៣.៨.២. ការដឹកនាំអនុវត្ត ការជំរុញ និងការគាំទ្រការអនុវត្តគំនិតច្នៃប្រឌិត និងឧត្តមានុវត្តន៍ក្នុងអង្គភាពផ្តល់សេវា

តាមរយៈការបណ្តុះបណ្តាលពីដៃគូអភិវឌ្ឍនិងផ្ទៃក្នុងរបស់មន្ទីរពេទ្យ ព្រមទាំងបទពិសោធន៍និងការខិតខំស្រាវជ្រាវរបស់គណៈគ្រប់គ្រងនិងបុគ្គលិកមន្ទីរពេទ្យ យើងឃើញថាមានស្នាដៃជានវានុវត្តន៍មួយចំនួនបានកើតមានឡើង រួមមាន÷

១. ទិវាវេជ្ជសាស្ត្រ សល្យសាស្ត្រ និងវិទ្យាសាស្ត្រថែទាំ ដែលរៀបចំឡើងដោយមន្ទីរពេទ្យ។

២. ឯកសារមួយចំនួនដើម្បីបំពេញតម្រូវការការងាររបស់មន្ទីរពេទ្យ មានដូចជា÷ ១) ទម្រង់ សម្រាប់តាមដានស្ត្រីសំរាលកូន ២) ទម្រង់សម្រាប់តាមដានទារកក្រោយពេលសំរាល ៣) បញ្ជីត្រួតពិនិត្យ (check list) សម្រាប់វាយតម្លៃរបស់គណៈកម្មការការពារការចម្លងរោគ ស៥. និងវិន័យ ដែលរៀបចំឡើងដោយមន្ទីរពេទ្យ។

៣. កម្មវិធីបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលរៀបចំឡើងដោយមន្ទីរពេទ្យ។

៤. ការកំណត់យកថ្ងៃទី១៤ ខែកុម្ភៈទៅជាថ្ងៃផ្តល់ឈាម ដោយមន្ទីរពេទ្យបានផ្តល់ផ្កា ១ទង ហើយប្រសិនបើចំថ្ងៃកំណើត មន្ទីរពេទ្យផ្តល់នំខួបកំណើតចំនួន១។

៥. ឧបករណ៍បរិក្ខារពេទ្យ មានដូចជា÷ ម៉ាស៊ីនស្កានែរ 64 slides ម៉ាស៊ីន Biochemistry Pentra C400 ដែលកើតមានឡើងតាមកិច្ចសហការជាមួយវិស័យឯកជនក្នុងរូបភាពបែងចែកផលចំណេញ។ នៅក្នុងកិច្ចដំណើរការមន្ទីរពេទ្យផ្តល់ទឹកន្លែង ទឹក និងភ្លើង ចំណែកឯក្រុមហ៊ុនទទួលខុសត្រូវបុគ្គលិក ថែទាំ និងជួសជុល។ នៅពេលចប់កិច្ចសន្យា ម៉ាស៊ីនស្កានែរជាកម្មសិទ្ធិរបស់មន្ទីរពេទ្យ។

៦. ធុងសំរាមធ្វើពីជបទឹកសុទ្ធ

៧. ថូផ្កាធ្វើពីគម្របជបទឹកសុទ្ធ

៨.រូបចម្លាក់ជ័យវរ្ម័នទី៧ ដែលកើតចេញពីការចូលរួមរបស់បុគ្គលិក

៩.ហេដ្ឋារចនាសម្ព័ន្ធមន្ទីរពេទ្យ ដូចជាបង់សម្រាប់អង្គុយលំហែរកាយ បានមកពីការកៀគរសប្បុរសជន

១០.កម្មវិធីលើកកម្ពស់បរិស្ថាន (កំណត់ឱ្យផ្នែកនីមួយៗមានស្នួនច្បាររបស់ខ្លួន) និងប្រឡងប្រណាំងតាមផ្នែក

១១.លាបព័ណ៌និងបិទផ្លាកឈ្មោះធុងសំណល់ឱ្យត្រូវទៅតាមគោលការណ៍ណែនាំ

១២.ទុកដាក់ឧបករណ៍ទៅតាមគោលការណ៍ ស៥.។

ដើម្បីជំរុញឱ្យមន្ត្រីមានគំនិតផ្តួចផ្តើមនៅក្នុងការបំពេញការងារ គណៈគ្រប់គ្រងមន្ទីរពេទ្យបានធ្វើការបណ្តុះបណ្តាល ព្រមទាំងផ្តល់ពេលវេលានិងឱកាសដល់បុគ្គលិកណាដែលមានបំណងចង់បន្តការសិក្សា ឬមានគំនិតផ្តួចផ្តើមថ្មីៗនៅក្នុងការអនុវត្តការងាររបស់ខ្លួន។ ជាក់ស្តែង មន្ទីរពេទ្យបានធ្វើការបណ្តុះបណ្តាលផ្ទៃក្នុងរបស់ខ្លួន និងអនុញ្ញាតឱ្យបុគ្គលិកទៅបណ្តុះបណ្តាលនៅក្រៅអង្គភាព ព្រមទាំងទៅបន្តការសិក្សារយៈពេលវែងផងដែរ។ ដើម្បីជាការលើកទឹកចិត្តដល់បុគ្គលិកដែលចូលរួមការបណ្តុះបណ្តាល គណៈគ្រប់គ្រងមន្ទីរពេទ្យបាន÷ ១)រក្សាបៀវត្ស ២)ផ្តល់ប្រាក់លើកទឹកចិត្តរបស់មន្ទីរពេទ្យ ៣)អនុញ្ញាតឱ្យធ្វើការនៅថ្ងៃសៅរ៍-អាទិត្យដើម្បីបានចំណូលបន្ថែម និង ៤)ផ្តល់ពេលវេលា[១២៤]។

ជាមួយគ្នាដែរ មន្ទីរពេទ្យក៏បានផ្តល់ការលើកទឹកចិត្តក្នុងរូបភាពជាប័ណ្ណសរសើរដល់បណ្តាផ្នែកដែលមានស្នាដៃល្អក្នុងការអនុវត្តសកម្មភាព រួមមាន÷ សកម្មភាពការត្រួតពិនិត្យការបង្ការការចម្លងរោគ(IPC) និងសកម្មភាពសម្រិតសម្រាំង សណ្តាប់ធ្នាប់ សោភ័ណភាព ស្តង់ដារ ស្ថេរភាព (ស៥.)។

[១២៤] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០





ទិវាវេជ្ជសាស្ត្រ សល្យសាស្ត្រ និងវិទ្យាសាស្ត្រថែទាំ ដែលរៀបចំឡើងដោយមន្ទីរពេទ្យ



ធុងសំរាមធ្វើពីដបទឹកសុទ្ធ



ថ្នូរផ្កាធ្វើពីគម្របដបទឹកសុទ្ធ



ម៉ាស៊ីនស្កានែរ 64 slides



ម៉ាស៊ីន Biochemistry Pentra C400 ដែលកើតមានឡើងតាមកិច្ចសហការជាមួយវិស័យឯកជន



ពិធីផ្តល់ឈាមនៅថ្ងៃទី១៤ ខែកុម្ភៈ



ពិធីផ្តល់ប័ណ្ណសរសើរដល់បុគ្គលិកឆ្នើម

៣.៩. កត្តាគន្លឹះនៃភាពជោគជ័យរបស់មន្ទីរពេទ្យខេត្តកំពង់ចាម

ការអនុវត្តដូចបានរៀបរាប់ខាងលើនេះ ជាមូលហេតុនាំឱ្យមន្ទីរពេទ្យខេត្តកំពង់ចាម ទទួលបានចំណាត់ថ្នាក់លេខ១ ក្នុងចំណោមមន្ទីរពេទ្យដែលផ្តល់សេវាសំណុំសកម្មភាព បង្ក្រប់កម្រិត៣ (CPA3) នៅទូទាំងប្រទេស នាឆ្នាំ២០១៩។

តាមការលើកឡើងរបស់អភិបាលរងខេត្តទទួលបន្ទុកការងារសុខាភិបាលបានឱ្យ ដឹងថា ការដែលមន្ទីរពេទ្យខេត្តទទួលបានលទ្ធផលដូចថ្ងៃនេះគឺដោយសារកត្តាមួយចំនួន រួមមាន÷

១) គោលនយោបាយនិងការចង្អុលបង្ហាញពីរាជរដ្ឋាភិបាលនិងក្រសួងសុខាភិបាល

២) ការគាំទ្រពីអាជ្ញាធរខេត្ត ក្រុង

៣) ការចូលរួមគាំទ្រ និងត្រួតពិនិត្យពីមន្ទីរសុខាភិបាល

៤) ការចូលរួមពីមន្ទីរជំនាញនៅជុំវិញខេត្ត និងភាគីពាក់ព័ន្ធ ព្រមទាំងប្រជាពលរដ្ឋ

៥) ការចូលរួមពីដៃគូអភិវឌ្ឍ

៦) សាមគ្គីភាពរវាងអាជ្ញាធរខេត្ត ក្រុង មន្ទីរសុខាភិបាល និងមន្ទីរពេទ្យ និង

៧) ការខិតខំកែលម្អជាប្រចាំរបស់មន្ទីរពេទ្យ[១២៥]។

ជាមួយគ្នានេះដែរ លោកប្រធានមន្ទីរសុខាភិបាលក៏បានលើកឡើងផងដែរថា ភាព ជោគជ័យរបស់មន្ទីរពេទ្យខេត្តគឺអាស្រ័យទៅលើកត្តាទំនាក់ទំនងល្អរវាងមន្ទីរសុខាភិបាល ជាមួយនឹងមន្ទីរពេទ្យ គឺប្រៀបបានទៅនឹងទំនាក់ទំនងរវាងអណ្តាតនិងធ្មេញ[១២៦]។

ដោយផ្អែកលើបទពិសោធន៍នៅក្នុងការដឹកនាំនិងគ្រប់គ្រងមន្ទីរពេទ្យក្នុងពេលកន្លង មក លោកប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម ក៏បានលើកឡើងនូវកត្តាមួយចំនួនសម្រាប់ ដឹកនាំមន្ទីរពេទ្យឱ្យទទួលបានជោគជ័យ រួមមាន÷

១) ការលះបង់

[១២៥] ការជួបពិភាក្សាជាមួយឯកឧត្តម ហាន កុសល អភិបាលរងខេត្តកំពង់ចាម នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០

[១២៦] ការជួបពិភាក្សាជាមួយលោកវេជ្ជបណ្ឌិត គីមសួ ភីរុណ ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ចាម នៅថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២០

២) តម្លាភាព

៣) ការធ្វើការងារជាក្រុម

៤) ការណែនាំតម្រង់ទិសដល់ថ្នាក់ក្រោម

៥) ការយកភាសាបេះដូងមកអនុវត្តនៅក្នុងពេលបំពេញការងារ

៦) ការចាប់យកមនុស្សគន្លឹះក្នុងមន្ទីរពេទ្យមកប្រើតាមរយៈការលើកទឹកចិត្ត និង

៧) ការបង្កើនទំនាក់ទំនងសិទ្ធស្មាលទាំងផ្ទៃក្នុង ទាំងផ្ទៃក្រៅ[១២៧]។

[១២៧] ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ យិន ស៊ីណាត ប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០

ជំពូកទី៤. សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេល៥ឆ្នាំ (២០១៥-២០១៩) មន្ទីរពេទ្យខេត្តកំពង់ចាមបានខិតខំបំពេញការងារ ដោយសម្រេចបាននូវលទ្ធផល ដូចជា÷ ១)ចំនួនប្រជាពលរដ្ឋមកប្រើប្រាស់សេវាមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ២)អត្រាស្លាប់របស់អ្នកជំងឺមានការថយចុះ ៣)បរិស្ថាននិងសោភ័ណភាពរបស់មន្ទីរពេទ្យកាន់តែស្រស់ស្អាត ៤)ហេដ្ឋារចនាសម្ព័ន្ធរបស់មន្ទីរពេទ្យកាន់តែរីកចម្រើននិងឆ្លើយតបទៅនឹងសេចក្តីត្រូវការ ៥)សមត្ថភាពនិងទឹកចិត្តបំពេញការងាររបស់បុគ្គលិកមានការកើនឡើង ៦)ការចែករំលែកចំណេះដឹងនិងបទពិសោធន៍ដល់មន្ទីរពេទ្យដទៃ។

ការសម្រេចបានលទ្ធផលខាងលើ ដោយសារមាន÷ ១)គោលនយោបាយ និងការចង្អុលបង្ហាញពីរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ២)ការគាំទ្រពីអាជ្ញាធរខេត្ត ក្រុង មន្ទីរសុខាភិបាល មន្ទីរជំនាញនៅជុំវិញខេត្ត និងភាគីពាក់ព័ន្ធ ព្រមទាំងប្រជាពលរដ្ឋ ៣)ការចូលរួមពីដៃគូអភិវឌ្ឍ ៤)ទំនាក់ទំនងល្អរវាងអាជ្ញាធរខេត្ត ក្រុង មន្ទីរសុខាភិបាល និងមន្ទីរពេទ្យ ៥)ការដឹកនាំនិងគ្រប់គ្រងល្អពីគណៈគ្រប់គ្រងមន្ទីរពេទ្យ និង៦)ការចូលរួមពីបុគ្គលិករបស់មន្ទីរពេទ្យ។

លទ្ធផលនិងកត្តាជោគជ័យខាងលើនេះ ជាមូលហេតុនាំឱ្យមន្ទីរពេទ្យខេត្តកំពង់ចាមទទួលបានចំណាត់ថ្នាក់លេខ១ ក្នុងចំណោមមន្ទីរពេទ្យដែលផ្តល់សេវាសំណុំសកម្មភាពបង្ក្រាប់កម្រិត៣ (CPA3) នៅទូទាំងប្រទេសនាឆ្នាំ២០១៩ ដែលពិធីប្រកាសទទួលស្គាល់ជ័យលាភីនេះ ធ្វើឡើងនៅវិទ្យាស្ថានអប់រំនាថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩ ក្រោមអធិបតីភាពឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

ការសម្រេចបានរបស់មន្ទីរពេទ្យខេត្តកំពង់ចាមក្នុងពេលកន្លងមក គឺជាឧត្តមានុវត្តន៍

សម្រាប់មន្ទីរពេទ្យខេត្តកំពង់ចាមនាពេលបច្ចុប្បន្ននិងអនាគត និងសម្រាប់មន្ទីរពេទ្យឬ អង្គភាពផ្តល់សេវាសាធារណៈដទៃធ្វើការគ្រប់គ្រង និងផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែ ប្រសើរឡើងថែមទៀត៕

គន្ថនិទ្ទេស

រាជរដ្ឋាភិបាលកម្ពុជា. ឆ្នាំ២០១៩ *របាយការណ៍វឌ្ឍនភាពគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៦-២០៣០*។

------- ឆ្នាំ២០១៣ *កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥*។

------- ឆ្នាំ២០១៨ អនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពី *ការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគុំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល*។

------- ឆ្នាំ២០០៩ អនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ស្តីពី *ការបង្កើតនិងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាល*។

ក្រសួងសុខាភិបាល, ឆ្នាំ២០២០ ស្តីពី *ប្រព័ន្ធសុខាភិបាល*. គេហទំព័រ www.moh.gov.kh។

------- ឆ្នាំ២០១៩ *របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០១៩*។

------- ឆ្នាំ២០១៨ ផែនការសកម្មភាពពហុវិស័យជាតិស្តីពី *ការការពារនិងការប្រយុទ្ធនឹងជំងឺមិនឆ្លង ២០១៨-២០២៨*។

------- ឆ្នាំ២០១៦ *ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០*, នាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាលនៃក្រសួងសុខាភិបាល, ខែឧសភា ឆ្នាំ២០១៦។

------- ឆ្នាំ២០១១ សេចក្តីណែនាំស្តីពី *ការគ្រប់គ្រងសេវាហិរញ្ញប្បទានសុខាភិបាល*។

សាលាខេត្តកំពង់ចាម, ឆ្នាំ២០១៦ ឯកសារស្តីពីខេត្តកំពង់ចាម។

មន្ទីរសុខាភិបាលខេត្តកំពង់ចាម, ឆ្នាំ២០១៩ *របាយការណ៍សមិទ្ធផលការងារវិស័យសុខាភិបាលឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០*។

មន្ទីរពេទ្យខេត្តកំពង់ចាម, ឆ្នាំ២០២០ លិខិតលេខ៤៦២/២០ មព.កច ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ស្តីពី *តារាងបែងចែកថៃទាំសួនច្បារក្នុងមន្ទីរពេទ្យ*។

------- ឆ្នាំ២០២០ *របាយការណ៍សំណល់ប្រចាំខែមករា ឆ្នាំ២០២០*។

------- ឆ្នាំ២០១៩ កំណត់ហេតុប្រជុំគណៈកម្មការធានាគុណភាពនៅផ្នែកវះកាត់ប្រចាំខែមករាឆ្នាំ២០១៩។

------- ឆ្នាំ២០១៩ តារាងស្ថានភាពមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងតម្រូវការផែនការធនធានមនុស្សសម្រាប់បម្រើការងារនៅមន្ទីរពេទ្យខេត្តកំពង់ចាម។

មន្ទីរពេទ្យខេត្តកំពង់ចាម, ឆ្នាំ២០១៨ សេចក្តីជូនព័ត៌មាន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨ *ស្តីពីការលើកលែងបង់ថ្លៃសេវារបស់មន្ទីរពេទ្យខេត្តកំពង់ចាម*។

------- ឆ្នាំ២០១៨ កំណត់ហេតុប្រជុំគណៈកម្មការធានាគុណភាពនៅផ្នែកវះកាត់ ផ្នែកកុមារ និងផ្នែកសម្ភពនិងរោគស្ត្រី ប្រចាំខែធ្នូ ឆ្នាំ២០១៨។

------- ឆ្នាំ២០១៨ សេចក្តីសម្រេចចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ *ស្តីពីតួនាទីរបស់ក្រុមត្រួតពិនិត្យនិងបង្ការការចម្លងរោគក្នុងមន្ទីរពេទ្យខេត្តកំពង់ចាម*។

------- ឆ្នាំ២០១៨ *របាយការណ៍សំណល់ប្រចាំឆ្នាំ២០១៨*។

------- ឆ្នាំ២០១៨ សេចក្តីសម្រេច ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ *ស្តីពីតួនាទីរបស់ក្រុមត្រួតពិនិត្យនិងបង្ការការចម្លងរោគក្នុងមន្ទីរពេទ្យខេត្តកំពង់ចាម*។

------- ឆ្នាំ២០១៧ លិខិតបង្គាប់ការ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧*ស្តីពីការតែងតាំងសមាសភាពគណៈកម្មការគ្រប់គ្រងសេវាហិរញ្ញប្បទាន អនុគណៈកម្មការត្រពិនិត្យតាមដាន និងអនុ គណៈកម្មការផ្គត់ផ្គង់និងលទ្ធកម្ម*។

------- ឆ្នាំ២០១៥ កិច្ចសន្យាលេខ២៧០ មពកច ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ *ស្តីពីសេវាផ្ទើរយានជំនិះ យានយន្ត និងអាហារដ្ឋានទៅមន្ទីរពេទ្យខេត្តកំពង់ចាម*។

យិន ស៊ីណាត, ឆ្នាំ២០១៩ បទបង្ហាញស្តីពីលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល។ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ នៅសាលាភូមិន្ទរដ្ឋបាល។

Haradhan Kumar Mohajan. 2018. *Qualitative Research Methodology in Social*

Science and Related Subjects. Journal of Economic Development. Environment and People. Vol-7. Issue 01. 2018. https://mpra.ub.uni-muenchen.de.

ឧបសម្ព័ន្ធ

១. ឯកសារទូទៅ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល
លេខ. ..១០១.....ស.ក.រ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងារសម្រាប់អម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈកំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៩/២៥៨ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍអភិបាលកិច្ច ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍នៃសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១១០ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់ដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញសេចក្តីសម្រេចលេខ ៣១ សសរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មការវាយម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ

អាសយដ្ឋាន : អគារលេខ ១៧ វិថីឧកញ៉ាញ៉ីកថ្ងឡុង (៤៦៦)
រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 62 22 266
អ៊ីម៉ែល : cea.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh

- យោងតាមស្មារតីអង្គប្រជុំថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ របស់គណៈកម្មការវាយម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ស្តីពីការប្រគល់ការងាររៀបចំករណីសិក្សា ដល់ក្រុមលេខាធិការនៃ គ.វ.ជ. និងមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍអភិបាលកិច្ច ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍នៃសាលាកូមិន្នរដ្ឋបាល

សម្រេច

ប្រការ១.-

បង្កើតក្រុមការងារដឹកនាំ និងគ្រប់គ្រងគម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩ ដែលមានសមាសភាព ដូចខាងក្រោម៖

- ឯកឧត្តម	**យក់ ប៊ុនណា**	រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈនិងជានាយកសាលាកូមិន្នរដ្ឋបាល	ប្រធានគម្រោង
- ឯកឧត្តមបណ្ឌិត	**ហ៊ែល ចំរើន**	អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ប្រធានប្រតិបត្តិ
- ឯកឧត្តម	**ឆាយ ឆត្រាឌុច**	អនុរដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ:	អនុប្រធានប្រតិបត្តិ
- ឯកឧត្តម	**ឈុន សុជាតិ**	អគ្គនាយក នៃក្រសួងមុខងារសាធារណៈ:	សមាជិក
- ឯកឧត្តម	**ប្រាក់ ម៉ូវ**	អគ្គនាយករងនៃក្រសួងមុខងារសាធារណៈ:	សមាជិក
- លោក	**សៀត ទិចិត្រ**	ប្រធាននាយកដ្ឋានសេវាសាធារណៈនៃក្រសួងមុខងារសាធារណៈ:	សមាជិក
- លោក	**ឆុន សុជាតិ**	មន្ត្រីនៃសាលាកូមិន្នរដ្ឋបាល	ជំនួយការ

ក្រុមការងារដឹកនាំ និងគ្រប់គ្រងគម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងចាត់ចែងគម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩
- កៀរគរដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រគម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩
- សម្រេចលើផែនការសម្រាប់ចុះសិក្សា និងប្រមូលទិន្នន័យពាក់ព័ន្ធនឹងការអនុវត្តដោគជ័យរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩
- សម្របសម្រួលនិងតាមដានជំណើរការនៃការរៀបចំ ការចុះប្រមូលទិន្នន័យនិងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩

- ណែនាំ និងផ្តល់អនុសាសន៍ដល់ក្រុមការងារ សម្រាប់រៀបចំករណីសិក្សាជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩ ឱ្យទទួលបានលទ្ធផលតាមការគ្រោងទុក
- ពិនិត្យ និងសម្រេចលើករណីសិក្សាជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩
- ផ្តល់របាយការណ៍ជូនគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ អំពីវឌ្ឍនភាពនៃអនុវត្តគម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩
- រៀបចំបោះពុម្ព បែងចែក និងផ្សព្វផ្សាយដល់បណ្តាអង្គភាពផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ។

ប្រការ២.-

បង្កើតក្រុមការងាររៀបចំចងក្រងករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩ ដែលមានសមាសភាពដូចខាងក្រោម៖

ក្រុមការងាររៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់វិទ្យាល័យពេជ្រចិន្តា ខេត្តបាត់ដំបង

. ឯកឧត្តមបណ្ឌិត	**ជ័យ សារិន**	អគ្គាធិការនៃក្រសួងអប់រំ យុវជននិងកីឡា	ប្រធាន
. លោកជំទាវ	**ឆាង លីណា**	ទីប្រឹក្សាក្រសួងមុខងារសាធារណៈ	អនុប្រធាន
. លោក	**ព្រឿង មរកត**	ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
. លោក	**តាំង ស៊ុនលាង**	អនុប្រធាននាយកដ្ឋាននៃសាលកូមិន្នរដ្ឋបាល	សមាជិក
. លោក	**ជ័យ រតនា**	អនុប្រធានលេខាធិការដ្ឋាននៃអគ្គាធិការដ្ឋាននៃក្រសួងអប់រំ យុវជននិងកីឡា	សមាជិក
. លោក	**លី ឌុច**	អនុប្រធានលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
. លោកស្រី	**យឹម សុគី**	ប្រធានការិយាល័យនៃសាលាកូមិន្នរដ្ឋបាល	សមាជិក
. លោក	**ហ៊ែល ប៊ុនថាន**	ប្រធានផ្នែកនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
. លោក	**យ៉ែម មករា**	មន្ត្រីនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
. លោក	**ទេព តុច្ឆី**	មន្ត្រីនៃសាលាកូមិន្នរដ្ឋបាល	សមាជិក
. លោក	**ហួត ខ្វ៉ែងហួ**	មន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
. លោក	**ឆយ ថានិត**	មន្ត្រីនៃសាលាកូមិន្នរដ្ឋបាល	សមាជិក

ក្រុមការងាររៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យខេត្តកំពង់ចាម

. ឯកឧត្តមបណ្ឌិត	**សយ រាសី**	អគ្គនាយករងនៃក្រសួងមុខងារសាធារណៈ	ប្រធាន

.	ឯកឧត្តម	**ស៊ាង ផល្លា**	ប្រធានលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	អនុប្រធាន
.	លោក	**ស្រ៊ាង ផានិត**	ប្រធាននាយកដ្ឋាននៃសាលាកូមិន្នរដ្ឋបាល	សមាជិក
.	លោក	**សុខ សំណាង**	ប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ	សមាជិក
.	លោកស្រី	**យក់ សុគន្ធា**	អនុប្រធាននាយកដ្ឋាននៃសាលាកូមិន្នរដ្ឋបាល	សមាជិក
.	លោកស្រី	**ឡុង ស៊ីម៉ាច**	អនុប្រធាននាយកដ្ឋាននៃសាលាកូមិន្នរដ្ឋបាល	សមាជិក
.	លោក	**រស់ សុខណារុណា**	អនុប្រធានលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោកស្រី	**ហាវ គីរម្យ**	ប្រធានការិយាល័យថវិកាវិស័យសង្គមកិច្ចទី១ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោក	**ឡៀប ពិសិដ្ឋ**	ប្រធានផ្នែកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោកស្រី	**ហ៊ួត គុយឈាង**	អនុប្រធានផ្នែកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោកស្រី	**រ៉ែន ឥសាខា**	មន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោកស្រី	**អាន ស៊ីវលី**	មន្ត្រីនៃសាលាកូមិន្នរដ្ឋបាល	សមាជិក

ក្រុមការងាររៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យខេត្តកោះកុង

.	លោកស្រីវេជ្ជបណ្ឌិត	**លឹម ខាន់ត្រីកា**	អនុប្រធានការិយាល័យធានាគុណភាពសុខាភិបាល នៃក្រសួងសុខាភិបាល	ប្រធាន
.	លោក	**លន គីមហេង**	ប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ	អនុប្រធាន
.	លោក	**ទួន សុភិត្យា**	ប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ	សមាជិក
.	លោក	**ញ៉ែម ឥច្ឆិកា**	អនុប្រធាននាយកដ្ឋាននៃសាលាកូមិន្នរដ្ឋបាល	សមាជិក
.	លោកបណ្ឌិត	**តាត ពុចសុជារី**	ទីប្រឹក្សាស្រាវជ្រាវជាន់ខ្ពស់នៃ CDRI	សមាជិក
.	លោក	**ណន សាមឌី**	អនុប្រធានលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោក	**សៅ សុភត្រ**	ប្រធានការិយាល័យនៃសាលាកូមិន្នរដ្ឋបាល	សមាជិក
.	លោកស្រី	**ឆុត រតនា**	អនុប្រធានការិយាល័យនៃសាលាកូមិន្នរដ្ឋបាល	សមាជិក
.	លោក	**សូ សុតា**	ប្រធានផ្នែកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោក	**លីហេង សុគន្ធារោ**	មន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោកស្រី	**ឃួន មិថុនា**	មន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោក	**សុខ លាងហោ**	មន្ត្រីនៃសាលាកូមិន្នរដ្ឋបាល	សមាជិក

ក្រុមការងាររៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យបង្អែកបាកានខេត្តពោធិ៍សាត់

.	លោកវេជ្ជបណ្ឌិត **លី ទិជ្ជាវ៉ាទុធ**	អនុប្រធាននាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាលនៃក្រសួងសុខាភិបាល	ប្រធាន
.	លោក **ធន់ ឃ៉ុនធឿន**	ប្រធាននាយកដ្ឋាននៃសាលាភូមិន្ទរដ្ឋបាល	អនុប្រធាន
.	លោក **ប្រាក់ ប្រានីជ្ជា**	ប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ	សមាជិក
.	លោក **ឡាយ រជ្ជា**	អនុប្រធាននាយកដ្ឋាននៃសាលាភូមិន្ទរដ្ឋបាល	សមាជិក
.	លោកស្រី **សេង សេរីវឌ្ឍនា**	អនុប្រធាននាយកដ្ឋាននៃសាលាភូមិន្ទរដ្ឋបាល	សមាជិក
.	លោក **ជា ម៉ែង**	ប្រធានការិយាល័យថវិកាវិស័យសង្គមកិច្ចទី១ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោក **អឹម ច័ន្ទសុតា**	ប្រធានការិយាល័យនៃសាលាភូមិន្ទរដ្ឋបាល	សមាជិក
.	លោក **សុខ ច័ន្ទកិត្យា**	ប្រធានផ្នែកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោក **ឈិត សុចន្ត្រា**	អនុប្រធានផ្នែកនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
.	លោកស្រី **អេង សុជាត្តា**	មន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោក **ខេន ចន្ថា**	មន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
.	លោក **ន្ទន ឃ៉ុនណា**	មន្ត្រីនៃសាលាភូមិន្ទរដ្ឋបាល	សមាជិក

ក្រុមការងាររៀបចំករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩ ខាងលើ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការលម្អិតនិងឯកសារពាក់ព័ន្ធសម្រាប់ចុះសិក្សា ប្រមូលទិន្នន័យ និងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់សាលារៀនឬមន្ទីរពេទ្យគោលដៅ ដើម្បីសុំការសម្រេចពីក្រុមការងារដឹកនាំនិងគ្រប់គ្រងគម្រោង
- សហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការរៀបចំករណីសិក្សា
- ចុះសិក្សានិងប្រមូលទិន្នន័យដល់ទីតាំងសាលារៀនឬមន្ទីរពេទ្យគោលដៅ និងភាគីពាក់ព័ន្ធ
- រៀបចំសេចក្តីព្រាងករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់សាលារៀន និងមន្ទីរពេទ្យជាគោលដៅ និងស្នើសុំការសម្រេចជាចុងក្រោយពីក្រុមការងារដឹកនាំនិងគ្រប់គ្រងគម្រោង
- បំពេញការងារចាំបាច់នានា តាមការណែនាំពីប្រធានក្រុមការងារដឹកនាំនិងគ្រប់គ្រងគម្រោង។

ប្រការពា.-

បង្កើតក្រុមការងាររដ្ឋបាលនិងលេខាធិការ សម្រាប់គម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩ ដែលមានសមាសភាពដូចខាងក្រោម៖

.	លោកស្រី **ឈាង អូនង៉ា**	អគ្គនាយកងនៃក្រសួងមុខងារសាធារណៈ	ប្រធាន

- ឯកឧត្តម **តាន់ បេចណាច** អគ្គនាយករងនៃក្រសួងមុខងារសាធារណៈ: អនុប្រធាន
- លោក **ប៉ូល អង្រ្គិតកិត្យា** អនុប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ: សមាជិក
- លោក **ឈឺន សាលីន** អនុប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ: សមាជិក
- លោក **ជា ឆ្មាលីន** ជំនួយការនៃក្រសួងមុខងារសាធារណៈ: សមាជិក
- លោក **អោ ចិត្រា** មន្ត្រីនៃក្រសួងមុខងារសាធារណៈ: សមាជិក
- លោក **ប៊ុនថន ប៊ុនឆៃ** មន្ត្រីនៃក្រសួងមុខងារសាធារណៈ: សមាជិក
- លោកស្រី **ហោច ចីតា** មន្ត្រីនៃក្រសួងមុខងារសាធារណៈ: សមាជិក

ក្រុមការងាររដ្ឋបាលនិងលេខាធិការ មានតួនាទីនិងការកិច្ច ដូចខាងក្រោម៖

- ផ្តល់ការគាំទ្រ និងសេវារដ្ឋបាលដល់ក្រុមការងារដឹកនាំនិងគ្រប់គ្រង និងក្រុមការងាររៀបចំចងក្រងករណីសិក្សា
- ទំនាក់ទំនង និងសម្របសម្រួល ជាមួយអង្គភាពផ្តល់សេវាសាធារណៈគំរូ ចំណាត់ថ្នាក់លេខ១ ឆ្នាំ ២០១៩ ដើម្បីរៀបចំចុះប្រមូលព័ត៌មាន និងទិន្នន័យដល់ទីតាំងអង្គភាពជាក់ស្តែង
- រៀបចំទីកន្លែងសម្រាប់កិច្ចប្រជុំ ពិភាក្សាលើការអនុវត្តគម្រោងរៀបចំករណីកសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩
- រៀបចំឯកសារ និងនីតិវិធីរដ្ឋបាលសម្រាប់ដំណើរការចុះបេសកកម្ម ការចំណាយ និងការទូទាត់ដល់ក្រុមការងារអនុវត្តគម្រោង
- បំពេញការងារផ្សេងទៀតទៅតាមការចាំបាច់។

ប្រការ៤.-

សមាសភាពក្រុមការងារ ដូចមានចែងក្នុងប្រការ១ និងប្រការ២ នៃសេចក្តីសម្រេចនេះ ត្រូវទទួលបាន៖

- ប្រាក់បេសកកម្មសម្រាប់ការចុះសិក្សា ការប្រមូលព័ត៌មាននិងទិន្នន័យដល់ទីតាំងអង្គភាពជាក់ស្តែង
- ប្រាក់ឧបត្ថម្ភស្មើ ៨ ម៉ោង បង្រៀននៃសាស្ត្រាចារ្យរបស់សាលាកូមិន្នរដ្ឋបាលក្នុងមួយថ្ងៃ ក្នុងការរៀបចំសរសេរករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩។

សមាសភាពក្រុមការងារដូចមានចែងក្នុងប្រការ៣ ត្រូវទទួលបាន៖

- ប្រាក់បេសកកម្ម សម្រាប់ការងារសម្របសម្រួលលើការចុះសិក្សា ការប្រមូលព័ត៌មាននិងទិន្នន័យដល់ទីតាំងអង្គភាពជាក់ស្តែង
- ប្រាក់កម្រៃឧបត្ថម្ភស្មើ ៤ ម៉ោងបង្រៀននៃសាស្ត្រាចារ្យរបស់សាលាកូមិន្នរដ្ឋបាលក្នុងមួយថ្ងៃសម្រាប់ការងារសម្របសម្រួលជូនក្រុមការងាររៀបចំសរសេរករណីសិក្សាស្តីពីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩។

ប្រការ៥.-

សមាសភាពក្រុមការងារ ដូចមានចែងក្នុងប្រការ១ ប្រការ២ និងប្រការ៣ ខាងលើត្រូវគោរពនិងអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ឧសភា ឆ្នាំ២០២០
រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ
និងជានាយកសាលាភូមិន្ទរដ្ឋបាល

យក់ ម៉ុនណា

ចម្លងជូន៖
- ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការ
  រាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ
- ដូចប្រការ១ ប្រការ២ និងប្រការ៣
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល
លេខ...១៦...ស.ភ.រ

សេចក្តីសម្រេច
ស្តីពី
ការកែសម្រួលនិងបន្ថែមសមាសភាពក្រុមការងារសម្រាប់គម្រោងរៀបចំការណីសិក្សា ស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩

ដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នសចុះថ្ងៃទី៣០ ៤២១/០៣២០/រកត/ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលបានប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៩/២៥៨ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិនៃសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍអភិបាលកិច្ច ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍នៃសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈតំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១១០ អនក្រ.បក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈតំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់ដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

អាសយដ្ឋាន : អគារលេខ ១៧ វិថីឧកញ៉ាញ៉ីកជ្ជឌុង (៤៦៦
រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : 023 62 22 266
អ៊ីមែល : era.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh

- បានឃើញសេចក្តីសម្រេចលេខ ៣១ សសរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ
- យោងតាមស្មារតីអង្គប្រជុំកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ របស់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ស្តីពីការប្រគល់រៀបចំករណីសិក្សា ដល់ក្រុមលេខាធិការនៃ គ.វ.ជ. និងមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍអភិបាលកិច្ច ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍នៃសាលាភូមិន្ទរដ្ឋបាល
- បានឃើញសេចក្តីសម្រេចលេខ ១០១ ស.ភ.រ របស់សាលាភូមិន្ទរដ្ឋបាល ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមការងារសម្រាប់គម្រោងរៀបចំករណីសិក្សា ស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០១៩។

សម្រេច

ប្រការ១.-

កែសម្រួល លោក **ជា ម៉ែង** ប្រធានការិយាល័យថវិការិស័យសង្គមកិច្ចទី១នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពីសមាជិកក្រុមការងាររៀបចំករណីសិក្សា ស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យបង្អែកបាកានខេត្តពោធិ៍សាត់ ទៅជាសមាជិកក្រុមការងាររៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់វិទ្យាល័យពេជ្រចិន្តា ខេត្តបាត់ដំបង។

ប្រការ២.-

បន្ថែមសមាសភាព លោក **សិ សុហេង** មន្ត្រីនៃនាយកដ្ឋានសេវាសាធារណៈ ក្រសួងមុខងារសាធារណៈ ជាសមាជិកក្រុមការងាររៀបចំករណីសិក្សា ស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យបង្អែកបាកានខេត្តពោធិ៍សាត់។

ប្រការ៣.-

សាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ៥ន្ទ ៤ ៥ៀ ៦ ខែ ៥ៃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ពជធានីភ្នំពេញ ថ្ងៃទី ៤៥ ខែ ឧសភ ឆ្នាំ២០២០

រដ្ឋលេខាធិការប្រចាំការនៃក្រសួងមុខងារសាធារណៈ
និងនាយកសាលាភូមិន្ទរដ្ឋបាល

យក់ ឫទណា

ចម្លងជូន៖

- ឧទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ "ដើម្បីជូនជ្រាប"
- ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ
- ដូចប្រការ១ និងប្រការ២
- ឯកសារ-កាលប្បវត្តិ

២. ស្តង់ដាសេវាសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរសុខាភិបាលខេត្តកំពង់ចាម
មន្ទីរពេទ្យខេត្តកំពង់ចាម
លេខ ២៥៧/១៤ មព.កច

ថ្ងៃ ពុធ ៨ កើត ខែ ពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦១
កំពង់ចាម ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០១៨

បទបញ្ជាផ្ទៃក្នុងរបស់មន្ទីរពេទ្យខេត្តកំពង់ចាម

ដើម្បីរក្សាបាននូវវិន័យការងារ និង សណ្តាប់ធ្នាប់សេចក្តីថ្លៃថ្នូរ ឲ្យបានល្អប្រសើររបស់មន្ត្រីរាជការស៊ីវិលនិងសំដៅលើកកំពស់គុណភាពការងារគ្រប់គ្រង ឲ្យមានប្រសិទ្ធភាពក្នុងមន្ទីរពេទ្យខេត្តកំពង់ចាម មន្ត្រីរាជការទាំងអស់ក្នុងមន្ទីរពេទ្យខេត្តកំពង់ចាម ត្រូវអនុវត្តបទបញ្ជាផ្ទៃក្នុងនេះចាប់តាំងពី ថ្នាក់ដឹកនាំមន្ទីរពេទ្យ រហូតដល់បុគ្គលិកជួល ដូចមានចែងខាងក្រោមនេះ៖

១. ត្រូវគោរពពេលវេលាធ្វើការឲ្យបានទៀងទាត់
   - ពេលព្រឹកពីម៉ោង ៧:៣០នាទី ដល់ម៉ោង ១១:៣០នាទី
   - ពេលល្ងាចពីម៉ោង ០១:៣០នាទី ដល់ម៉ោង ១៧:៣០នាទី
២. ត្រូវមានសំលៀកបំពាក់សមរម្យពេលមកបំពេញការងារ និងត្រូវស្លៀកពាក់ឯកសណ្ឋានពេទ្យ និងមានស្លាកឈ្មោះត្រឹមត្រូវក្នុងម៉ោងធ្វើការ និងម៉ោងយាម ។
៣. មន្ត្រីរាជការទាំងអស់ត្រូវចូលរួមប្រជុំស្តាប់ របាយការណ៍រៀងរាល់ព្រឹក នៅម៉ោង៧.៣០នាទី ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ លើកលែងតែបុគ្គលិកដែលត្រូវយាមប្រចាំការ
៤. ត្រូវចុះហត្ថលេខាវត្តមាន៖
   - ពេលព្រឹកម៉ោង ៧.១៥ ដល់ម៉ោង ៧.៣០ នាទី ពេលចេញម៉ោង ១១.១៥ ដល់ម៉ោង ១១.៣០នាទី
   - ពេលរសៀលពីម៉ោង ១៤.០០ ដល់ម៉ោង ១៤.១៥នាទី ពេលចេញម៉ោង ១៧.១៥ ដល់ម៉ោង ១៧.៣០នាទី
   - ពេលម៉ោងយាម ពេលយប់ ម៉ោង ២០.០០ ដល់ម៉ោង ២១.០០នាទី ពេលព្រឹកពី ម៉ោង ៥.០០ ដល់ម៉ោង ៦.០០នាទី ។
៥. មិនអនុញ្ញាតឲ្យអ្នកផ្សេងចុះហត្ថលេខាជំនួសទាំងក្នុងម៉ោងធ្វើការពេលព្រឹក និងពេលរសៀល រួមទាំងក្នុងម៉ោងយាមប្រចាំការដាច់ខាត ។
៦. បុគ្គលិកយាមត្រូវមាន វត្តមានជាប់ជានិច្ចក្នុងមន្ទីរពេទ្យក្នុងម៉ោងយាមប្រចាំការ អ្នកយាមត្រូវបាន អនុញ្ញាតឲ្យឈប់សំរាកនាពេលរសៀលថ្ងៃបន្ទាប់ ។
៧. បុគ្គលិកមិនត្រូវបែងចែកវេនយាមក្នុងក្រមយាមរបស់ខ្លួនឡើយ ។
៨. ត្រូវគោរពការចាត់តាំងរបស់ថ្នាក់ដឹកនាំមន្ទីរពេទ្យ
